ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម

# សៀវភៅផែនការរៀបចំដែនដី លេខ ២

# សេចក្តីណែនាំស្តីពីការកសាងផែនការ រៀបចំដែនដីថ្នាក់ខេត្ត

ខែមិថុនា ឆ្នាំ២០១៦

# សេចក្ដីព្រាង

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ


ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

អគ្គនាយកដ្ឋានរៀបចំដែនដី និងនគរូបនីយកម្ម


# សៀវភៅផែនការរៀបចំដែនដី លេខ ២

# សេចក្តីណែនាំស្តីពីការកសាងផែនការ រៀបចំដែនដីថ្នាក់ខេត្ត


ខែមិថុនា ឆ្នាំ២០១៦

សូមឧទ្ទិសសៀវភៅនេះជូនចំពោះ

លោកបណ្ឌិត Franz-Volker Müller

កើតថ្ងៃទី ០៣ ខែ សីហា ឆ្នាំ ១៩៥០

ទទួលមរណៈភាព ថ្ងៃទី ២២ ខែ មីនា ឆ្នាំ ២០១៥

សម្រាប់ការគាំទ្រអស់ពីកម្លាំងកាយចិត្តដល់ការរៀបចំដែនដី

និងការទទួលស្គាល់សិទ្ធិលើដីធ្លីនៅក្នុងប្រទេសកម្ពុជា

កិច្ចសហប្រតិបត្តិការ
អាល្លឺម៉ង់
DEUTSCHE ZUSAMMENARBEIT

គាំទ្រដោយ ៖ GIZ - កម្មវិធីសិទ្ធិលើដីធ្លី ॥

# បុព្វកថា

ផ្តើមចេញពីគោលនយោបាយឈ្នះឈ្នះរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ប្រទេសកម្ពុជាទទួលបានសន្តិភាពពេញលេញមានសន្តិសុខ សុវត្ថិភាព និងស្ថេរភាពនយោបាយល្អ ដែលជាកត្តាមូលដ្ឋានចម្បងនាំឲ្យមានការអភិវឌ្ឍលើគ្រប់វិស័យ ជាមួយនឹងកំណើនប្រជាជនយ៉ាងឆាប់រហ័សដែលកើនឡើងជាង ១៥ លាននាក់។ ដោយប្រជាជនភាគច្រើនរស់នៅពឹងផ្អែកទៅលើកសិកម្ម ទំនាក់ទំនងសង្គមរបស់ពួកគាត់ជាមួយដីធ្លី បានប្រែប្រួលគួរឲ្យកត់សំគាល់ក្នុងរយៈពេលកន្លងមកនាពេលថ្មីៗនេះ។ ចំនួនប្រជាជននៅទីប្រជុំជនមានការកើនឡើងយ៉ាងឆាប់រហ័សជាងចំនួនប្រជាជននៅតំបន់ជនបទ ដែលជាហេតុដែលនាំឲ្យកើនឡើងបញ្ហាប្រឈមចំពោះការបង្កើតការងារ ការផ្តល់សេវា សាធារណៈ និងការបង្កើតនូវអត្តសញ្ញាណទីប្រជុំជនក្នុងព្រះរាជាណាចក្រកម្ពុជា។

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនត្រូវបានធ្វើឲ្យប្រសើរឡើងយ៉ាងឆាប់រហ័ស ហើយវាមិនត្រឹមតែផ្តល់និងភ្ជាប់ទៅនឹងរាជធានីនោះទេ ប៉ុន្តែដល់តំបន់ដទៃជាច្រើនទៀតនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលជួយជម្រុញដល់កំណើនសេដ្ឋកិច្ច និងបង្កើតបណ្តាញពហុតំបន់ស្នូលរបស់ក្រុង។ លំហូរចលនាអន្តោប្រវេសន៍ឆ្លងកាត់ព្រំដែនទៅបរទេសនិងនៅក្នុងស្រុក ជាបញ្ហាប្រឈមដល់អភិបាលកិច្ចថ្នាក់ជាតិ និងមូលដ្ឋាន និងធ្វើឲ្យមានការប្រែប្រួលដល់ទំនាក់ទំនងរបស់ប្រជាជននិងធនធាននៅលើដីធ្លី។ ក្នុងគោលដៅការពារដល់ធនធានព្រៃឈើ និងធនធានធម្មជាតិដទៃទៀត យើងព្យាយាមខិតខំថែរក្សាការពារបរិស្ថានដែលយើងទាំងអស់គ្នាត្រូវពឹងផ្អែកទៅលើសម្រាប់ការរស់នៅ ដោយធ្វើការថែរក្សាឲ្យស្របទៅនឹងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។

ការប្រើប្រាស់ និងមុខងារជាច្រើនរបស់ដីត្រូវបានគ្រប់គ្រងដោយក្រសួងផ្សេងៗ ហើយក៏ត្រូវបានលើកឡើងនៅក្នុងគោលនយោបាយតាមវិស័យនិងផែនការនានា។ គោលបំណងរបស់ផែនការរៀបចំដែនដី គឺខិតខំព្យាយាមធ្វើឲ្យមានតុល្យភាពរវាងមុខងារ និងការប្រើប្រាស់ដីដែលមានការប្រកួតប្រជែង ព្រមទាំងព្យាយាមផ្តល់នូវការអភិវឌ្ឍដែនដីប្រកបដោយចីរភាព។ ដូច្នេះរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈគណៈរដ្ឋមន្ត្រីបានអនុម័តគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជានាថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១១ និងបានបង្កើតគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ ដែលមានក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ជាប្រធាន ដោយគណៈកម្មាធិការនេះជាស្ថាប័នធ្វើការអនុវត្តការកសាងផែនការរៀបចំដែនដីនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ក្រោមជាតិទើបតែត្រូវបានបង្កើតឡើង ដូច្នេះសបញ្ជាក់យ៉ាងច្បាស់ថា បទពិសោធន៍ដែលមានស្រាប់ដែលទាក់ទងទៅនឹងការកសាងផែនការរៀបចំដែនដី គឺនៅមានកម្រិតនៅឡើយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នេះជាមូលហេតុយ៉ាងសំខាន់ដែលគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិចាប់ផ្តើមរៀបចំសៀវភៅណែនាំស្តីពីការកសាងផែនការរៀបចំដែនដីនៅថ្នាក់ក្រោមជាតិដែលផ្តល់នូវការណែនាំតម្រង់ទិស ដំណើរការជាក់លាក់ និងចំណេះដឹងពីការអនុវត្តការងារជាក់ស្តែង និងការណែនាំដែលផ្អែកទៅលើដំណើរការកសាងផែនការរៀបចំដែនដីដែលបានធ្វើឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ក្រោមកិច្ចសហប្រតិបត្តិការជាមួយនឹងអង្គការ GIZ ។

សៀវភៅណែនាំនេះ ត្រូវបានរៀបចំឡើងជាមូលដ្ឋានសម្រាប់អ្នកកសាងផែនការអនុវត្តន៍តាមជាឯកសារយោង និងធ្វើការផ្លាស់ប្តូរទៅវិញទៅមក។ សៀវភៅណែនាំនេះ ជាការចូលរួមចំណែកដ៏សំខាន់មួយក្នុងការជួយដល់ក្របខ័ណ្ឌនៃការកសាងផែនការរៀបចំដែនដី ដោយមានការចូលរួមនិងជួយដល់ការអភិវឌ្ឍ ដែនដីនៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយចីរភាពនាពេលអនាគត។

ថ្ងៃ.................................ខែ................ ឆ្នាំវក ព.ស ២៥៦០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.........ខែ................ឆ្នាំ ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា**

**ប្រធានគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ**

# អារម្ភកថា

គោលដៅនៃការរៀបចំដែនដីគឺសំដៅធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយតម្លាភាពនិងប្រសិទ្ធភាព ដើម្បីរក្សានិរន្តរភាពបរិស្ថាននិងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមប្រកបដោយសមធម៌នៅទីប្រជុំជន និងជនបទព្រមទាំងទប់ស្កាត់វិវាទលើការប្រើប្រាស់ដីដោយដាក់បញ្ញត្តិលើការអភិវឌ្ឍដី ឬការប្តូរប្រភេទនៃការប្រើប្រាស់ដី។

ការរៀបចំដែន ដីគឺការធ្វើសមាហរណកម្មផែនការយុទ្ធសាស្ត្រ នៃការរៀបចំដែនដីជាមួយនឹងវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យឲ្យមានភាពរលូនទៅតាមតំបន់ភូមិសាស្ត្រនីមួយៗ ចៀសវាងនូវការខ្វែងគំនិតយោបល់ក្នុងការប្រើប្រាស់ដី និងធនធានធម្មជាតិ ក្នុងគោលដៅធានាដល់សន្តិសុខស្បៀង កិច្ចការពារជាតិ និងរក្សាលំនឹងបរិស្ថានធម្មជាតិ ព្រមទាំងតម្រង់ទិសដល់ការអភិវឌ្ឍឲ្យមានតុល្យភាពលើផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងមានភាពងាយស្រួលដល់ទំនាក់ទំនងពីតំបន់មួយទៅ តំបន់មួយទៀតក្នុងប្រទេស ក្នុងតំបន់ និងអន្តរជាតិ។

អាជ្ញាធរមានសមត្ថកិច្ចដែលធ្វើការផ្តួចផ្តើម រៀបចំ សម្របសម្រួល និងអនុម័តលើផែនការរៀបចំដែនដី គឺមានបួនកម្រិតផ្សេងគ្នា ៖ ថ្នាក់ជាតិ/តាមតំបន់ ថ្នាក់រាជធានី/ខេត្ត ថ្នាក់ក្រុង/ស្រុក/ខណ្ឌ និង ថ្នាក់ឃុំ/សង្កាត់។ នៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្ម (គ.ដន) ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវបានបញ្ចូលទៅក្នុងរដ្ឋបាលឯកភាពដូចដែលមានចែងនៅក្នុងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងដោយផ្អែកទៅលើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ/សង្កាត់។

ដោយផ្អែកទៅលើអនុក្រឹត្យស្តីពីការបង្កើត គ.ដ.ន ថ្នាក់ រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គ.ដ.ន ថ្នាក់ខេត្ត អាចដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត ដែលរួមមានទំហំការងារ និងខ្លឹមសារអប្បបរិមាស្របតាមគោលការណ៍ នីតិវិធី និងបទដ្ឋានគតិយុត្តិនានាដែលមាន។ សៀវភៅណែនាំស្តីពីការកសាងផែនការរៀបចំដែនដីនេះ នឹងបង្ហាញ និងបំពេញបន្ថែមដល់ដំណើរការកសាងផែនការរូបវន្តជាផ្លូវការដែលបានអនុវត្តដោយក្រសួង។ សៀវភៅណែនាំនេះ នឹងត្រូវប្រើប្រាស់ជាឯកសារយោងដែលមានភាពងាយស្រួលក្នុងការពិភាក្សាពិគ្រោះយោបល់ និងផ្តល់នូវការតម្រង់ទិសដល់ដំណើរការកសាងផែនការរៀបចំដែនដី។ វាក៏ជាសៀវភៅណែនាំដែលជួយធ្វើការណែនាំតម្រង់ទិសនិងសម្រួលដល់ក្រុមការងារនៅថ្នាក់ក្រោមជាតិអាចធ្វើការកសាងផែនការរៀបចំដែនដីផងដែរ។

ថ្ងៃ..........................ខែ............ ឆ្នាំរកា ព.ស២៥៦០

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី.........ខែ................ឆ្នាំ ២០១៦

ឯកឧត្តមបណ្ឌិត **ម៉ែន សុផល**

រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជា

អគ្គលេខាធិការ នៃគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

# មាតិកា


**បុព្វកថា** ........ i

**អារម្ភកថា** ........ iii

**តារាង** ........ vii

**បញ្ជីផែនទី** ........ viii

**បញ្ជីអក្សរកាត់** ........ x

**ស្ថានភាពទូទៅ៖ ផែនការរៀបចំដែនដីថ្នាក់ខេត្ត** ........ ១

**ជំហានទី១ ការរៀបចំ និងការចាប់ផ្ដើមដំណើរការកសាងផែនការរៀបចំដែនដី** ........ ៤

គោលបំណងរួម ........ ៤

ការងារ ១.១ ធ្វើការណែនាំអំពីផែនការរៀបចំដែនដីដល់អាជ្ញាធរខេត្ត ........ ៤

ការងារ ១.២ បង្កើតក្រុមការងារកសាងផែនការរៀបចំដែនដី ........ ៥

ការងារ ១.៣ ពង្រឹងសមត្ថភាពដល់ក្រុមការងារកសាងផែនការរៀបចំដែនដី ........ ៧

ការងារ ១.៤ ការកំណត់ និងគៀងគរការចូលរួមពីអ្នកពាក់ព័ន្ធ ........ ៨

**ជំហានទី២ ការវិភាគស្ថានភាព** ........ ១១

គោលបំណងរួម ........ ១១

ការងារ ២.១ ការប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ ........ ១១

ការងារ ២.២ ការវិភាគទិន្នន័យ និងការផលិតផែនទី ........ ១៥

ក) រដ្ឋបាល ........ ១៧

ខ) បរិស្ថានជីវសាស្ត្រ ........ ១៩

គ) ការប្រើប្រាស់ដី និងការកាន់កាប់ដី ........ ៣១

ឃ) ប្រជាសាស្ត្រ និងលំនៅឋាន ........ ៤១

ង) ការផ្ដល់នូវសេវាសង្គម ........ ៤៦

ច) ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ........ ៤៩

ឆ) ស្ថានភាពសេដ្ឋកិច្ចខេត្ត (Economic Profile) ........ ៥៥

ការងារ ២.៣ ការពិនិត្យផ្ទៀងផ្ទាត់នៅថ្នាក់ស្រុក សិក្ខាសាលាវិភាគ និងធ្វើបច្ចុប្បន្នភាព ........ ៦០

ក) ការប្រើប្រាស់ដី ........ ៦២

ខ) ការទទួលបានសេវាសង្គម និងការកំណត់តំបន់ផ្ដល់នូវសេវាទាំងនោះ ........ ៦៤

គ) រចនាសម្ព័ន្ធសេដ្ឋកិច្ច និងការធ្វើបច្ចុប្បន្នភាព ........ ៦៥

ការងារ ២.៤ ការវិភាគស្ថាប័នដោយផ្អែកទៅលើការវិភាគ SWOT នៅថ្នាក់ខេត្ត ........ ៦៨

ការងារ ២.៥ ការវិភាគទម្រង់លក្ខណៈដែនដីបច្ចុប្បន្ននៅក្នុងដែនដីខេត្ត ........ ៧០

ក) ការកំណត់ និងវិភាគប្រព័ន្ធប្រើប្រាស់ដី ........ ៧២

ខ) ការធ្វើចំណាត់ថ្នាក់ និងវិភាគពីមជ្ឈមណ្ឌលទីប្រជុំជន ........ ៧៤

គ) ការកំណត់ និងវិភាគពីរចនាសម្ព័ន្ធសេដ្ឋកិច្ចខេត្ត ........ ៧៧

**ជំហានទី៣ កំណត់ចក្ខុវិស័យសម្រាប់អនាគត** ........ ៨០

គោលបំណងរួម ........ ៨០

ការងារ ៣.១ កំណត់សេណារីយ៉ូអភិវឌ្ឍន៍សម្រាប់អនាគត ........ ៨០

ក) សេណារីយ៉ូកំណើនប្រជាសាស្ត្រ ........ ៨៣

ខ) សេណារីយ៉ូសម្រាប់ការប្រែប្រួលការប្រើប្រាស់ដី ........ ៨៤

គ) ភាពងាយរងគ្រោះ និងសេណារីយ៉ូប្រែប្រួលអាកាសធាតុ ........ ៨៦

ការងារ ៣.២ ការពិពណ៌នាពីចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍រយៈពេលវែង ........ ៨៩

**ជំហានទី៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី** ........ ៩៤

គោលបំណងរួម ........ ៩៤

ការងារ ៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី ........ ៩៤

ក) ការប្រើប្រាស់ដីនាពេលអនាគត និងមុខងារនៃទេសភាព ........ ៩៦

ខ) មជ្ឈមណ្ឌលទីប្រជុំជននាពេលអនាគត និងការផ្តល់សេវាកម្ម ........ ៩៩

គ) រចនាសម្ព័ន្ធសេដ្ឋកិច្ចសម្រាប់អនាគត ........ ១០១

ឃ) សមាហរណកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី ........ ១០៣

ការងារ ៤.២ សម្របយុទ្ធសាស្ត្រតាមវិស័យ និងបច្ចុប្បន្នភាពផែនការតាមវិស័យ ........ ១០៥

ការងារ ៤.៣ ការពិភាក្សាផ្ទៃក្នុងជាមួយអាជ្ញាធរខេត្ត ........ ១០៧

**ជំហានទី៥ ការអនុវត្ត ត្រួតពិនិត្យ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពផែនការ** ........ ១០៨

គោលបំណងរួម ........ ១០៨

ការងារ ៥.១ ការអនុវត្ត និងការត្រួតពិនិត្យ ........ ១០៨

ការងារ ៥.២ ការវាយតម្លៃ ធ្វើបច្ចុប្បន្នភាព និងការធ្វើឲ្យមានភាពរលូននៃការធ្វើផែនការ ........ ១១១

**ជំហានទី៦ បញ្ចប់ដំណើរការកសាងផែនការ** ........ ១១៣

គោលបំណងរួម ........ ១១៣

ការងារ ៦.១ ការពិភាក្សាជាសាធារណៈចុងក្រោយជាមួយអ្នកពាក់ព័ន្ធទាំងអស់ ........ ១១៣

ការងារ ៦.២ ការរៀបចំរបាយការណ៍បច្ចេកទេសចុងក្រោយ ........ ១១៤

ការងារ ៦.៣ ការបិទផ្សាយជាសាធារណៈ និងការគាំទ្រលើផែនការដោយក្រុមប្រឹក្សាខេត្ត ........ ១១៥

ការងារ ៦.៤ ការឯកភាពលើផែនការដោយគណៈកម្មាធិការរៀបចំដែនដី
និងនគរូបនីយកម្មថ្នាក់ជាតិ ........ ១១៧

**ឯកសារយោង** ........ ១១៨

**ឧបសម្ព័ន្ធ** ........ ១១៩

ឧបសម្ព័ន្ធ១៖ សុច្ឆនាកររបស់សិក្ខាសាលាដែលនឹងត្រូវធ្វើឡើងក្នុងកំឡុងពេលដំណើរការកសាងផែនការរៀបចំដែនដី........ ១១៩

ឧបសម្ព័ន្ធ២៖ តារាងទិន្នន័យទីតាំងភូមិសាស្ត្រ និងទិន្នន័យមិនមានភ្ជាប់ទៅទីតាំង (spatial and non-spatial) ដែលត្រូវការ ........ ១២០

ឧបសម្ព័ន្ធ៣៖ រចនាសម្ព័ន្ធសម្រាប់របាយការណ៍បច្ចេកទេសផែនការរៀបចំដែនដីថ្នាក់ខេត្ត........ ១២៤

## បញ្ជីរូបភាព

**រូបភាព១៖** ជំហានដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត ........ ៣

**រូបភាព២៖** ការបញ្ចូលទិន្នន័យដែលពាក់ព័ន្ធនឹងផែនការរៀបចំដែនដីទៅក្នុងដាតាបេសទិន្នន័យ........ ១៤

**រូបភាព៣៖** រូបភាពដាតាបេសមេ (Meta-Databse) សម្រាប់ផែនការរៀបចំដែនដី........ ១៤

**រូបភាព ៤ ៖** ដ្យាក្រាម Ombrothermic សម្រាប់ស្ថានីយ៍នៅខេត្តកំពង់ឆ្នាំង ផ្ទៃពណ៌លឿងបង្ហាញពីខែដែលមានសក្តានុពលរងនូវភាពរាំងស្ងួត........ ២១

**រូបភាព៥៖** ការប្រែប្រួលនៃរបាយទឹកភ្លៀង (ស្ថានីយ៍ខេត្តបាត់ដំបង) រវាងឆ្នាំ ១៩២០-១៩៣០ និងឆ្នាំ ១៩៩០ - ២០០០ ដែលបង្ហាញពីការប្រែប្រួលរបាយទឹកភ្លៀងយ៉ាងជាក់លាក់រវាងទសវត្សរ៍ឆ្នាំ ១៩២០-១៩៣០ និងឆ្នាំ ១៩៩០ - ២០០០........ ២២

**រូបភាព ៦ ៖** ការវិភាគកំពស់ទឹកភ្លៀង (ស្ថានីយ៍ខេត្តបាត់ដំបង) រវាងឆ្នាំ១៩៨១ និង២០១២ ដែលបង្ហាញថាកំណកអាកាសយ៉ាងខ្លាំងដូចដែលបង្ហាញនៅក្នុងសុច្ឆនាករភាគច្រើន តែងតែកើនឡើង........ ២៣

**រូបភាព៧៖** ពីរ៉ាមីតអាយុប្រជាជននៅក្នុងខេត្តកំពង់ឆ្នាំងក្នុងឆ្នាំ១៩៩៨ (ខាងឆ្វេង) និងឆ្នាំ២០០៨ (ខាងស្តាំ)........ ៤៤

**រូបភាព៨៖** សេណារីយ៉ូកំណើនប្រជាជនខេត្តបាត់ដំបង ២០០៨ - ២០៣០ ដោយផ្អែកទៅលើអត្រាកំណើន ប្រជាជន ៣.១០%/ឆ្នាំ រវាងឆ្នាំ១៩៩៨ និង២០០៨........ ៨៣

**រូបភាព៩៖** បទបង្ហាញចុងក្រោយនៃផែនការរៀបចំដែនដីខេត្តបាត់បងដល់ក្រុមប្រឹក្សាខេត្ត........ ១១៦

## តារាង

**តារាង១៖** រចនាសម្ព័ន្ធទូទៅនៃប្រព័ន្ធដាតាបេសទិន្នន័យសម្រាប់កសាងផែនការរៀបចំដែនដី ........ ១២

**តារាង២៖** ការចងក្រងឯកសារនៃការប្រែប្រួលការប្រើប្រាស់ដី (សំដៅដល់ផែនទីប្រែប្រួលការប្រើប្រាស់ដី ........ ៦៤

**តារាង៣៖** ការធ្វើចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជននៅក្នុងខេត្តបាត់ដំបង ........ ៧៥

**តារាង ៤ ៖** សេណារីយ៉ូកំណើនប្រជាជនតាមស្រុក ក្នុងខេត្តបាត់ដំបង ២០០៨-២០៣០........ ៨៤

**តារាង ៥៖** មុខងាររបស់មជ្ឈមណ្ឌលទីប្រជុំជននាពេលអនាគត និងមានស្រាប់ក្នុងខេត្តបាត់ដំបង.... ១០០

## បញ្ជីផែនទី

**ផែនទី១៖** ឈ្មោះនិងទីតាំងតំបន់រដ្ឋបាលផ្សេងៗគ្នាក្នុងខេត្តបាត់ដំបង ...................... ១៩
**ផែនទី២ ៖** ពហុកោណ Thiessen នៃកំពស់ទឹកភ្លៀងនៅទីជម្រាលស្ទឹងខេត្តសៀមរាប ...................... ២២
**ផែនទី៣ ៖** សណ្ឋានដីនៅក្នុងខេត្តកំពង់ឆ្នាំង រយៈកំពស់ខ្ពស់ជាងនីវ៉ូទឹកសមុទ្រ(ខាងឆ្វេង) និងជម្រាល (ខាងស្តាំ)...................... ២៤
**ផែនទី ៤ ៖** របាយប្រភេទដីសំខាន់ៗ (ខាងឆ្វេង) និងដីជាតិដី (ខាងស្តាំ) ខេត្តកំពង់ឆ្នាំង...................... ២៥
**ផែនទី ៥ ៖** ធនធានទឹកសំខាន់ៗនៅក្នុងខេត្តកំពង់ឆ្នាំង ...................... ២៦
**ផែនទី ៦ ៖** ប្រព័ន្ធអេកូឡូស៊ីក្នុងខេត្តកំពង់ឆ្នាំង៖ តំបន់ទីជម្រាល(ខាងឆ្វេង) និង តំបន់អេកូឡូស៊ីទៅតាមហៃ្សន (ខាងស្តាំ) ...................... ២៩
**ផែនទី ៧ ៖** តំបន់លិចទឹកក្នុងខេត្តកំពង់ឆ្នាំង ស្ថិតនៅក្រោមទំហំកម្រិតបីផ្សេងៗគ្នា ...................... ៣០
**ផែនទី ៨ ៖** ការកើនឡើងតំបន់លិចទឹកឆ្នាំ២០១១ នៅក្នុងខេត្តកំពង់ឆ្នាំង ...................... ៣០
**ផែនទី ៩ ៖** ដំណើរការធ្វើបច្ចុប្បន្នភាពការប្រើប្រាស់ដីក្នុងខេត្តតាកែវ (ផែនទីប្រើប្រាស់ដីឆ្នាំ១៩៩៩ ខាងឆ្វេង) រូបថតបច្ចុប្បន្នភាពពី Google Earth (កណ្តាល) និងផែនទីបច្ចុប្បន្នភាពប្រើប្រាស់ដីឆ្នាំ ២០១៤ (ខាងស្តាំ) ...................... ៣២
**ផែនទី ១០ ៖** គម្របព្រៃឈើដែលមានស្រាប់ និងប្រភេទផ្សេងៗគ្នានៃការគ្រប់គ្រងព្រៃឈើ ខេត្តកំពង់ឆ្នាំង ...................... ៣៣
**ផែនទី១១៖** ទីតាំងកន្លែងនេសាទត្រីដែលមានស្រាប់ និងប្រភេទផ្សេងៗនៃការគ្រប់គ្រងជលផលខេត្តកំពង់ឆ្នាំង ...................... ៣៥
**ផែនទី១២៖** តំបន់ការពារដែលមានស្រាប់ក្នុងខេត្តកំពង់ឆ្នាំង ...................... ៣៦
**ផែនទី១៣៖** សារៈសំខាន់នៃទំហំតំបន់ធ្វើកសិកម្ម (តាមឃុំ) ឆ្នាំ២០១២ នៅខេត្តកំពង់ឆ្នាំង...................... ៣៨
**ផែនទី ១៤ ៖** ទីតាំងតំបន់ដែលប័ណ្ណកម្មសិទ្ធិដីធ្លីឯកជនបានចែកជូនហើយក្នុងខេត្តកពង់ឆ្នាំង(ឆ្វេង) និងសម្បទានដីសេដ្ឋកិច្ច និងតំបន់សម្បទានដីសង្គមកិច្ចបីប្រភេទផ្សេងទៀតក្នុងខេត្តកំពង់ឆ្នាំង(ស្តាំ) ៤០
**ផែនទី១៥៖** អត្រាកំណើនប្រជាជនតាមស្រុកសម្រាប់រយៈពេលពីឆ្នាំ១៩៩៨ - ២០០៨ ក្នុងខេត្តកំពង់ឆ្នាំង (ខាងឆ្វេង) និងអត្រាចំណូលនិងចំណាកស្រុកតាមស្រុកនៅក្នុងខេត្តតែមួយក្នុងរយៈពេលដូចគ្នា (ខាងស្តាំ)...................... ៤៣
**ផែនទី ១៦ ៖** ដង់ស៊ីតេប្រជាជន (ខាងឆ្វេង) និងអត្រាកំណើន (ខាងស្តាំ) តាមឃុំ នៅខេត្តតាកែវ (២០០៦-២០១៤) ...................... ៤៤
**ផែនទី១៧៖** ទីតាំងសេវាសុខភាពផ្សេងៗគ្នា (ខាងឆ្វេង) និង ការទទួលបានសេវាកពីមណ្ឌលសុខភាព នៅខេត្តកំពង់ឆ្នាំង...................... ៤៧
**ផែនទី១៨ ៖** ការទទួលបានសេវាអប់រំថ្នាក់បឋមសិក្សាក្នុងខេត្តតាកែវ...................... ៤៨
**ផែនទី ១៩ ៖** បណ្តាញហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ចរាចរ) ក្នុងខេត្តកំពង់ឆ្នាំង ...................... ៥១
**ផែនទី ២០៖** ទីតាំងបណ្តាញ/ប្រព័ន្ធធារាសាស្ត្រផ្សេងៗគ្នាក្នុងខេត្តកំពង់ឆ្នាំង...................... ៥៣

**ផែនទី២១៖** ទីតាំងបណ្តាញអគ្គីសនីដែលមានស្រាប់នៅក្នុងខេត្តបាត់ដំបង ........................................ ៥៤
**ផែនទី២២៖** សារៈសំខាន់និងរបាយប្រភេទមុខរបរ (តាមឃុំ និងតាមវិស័យសំខាន់ៗ) ក្នុងខេត្តកំពង់ឆ្នាំង ៥៧
**ផែនទី២៣៖** សារៈសំខាន់ និងរបាយប្រភេទមុខរបរ (តាមវិស័យឧស្សាហកម្ម និងតាមថ្នាក់ស្រុក) ក្នុងខេត្តបាត់ដំបង........................................................................................................................ ៥៨
**ផែនទី ២៤៖** ទីតាំងតំបន់ទាក់ទាញទេសចរណ៍សំខាន់ៗក្នុងខេត្តបាត់ដំបង............................................ ៥៨
**ផែនទី ២៥៖** ការប្រើប្រាស់ដីនៅក្នុងស្រុកបវេល ឆ្នាំ២០០២ និង ២០១០ (ខាងឆ្វេង) និងការប្រែប្រួល ការប្រើប្រាស់ដីរវាងឆ្នាំ ២០០២ និង២០១០ (ខាងស្តាំ).........................................................................៦៣
**ផែនទី២៦៖** ការកំណត់ប្រព័ន្ធប្រើប្រាស់ដីនៅក្នុងខេត្តតាកែវ (ផ្នែកប្រើប្រាស់ដី - ខាងឆ្វេង, ការប្រែប្រួល ការប្រើប្រាស់ដី - កណ្តាល , និងប្រព័ន្ធប្រើប្រាស់ដីធ្លី - ខាងស្តាំ)....................................៧៣
**ផែនទី ២៧៖** ចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជនក្នុងខេត្តតាកែវ..............................................................៧៦
**ផែនទី ២៨៖** ការកំណត់ប៉ូលអភិវឌ្ឍន៍សំខាន់ៗនៅក្នុងខេត្តតាកែវ.........................................................៧៨
**ផែនទី ២៩៖** ការវិវត្តគម្របព្រៃឈើ និងការពង្រីកសិកម្មក្នុងខេត្តបាត់ដំបង ............................................ ៨៥
**ផែនទី៣០៖** ភាពងាយរងគ្រោះនៃផលិតផលកសិកម្មទៅនឹងទឹកជំនន់ (តាមឃុំ)................................ ៨៨
**ផែនទី៣១៖** ការកំណត់តំបន់គ្រប់គ្រងទីជម្រាលនាពេលអនាគតក្នុងខេត្តបាត់ដំបង ........................... ៩៧
**ផែនទី៣២៖** ទីតាំងអភិវឌ្ឍន៍ធារាសាស្ត្រនាពេលអនាគតក្នុងខេត្តបាត់ដំបង ........................................ ៩៨
**ផែនទី៣៣៖** រចនាសម្ព័ន្ធពហុមជ្ឈមណ្ឌលរបស់មជ្ឈមណ្ឌលទីប្រជុំជនក្នុងខេត្តបាត់ដំបង ................. ៩៩
**ផែនទី៣៤៖** ទីតាំងតំបន់ឧស្សាហកម្មនាពេលអនាគតស្របជាមួយនឹងការចែកចាយថាមពលអគ្គីសនី និងបណ្តាញវារីអគ្គីសនីនៅក្នុងតំបន់នាពេលអនាគត និងប្រព័ន្ធប្រើប្រាស់ដីនាពេលអនាគត..........១០២
**ផែនទី៣៥៖** ប្រព័ន្ធផ្លូវខេត្តនាពេលអនាគតសម្រាប់ខេត្តបាត់ដំបង ជាមួយនឹងប្រភេទការងារហេដ្ឋារចនាសម្ព័ន្ធជាក់លាក់ដែលត្រូវការសម្រាប់ផ្នែកផ្សេងៗគ្នានៃប្រព័ន្ធទាំងនោះ (ថែទាំ ជួសជុល និងកសាងថ្មី) ..................................................................................................................................១០៣
**ផែនទី៣៦៖** យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដីដែលបានធ្វើសមាហរណកម្មនៅក្នុងខេត្តបាត់ដំបង...........១០៤

## បញ្ជីអក្សរកាត់

| | |
|---|---|
| CDP | ផែនការអភិវឌ្ឍន៍ឃុំ |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា |
| CEMAT | សន្និសីទរដ្ឋមន្ត្រីរបស់សហភាពអឺរ៉ុបដែលទទួលខុសត្រូវលើការកសាងផែនការតំបន់/ផែនការរៀបចំដែនដី |
| CMDP | ដៃគូអភិវឌ្ឍន៍រៀបចំសហគមន៍ (អង្គការក្រៅរដ្ឋាភិបាល) |
| CLUP | ផែនការប្រើប្រាស់ដីថ្នាក់ឃុំ |
| CWG | ក្រុមការងារស្នូល (ស្ថិតនៅក្រោមក្រុមការងារថ្នាក់ក្រុងសម្រាប់កសាងផែនការរៀបចំទីក្រុង) |
| D&D | ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យ (ដែលពីមុនហៅថាវិមជ្ឈការ និងវិសហមជ្ឈការ) |
| DED | Deutscher Entwicklungsdienst (សេវាកម្មអភិវឌ្ឍន៍អាល្លឺម៉ង់) |
| DLUMP | ប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក |
| DP | ផែនការលម្អិត |
| DSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ស្រុក |
| GDP | ផលិតផលក្នុងស្រុកសរុប |
| GIS | ប្រព័ន្ធព័ត៌មានភូមិសាស្ត្រ |
| GIZ | Deutsche Gesellschaft für Internationale Zusammenarbeit GmbH (អង្គការGIZ) |
| ISIC | ចំណាត់ថ្នាក់ឧស្សាហកម្មស្តង់ដាអន្តរជាតិនៃសកម្មភាពសេដ្ឋកិច្ចទាំងអស់ |
| LMUP | ការរៀបចំដែនដី និងនគរូបនីយកម្ម |
| LMUP-C | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្ម (គ.ដ.ន) |
| LMUP-WG | ក្រុមការងារកសាងផែនការរៀបចំដែនដី និងនគរូបនីយកម្ម |
| LUMP | ប្លង់គោលប្រើប្រាស់ដី |
| LUMP-LUP | ប្លង់គោលប្រើប្រាស់ដី និងផែនការប្រើប្រាស់ដី |
| LRP II | កម្មវិធីសិទ្ធិលើដីធ្លី II (ដោយអង្គការ GIZ) |
| LUP | ផែនការប្រើប្រាស់ដី |
| M&E | ការត្រួតពិនិត្យ និងវាយតម្លៃ |
| MCLMUP | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ក្រុង (គ.ដ.ន.ក) |
| MIP | កម្មវិធីវិនិយោគក្រុង |
| MLMUPC | ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ (ក្រសួង ដ.ន.ស) |
| MLUMP | ប្លង់គោលប្រើប្រាស់ដីថ្នាក់ក្រុង |
| MoI | ក្រសួងមហាផ្ទៃ |
| MoP | ក្រសួងផែនការ |
| MPLUP | ប្លង់គោល និងផែនការប្រើប្រាស់ដី |

| | |
|---|---|
| MRC | គណៈកម្មការទន្លេមេគង្គ |
| MSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ក្រុង |
| MSLWG | ក្រុមការងារគ្រប់គ្រងដីរដ្ឋថ្នាក់ក្រុង |
| NCDD | គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបលទ្ធិប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ |
| NCLMUP | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ (គ.ដ.ន.ជ) |
| NGO | អង្គការក្រៅរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានស្ថិតិជាតិ |
| NSDP | ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ (រយៈពេល ៥ឆ្នាំ) |
| OD | ស្រុកប្រតិបត្តិ |
| PCLMUP | គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ខេត្ត (គ.ដ.ន.ខ) |
| PDLMUPCC | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត |
| PES | ការទូទាត់សេវាកម្មបរិស្ថាន |
| PIP | កម្មវិធីវិនិយោគសាធារណៈ |
| PPPS | គោលនយោបាយ កម្មវិធី ផែនការ និងយុទ្ធសាស្ត្រ |
| PSLMC | គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត |
| PSP | ផែនការរៀបចំដែនដីថ្នាក់ខេត្ត |
| PWG | ក្រុមការងារខេត្ត (រៀបចំដែនដី និងនគរូបនីយកម្ម) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ |
| SEIA | ការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងសង្គម |
| SNEC | ឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ |
| SWOT | ភាពខ្លាំង ភាពខ្សោយ ឱកាស និងការគំរាមកំហែង |
| VGGT | គោលការណ៍ណែនាំស្ម័គ្រចិត្តស្តីអំពីអភិបាលកិច្ចប្រកបដោយទំនួលខុសត្រូវលើការកាន់កាប់ដី ជលផល និងព្រៃឈើ ក្នុងបរិបទសន្តិសុខស្បៀង |
| WWF | World Wide Fund for Nature |

# ស្ថានភាពទូទៅ ៖ ផែនការរៀបចំដែនដីថ្នាក់ខេត្ត

**ប្រភេទផែនការ**

ផែនការរៀបចំដែនដីថ្នាក់ខេត្ត គឺជាគម្រោងផែនការអភិវឌ្ឍន៍ដែលផ្អែកទៅលើចក្ខុវិស័យ។

វាផ្តល់នូវការណែនាំតម្រង់ទិសជាយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍដែនដីរបស់ខេត្ត ៖

- ចក្ខុវិស័យបង្ហាញពីការអភិវឌ្ឍដែនដីរយៈពេលយូរដែលប្រាថ្នាចង់បាន
- យុទ្ធសាស្ត្រផ្សារភ្ជាប់នឹងការអភិវឌ្ឍដែនដីដែលប្រាថ្នាចង់បានដោយភ្ជាប់ជាមួយនឹងមធ្យោបាយនានាដើម្បីសម្រេចឲ្យបាននូវសេចក្តីប្រាថ្នាទាំងនោះ។

**តួនាទី និងមុខងារ**

នៅក្នុងប្រព័ន្ធផែនការប្រទេសកម្ពុជា

- ផែនការរៀបចំដែនដីថ្នាក់ខេត្ត មានគោលបំណងចង្អុលបង្ហាញនូវយុទ្ធសាស្ត្រ ផែនការ កម្មវិធី គោលនយោបាយ (PPPS) នានា ដែលពាក់ព័ន្ធនឹងការរៀបចំដែនដីនៅថ្នាក់ជាតិ ដើម្បីជាការណែនាំដល់ការកសាងផែនការរៀបចំដែនដីនៅថ្នាក់ក្រោមជាតិ (មូលដ្ឋាន) និងដើម្បីធ្វើសមាហរណកម្មរវាងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាមួយគ្នា(សមាហរណកម្មខ្សែបណ្តោយ)។
- វាធ្វើការសម្របសម្រួល និងសមាហរណកម្មយុទ្ធសាស្ត្រ ផែនការ កម្មវិធីគោល នយោបាយដែលពាក់ព័ន្ធតាមវិស័យរបស់ខេត្ត ដើម្បីដាក់បញ្ចូលជាមួយគ្នាក្នុងផែនការរៀបចំដែនដី (សមាហរណកម្មខ្សែទទឹង) និងផ្តល់ព័ត៌មានបន្ថែមដល់ការបង្កើតផែនការអភិវឌ្ឍន៍រយៈពេល៥ឆ្នាំ និងផែនការវិនិយោគរំកិល។

**ទំហំការងារ និងខ្លឹមសារ**

ផែនការរៀបចំដែនដីថ្នាក់ខេត្ត មានគោលបំណងកំណត់នូវទម្រង់លក្ខណៈដែនដីរបស់ខេត្តដែលបានប្រមើលមើលទុកមុនសម្រាប់ពេលអនាគត និងធ្វើការរៀបចំមុខងារ ដែលឆ្លើយតបទៅនឹងតំបន់ផ្សេងៗនៅក្នុងដែនដីរបស់ខេត្ត។ ដូច្នេះផែនការនេះនឹង ៖

- ពិនិត្យនិងគិតគូរពិចារណាលើលក្ខណៈសម្បត្តិរបស់ខេត្តនៅក្នុងតំបន់។
- កំណត់ និងវិភាគទម្រង់លក្ខណៈដែនដីដែលមានស្រាប់ និងទម្រង់នៃការអភិវឌ្ឍដែនដី។
- បង្កើតទម្រង់លក្ខណៈដែនដីនៃការតាំងទីលំនៅ និងហេដ្ឋារចនាសម្ព័ន្ធ តំបន់លំហនិងតំបន់ទូទៅសំខាន់ៗដែលប្រាថ្នាចង់បាន និងដែលមានមុខងារពិសេសព្រមទាំងគិតអំពីទំនាក់ទំនងរវាងសមាសភាគទាំងនេះ ដោយផ្អែកទៅលើសក្តានុពល និងតម្រូវការនៅមូលដ្ឋាន ហើយក៏ត្រូវស្របជាមួយការណែនាំតម្រង់ទិសពីថ្នាក់ជាតិផងដែរ (**យុទ្ធសាស្ត្រ ផែនការ កម្មវិធី គោលនយោបាយដែលពាក់ព័ន្ធផ្សេងៗរបស់ថ្នាក់ជាតិ**)។

- រៀបចំកំណត់មុខងារតំបន់ទីប្រជុំជន និងជនបទដែលខុសៗគ្នា និងរៀបចំវិធានការផ្សេងៗដើម្បីឆ្លើយតបដល់ការអភិវឌ្ឍប្រកបដោយចីរភាព។
- ផ្តល់ការណែនាំតម្រង់ទិស និងដាក់កម្រិតដល់ការកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុកនិងក្រុងនៅក្នុងខេត្ត។
- ជាឯកសារយោងសម្រាប់កសាងផែនការអភិវឌ្ឍន៍រយៈពេលមធ្យម និងកម្មវិធីវិនិយោគរបស់ខេត្ត។

**ខ្លឹមសារសំខាន់ៗនៅក្នុងផែនការរៀបចំដែនដីថ្នាក់ខេត្តរួមមាន៖**

- ការអភិវឌ្ឍដែលបានប្រមើលមើលទុកជាមុន នៃទម្រង់លក្ខណៈការតាំងទីលំនៅសំខាន់ៗនៅក្នុងខេត្ត ដែលត្រូវបានបង្កើតឡើងដោយប្រភេទតំបន់តាំងទីលំនៅផ្សេងៗគ្នា ( ចាប់ពីប្រភេទតំបន់តាំងទីលំនៅកម្រិតខ្ពស់ រហូតដល់កម្រិតទាបដែលភ្ជាប់ទំនាក់ទំនងជាមួយនឹងតំបន់ជនបទដែលនៅជុំវិញនោះ) ដោយផ្តល់នូវហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងសង្គម និងគ្រឿងបរិក្ខារផ្សេងៗ និងធ្វើការភ្ជាប់មជ្ឈមណ្ឌល ឬប៉ូលអភិវឌ្ឍន៍ផ្សេងៗជាមួយគ្នាតាមរយៈច្រកផ្លូវអភិវឌ្ឍន៍។
- ទម្រង់លក្ខណៈតំបន់ទេសភាព និងតំបន់លំហដែលបានប្រមើលមើលទុកមុនជាពិសេសសម្រាប់ការផ្តល់ជាទីជំរក និងការការពារប្រព័ន្ធអេកូឡូស៊ី (ដូចជាព្រៃឈើ និងទីជម្រាល) កសិកម្ម និងឧស្សាហកម្មទាញយកធនធានរ៉ែ ការកំណត់តំបន់សម្រាប់ការគ្រប់គ្រងទឹកជំនន់តំបន់ទេសចរណ៍ និងតំបន់កំសាន្ត។
- ច្រកផ្លូវសម្រាប់តំបន់ទ្រនាប់សមស្រប និងទីតាំងសម្រាប់ការដឹកជញ្ជូន និងការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ ដែលធានាដល់ការធ្វើចរាចរណ៍ និងការចល័តរបស់ប្រជាពលរដ្ឋ និងទំនិញដែលជាសេចក្តីត្រូវការសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនិងការទទួលបានហេដ្ឋារចនាសម្ព័ន្ធសង្គមដោយជៀសវាង ឬកាត់បន្ថយដល់ការធ្វើឲ្យខូចខាតដល់ប្រព័ន្ធអេកូឡូស៊ី។
- តំបន់ដែលមានមុខងារពិសេសឧទាហរណ៍ដូចជា ៖ តំបន់សមស្របសម្រាប់សម្បទានដីសេដ្ឋកិច្ច ឬសង្គមកិច្ច តំបន់សេដ្ឋកិច្ចពិសេសជាដើម ដោយធានាដល់ការកាត់បន្ថយនូវផលប៉ះពាល់ទំនាស់លើការប្រើប្រាស់ដី (ឧ. តំបន់លំនៅឋាន និងតំបន់ការពារបរិស្ថាន)។

**រយៈពេល** យ៉ាងតិច ២០ ឆ្នាំ

**មាត្រដ្ឋាន** ១:២៥០,000 ទៅ ១:១00,000

## ដំណើរការកសាងផែនការ

ដំណើរការក្នុងការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្តមាន ៦ ជំហានសំខាន់ៗ ដែលនឹងត្រូវធ្វើឡើងក្នុងរយៈពេលប្រមាណជា ២ ឆ្នាំ។ នេះជារយៈពេលមួយដែលការងារនេះត្រូវបានធ្វើឡើងប្រកបដោយភាពរលូន គ្មានការរំខាន ដោយមានធនធាន និងសមត្ថភាពគ្រប់គ្រាន់។ ប្រសិនបើត្រូវធ្វើការកសាងសមត្ថភាពដំណាលគ្នាក្នុងកំឡុងពេលដំណើរការកសាងផែនការ នោះរយៈពេលនៃការកសាងផែនការនេះនឹងត្រូវចំណាយពេលវែងជាងនេះ។

| ជំហាន | ការងារ | រយៈពេល |
|---|---|---|
| ជំហានទី១ ការរៀបចំ និងការចាប់ផ្តើមដំណើរការកសាងផែនការរៀបចំដែនដី | ការងារ១.១ ធ្វើការណែនាំអំពីផែនការរៀបចំដែនដីដល់អាជ្ញាធរខេត្ត | ១ ខែ |
| | ការងារ១.២ បង្កើតក្រុមការងារកសាងផែនការរៀបចំដែនដី | |
| | ការងារ១.៣ ពង្រឹងសមត្ថភាពដល់ក្រុមការងារកសាងផែនការរៀបចំដែនដី | |
| | ការងារ១.៤ ការកំណត់ និងគៀងគរការចូលរួមពីអ្នកពាក់ព័ន្ធ | |
| ជំហានទី២ ការវិភាគស្ថានភាព | ការងារ២.១ ការប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ | ៩ ខែ |
| | ការងារ២.២ ការវិភាគទិន្នន័យ និងការផលិតផែនទី | |
| | ការងារ២.៣ ការពិនិត្យផ្ទៀងផ្ទាត់នៅថ្នាក់ស្រុក សិក្ខាសាលាវិភាគ និងធ្វើបច្ចុប្បន្នភាព | |
| | ការងារ២.៤ ការវិភាគស្ថាប័នថ្នាក់ខេត្ត | |
| | ការងារ២.៥ ការវិភាគទម្រង់លក្ខណៈដែនដីបច្ចុប្បន្នក្នុងដែនដីខេត្ត | |
| ជំហានទី៣ កំណត់ចក្ខុវិស័យសម្រាប់អនាគត | ការងារ៣.៣ កំណត់សេណារីយ៉ូអភិវឌ្ឍន៍សម្រាប់អនាគត | ២ខែ |
| | ការងារ៣.៤ ការកំណត់ចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍រយៈពេលវែង | |
| ជំហានទី៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី | ការងារ៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី | ៦ខែ |
| | ការងារ៤.២ ធ្វើការសម្របយុទ្ធសាស្ត្រតាមវិស័យ | |
| | ការងារ៤.៣ ការពិភាក្សាជាមួយអាជ្ញាធរខេត្ត | |
| ជំហានទី៥ ការអនុវត្ត ត្រួតពិនិត្យ វាយតម្លៃ និងការធ្វើបច្ចុប្បន្នភាពផែនការ | ការងារ៥.១ ការអនុវត្ត និងត្រួតពិនិត្យ | ១ខែ |
| | ការងារ៥.២ ការវាយតម្លៃ ការធ្វើបច្ចុប្បន្នភាព និងការធ្វើឲ្យមានភាពស៊ីគ្នានៃឧបករណ៍កសាងផែនការ | |
| ជំហានទី៦ ការបញ្ចប់ដំណើរការកសាងផែនការ | ការងារ៦.១ ការពិភាក្សាជាសាធារណៈចុងក្រោយជាមួយអ្នកពាក់ព័ន្ធទាំងអស់ | ៥ខែ |
| | ការងារ៦.២ ការរៀបចំរបាយការណ៍បច្ចេកទេសចុងក្រោយ | |
| | ការងារ៦.៣ ការបិទផ្សាយជាសាធារណៈ និងការគាំទ្រលើផែនការដោយក្រុមប្រឹក្សាខេត្ត | |
| | ការងារ៦.៤ ការឯកភាពលើផែនការដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ | |

**រូបភាព ១៖** ជំហានដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត

## ជំហានទី១ ការរៀបចំ និងការចាប់ផ្តើមដំណើរការកសាងផែនការរៀបចំដែនដី

### គោលបំណងរួម

- បង្កើតនូវការយល់ដឹង និងភាពជាម្ចាស់សម្រាប់ដំណើរការកសាងផែនការរៀបចំដែនដី
- កំណត់ និងគៀងគរការចូលរួមពីអ្នកពាក់ព័ន្ធទាំងអស់
- កំណត់ឲ្យច្បាស់ពីតួនាទី និងការទទួលខុសត្រូវ
- បង្កើតក្រុមការងារប្រតិបត្តិកសាងផែនការរៀបចំដែនដី។

### ការងារ ១.១ ធ្វើការណែនាំអំពីផែនការរៀបចំដែនដីដល់អាជ្ញាធរខេត្ត

### ស្ថានភាពទូទៅ

ក្នុងការពិភាក្សាលើកដំបូងនៅថ្នាក់ខេត្ត (កិច្ចប្រជុំតូចសម្រាប់ចាប់ផ្តើមគម្រោងដំបូងឧបសម្ព័ន្ធ១) គោលបំណង និងទំហំការងារនៃផែនការរៀបចំដែនដីខេត្ត ត្រូវបង្ហាញជូនអាជ្ញាធរខេត្តសំខាន់ៗ និងធ្វើការពិភាក្សាពីសក្តានុពល បញ្ហាប្រឈម និងតម្រូវការផ្សេងៗសម្រាប់កសាងផែនការរៀបចំដែនដីនៅក្នុងខេត្តនោះ។

### អ្នកណាខ្លះ នឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- **អ្នកផ្តួចផ្តើម**
  - ក្រុមប្រឹក្សាខេត្ត
  - ក្រសួង ដ.ន.ស (ជាអ្នកផ្តល់ជំហរគាំទ្រ)
  - មន្ទីរ ដ.ន.ស.សខេត្ត
  - គ.ជ.ន.ខ (ជាអ្នកសម្របសម្រួល)
- **អ្នកចូលរួម**
  - ក្រុមប្រឹក្សាខេត្ត និងគណ:អភិបាលខេត្ត
  - មន្ទីរជំនាញជុំវិញខេត្ត
  - អ្នកតំណាងមកពីខេត្តដែលបានកសាងផែនការរៀបចំដែនដីប្រកបដោយភាពជោគជ័យ

### សកម្មភាពការងារ/វិធីសាស្ត្រ

- ប្រជុំជាមួយអាជ្ញាធរខេត្តដើម្បីធ្វើការណែនាំពីវិធីសាស្ត្រកសាងផែនការរៀបចំដែនដី (ជាបទបង្ហាញដែលបង្ហាញលើផ្ទាំងក្រដាសធំ)។ បទបង្ហាញនេះគួរធ្វើការពន្យល់ឲ្យបានច្បាស់ពីគោលបំណងរួម និងវិធីសាស្ត្រកសាងផែនការរៀបចំដែនដី និងគុណតម្លៃនៃផែនការរៀបចំដែនដី ដែលផ្តល់គុណប្រយោជន៍បន្ថែមទៅដល់ដំណើរការកសាងផែនការដែលមានស្រាប់។
- គួរអញ្ជើញអ្នកជំនាញមានបទពិសោធន៍សំខាន់ៗ (មកពីក្រសួង ដ.ន.ស ឬអ្នកខាងក្រៅ) ធ្វើបទបង្ហាញពីករណីសិក្សានៃការកសាងផែនការរៀបចំដែនដីដែលបានធ្វើនៅក្នុងខេត្តដទៃផ្សេងទៀត។

- សម្របសម្រួលការពិភាក្សាពីសក្តានុពល បញ្ហាប្រឈម និងតម្រូវការផ្សេងៗសម្រាប់កសាងផែនការរៀបចំដែនដីនៅក្នុងខេត្ត និងពិភាក្សាពីទំហំនៃផែនការទាំងមូល។
- ជម្រុញឲ្យមានការពិភាក្សាផុលផុសពីអ្នកចូលរួមទាំងអស់ (ឲ្យមានពេលវេលាគ្រប់គ្រាន់សម្រាប់ការពិភាក្សា)។
- ឯកភាពនូវជំហានបន្ទាប់ (ជំហាន ១.២-១.៤) ជាមួយនឹងកាលវិភាគពេលវេលាធ្វើការងារ និងការទទួលខុស ត្រូវ។

**លទ្ធផលរំពឹងទុក**

- អាជ្ញាធរខេត្តយល់ពីគោលបំណង និងដំណើរការរួមនៃការកសាងផែនការរៀបចំដែនដី និងបង្ហាញពីការប្តេជ្ញាចិត្ត និងភាពជាម្ចាស់គម្រោងនៃដំណើរការកសាងផែនការ។
- ក្រុមប្រឹក្សាខេត្តអនុញ្ញាតឲ្យអនុវត្តតាមដំណើរការ។
- តារាងបញ្ជីដែលមានការឯកភាពសម្រាប់ជំហានបន្ទាប់ភ្ជាប់ជាមួយនឹងការទទួលខុសត្រូវ និងកាលវិភាគអនុវត្តការងារ។

**ការងារ ១.២ បង្កើតក្រុមការងារកសាងផែនការរៀបចំដែនដី**

**ស្ថានភាពទូទៅ**

គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ខេត្ត **(គ.ដ.ន.ខ)** ដែលមានអភិបាលខេត្តជាប្រធាននឹងត្រូវផ្តួចផ្តើមនិងសម្រសម្រួលលើដំណើរការកសាងផែនការ ហើយនិងមានតំណាងពីមន្ទីរជំនាញនីមួយៗនៅក្នុងគណៈកម្មាធិការនេះ។ លេខាធិការដ្ឋាន (តទៅនេះហៅក្រុមការងារខេត្ត) ដែលដឹកនាំដោយប្រធានមន្ទីរ ដ.ន.ស.ស និងមានសមាសភាគតំណាងមកពីសាលាខេត្ត មន្ទីរជំនាញ និងអង្គការដែលពាក់ព័ន្ធផងដែរនោះនឹងត្រូវធ្វើជាជំនួយការដល់ គ.ដ.ន.ខ។ ក្រុមប្រឹក្សាខេត្តនឹងត្រូវធ្វើការសម្រេចនូវចំនួនសមាសភាគជាក់ស្តែងរបស់ គ.ដ.ន.ខ និងអនុម័តលើចំនួនសមាសភាគរបស់ក្រុមការងារខេត្តផងដែរ។(អានបន្ថែមអនុក្រឹត្យលេខ ៧៧ ឆ្នាំ២០១៣ ជាពិសេសត្រង់មាត្រា ០៣)។

ក្រុមការងារខេត្តត្រូវបានចាត់តាំងឲ្យធ្វើការរៀបចំ និងអនុវត្តដំណើរការកសាងផែនការរៀបចំដែនដី៖ ប្រមូល និងវិភាគទិន្នន័យសំខាន់ៗ ថែរក្សាទិន្នន័យសម្រាប់កសាងផែនការរៀបចំដែនដីរៀបចំផែនទី រៀបចំដាក់ចេញជម្រើសផែនការរៀបចំដែនដីទៅអនាគត និងធ្វើសេចក្តីព្រាងរបាយការណ៍បច្ចេកទេសនៃផែនការរៀបចំដែនដី។ វាមានសារៈសំខាន់ណាស់ដែលមុខងារនៃផែនការរៀបចំដែនដី ដែលជាយន្តការសមាហរណកម្មមួយ ត្រូវបានឆ្លុះបញ្ចាំងតាមរយៈសមាសភាគចម្រុះ (អន្តរវិស័យ)នៃក្រុមការងារ។ ជាពិសេសនោះ សមាជិករបស់ក្រុមការងារ គឺជាមន្ត្រីបច្ចេកទេសមកពីមន្ទីរជំនាញដែលមានតំណាងនៅក្នុង គ.ដ.ន.ខ។ ជាជម្រើសមួយវិញទៀត ក្រុមការងារក៏អាចបញ្ចូលសមាជិកដែលមកពីស្ថាប័នដែលមិនមែនរដ្ឋាភិបាល (ដូចជាវិស័យឯកជន និងអង្គការក្រៅរដ្ឋាភិបាល ជាដើម)។ ប្រសិនបើក្រុមការងារខេត្ត មិនមានការចូលរួមផ្តល់ការគាំទ្របច្ចេកទេសក្នុងដំណើរការកសាងផែនការនេះទេ ត្រូវរៀបចំក្រុមការងារស្នូលមួយដើម្បីអនុត្តការងារនេះ។

**អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?**

- អ្នកផ្តួចផ្តើម
  - ក្រុមប្រឹក្សាខេត្ត
  - មន្ទីរ ដ.ន.ស.ស ខេត្ត
  - គ.ដ.ន.ខ
- អ្នកចូលរួម
  - គណៈអភិបាលខេត្ត
  - មន្ទីរជំនាញរបស់ខេត្ត

**សកម្មភាពការងារ/វិធីសាស្ត្រ**

- ការងាររបស់ក្រុមការងារខេត្តគួរស្របជាមួយនឹងការចាត់តាំងតួនាទី និងការទទួលខុសត្រូវរបស់ខ្លួន ក៏ដូចជាការកំណត់កាលវិភាគប្រជុំឲ្យបានទៀងទាត់។ ក្រុមកាងារខេត្តត្រូវការការិយាល័យដែលនឹងត្រូវផ្តល់ឲ្យដោយរដ្ឋបាលខេត្តជាពិសេសវាគួរស្ថិតនៅក្នុងមន្ទីរ ដ.ន.ស.ស ខេត្ត។ ការិយាល័យនេះត្រូវបំពាក់ដោយបច្ចេកវិទ្យាព័ត៌មាន និងបរិក្ខារផ្សេងៗទៀតក្នុងការិយាល័យ។
- **គន្លឹះសំខាន់៖** ប្រសិនបើមានការរៀបចំបានត្រឹមត្រូវ កិច្ចការនេះអាចដាក់បញ្ចូលគ្នាជាមួយនឹងកិច្ចប្រជុំតូចសម្រាប់ចាប់ផ្តើមគម្រោងដំបូងឲ្យហើយ ព្រោះនៅពេលនោះអាជ្ញាធរជំនាញពាក់ព័ន្ធមានវត្តមាននៅទីនោះ ដូច្នេះប្រសិនបើត្រូវអញ្ជើញពួកគាត់មកលើកក្រោយសារជាថ្មីម្តងទៀតវានឹងត្រូវការចំណាយពេលវេលាច្រើន។

**លទ្ធផលរំពឹងទុក**

- ក្រុមការងារកសាងផែនការរៀបចំដែនដីខេត្ត (គ.ដ.ន.ខ និងក្រុមការងារខេត្ត) ត្រូវបានបង្កើតឡើងជាផ្លូវការ
  - ក្រុមប្រឹក្សាខេត្ត ចាត់តាំងបង្កើត គ.ដ.ន.ខ ដោយផ្អែកលើសេចក្តីដូចដែលមានចែងក្នុងមាត្រា០៣ នៃអនុក្រឹត្យលេខ ៧៧។
  - ការិយាល័យរបស់ក្រុមការងារខេត្តត្រូវបានផ្តល់ឲ្យ និងបំពាក់នូវសម្ភារៈគ្រប់គ្រាន់។

## ការងារ ១.៣ ពង្រឹងសមត្ថភាពដល់ក្រុមការងារកសាងផែនការរៀបចំដែនដី

### ស្ថានភាពទូទៅ

រយៈពេល ក៏ដូចជាគុណភាពនៃដំណើរការការងារកសាងផែនការ ព្រមទាំងផែនការរៀបចំដែនដីនេះផ្ទាល់ អាស្រ័យទៅលើកម្រិតចំណេះដឹងសមត្ថភាពរបស់ក្រុមការងារកសាងផែនការរៀបចំដែនដី។ សិក្ខាសាលាកសាងក្រុមការងារជាមួយសមាសភាគទាំងអស់របស់មន្ទីរ ដ.ន.ស ខេត្ត និងក្រុមការងារខេត្ត គឺជាឱកាសមួយដ៏ល្អដើម្បីពន្យល់ពីទំហំការងារនិងនីតិវិធីលម្អិតស្តីអំពីដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្តនិងធ្វើការវាយតម្លៃទៅលើអ្វីដែលមានស្រាប់និងវាយតម្លៃទៅលើចំណេះដឹងសមត្ថភាពដែលក្រុមការងារខេត្តត្រូវការដើម្បីកសាងផែនការនេះ។ វារួមមានការពិភាក្សា និងការឯកភាពគ្នាទៅលើការងារ និងតួនាទីរបស់សមាជិក នីមួយៗ។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកចូលរួម
    - គ.ដ.ន.ខ និង ក្រុមការងារខេត្ត
    - គ្រូបណ្តុះបណ្តាល (ក្រសួង ដ.ន.ស ឬអ្នកខាងក្រៅ)

### សកម្មភាពការងារ/វិធីសាស្រ្ត

ការងារដែលត្រូវធ្វើសម្រាប់ក្រុមការងារខេត្ត ក្នុងសិក្ខាសាលាកសាងក្រុមការងារជាលើកដំបូងមាន៖

- ផ្តល់នូវការបណ្តុះបណ្តាលណែនាំពីនីតិវិធីលម្អិតស្តីពីការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត។
- សម្របសម្រួលការពិភាក្សាពីតួនាទី និងការទទួលខុសត្រូវក៏ដូចជាបែបបទក្នុងការធ្វើការងារ។
- ធ្វើការវាយតម្លៃពីជំនាញដែលមានស្រាប់ និងចំណេះដឹងសមត្ថភាពត្រូវការបន្ថែមទៀតរបស់សមាជិកក្រុមការងារខេត្ត ដើម្បីជួយដល់ការកំណត់ពីតួនាទី និងការទទួលខុសត្រូវក៏ដូចជាតម្រូវការសម្រាប់ការអភិវឌ្ឍសមត្ថភាពផងដែរ។
- លក្ខខន្តិកៈធ្វើការងារគួរមានការឯកភាពគ្នា ពិពណ៌នាលម្អិតពីតួនាទី ការទទួលខុសត្រូវ និងកាលវិភាគធ្វើការងារដោយផ្អែកទៅលើការវាយតម្លៃលើចំណេះដឹងសមត្ថភាព។
- សិក្ខាសាលាគួរធ្វើការកសាងឬពិនិត្យលើផែនការថវិកា និងការងារដែលមានស្រាប់ យ៉ាងហោចណាស់ពិនិត្យទៅលើអ្វីដែលនៅសល់ប្រចាំឆ្នាំ។
- **គន្លឹះសំខាន់៖** ដើម្បីជម្រុញការងារនេះឲ្យមានប្រសិទ្ធភាពក្រុមការងារគួរធ្វើទស្សនកិច្ចទៅកាន់ខេត្តដែលបានកសាងផែនការរៀបចំដែនដីថ្នាក់ខេត្តនេះរួចហើយ ដើម្បីធ្វើការស្វែងយល់ពីបទពិសោធន៍ទាក់ទងនឹងការងារនេះ ដូចជាការងារដែលទាក់ទងទៅនឹងការៀបចំការធ្វើផែនការ និងថវិកាជាដើម ។

**លទ្ធផលរំពឹងទុក**

- ការយល់ដឹងពីទំហំ និងដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត ក៏ដូចជាតួនាទី និងការងាររបស់ក្រុមការងារខេត្តត្រូវបានធ្វើឲ្យប្រសើរឡើង។
- ផែនការសកម្មភាព ត្រូវបានរៀបចំឡើង និងឯកភាពពីគ្រប់សមាជិកក្រុមការងារទាំងអស់ រួមបញ្ចូលទាំង តួនាទី និងការងាររបស់សមាជិកក្រុមការងារខេត្ត (លក្ខខន្តិក:ការងារ)។
- ដោយផ្អែកលើតម្រូវការ និងតួនាទីដែលបានកំណត់ ផែនការកសាងសមត្ថភាពដល់សមាជិកផ្សេងៗគ្នារបស់ក្រុមការងារខេត្តត្រូវបានរៀបចំឡើង។
- ដោយផ្អែកលើផែនការផែនការបណ្តុះបណ្តាលកសាងសមត្ថភាពនេះ ធនធានសម្រាប់បណ្តុះបណ្តាល (អ្នកជំនាញមានបទពិសោធន៍ ថវិកាគាំទ្រជាដើម) ត្រូវបានកំណត់។
- ផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំ និង/ឬពិនិត្យលម្អិត។

## ការងារ ១.៤ ការកំណត់ និងគៀងគរការចូលរួមពីអ្នកពាក់ព័ន្ធ

### ស្ថានភាពទូទៅ

នៅពេលដែលក្រុមការងារកសាងផែនការរៀបចំដែនដីថ្នាក់ខេត្តត្រូវបានបង្កើតឡើងហើយនោះ ជនបង្គោលផ្សេងៗនៅក្នុងដំណើរការកសាងផែនការ ឬក្នុងការអនុវត្តការងារ ត្រូវបានកំណត់និងជួបជុំគ្នានៅក្នុងកិច្ចប្រជុំចាប់ផ្តើមគម្រោងដំបូងធំមួយ។ គោលបំណងនិងទំហំការងារកសាងផែនការរៀបចំដែនដីនឹងត្រូវបង្ហាញដល់អ្នកពាក់ព័ន្ធទាំងអស់ ហើយតួនាទី និងការចូលរួមសំខាន់ៗរបស់ពួកគាត់ក៏នឹងត្រូវធ្វើការពិភាក្សាជាមួយគ្នាផងដែរ។ កិច្ចប្រជុំការងារដំបូងត្រូវបានរៀបចំឡើងដើម្បីធ្វើការពិភាក្សាពីការរំពឹងទុករបស់អ្នកពាក់ព័ន្ធទាំងអស់ ទៅលើដំណើរការកសាងផែនការរៀបចំដែនដី និងអំពីបញ្ហាអភិវឌ្ឍន៍ដែនដីសំខាន់ៗដែលត្រូវធ្វើការដោះស្រាយ។ នៅក្នុងកិច្ចប្រជុំនេះក៏អាចពិភាក្សាពីអ្នកពាក់ព័ន្ធផ្សេងៗបន្ថែមទៀតដែលអាចស្នើឡើងផងដែរ។

**អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?**

- អ្នកផ្តួចផ្តើម
    - ក្រុមប្រឹក្សាខេត្ត
    - គ.ដ.ន.ខ និង ក្រុមការងារខេត្ត
- អ្នកចូលរួម
    - អ្នកពាក់ព័ន្ធទាំងអស់ (តារាង១)

**សកម្មភាពការងារ/វិធីសាស្ត្រ**

- សម្របសម្រួលការពិភាក្សារវាងក្រុមការងារខេត្ត និង គ.ដ.ន.ខ ដើម្បីកំណត់ពីអ្នកចូលរួមពាក់ព័ន្ធក្នុងការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្តទាំងអស់ ដូចជាអ្នកដែលត្រូវចូលរួមក្នុងដំណើរការក៏ដូចជាអ្នកដែលត្រូវពាក់ព័ន្ធនឹងការអនុវត្តផែនការ(តារាង១បង្ហាញពីបញ្ជីស្ថាប័នពាក់ព័ន្ធសំខាន់ៗ)។

**តារាង ១ ៖** បង្ហាញពីអ្នកពាក់ព័ន្ធសំខាន់ៗក្នុងដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត

| **វិស័យ** | | **អ្នកពាក់ព័ន្ធ** |
|---|---|---|
| ស្ថាប័នរដ្ឋ | | រដ្ឋបាលខេត្ត |
| | | មន្ទីរជំនាញខេត្ត |
| | | រដ្ឋបាលស្រុក (ក្រុមប្រឹក្សា និង/ឬ គណៈអភិបាលស្រុក) |
| | | សមាគមន៍ក្រុមប្រឹក្សាឃុំថ្នាក់ខេត្ត |
| | | គណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយ |
| | | គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ |
| | | គណៈកម្មាធិការគ្រប់គ្រងទីជម្រាល |
| ស្ថាប័ន មិនមែន រដ្ឋាភិបាល | វិស័យឯកជន | សភាពាណិជ្ជកម្ម |
| | | តំណាងសហគ្រាសខ្នាតធំ ( ឬក៏សហព័ន្ធ ប្រសិនបើមាន) |
| | | តំណាងសហគ្រាសខ្នាតតូច និងមធ្យម( ឬក៏សហជីព ប្រសិនបើមាន) |
| | | អ្នកអភិវឌ្ឍន៍ ឬម្ចាស់ដីដែលមានឥទ្ធិពល |
| | អង្គការក្រៅ រដ្ឋាភិបាល | ស្ថាប័នសម្របសម្រួលថ្នាក់ខេត្តរបស់អង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក |
| | | អង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ (ដូចជាអង្គការដែលធ្វើការងារពាក់ព័ន្ធនឹងការប្រែប្រួលអាកាសធាតុ សេដ្ឋកិច្ចជនបទ និងបរិស្ថានជាដើម) |
| | កម្មវិធី/គម្រោង សហប្រតិបត្តិការ ទ្វេភាគី/ពហុភាគី | គម្រោង/កម្មវិធីនានាដែលពាក់ពន្ធ័នឹងការងារអភិវឌ្ឍន៍ក្នុងខេត្ត |
| | អប់រំ | សាកលវិទ្យាល័យ |
| | សង្គមស៊ីវិល | សាសនា សមាគមស្ត្រី/យុវជន សមាគមជនជាតិដើមភាគតិចនិងក្រុមតំណាងផ្សេងៗទៀតដែលធ្វើការពាក់ព័ន្ធនឹងការកសាងផែនការរៀបចំដែនដី |
| | សារព័ត៌មាន | សមាគម និងអ្នកកាសែត (វិទ្យុ ទូរទស្សន៍ និងសារព័ត៌មាន) |

- រៀបចំសិក្ខាសាលាដោយមានបទបង្ហាញពីគោលបំណងរួម វិធីសាស្រ្តកសាងផែនការរៀបចំដែនដី និងការរំពឹងទុកពីការចូលរួមចំណែករបស់អ្នកពាក់ព័ន្ធទាំងអស់។អ្នកខាងក្រៅដែលមានបទពិសោធន៍ទាក់ទងនឹងការងារនេះ អាចបង្ហាញករណីសិក្សាពីការកសាងផែនការរៀបចំដែនដីដែលបានធ្វើឡើងនៅក្នុងខេត្តដទៃផ្សេងទៀត។
- សម្របសម្រួលក្រុមពិភាក្សា (បំផុសគំនិត) ពិភាក្សាពីលទ្ធផលរំពឹងទុកពីដំណើរការ ការត្រៀមខ្លួនរបស់អ្នកពាក់ព័ន្ធទាំងអស់ក្នុងការចូលរួមនិងបញ្ហាអភិវឌ្ឍន៍ដែនដីសំខាន់ៗដែលនឹងត្រូវដោះស្រាយ។
- បង្ហាញពីដំណើរការកសាងផែនការ ទំហំ និងគោលបំណងការងារនេះ តាមរយៈប្រព័ន្ធផ្សព្វផ្សាយផ្សេងៗ (ដូចជា វិទ្យុ ទូរទស្សន៍ និងសារព័ត៌មាន)។
- ត្រូវចាំថា ត្រូវធ្វើការថែរក្សា និងធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះអ្នកពាក់ព័ន្ធនៅក្នុងក្រុមការងារខេត្តតាមរយៈដំណើរការកសាងផែនការ។ វាអាចមានប្រយោជន៍ដល់ការព្រាងផែនទីអ្នកពាក់ព័ន្ធជាក់លាក់មួយ។

- **គន្លឹះសំខាន់៖** អាចប្រើប្រាស់សិក្ខាសាលាចាប់ផ្តើមគម្រោងដំបូងដ៏ធំនេះ ដើម្បីចាប់ផ្តើម ឬ យ៉ាងហោចណាស់ក៏ជាការរៀបចំដើម្បីប្រមូលទិន្នន័យ (ជំហាន២ ការងារ ២.១)។ ដូច្នេះនៅក្នុង លិខិតអញ្ជើញអ្នកពាក់ព័ន្ធចូលរួមក្នុងសិក្ខាសាលាទាំងអស់ ត្រូវភ្ជាប់ជាមួយទម្រង់បែបបទបំពេញ ព័ត៌មានបន្ថែមមួយដែលបញ្ជាក់អំពីទិន្នន័យដែលស្ថាប័នអ្នកចូលរួមមានស្រាប់ ប្រភេទទិន្នន័យ (ទម្រង់ទិន្នន័យ)បច្ចុប្បន្នភាពទិន្នន័យចុងក្រោយ ព័ត៌មានសម្រាប់ទំនាក់ទំនងលម្អិតនៅពេលត្រូវការ ឲ្យមានការបញ្ជាក់បន្ថែមទៅលើទិន្នន័យដែលផ្តល់ឲ្យ ក៏ដូចជាព័ត៌មានផ្សេងៗទៀតដែលត្រូវការ ផងដែរ។ ទម្រង់បែបបទបំពេញព័ត៌មាននេះត្រូវប្រមូលនៅក្នុងពេលធ្វើសិក្ខាសាលានេះ និងត្រូវ រៀបចំពេលវេលាសម្រាប់ពិភាក្សាពីទិន្នន័យទាំងនេះ ក៏ដូចជាពិភាក្សាពីជំហានដែលនឹងត្រូវធ្វើបន្ត ទៀត។

**លទ្ធផលរំពឹងទុក**

- កំណត់បាននូវសមាសភាគអ្នកពាក់ព័ន្ធក្នុងការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត (ផែនទីអ្នកពាក់ព័ន្ធ)។
- អ្នកពាក់ព័ន្ធបានដឹង និងយល់អំពីដំណើរការទូទៅនៃការកសាងផែនការរៀបចំដី។
- កំណត់បានពីការប្តេជ្ញាចិត្តរបស់អ្នកពាក់ព័ន្ធផ្សេងៗក្នុងការចូលរួមក្នុងដំណើរកសាងផែនការ។
- បានធ្វើផែនទីបង្ហាញពីបញ្ហាអាទិភាពចំបងៗដែលត្រូវដោះស្រាយក្នុងផែនការរៀបចំដែនដីថ្នាក់ខេត្ត។

## ជំហានទី២ ការវិភាគស្ថានភាព

**គោលបំណងរួម**

- ប្រមូល និងផ្ទៀងផ្ទាត់ពិនិត្យទិន្នន័យទី២ (ទិន្នន័យដែលមានស្រាប់) ហើយករណីដែលចាំបាច់ទិន្នន័យណាដែលខ្វះខាតនឹងត្រូវបំពេញបន្ថែមដោយទិន្នន័យបឋមតាមរយៈការចុះអង្កេតប្រមូលផ្ទាល់នៅវាល
- បង្កើតឃ្លាំងផ្ទុកទិន្នន័យដែនដី (ដាតាបេស) ថ្នាក់ខេត្តរួមមួយ
- កំណត់ និងវិភាគទម្រង់លក្ខណៈដែនដីដែលមានស្រាប់ និងបែបផែននៃការអភិវឌ្ឍដែនដីនៅក្នុងដែនដីខេត្ត
- ពិនិត្យឡើងវិញជាប្រព័ន្ធទៅលើភាពខ្លាំង និងភាពខ្សោយនៃបញ្ហា និងតាមវិស័យដែលពាក់ព័ន្ធនឹងការរៀបចំដែនដី ក៏ដូចជាការពិភាក្សាទៅលើតម្រូវការ សក្តានុពល ជម្រើស និងការគំរាមកំហែង
- ប្រមូលផ្តុំចងក្រងនូវព័ត៌មានដែនដី ព្រឹត្តិការណ៍ តួរលេខជាសង្ខេប អំពីស្ថានភាពបច្ចុប្បន្ននៃដែនដីខេត្តសម្រាប់ជាមូលដ្ឋានក្នុងការវិភាគបន្តបន្ទាប់ទៀត។

### ការងារ ២.១ ការប្រមូលទិន្នន័យ និងការគ្រប់គ្រងទិន្នន័យ

#### ស្ថានភាពទូទៅ

ដំណើរការនេះ ចាប់ផ្តើមជាមួយការប្រមូលចងក្រងទិន្នន័យដែលមានស្រាប់ទាំងអស់ដែលពាក់ព័ន្ធនឹងការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត ដែលទិន្នន័យទាំងនោះប្រមូលមកពីវិស័យផ្សេងៗគ្នា ហើយធ្វើការចងក្រងពិនិត្យ និងបញ្ចូលទៅក្នុងឃ្លាំងផ្ទុកទិន្នន័យមួយសម្រាប់ការកសាងផែនការរៀបចំដែនដីពហុវិស័យ។ ក្នុងដំណាក់កាលនេះ វាមានសារៈសំខាន់ណាស់ក្នុងការប្រើប្រាស់ (សហការ)ជាមួយមន្ទីរជំនាញជុំវិញខេត្ត។ វាសំខាន់ណាស់ក្នុងការស្វែងយល់ថាដំណាក់ការងារនេះនៅមិនទាន់បានកសាងផែនការតំបន់ ឬតាមវិស័យទេ វាគ្រាន់តែផ្តល់នូវព័ត៌មានគន្លឹះ និងស្វែងយល់ពីស្ថានភាពបច្ចុប្បន្នដែលបង្កើតបានជាមូលដ្ឋានសម្រាប់ការវិភាគរួមគ្នា (សមាហរណកម្ម) ហើយការកសាងផែនការនឹងត្រូវបានធ្វើការបកស្រាយពន្យល់ក្នុងជំហានទី៤ បន្ទាប់។

#### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកផ្តួចផ្តើម និងអនុវត្ត
  - ក្រុមការងារខេត្ត
  - អ្នកជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)/គ្រប់គ្រងទិន្នន័យ
  - គ្រូបណ្តុះបណ្តាល (ក្រសួង ដ.ន.ស ឬអ្នកជំនាញខាងក្រៅ)
- អ្នកដែលត្រូវចូលរួមពិភាក្សា
  - អ្នកពាក់ព័ន្ធទាំងអស់ (តារាង១)

## សកម្មភាពការងារ/វិធីសាស្ត្រ

- កំណត់រចនាសម្ព័ន្ធប្រព័ន្ធដាតាបេសទិន្នន័យឲ្យបានច្បាស់លាស់ ដោយផ្អែកទៅលើប្រភេទទិន្នន័យតាមវិស័យមេសំខាន់ និងអនុប្រភេទទិន្នន័យ (តារាង២)។ វាមានសារៈសំខាន់ណាស់ក្នុងធ្វើការងារនេះឲ្យបានជាក់លាក់ ដោយវាជាមូលដ្ឋានគ្រឹះសម្រាប់ដំណើរការកសាងផែនការទាំងមូល។
- រៀបចំរចនាសម្ព័ន្ធគ្រប់គ្រងដាតាបេស និងប្រមូលទិន្នន័យស្របទៅតាមតារាងបញ្ជីទិន្នន័យដែលត្រូវការចាំបាច់សម្រាប់យកមកកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត (ឧបសម្ព័ន្ធ ២)។
- ធ្វើការចងក្រងប្រមូលទិន្នន័យទី២ជាជំហានដំបូង ដោយចូលទៅកាន់គេហទំព័រដែលមានផ្ទុកទិន្នន័យមានស្រាប់សម្រាប់សាធារណៈជន (the open access) (ឧបសម្ព័ន្ធ២)។
- ដើម្បីទទួលបានទិន្នន័យដែលមិនមាននៅតាមគេហទំព័រ ដែលមានផ្ទុកទិន្នន័យមានស្រាប់សម្រាប់សាធារណៈជន ត្រូវផ្តួចផ្តើមរៀបចំដំណើរការប្រមូលទិន្នន័យបំពេញបន្ថែមមួយទៀតជាមួយមន្ទីរជំនាញជុំវិញខេត្តនីមួយៗ និងស្ថាប័នពាក់ព័ន្ធផ្សេងៗទៀតដែលមិនមែនរដ្ឋាភិបាល (មើលគន្លឹះសំខាន់សម្រាប់ការងារ ១.៤)។ សមាជិករបស់ក្រុមការងារនីមួយៗ ត្រូវទទួលខុសត្រូវប្រមូលទិន្នន័យដែលមានក្នុងស្ថាប័នរបស់ខ្លួន។ ជាអនុសាសន៍ដ៏ល្អនោះ ទិន្នន័យគួរតែប្រមូលទៅតាមដំណាក់កាលពេលវេលារបស់វា ដើម្បីងាយស្រួលក្នុងការវិភាគពីទំនោរ នៃការប្រែប្រួលនាពេលក្រោយទៀត។

**តារាង១៖** រចនាសម្ព័ន្ធទូទៅនៃប្រព័ន្ធដាតាបេសទិន្នន័យសម្រាប់កសាងផែនការរៀបចំដែនដី

| ប្រភេទសំខាន់ៗតាមវិស័យ (មេ) | អនុប្រភេទ |
|---|---|
| រដ្ឋបាល | មជ្ឈមណ្ឌលរដ្ឋបាល និងព្រំប្រទល់ |
| បរិស្ថានរូបវន្តជីវសាស្ត្រ | សណ្ឋានដី |
| | អាកាសធាតុ |
| | ជលវិទ្យា (ធនធានទឹក) |
| | ភូគព្ភសាស្ត្រ |
| | ដី |
| | ហានិភ័យផ្នែកបរិស្ថាន និងអេកូឡូស៊ី |
| ប្រជាជន និងលំនៅឋាន | ប្រជាសាស្ត្រ |
| | ទម្រង់លក្ខណៈនៃការតាំងទីលំនៅ (ជនបទ និងទីប្រជុំជន) |
| ការប្រើប្រាស់ដី និងការកាន់កាប់ដី | គម្របព្រៃឈើ និងការគ្រប់គ្រង |
| | តំបន់ការពារ |
| | បរិស្ថាន |
| | ជលផល |
| | តំបន់សាងសង់ |
| | តំបន់យកថ្ម |
| | ការកាន់កាប់ |

| | | |
|---|---|---|
| ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | ការដឹកជញ្ជូន (ផ្លូវគោក ផ្លូវដែក ផ្លូវអាកាស និងផ្លូវទឹក) |
| | ថាមពល |
| | ការគ្រប់គ្រងកាកសំណល់ |
| | ការគ្រប់គ្រងទឹក ( ទ្វារទឹក ទំនប់ទឹក ធារាសាស្ត្រ) |
| សេវាកម្មវប្បធម៌និងសង្គម | សុខភាព |
| | ការអប់រំ |
| | កេរមរតក (បុរាណវិទ្យា វិស្វកម្ម) |
| សេដ្ឋកិច្ច | ការអភិវឌ្ឍសេដ្ឋកិច្ច |
| | ការងារ |
| | ពាណិជ្ជកម្ម និងជំនួញ |
| | កសិកម្ម |
| | ឧស្សាហកម្ម |
| | ទេសចរណ៍ និងការកំសាន្ត |

- ដាក់បញ្ចូលរាល់ទិន្នន័យទាំងអស់ទៅក្នុងប្រព័ន្ធដាតាបេសផែនការរៀបចំដែនដីដែលបានរៀបចំហើយ ដូច្នេះទើបយើងអាចបង្ហាញទិន្នន័យទាំងអស់នៅលើផែនទី។ការបញ្ចូលទិន្នន័យនេះ ទាមទារឲ្យមានការរៀបចំទិន្នន័យជាក់លាក់មួយ ដែលអាស្រ័យលើទម្រង់ទិន្នន័យដែលនឹងត្រូវបញ្ចូលទៅក្នុងដាតាបេស(រូបភាព២)។ ទិន្នន័យទីតាំងភូមិសាស្ត្រ ជាទិន្នន័យដែលមាននិយាមការភូមិសាស្ត្រជាក់លាក់ ដូចន្នេះទើបវាអាចបញ្ចូលជាមួយទិន្នន័យផ្សេងទៀតនិងតាងបង្ហាញនៅលើផែនទី។ ក្រៅពីទិន្នន័យទីតាំងភូមិសាស្ត្រនេះ ក៏មានទិន្នន័យមួយចំនួនទាក់ទងនឹងផែនការរៀបចំដែនដីដែលមិនចាំបាច់ត្រូវមានលក្ខណៈទីតាំងភូមិសាស្ត្រ (spatial attribute) ប៉ុន្តែអាចយកមកតាងបង្ហាញនៅលើផែនទីបាន។

**ប្រភេទទិន្នន័យ**

- ទិន្នន័យទីតាំងភូមិសាស្ត្រក្នុងទម្រង់ជាវិចទ័រ (Vector) ដែលបង្ហាញជាចំណុច បន្ទាត់ ឬពហុកោណ។
- ទិន្នន័យទីតាំងភូមិសាស្ត្រក្នុងទម្រង់ជារ៉ាស្ទ័រ (Raster) ដែលបង្ហាញជាក្រឡាចក្រត្រង្គភីកសែល (រូបថត)។
- ផែនទីដែលមានតែនៅក្នុងទម្រង់ជាក្រដាស អាចយកមកស្កេន ហើយបម្លែងវាឲ្យមាននិយាមការភូមិសាស្ត្រ (Geo-referencing) ដោយប្រើកម្មវិធីប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)។
- ស្ថិតិផ្នែករដ្ឋបាល (ឃុំ ស្រុក) អាចយកមកភ្ជាប់/បញ្ចូលជាមួយទិន្នន័យទីតាំងភូមិសាស្ត្ររដ្ឋបាលដែលមានស្រាប់ហើយធ្វើការបង្ហាញនៅលើផែនទី។
- ទិន្នន័យមានស្រាប់ដែលបានពីការអង្កេតដោយប្រើប្រាស់ឧបករណ៍GPS ដែលមាននិយាមការ (X និងY) អាចយកមកបញ្ចូលក្នុងប្រព័ន្ធ និងប្រើប្រាស់បង្កើតជាទិន្នន័យទីតាំងភូមិសាស្ត្របាន។




**រូបភាព២៖** ការបញ្ចូលទិន្នន័យដែលពាក់ព័ន្ធនឹងផែនការរៀបចំដែនដីទៅក្នុងដាតាបេសទិន្នន័យ

- ក្នុងពេលធ្វើការពិនិត្យទៅលើគុណភាព ភាពស៊ីគ្នា និងសុក្រឹត្យភាព (ពេញលេញ) របស់ទិន្នន័យទាំងអស់ ត្រូវធានាឲ្យច្បាស់ថាប្រព័ន្ធនិយាមការភូមិសាស្ត្រ (projection and datum) របស់ទិន្នន័យទាំងអស់នៅក្នុងដាតាបេសទិន្នន័យគឺដូចគ្នា។ ទាក់ទងនឹងប្រព័ន្ធនិយាមការភូមិសាស្ត្រសម្រាប់ទិន្នន័យទីតាំងដែនដីទាំងអស់ ជាអនុសាសន៍គួរប្រើ ៖ Ellipsoid: Everest 1831, Projection: UTM, Horizontal Datum: wgs84។
- ត្រូវបង្កើតនូវដាតាបេសមេ (Meta-Database) សម្រាប់ជាបទដ្ឋានជាក់លាក់មួយដែលមានការពិពណ៌នាយ៉ាងលម្អិតពេញលេញពីលក្ខណៈទិន្នន័យនីមួយៗ (ដូចជាប្រភេទទិន្នន័យតាមវិស័យព័ត៌មានលម្អិត ប្រភេទ ការធ្វើបច្ចុប្បន្នភាព ប្រភពទិន្នន័យជាដើម)។ (រូបភាព ៣)


KCHH_Commune_Boundary_wgs84 - Notepad

File Edit Format View Help

| | |
|---|---|
| Shapefile Name | KCHH_Commune_Boundary_wgs84 |
| Coordinate system | UTM, Meters, Zn: 48, Spheroid: Everest 1830, Datum: WGS 84 |
| Feature type | Polygon |
| Description | Boundaries of communes (69) in Kampong Chhnang province |
| Item definition | |
| COMM_Code | Code of commune (text) |
| COMM_Name | Commune name (Latin) |
| CodeKHUM | Code of Commune (Numeric) |
| KHUM_CAMLS | Commune name (???) |
| KHUM_LIMON | Commune name (LIMON) |
| Data Source: | NIS, Census Data (MoP, NIS) |
| Update (year) | 2008 |
| Processed by: | Kampong Chhnang Spatial Planning Team |
| Processed in: | December 2012 |

**រូបភាព៣៖** រូបភាពដាតាបេសមេ (Meta-Databse) សម្រាប់ផែនការរៀបចំដែនដី

**លទ្ធផលរំពឹងទុក**

- ដាតាបេសទិន្នន័យដែនដីមួយ បានបង្កើតឡើងនៅក្នុងកុំព្យូទ័រដោយមានរចនាសម្ព័ន្ធច្បាស់លាស់ និងមានដាតាបេសទិន្នន័យមេ ដែលបញ្ចូលទិន្នន័យពាក់ព័ន្ធទាំងអស់ស ម្រាប់កសាងផែនការរៀបចំដែនដី។

**ការងារ ២.២ ការវិភាគទិន្នន័យ និងការផលិតផែនទី**

**ស្ថានភាពទូទៅ**

ក្នុងដំណាក់កាលនេះទិន្នន័យទាំងអស់នឹងត្រូវធ្វើការវិភាគដើម្បីស្វែងយល់ពីទម្រង់លក្ខណៈដែនដីបច្ចុប្បន្ន (ការវិភាគ ស្ថានភាពមានស្រាប់ និងវិភាគស្ថិតិ) និងបែបផែនលក្ខណៈនៃការអភិវឌ្ឍដែនដី (កំណត់ពីទំនោរនៃការ ផ្លាស់ប្តូរប្រែប្រួល និងការវិភាគឌីណាមិក) ដែលទាក់ទងទៅនឹងការធ្វើសេចក្តីសន្និដ្ឋានសម្រាប់ការអភិវឌ្ឍដែនដីនាពេលអនាគតរបស់ខេត្ត។ មានន័យថាត្រូវតែធ្វើការស្វែងយល់ទៅលើគ្រប់វិស័យពាក់ព័ន្ធទាំងអស់ (ដូចជាវិស័យទេសចរណ៍ ឬវិស័យកសិកម្មជាដើម) ទៅតាមទីតាំងផ្សេងៗគ្នារបស់ខេត្ត។ ត្រូវតែធ្វើការសម្រេចចិត្តថាតំបន់ណាខ្លះរបស់ខេត្ត ដែលមានការពាក់ព័ន្ធជាពិសេសសម្រាប់សិក្សាវិស័យផ្សេងៗទាំងនោះ ឬក៏មានការពាក់ព័ន្ធទៅនឹងផ្នែកសេដ្ឋកិច្ចឬបរិស្ថានជាដើម។ ផែនទីជំនាញតាមប្រធានបទ (thematic map) និងផែនទីតាមវិស័យត្រូវធ្វើការរៀបចំឡើងដើម្បីជួយគាំទ្រដល់ការងារវិភាគ និងបង្ហាញនូវលក្ខណៈភូមិសាស្ត្រនៅលើផែនទី (geographic attribute)។ ហើយផែនទីទាំងនេះនឹងជាឯកសារយ៉ាងសំខាន់សម្រាប់ការងារកសាងផែនការបន្ថែមទៀត។ការបញ្ចប់នូវការវិភាគទិន្នន័យទាំងស្រុងជាការងារមួយយ៉ាងសំខាន់ ហើយវាគួរតែត្រូវបានធ្វើការរៀបចំឡើងឲ្យបានល្អ និងធ្វើការបែងចែកពេលវេលាធ្វើការងារនេះឲ្យបានគ្រប់គ្រាន់។ ផែនទីនីមួយៗគួរមានមាត្រដ្ឋានចាប់ពី ១/២៥០,០០០ ទៅ ១/១០០,០០០ ហើយគួរធ្វើការព្រីនលើទំហំក្រដាសមួយដែលសមស្របទៅតាមមាត្រដ្ឋានទាំងនោះ (ទំហំ A0, A1, ឬអាស្រ័យទៅលើទំហំដែនដីរបស់ខេត្ត)។

**អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?**

- អ្នកចូលរួម
  - ក្រុមការងារខេត្ត ( PWG)
  - អ្នកជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)/គ្រប់គ្រងទិន្នន័យ

## សកម្មភាពការងារ/វិធីសាស្ត្រ

- រៀបចំវគ្គវិភាគទិន្នន័យអំពីវិស័យនិងទិន្នន័យសំខាន់ៗ (សូមមើលខាងក្រោម) ដែលក្រុមការងារខេត្ត គួរធ្វើការពិនិត្យអំពីភាពជាក់លាក់ភាពត្រឹមត្រូវពេញលេញ និងព័ត៌មានដែលពាក់ព័ន្ធទាំងអស់ ហើយសំខាន់ជាងនេះទៅទៀតនោះ គឺព្យាយាមយល់និងចងក្រងឯកសារអំពីបែបផែនលក្ខណៈ នៃដែនដីតាមភាពជាក់ស្តែងនោះ។កិច្ចការនេះទាមទារនូវជំនាញគ្រប់គ្រាន់នៅក្នុងក្រុមការងារខេត្ត ដើម្បីធ្វើការវិភាគដែនដី និងធ្វើការបកស្រាយលើផែនទីដែលបានផលិតហើយ។ វាមានសារៈសំខាន់ណាស់ នៅពេលដែលមានការចូលរួមពីមន្ទីរជំនាញពាក់ព័ន្ធ ឬអ្នកពាក់ព័ន្ធដ៏ទៃទៀត ជាពិសេសអ្នកពាក់ព័ន្ធដែលមានជំនាញឯកទេសលើកិច្ចការរបស់ខ្លួន។ ព័ត៌មានមួយចំនួន នឹងត្រូវធ្វើការវិភាគក្នុងទម្រង់ជាស្ថិតិ (ទៅតាមពេលវេលាជាក់លាក់ណាមួយ) ហើយព័ត៌មានមួយចំនួនផ្សេងទៀតនឹងទាមទារការវិភាគជាឌីណាមិក (ការប្រែប្រែលទៅតាមពេលវេលា) ដើម្បីធ្វើការវាយតម្លៃទៅលើការប្រែប្រួលទិន្នន័យ ដោយប្រៀបធៀបទៅតាមចន្លោះពេលវេលាជាក់លាក់នៃព្រឹត្តិការណ៍នោះ។
- ព័ត៌មានអំពីរាល់ទិន្នន័យទីតាំងភូមិសាស្ត្រដែនដីនិងទិន្នន័យមិនមែនទីតាំងភូមិសាស្ត្រដែលត្រូវការទាំងអស់ ព្រមទាំងប្រភពដែលអាចទទួលបានទិន្នន័យទាំងនោះមានបង្ហាញនៅក្នុងឧបសម្ព័ន្ធ២។ ជាការល្អ គួរមានបញ្ជីតារាងទិន្នន័យឲ្យហើយក្នុងកំឡុងពេលធ្វើការវិភាគទិន្នន័យនេះ។
- ក្នុងពេលដំណាលគ្នានេះដែរ ត្រូវរៀបចំវគ្គកសាងផែនទី (ដោយមានជំនួយពីអ្នកជំនាញ GIS) ដើម្បីបង្ហាញនូវលទ្ធផលនៃការវិភាគទិន្នន័យទីតាំងដែនដីនៅលើផែនទី ឬធ្វើការវិភាគទិន្នន័យទីតាំងដែនដី។ ការងារវិភាគទិន្នន័យ និងការកសាងផែនទីនេះ អាចធ្វើមុននិងក្រោយគ្នាត្រលប់ចុះឡើងទៅតាមភាពជាក់ស្តែង។
- គួររៀបចំចំណុចសំខាន់ៗ និងសំនួរទាំងឡាយណាដែលនឹងត្រូវធ្វើការដោះស្រាយក្នុងដំណាក់កាលវិភាគទិន្នន័យឲ្យហើយ ដើម្បីឲ្យក្រុមការងារអាចធ្វើការងារដែលមានភាពស្មុគស្មាញនេះបានដោយងាយស្រួល។ គួរបង្ហាញពីឧទាហរណ៍ជាក់ស្តែង នៃដំណើរការកសាងផែនការរៀបចំដែនដីក្នុងខេត្តបាត់ដំបង កំពង់ឆ្នាំង និងតាកែវជាដើម។
- គួររៀបចំរបាយការណ៍សង្ខេបសំខាន់ៗតាមប្រធានបទ រួមជាមួយនឹងផែនទីពាក់ព័ន្ធ និងការពន្យល់ពីទិន្នន័យព័ត៌មានដែលបានវិភាគហើយ ក៏ដូចជាសេចក្តីសន្និដ្ឋានដំបូងជាដើម (អាស្រ័យទៅលើការពិភាក្សាក្នុងក្រុមនិងបំណកស្រាយផែនទី)។
- **គន្លឹះសំខាន់៖** ការវិភាគទាក់ទងនឹងដែនដី បំណកស្រាយទិន្នន័យ និងផែនទី មិនអាចយល់បានទាំងស្រុងទៅតាមតែទ្រឹស្តីនោះទេ វាក៏ទាមទារនូវបទពិសោធន៍និងការអនុវត្តជាក់ស្តែងផងដែរ។ ដោយសារតែក្រុមការងារមិនមានបទពិសោធន៍លើការងារនេះ ដូច្នេះគួរមានការចូលរួមពីអ្នកបណ្តុះបណ្តាល ទីប្រឹក្សា មកពីខាងក្រៅបណ្តុះបណ្តាល និង/ឬសម្របសម្រួលក្នុងដំណើរការនេះ។

**លទ្ធផលរំពឹងទុក**

- ព័ត៌មាននិងទិន្នន័យរបស់វិស័យដែលពាក់ព័ន្ធទាំងអស់ និងផែនទីជំនាញតាមប្រធានបទត្រូវបានបង្កើតឡើង។ បញ្ជីផែនទីដែលត្រូវការគឺមាននៅក្នុងឧបសម្ព័ន្ធ៣ (រចនាសម្ព័ន្ធសំខាន់ៗនៃផែនការរៀបចំដែនដីថ្នាក់ខេត្ត)។
- ផែនទីនីមួយៗនឹងមានអត្ថបទខ្លីដែលធ្វើការរៀបរាប់និងពន្យល់ពីព័ត៌មានសំខាន់ៗដែលបង្ហាញនៅលើផែនទី និងព័ត៌មានផ្សេងៗទៀតដែលទាក់ទងទៅនឹងទម្រង់លក្ខណៈដែនដី និងការអភិវឌ្ឍរបស់ខេត្ត។
- នៅក្នុងផ្នែកខាងក្រោមនេះ ទិន្នន័យ/លទ្ធផលដែលសំខាន់ចាំបាច់និងមិនសូវសំខាន់(ជាជម្រើស) ត្រូវបានលើកឡើង ដើម្បីបែងចែករវាងព័ត៌មានណាដែលចាំបាច់សម្រាប់ដំណើការរៀបចំផែនការ និងព័ត៌មានណាដែលមានលក្ខណៈបន្ទាប់បន្សំ។

**ក) រដ្ឋបាល**

**ការពាក់ព័ន្ធ៖** ព័ត៌មាន និងទិន្នន័យជាក់លាក់អំពីការបែងចែករដ្ឋបាលនៅក្នុងខេត្ត (ស្រុក/ក្រុង ឃុំ/ សង្កាត់ និងភូមិ) ត្រូវតែធ្វើការកំណត់ពីយុត្តាធិកាផ្នែករដ្ឋបាល ដែលទទួលខុសត្រូវក្នុងការកសាងផែនការ។ បន្ថែមលើនេះ ការវិភាគជាច្រើនក្នុងជំពូកនេះ ទាមទារឲ្យមានការវិភាគប្រៀបធៀបទិន្នន័យក្នុងកម្រិតរដ្ឋបាលមូលដ្ឋានថ្នាក់ផ្សេងៗគ្នា។

**ទិន្នន័យដែលត្រូវការ**

***ទិន្នន័យចាំបាច់***

- ព្រំប្រទល់ខេត្ត
- ចំនួន ឈ្មោះ លេខកូដ និងព្រំប្រទល់របស់ស្រុក ឃុំ និងភូមិ
- ឈ្មោះ និងទីតាំងមជ្ឈមណ្ឌលខេត្ត ស្រុក ឃុំ និងភូមិ
- បញ្ហាព្រំប្រទល់ ប្រសិនបើមាន

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- សក្តានុពល ឬព្រំប្រទល់ជាជម្រើស សម្រាប់ អនាគត ការបែងចែក ឬការបង្រួមរដ្ឋបាល

**ការវិភាគ និងលទ្ធផល**

- ពិនិត្យមើលទិន្នន័យបច្ចុប្បន្នភាពចុងក្រោយដែលមាននៅថ្នាក់ខេត្ត និងពិនិត្យពីភាពមិនស្របគ្នាជាមួយទិន្នន័យថ្នាក់ជាតិដែលបានពីក្រសួងផែនការ(ឧ.ទិន្នន័យជំរឿន)។ ព្រំប្រទល់ក្នុងប្រទេសកម្ពុជាតែងតែត្រូវបានលើកមកពិភាក្សា និងកែតម្រូវឡើងវិញ ដូច្នេះវាមានសារៈសំខាន់ណាស់ដែលក្រុមការងារខេត្តត្រូវតាមដានរាល់បច្ចុប្បន្នភាពទិន្នន័យទាំងនោះ។
- ឯកភាពទៅលើឈ្មោះ និងការបកប្រែទៅជាភាសាអង់គ្លេស ប្រសិនបើត្រូវការ ។
- កំណត់ និងធ្វើផែនទីព្រំប្រទល់ស្រុកទាំងអស់ដែលនៅក្នុងខេត្ត។

- កំណត់កន្លែងដែលមានព្រំប្រទល់ឃុំ/ស្រុកមិនច្បាស់លាស់ ដែលនាំឲ្យកើតបញ្ហាទំនាស់មិនអាចដោះស្រាយបាន។ ធ្វើការពិភាក្សាថាតើទំនាស់នោះត្រូវដោះស្រាយយ៉ាងណា និងដំណោះស្រាយនោះត្រូវសម្រេចដោយវិធីណា។
- នៅក្នុងករណីខ្លះ ទោះបីជាមានព្រំប្រទល់បច្ចុប្បន្នច្បាស់លាស់ក៏ដោយ ក៏មានព័ត៌មានដែលបង្ហាញពីការកែប្រែព្រំប្រទល់នាពេលអនាគតផងដែរ។ នេះវាអាចមានការលំបាកដល់ការកំណត់ព្រំប្រទល់ឡើងវិញ ឬក៏ធ្វើការបែងចែក ឬបញ្ចូលគ្នានូវព្រំប្រទល់ដែនដីរដ្ឋបាលបច្ចុប្បន្នដែលអាចនឹងមានផលប៉ះពាល់ដល់មជ្ឈមណ្ឌលរដ្ឋបាលមួយចំនួនផងដែរ។ ដូច្នេះវាជាការប្រឈមមួយគួរឲ្យកត់សំគាល់សម្រាប់ដំណើរការកសាងផែនការរៀបចំដែនដី៖ តើគួរធ្វើផែនការសម្រាប់តំបន់ដែលអាចនឹងត្រូវបញ្ចូលទៅក្នុងព្រំប្រទល់ដែនដី ដែលគ្រោងសម្រាប់ពេលអនាគត ឬក៏សម្រាប់ក្នុងអាណត្តិណាមួយទេ? ហើយថាតើហេតុអ្វីត្រូវធ្វើផែនការសម្រាប់តំបន់ដែលនឹងលែងស្ថិតនៅក្នុងព្រំប្រទល់ដែនដីក្នុងពេលអនាគតឆាប់ៗខាងមុខនេះ? ហើយថាតើត្រូវដោះស្រាយជាមួយភាពមិនច្បាស់លាស់ នៃការប្រែប្រួលដែលអាចឬមិនអាចនឹងកើតឡើងនេះបានដោយរបៀបណា? ក្រុមការងារខេត្តត្រូវធ្វើការពិភាក្សាពីបញ្ហានេះដោយប្រុងប្រយ័ត្ន និងត្រូវគិតពីការជាប់ពាក់ព័ន្ធនឹងជម្រើសជាដំណោះស្រាយផ្សេងៗសម្រាប់ដំណើរការកសាងផែនការនេះ។ ការងារនេះគួរធ្វើការបង្ហាញដល់ គ.ដ.ន.ខ ដើម្បីធ្វើការសម្រេចចិត្តអំពីទំហំដែនដីដែលនឹងត្រូវធ្វើផែនការ។ ប្រសិនជាមានផលប៉ះពាល់ដល់ព្រំប្រទល់ ក្រុង/ស្រុក ឬខេត្ត គួរស្វែងរកការណែនាំពី គ.ដ.ន.ជ ដែល ជាស្ថាប័នគាំទ្រឯកភាពលើការងារនេះ។




**ផែនទី១៖** ឈ្មោះនិងទីតាំងតំបន់រដ្ឋបាលផ្សេងៗគ្នាក្នុងខេត្តបាត់ដំបង

## ខ) បរិស្ថានជីវសាស្ត្រ

**ការពាក់ព័ន្ធ៖** លក្ខណៈសម្បត្តិជីវសាស្ត្រនៃតំបន់មួយមានឥទ្ធិពលដល់តួនាទីនិងការប្រើប្រាស់សមស្របចំពោះដីនៅតំបន់នោះ។ ការថែរក្សាជីវិត និងមុខងារគាំទ្រដល់ជីវិតរស់នៅរបស់បរិស្ថានជីវសាស្ត្រ គឺជាទិដ្ឋភាពមួយយ៉ាងសំខាន់ក្នុងការធានាដល់ស្ថេរភាពនៃការគ្រប់គ្រងដីធ្លីក្នុងខេត្ត។

## អាកាសធាតុ

ការស្វែងយល់ពីលក្ខណៈអាកាសធាតុ គឺមានសារៈសំខាន់ណាស់ ព្រោះការទាក់ទងជាមួយនឹងសណ្ឋានដី និងប្រភេទដី អាកាសធាតុ វាកំណត់ពីសក្តានុពលកសិ្យត្របរិស្ថាន (agro-ecological) របស់តំបន់នោះ។ អាកាសធាតុកំណត់ពីវដ្តនៃទឹកដែលមានឥទ្ធិពលដល់បរិមាណទឹកដែលមាននៅក្នុងប្រព័ន្ធអេកូឡូស៊ី ផលិតភាព និងការអភិវឌ្ឍកសិកម្ម។ លើសពីនេះទៅទៀត ចំពោះការកើនឡើងពីភាពមិនទៀងទាត់នៃការប្រែប្រួលអាកាសធាតុ និងការប្រែប្រួលបរិស្ថានអាកាសធាតុ បានក្លាយជាបញ្ហាសំខាន់មួយសម្រាប់អ្នកធ្វើផែនការនិងអ្នកធ្វើសេចក្តីសម្រេចចិត្ត។ ការប្រែប្រួលអាកាសធាតុភាគច្រើនត្រូវបានមើលឃើញ និងដឹងតាមរយៈការផ្លាស់ប្តូរវដ្តនៃទឹក និងកើតឡើងតាមរយៈគ្រោះធម្មជាតិ (ឧ.រាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ) ដែលនឹងអាចកើតមានឡើង ជារឿយៗខ្លាំងឡើងៗនៅពេលអនាគត (IPCC, 2013)។

## ទិន្នន័យដែលត្រូវការ

**ទិន្នន័យចាំបាច់**

ទិន្នន័យសីតុណ្ហភាព និងកំពស់ទឹកភ្លៀងប្រចាំខែ

**ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)**

ទិន្នន័យសីតុណ្ហភាព និងកំពស់ទឹកភ្លៀងប្រចាំខែ
ទិន្នន័យសីតុណ្ហភាព និងកំពស់ទឹកភ្លៀងរយៈពេលវែង
ទិន្នន័យសីតុណ្ហភាពនិងកំពស់ទឹកភ្លៀងនៅទីតាំងផ្សេងៗគ្នា

| ប្រអប់ព័ត៌មាន | | |
|---|---|---|
| **ធាតុអាកាស** | **អាកាសធាតុ** | **ការប្រែប្រួលអាកាសធាតុ** |
| ធាតុអាកាសឆ្លុះបញ្ចាំងពីលក្ខខណ្ឌរយៈពេលខ្លីរបស់បរិយាកាស (សីតុណ្ហភាព សំណើម កំណកអាកាស លក្ខខណ្ឌពពក ពន្លឺ ភាពអាចមើលឆ្ងាយ ខ្យល់ និង សំពាធបរិយាកស ) | អាកាសធាតុ គឺជាលក្ខណៈរបស់បរិយាកាស "ដែលប្រព្រឹត្តិទៅ" ក្នុងរយៈពេលវែងជាប់គ្នា។ | ការប្រែប្រួលអាកាសធាតុ សំដៅដល់ការប្រែប្រួលធាតុអាកាសប្រចាំថ្ងៃជាមធ្យម រយៈពេលវែង (ជាធម្មតា វាធ្វើការប្រៀបធៀបរវាងបីទសវត្សរ៍) |

## ការវិភាគ និងលទ្ធផល

- ប្រមូលទិន្នន័យបច្ចុប្បន្នភាពចុងក្រោយនៃកំណកអាកាស កំពស់ទឹកភ្លៀង និងសីតុណ្ហភាពប្រចាំខែ (មាននៅក្រសួងធនធានទឹកនិងឧតុនិយមទាំងនៅថ្នាក់ខេត្តនិងថ្នាក់ជាតិ) (សូមមើលឧបសម្ព័ន្ធ២)។ ទិន្នន័យទាំងពីរនេះអាចបញ្ចូលជាមួយគ្នាបានដោយងាយទៅក្នុងដ្យាក្រាម ដែលមានឈ្មោះថា "ombrothermic" ដែលវានឹងបង្ហាញពីភាពខុសគ្នានៃសីតុណ្ហភាពមធ្យមប្រចាំខែ និងកំណកអាកាសសរុបសម្រាប់ទីតាំងដែលបានជ្រើសរើស។ វាមានភាពងាយស្រួលហើយក៏ជាកម្មវិធីមិនគិតលុយសម្រាប់បង្កើតនូវដ្យាក្រាមប្រភេទនេះដែលមាននៅលើគេហទំព័រ(http://www.becyhome.de/news_eng.htm) ។ វាបង្ហាញឲ្យឃើញថាមាត្រ ដ្ឋានរបស់កំណកអាកាសមានទំហំធំជាងមាត្រដ្ឋានរបស់សីតុណ្ហភាពពីរដង(មើលដ្យាក្រាមខាងក្រោម)ដ្យាក្រាមអាចកំណត់ឲ្យឃើញពីរយៈពេលដែលងាយរងគ្រោះពីភាពរាំងស្ងួត (នៅពេលដែលតម្លៃរបស់កំណកអាកាសទាបជាងខ្សែកោងរបស់សីតុណ្ហភាព)។ ព័ត៌មាននេះ មានសារៈសំខាន់ណាស់សម្រាប់យកមកគិតគូរសម្រាប់ការធ្វើផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍កសិកម្ម នៅក្នុងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក ដែលនឹងត្រូវធ្វើការអភិវឌ្ឍ។




**រូបភាព ៤៖** ដ្យាក្រាម Ombrothermic សម្រាប់ស្ថានីយ៍នៅខេត្តកំពង់ឆ្នាំង ផ្ទៃពណ៌លឿងបង្ហាញពីខែដែលមានសក្តានុពលរងនូវភាពរាំងស្ងួត

## ជាជម្រើស

- អាស្រ័យទៅលើទិន្នន័យដែលអាចរកបាន ក្រុមការងារខេត្តគួរតែភ្ជាប់វាទៅនឹងទីតាំងឲ្យបានលម្អិតថែមទៀតហើយនិងវិភាគទៅតាមដំណាក់កាលពេលវេលាខុសៗគ្នា៖
  - ប្រសិនបើទិន្នន័យកំពស់ទឹកភ្លៀងអាចរកបានមកពីស្ថានីយ៍បីបួនកន្លែងនៅក្នុងខេត្ត យើងអាចបង្កើតនូវ ពហុកោណ Thiessen (Thiessen polygon) ដើម្បីបង្ហាញឲ្យឃើញនូវតំបន់ដែលមានរយៈកំពស់ទឹកភ្លៀងធ្លាក់ខុសៗគ្នា (ផែនទី២)។
  - ប្រសិនបើមានទិន្នន័យអាកាសធាតុដែលបានកត់ត្រាក្នុងរយៈពេលវែងនោះ យើងអាចធ្វើការវិភាគទិន្នន័យអាកាសធាតុទៅតាមដំណាក់កាលពេលវេលាខុសៗគ្នា ដែលវាមានសារៈសំខាន់ក្នុងការកំណត់ឲ្យឃើញពីលទ្ធភាពនៃការប្រែប្រួលកំពស់ទឹកភ្លៀងឬសីតុណ្ហភាព។ ជាលទ្ធផលការកសាងប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក នឹងទទួលបានអត្ថប្រយោជន៍ពីការផ្តល់ព័ត៌មានអំពីការប្រែប្រួលរបាយទឹកភ្លៀងប្រចាំខែក្នុងរយៈពេលជាច្រើនឆ្នាំកន្លងមកនេះ ខណៈដែលការប្រែប្រួលនេះកំណត់អំពីប្រតិទិន និងរយៈពេលសម្រាប់ធ្វើការដាំដុះ (រូបភាព ៥)។
  - ប្រសិនបើមានកំណត់ត្រាសីតុណ្ហភាព និងកំពស់ទឹកភ្លៀងប្រចាំថ្ងៃនោះ ការវិភាគព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ (កំពស់ទឹកភ្លៀង និងសីតុណ្ហភាព) អាចធ្វើឡើងតាមរយៈការគណនាសុចនាករនៃការប្រែប្រួលអាកាសធាតុ (http://etccdi.pacificclimate.org/indices.shtml) និងវិភាគពីទំនោរនៃការផ្លាស់ប្តូរប្រែប្រួលរបស់វា (រូបភាព ៦)។




**ផែនទី ២ ៖** ពហុកោណ Thiessen នៃកំពស់ទឹកភ្លៀងនៅទីជម្រាលស្ទឹងខេត្តសៀមរាប




**រូបភាព៥៖** ការប្រែប្រួលនៃរបាយទឹកភ្លៀង (ស្ថានីយ៍ខេត្តបាត់ដំបង) រវាងឆ្នាំ ១៩២០-១៩៣០ និងឆ្នាំ ១៩៩០ - ២០០០ ដែលបង្ហាញពីការប្រែប្រួលរបាយទឹកភ្លៀងយ៉ាងជាក់លាក់រវាងទសវត្សរ៍ឆ្នាំ ១៩២០-១៩៣០ និងឆ្នាំ ១៩៩០ - ២០០០

| សុច្ចនាករ | ទំនោរនៃការប្រែប្រួល ១៩៨១-២០១២ | ខែនៃការកើតឡើង (Mode) |
|---|---|---|
| Wdays>1mm = *ចំនួនថ្ងៃធ្លាក់ភ្លៀងសរុបប្រចាំឆ្នាំនៅពេលកំណកអាកាស > ១មម* | កើនឡើង | កញ្ញា (n=500) |
| PRCTOT =*កំណកអាកាសសរុបប្រចាំឆ្នាំក្នុងថ្ងៃធ្លាក់ភ្លៀង (កំពស់ទឹកភ្លៀង> ១មម)* | កើនឡើង | N-A |
| SDII =*សុច្ចនាករកំណើនកំណកអាកាសធម្មតា = PRCTOT/ចំនួនWet days (កំពស់ទឹកភ្លៀង> ១មម)* | ថយចុះ | N-A |
| Max. CWD>1mm =*ចំនួនថ្ងៃធ្លាក់ភ្លៀងប្រចាំឆ្នាំ (នៅពេលកំពស់ទឹកភ្លៀង> ១មម)* | ថយចុះ | កញ្ញា (n=10) |
| Max CDD<1mm =*ចំនួនថ្ងៃរាំងភ្លៀងប្រចាំឆ្នាំ (នៅពេលកំពស់ទឹកភ្លៀង> ១មម)* | ថយចុះ | N-A |
| Rx1day Rx1Day = *កំណកអាកាសអតិបរិមាក្នុងមួយថ្ងៃប្រចាំឆ្នាំ* | ថយចុះ | តុលា (13) |
| Rx5days *Rx5D* =*កំណកអាកាសអតិបរិមា៥ថ្ងៃជាប់គ្នាប្រចាំឆ្នាំ* | កើនឡើង | តុលា(12) |
| R20mm = *ចំនួនថ្ងៃដែលកំពស់ទឹកភ្លៀង > ២០មម ប្រចាំឆ្នាំ* | កើនឡើង | តុលា(124) |
| R25mm =*ចំនួនថ្ងៃដែលកំពស់ទឹកភ្លៀង > ២៥មម ប្រចាំឆ្នាំ* | កើនឡើង | តុលា(89) |
| R50mm =*ចំនួនថ្ងៃដែលកំពស់ទឹកភ្លៀង > ៥០មម ប្រចាំឆ្នាំ* | កើនឡើង | តុលា(32) |

**រូបភាព ៦៖** ការវិភាគកំពស់ទឹកភ្លៀង (ស្ថានីយ៍ខេត្តបាត់ដំបង) រវាងឆ្នាំ១៩៨១ និង២០១២ ដែលបង្ហាញថាកំណកអាកាសយ៉ាងខ្លាំងដូចដែលបង្ហាញនៅក្នុងសុច្ចនាករភាគច្រើនតែងតែកើនឡើងនិងកើតឡើងក្នុងខែតុលា

## សណ្ឋានដី

ព័ត៌មានលម្អិតពីដី និងលក្ខណៈធម្មជាតិរបស់វា គឺមានសារសំខាន់ណាស់សម្រាប់រៀបចំផែនការកសាងហេដ្ឋារចនាសម្ព័ន្ធ ឬក៏គម្រោងចាក់បំពេញដីឡើងវិញ។ សណ្ឋានដីក៏មានឥទ្ធិពលដល់ប្រភេទដីរូបរាងនៃដៃទីជម្រាល (តំបន់អាងរងទឹករបស់ស្ទឹង) ទីតាំងតំបន់សាងសង់ និងតំបន់លំហសាធារណៈ។

## ទិន្នន័យដែលត្រូវការ

### ទិន្នន័យចាំបាច់

- ខ្សែរយៈកំពស់ (ជាប្រភេទ *vector*)
- *Digital elevation model (*ជាប្រភេទ *raster)*
- ជម្រាល (*Slope*) *(*ជាប្រភេទ *raster)*

### ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)

- *Hill shade (*ជាប្រភេទ *raster)*

## ការវិភាគ និងលទ្ធផល

- បង្កើតផែនទីដែលបង្ហាញពីព័ត៌មានសណ្ឋានដី (រយៈកំពស់ និង/ឬ ជម្រាល)។
- ស្វែងយល់ពីទិន្នន័យទាំងអស់នេះ និងកំណត់ពីទម្រង់ដីចំពោះកន្លែងដែលសណ្ឋាន និងជម្រាលបង្ហាញលក្ខណៈដូចគ្នាជាឯកសណ្ឋាន។
- កំណត់តំបន់ដែលមានចំណោទខ្លាំងហើយមានបញ្ហាចំបងចំពោះការហូរច្រោះដី។
- កំណត់តំបន់ដីទំនាបទាប ហើយមានហានិភ័យខ្លាំងចំពោះទឹកជំនន់។







**ផែនទី៣៖** សណ្ឋានដីនៅក្នុងខេត្តកំពង់ឆ្នាំង រយៈកំពស់ខ្ពស់ជាងនីវ៉ូទឹកសមុទ្រ(ខាងឆ្វេង) និងជម្រាល (ខាងស្តាំ)

## ភូគព្ភសាស្ត្រ និងដី

ភូគព្ភសាស្ត្រ វិភាគពីដីថាតើវាត្រូវបានបង្កើតឡើងពីថ្ម និងដីរឹងប្រភេទណា។ ដីជាកន្លែងដែលរុក្ខជាតិរីកលូតលាស់ ដូចនេះហើយវាពិតជាមានសារសំៈខាន់ណាស់សម្រាប់កសិកម្ម។ វាបានភ្ជាប់ដោយមិនអាចកាត់ផ្តាច់បានទៅនឹងវដ្តរបស់ទឹក និងមានសារៈសំខាន់ដល់ជីវិតរស់នៅ។ ជារួមការវាយតម្លៃទៅលើលក្ខណៈសម្បត្តិរបស់ដីនៅក្នុងខេត្ត វាជួយដល់ការកំណត់ពីវិធីសាស្ត្រអភិវឌ្ឍន៍កសិកម្មនាពេលអនាគត។

## ទិន្នន័យដែលត្រូវការ

***ទិន្នន័យចាំបាច់***

- ទិន្នន័យជីជាតិដី

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ទិន្នន័យជាក់លាក់បន្ថែមទៀតអំពីប្រភេទដី ដោយផ្អែកទៅលើការធ្វើចំណាត់ថ្នាក់ដីលក្ខណៈអន្តរជាតិ ដូចជាពីអង្គការ FAO (ឧបសម្ព័ន្ធ២)

## ការវិភាគ និងលទ្ធផល

- ការវិភាគ និងការកំណត់ប្រភេទដីអាចជាការងារដែលមានការលំបាក ប៉ុន្តែព័ត៌មានដីសាមញ្ញៗ អាចរកបាន ។ ផែនទី និងការវាយតម្លៃពីជីជាតិដីទូទៅនៅក្នុងខេត្ត។
- កំណត់ប្រភេទដី ដែលគួរធ្វើការអភិវក្សសម្រាប់កសិកម្ម ឬព្រៃឈើ។

## ជាជម្រើស

- កំណត់ និងរៀបរាប់ពីប្រភេទដីសំខាន់ៗ៖ ស្វែងយល់ពីលក្ខណៈសម្បត្តិគីមីសាស្ត្រ រូបសាស្ត្រ និងជលសាស្ត្រ ក៏ដូចជាសម្បទានធម្មជាតិរបស់ដី ក្នុងបំណងប្រើប្រាស់ដីជាក់លាក់សម្រាប់កសិកម្ម។




**ផែនទី៤ ៖** របាយប្រភេទដីសំខាន់ៗ (ខាងឆ្វេង) និងជីជាតិដី (ខាងស្តាំ) ខេត្តកំពង់ឆ្នាំង

## ជលសាស្ត្រ (ធនធានទឹក)

ការគ្រប់គ្រងធនធានទឹក គឺជាកិច្ចការងារមួយយ៉ាងសំខាន់ នៅគ្រប់ខេត្តទាំងអស់ក្នុងប្រទេសកម្ពុជា។ ការទទួលបាន និងការប្រើប្រាស់ទឹក គឺមានសារៈសំខាន់ណាស់ដើម្បីជួយគាំទ្រដល់ជីវិតការអភិវឌ្ឍកសិកម្ម និងធានាដល់ការដឹកជញ្ជូនទំនិញ និងមនុស្ស។ ទឹកគឺជាធនធានដែលមានចលនា ដូច្នេះត្រូវធ្វើការវិភាគដោយផ្តោតទៅលើធាតុសំខាន់ៗពីរគឺៈ ការស្តុបទឹក និងចរន្តលំហូររបស់វាជាមួយនឹងការស្តុបទឹកទាំងនេះ។

## ទិន្នន័យដែលត្រូវការ

*ទិន្នន័យចាំបាច់*

- ចរន្តទឹកហូរ (ស្ទឹងសំខាន់ៗ ខ្សែទឹក ប្រឡាយ) ទឹកនៅនឹង (ដីសើម បឹង និងស្រះ)

*ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)*

- កម្រិតទឹក និងការហូរចេញពីស្ទឹងទន្លេ

## ការវិភាគ និងលទ្ធផល

- កំណត់ ធ្វើផែនទី និងពិពណ៌នាផ្ទៃទឹក និងខ្សែទឹកសំខាន់ៗ ហើយនិងស្ថានភាពទឹកក្នុងរដូវវស្សា និងរដូវប្រាំង។
- កំណត់បង្ហាញពីប្រភពទឹកសំខាន់ៗសម្រាប់ការប្រើប្រាស់របស់មនុស្ស និងសម្រាប់កសិកម្ម (ទឹកពីក្រោមដី /អណ្តូង ស្រះ/បឹងបួរ ស្ទឹង/ខ្សែទឹក)។




**ផែនទី ៥ ៖** ធនធានទឹកសំខាន់ៗនៅក្នុងខេត្តកំពង់ឆ្នាំង

## ហានិភ័យបរិស្ថាន និងអេកូឡូស៊ី

អេកូឡូស៊ី វិភាគពីអន្តរអំពើរវាងសរីរាង្គមានជីវិត និងបរិស្ថានរបស់វា ជាទូទៅផ្តោតទៅលើស្ថានប្រព័ន្ធអេកូឡូស៊ីដែលតំណាងឲ្យតំបន់ទីតាំងជុំវិញនៃអន្តរអំពើទាំងអស់នោះ។ វាមិនមានភាពងាយស្រួលក្នុងការកំណត់ពីដែនកំណត់របស់វាទេ ហើយប្រព័ន្ធអេកូឡូស៊ីផ្សេងៗគ្នាដូចជាទីជម្រាលព្រៃឈើឬដីសើមជាដើមតែងតែនៅត្រួតជាមួយគ្នា។ ប្រព័ន្ធអេកូឡូស៊ីមានមុខងារជាច្រើន ហើយវាក៏ផ្តល់នូវសេវាផ្សេងៗ ហើយភាគច្រើនវាមានសារៈសំខាន់ដល់សកម្មភាព និងជីវិតរបស់មនុស្ស។ ស្របគ្នានេះដែរ សកម្មភាពរបស់មនុស្សក៏មានឥទ្ធិពលដល់មុខងាររបស់ប្រព័ន្ធអេកូឡូស៊ី ក៏ដូចជាសេវាដែលទទួលបានពីស្ថានប្រព័ន្ធទាំងនោះ។ ការសិក្សាស្វែងយល់ និងការគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ីប្រកបដោយស្ថេរភាព ឧទាហរណ៍ដូចជាតាមរយៈការជៀសវាងការធ្វើឲ្យខូចខាត ឬបំពុលដល់ទីជម្រាល ឬការបែកខ្ញែកដល់ជីវិតរស់នៅ ទាំងអស់នេះជាស្នូលសំខាន់ក្នុងការគ្រប់គ្រងដីធ្លីប្រកបដោយជោគជ័យ។ នៅក្នុងប្រទេសកម្ពុជាមានគម្រោងផ្សេងៗដែលបង្កើតនូវព័ត៌មានស្តីពីប្រព័ន្ធអេកូឡូស៊ីនិងប្រភេទផ្សេងៗគ្នានៃអេកូឡូស៊ី ប៉ុន្តែសម្រាប់ព័ត៌មានលម្អិតនោះវានៅមានកម្រិតនៅឡើយ ហើយព័ត៌មានទាំងនេះមានការប្រែប្រួលខុសគ្នាពីខេត្តមួយទៅខេត្តមួយ។ ដូចនេះ ផ្អែកទៅលើព័ត៌មានទាក់ទងនឹងអេកូឡូស៊ីដែលមាននៅក្នុងខេត្តនីមួយៗ ជាឱកាសមួយដែលអាចយកព័ត៌មានទាំងនោះមកប្រើប្រាស់បានទោះជាព័ត៌មាននៅមានកម្រិតក៏ដោយ។

លើសពីនេះទៅទៀតគ្រោះធម្មជាតិដូចជាភាពរាំងស្ងួត និងទឹកជំនន់ជាដើមអាចមានផលប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាពរស់នៅរបស់មនុស្ស។ ប្រទេសកម្ពុជា មានកំណត់ត្រារយៈពេលវែងអំពីគ្រោះធម្មជាតិ (Centre for Research on the Epidemiology of Disasters, 2011) ប៉ុន្តែការកើតឡើងគ្រោះធម្មជាតិទាំងនេះ មានទំនោរកើនឡើងនាពេលអនាគតដោយសារការប្រែប្រួលអាកាសធាតុ។ ព័ត៌មានអំពីគ្រោះធម្មជាតិ មានសារៈសំខាន់ណាស់សម្រាប់ជួយដល់កិច្ចការវិធានការកាត់បន្ថយ និងសម្របខ្លួនទៅនឹងបញ្ហាទាំងនោះ។ ទាក់ទងនឹងបញ្ហានេះ ផែនការរៀបចំដែនដីថ្នាក់ខេត្តគួរជាចំណុចចាប់ផ្តើមមួយសម្រាប់កសាងផែនការកាត់បន្ថយហានិភ័យគ្រោះធម្មជាតិ តាមរយៈគណៈកម្មាធិការគ្រប់គ្រងគ្រោះមហន្តរាយខេត្ត។

## ទិន្នន័យដែលត្រូវការ

### *ទិន្នន័យចាំបាច់*

- ព្រំប្រទល់ប្រព័ន្ធអេកូឡូស៊ីទីជម្រាល (ពី MRC)
- តំបន់ប្រឈម និងមានហានិភ័យពិតប្រាកដពីការបំពុលទឹកធ្ងន់ធ្ងរ
- ការបែងចែកតំបន់អេកូឡូស៊ីតាមហ្សែន-GENE (GENE-ecological zonning) (ពីរដ្ឋបាលព្រៃឈើ/គម្រោងរុក្ខកម្ពុជា ២០០៣)
- តំបន់រងគ្រោះពីភាពរាំងស្ងួត និងទឹកជំនន់

### *ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)*

- ទិន្នន័យប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ (ឧបករណ៍InVEST ពីសាកលវិទ្យាល័យភូមិន្ទ ភ្នំពេញ និង WWF)
- ទិន្នន័យទី២ ដែលអាចរកបានទាក់ទងទៅនឹងទឹកលិច(ទឹកជំនន់) នៅតំបន់បឹងទន្លេសាបកណ្តាល

| ប្រអប់ព័ត៌មាន | |
|---|---|
| **ការបែងចែកតំបន់អេកូឡូស៊ីតាមហ្សែន** | **ឧបករណ៍ InVEST** |
| គម្រោងរុក្ខាកម្ពុជា (The Cambodian tree seed project) ជាឯកសារយោងយ៉ាងសំខាន់ដើម្បីស្វែងយល់ឲ្យកាន់តែ ច្បាស់ពីភាពផ្សេងៗគ្នានៃអេកូឡូស៊ី (ភាគច្រើនរុក្ខជាតិ) ។ ក្រុមការងារបង្កើតទស្សនទាននេះឡើង គឺដើម្បី ( បែងចែក តំបន់អេកូឡូស៊ីតាមហ្សែន - gene-ecological zoning - ដែលជាតំបន់ដែលមានលក្ខខណ្ឌបរិស្ថានដូចគ្នា ប៉ុន្តែវាបង្កឲ្យមានលក្ខណៈហ្សេណេតិចហ្វេណូទិចខុសគ្នាក្នុងពូជរុក្ខជាតិ មួយ (Cambodia Tree Seed Project, 2003)។ ទស្សនទាន និងវិធីសាស្ត្រនេះ អាចយកមកអនុវត្ត សម្រាប់ការវាយតម្លៃបរិស្ថាន ដោយវាមានភាពសាមញ្ញ និងជាឧបករណ៍ដែលចំណាយតិចក្នុងការរៀបចំ និងធ្វើ អាទិភាពផែនការសកម្មភាពសម្រាប់ការអភិរក្សពពួកប្រភេទពូជឈើសំខាន់ៗ។ | InVEST ជួយដល់អ្នកធ្វើសេចក្ដីសម្រេចចិត្តក្នុងការវាយតម្លៃពីការធ្វើឲ្យមានតុល្យភាពជាបរិមាណ ជាមួយនឹងការជ្រើសរើសជម្រើសនៃការគ្រប់គ្រង និងកំណត់តំបន់វិនិយោគទៅលើធនធានធម្មជាតិ ដែលអាចធ្វើឲ្យប្រសើរឡើងដល់ការអភិវឌ្ឍធនធានមនុស្ស និងការអភិរក្ស។ (http://www.naturalcapitalproject.org/invest) សាកលវិទ្យាល័យភូមិន្ទភ្នំពេញសហការជាមួយអង្គការ WWF ធ្វើការប្រមូលនិងវិភាគទិន្នន័យយ៉ាងទូលំទូលាយទាក់ទងទៅនឹងប្រព័ន្ធអេកូឡូស៊ី ធនធានធម្មជាតិ និងជីវៈចម្រុះដោយប្រើប្រាស់មុខងារនៃឧបករណ៍ InVEST ។ វាបានផ្ដល់ទិន្នន័យព័ត៌មានយ៉ាងទូលំទូលាយ និងផែនទីដែលអនុញ្ញាតដល់ការកំណត់តំបន់សំខាន់ៗសម្រាប់ការពារមុខងាររបស់ប្រព័ន្ធអេកូឡូស៊ី និងសេវារបស់វា។ |

## ការវិភាគ និងលទ្ធផល

- ធ្វើផែនទី និងប្រមូលព័ត៌មានទាក់ទងទៅនឹងប្រព័ន្ធអេកូឡូស៊ី ដូចជាទីជម្រាលនិងប្រភេទផ្សេងៗនៃអេកូឡូស៊ី និងការគំរាមកំហែងដល់ស្ថានប្រព័ន្ធទាំងនោះ៖
    - គណៈកម្មការទន្លេមេគង្គ (MRC) បានផលិតផែនទីតំបន់ដៃទីជម្រាល។ " ការស្វែងយល់ពីទម្រង់លក្ខណៈតំបន់ទីជម្រាលនិងដំណើរធម្មជាតិរបស់វា គឺមានសារៈសំខាន់ណាស់ដើម្បីដឹងថាតើសកម្មភាពរបស់មនុស្សអាចធ្វើឲ្យខូចខាត ឬធ្វើឲ្យប្រសើរឡើងដល់លក្ខខណ្ឌរបស់ទីជម្រាល រួមទាំងគុណភាពទឹក ជីវិត សត្វព្រៃ និងត្រី ព្រៃឈើ រុក្ខជាតិដ៏ទៃទៀត និងគុណភាពជីវិតរបស់សហគមន៍រស់នៅតំបន់នោះដោយរបៀបណា។ ការយល់ដឹងពីលក្ខណៈសម្បត្តិមុខងារ និងទម្រង់លក្ខណៈតំបន់ទីជម្រាល និងពីរបៀបដែលមនុស្សអាចធ្វើឲ្យមានផលប៉ះពាល់ដល់ទីជម្រាល ជាដំណាក់កាលដ៏ល្អសម្រាប់ការគ្រប់គ្រងទីជម្រាលប្រកបដោយប្រសិទ្ធភាព" (O'Keefe, Elliott, & Naiman, Sine Die)។
    - ព័ត៌មានទាក់ទងទៅនឹងភាពចម្រុះគ្នានៃតំបន់ជីវៈអេកូឡូស៊ីផ្សេងៗគ្នាអាចរកបានមកពីគម្រោងរុក្ខាកម្ពុជា (តាមរយៈរដ្ឋបាលព្រៃឈើ)។ ធ្វើផែនទីតំបន់អេកូឡូស៊ីតាមហ្សែននៅក្នុងខេត្ត។
    - ស្វែងយល់ពីសារៈសំខាន់ និងទំនាក់ទំនងប្រព័ន្ធអេកូឡូស៊ី និងធនធានធម្មជាតិ និងកំណត់តំបន់ដែលមានសារៈសំខាន់ជាពិសេសសម្រាប់មុខងារប្រព័ន្ធអេកូឡូស៊ី។
    - កំណត់ប្រភពដែលមានសក្ដានុពលជាក់ស្ដែងដល់ការបំពុលប្រព័ន្ធអេកូឡូស៊ី ជាពិសេសដល់ទីជម្រាល តាមរយៈសកម្មភាពមួយចំនួនដូចជាលំនៅឋាន ឧស្សាហកម្ម និងការយករ៉ែជាដើម ។

- ប្រមូល និងធ្វើផែនទីតំបន់ដែលងាយរងគ្រោះពីគ្រោះធម្មជាតិ ដូចជាភាពរាំងស្ងួត និងទឹកជំនន់
    - ធ្វើផែនទីតំបន់ដែលរងគ្រោះដោយទឹកជំនន់(ទឹកលិច)
    - ស្វែងយល់ពីលក្ខណៈសម្បត្តិទឹកជំនន់ដែលជន់លិចក្នុងខេត្ត (រយៈពេលនៃទឹកជំនន់ ប្រភេទនៃការប្រើប្រាស់ដីដែលរងនូវផលប៉ះពាល់៖ កសិកម្ម លំនៅឋាន ហេដ្ឋារចនាសម្ព័ន្ធ និងឧស្សាហកម្ម ជាដើម។)
    - យល់ពីភាពខុសប្លែកគ្នានៃតំបន់លិចទឹក (ទឹកជំនន់) ដែលមានទ្រង់ទ្រាយតូច មធ្យម និងទ្រង់ទ្រាយធំ
    - ធ្វើផែនទីតំបន់ដែលងាយរងគ្រោះពីភាពរាំងស្ងួត
    - ស្វែងយល់ពីលក្ខណៈសម្បត្តិនៃភាពរាំងស្ងួត (រយៈពេលរាំងស្ងួត ផលប៉ះពាល់ទៅលើកសិកម្មជាដើម។)
    - ស្វែងយល់ថាតើភាពរាំងស្ងួតនិងទឹកជំនន់ដែលបានកើតឡើងអស់ពេលជាយូរមកហើយ ជាប់ពាក់ព័ន្ធ ទៅនឹងការប្រែប្រួលអាកាសធាតុដោយរបៀបណា។

**ជាជម្រើស**

ការកសាងផែនទីនិងការវិភាគលម្អិតអំពីទឹកជំនន់ដែលបង្ហាញពីការកើនទំហំទឹកជំនន់ទៅតាមទិន្នន័យតាមដំណាក់កាលពេលវេលា សម្រាប់តំបន់ទំនាបបឹងទន្លេសាបកណ្តាល (ប្រើប្រាស់បច្ចេកវិទ្យា RADAR) ។ ទិន្នន័យនេះ មានសារៈសំខាន់ក្នុងការស្វែងយល់ពីការរីករាលដាលនៃតំបន់លិចទឹកដោយយោងទៅតាមសេណារីយ៉ូផ្សេងៗគ្នា (ជន់លិចតិច មធ្យម និងខ្លាំង) ក៏ដូចជាការកើនឡើងនៃទំហំទឹកជំនន់។




**ផែនទី ៦ ៖** ប្រព័ន្ធអេកូឡូស៊ីក្នុងខេត្តកំពង់ឆ្នាំង៖ តំបន់ទីជម្រាល(ខាងឆ្វេង) និងតំបន់អេកូឡូស៊ីទៅតាមហ្សែន (ខាងស្តាំ)




**ផែនទី ៧ ៖** តំបន់លិចទឹកក្នុងខេត្តកំពង់ឆ្នាំង ស្ថិតនៅក្រោមទំហំកម្រិតបីផ្សេងៗគ្នា




**ផែនទី ៨ ៖** ការកើនឡើងតំបន់លិចទឹកឆ្នាំ២០១១ នៅក្នុងខេត្តកំពង់ឆ្នាំង

## គ) ការប្រើប្រាស់ដី និងការកាន់កាប់ដី

**ការពាក់ព័ន្ធ៖** នៅក្នុងការងារផែនការរៀបចំដែនដី ព័ត៌មានទាក់ទងនឹងការប្រើប្រាស់ដី និងការកាន់កាប់ដីធ្លីជាព័ត៌មានស្នូល ពីព្រោះផែនការនេះមានគោលបំណងស្វែងរកឲ្យបាននូវតុល្យភាពរវាងតំបន់លំហសាធារណៈ ជាពិសេសសម្រាប់ជាទីជម្រក និងការការពារដល់ប្រព័ន្ធអេកូឡូស៊ី/ទីជម្រាលកសិកម្ម និងឧស្សាហកម្មយករ៉ែ ជាមួយនឹងតំបន់តាំងទីលំនៅ/ទម្រង់លក្ខណៈតំបន់ទីប្រជុំជន និងហេដ្ឋារចនាសម្ព័ន្ធដែលភ្ជាប់ទៅនឹង តំបន់ទាំងអស់នោះ។

ការប្រើប្រាស់ដីសំដៅដល់ការប្រើប្រាស់ធនធានដីដោយមនុស្ស។ វាទាក់ទងទៅនឹងការគ្រប់គ្រង និងការកែប្រែបរិស្ថានធម្មជាតិ ទៅជាបរិស្ថាននៃតំបន់អាចសាងសង់បានដូចជាវាលលែងកីឡា វាលស្មៅចិញ្ចឹមសត្វ និងលំនៅឋានជាដើម។

ការរៀបចំការកាន់កាប់ដីធ្លីរួមមាន៖ បទបញ្ញត្តិទាក់ទងនឹងការទទួលបានដី និងនិយ័តកម្មទទួលស្គាល់សិទ្ធិជាផ្លូវការ ដែលរួមមានការចុះបញ្ជីដីកម្មសិទ្ធិឯកជន ឬដីសហគមន៍ សម្បទានដីរដ្ឋ (សម្បទានសង្គមកិច្ច សម្បទានសេដ្ឋកិច្ច ឬសម្បទានរ៉ែ) តំបន់ការពារ ក៏ដូចជាសហកម្មសិទ្ធិ/ការផ្តល់នូវសិទ្ធិក្នុងការគ្រប់គ្រងរួមគ្នា (ដូចជាសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងតំបន់ប្រើប្រាស់សហគមន៍នៅក្នុងតំបន់ការពារជាដើម)។

### ការប្រើប្រាស់ដី/បច្ចុប្បន្នភាពគម្រមដី

ដើម្បីបង្កើតផែនទីយោងដ៏ល្អមួយដែលរៀបរាប់ពីការប្រើប្រាស់ដីនៅក្នុងខេត្ត វាជាការចាំបាច់ណាស់ក្នុងការបង្កើតនូវដំណើរការធ្វើបច្ចុប្បន្នភាពមួយទៅលើទិន្នន័យដែលមានស្រាប់។ ទិន្នន័យប្រើប្រាស់ដីឆ្នាំ១៩៩៩ ដែលជាទិន្នន័យមានគុណភាពល្អ (ទិន្នន័យអង្គការ JICA) គ្របដណ្តប់ទូទាំងប្រទេសមកដល់ពេលនេះ វាជាទិន្នន័យចាស់ណាស់ហើយ ដូចនេះបើយើងគិតពីទិន្នន័យទី២ (ទិន្នន័យមានស្រាប់) ក្រុមការងារខេត្តត្រូវផ្តួចផ្តើម ធ្វើបច្ចុប្បន្នភាពទិន្នន័យប្រើប្រាស់ដីនេះ។

ប្រើប្រាស់នូវទិន្នន័យដែលមានស្រាប់ពីJICA សម្រាប់ការងារធ្វើបច្ចុប្បន្នភាពនេះ។ បំណកប្រែរូបថតពីលើអាកាស ឬរូបថតផ្កាយរណបទៅជាប្រភេទប្រើប្រាស់ដីវាពិតជាជួយដល់ការបង្កើតស្រទាប់ប្រើប្រាស់ដីដែលមានភាពជាក់លាក់ទីតាំងភូមិសាស្ត្រខ្ពស់។ មានប្រភេទរូបថតផ្កាយរណបជាច្រើន (ខុសគ្នាទាំងតម្លៃ និងកម្រិតភាពជាក់លាក់) ដែលអាចយកមកប្រើប្រាស់បាន។ ក្រុមការងារក៏អាចពិនិត្យស្វែងរករូបថតពីលើអាកាសដែលមិនគិតលុយពី "Google Earth" ពីនាយកដ្ឋានភូមិសាស្ត្រ ឬពីUSGSដែលផ្តល់នូវរូបភាពផ្កាយរណប Landsat ដោយឥតគិតថ្លៃដល់អ្នកប្រើប្រាស់ (មើលឧបសម្ព័ន្ធ២)។

អ្នកជំនាញផ្នែក Remote Sensing គឺមានសារៈសំខាន់ណាស់ក្នុងការបកប្រែរូបថតផ្កាយរណបដើម្បីទទួលបានចំណាត់ថ្នាក់ប្រើប្រាស់ដីដ៏មានអត្ថន័យ ប៉ុន្តែការងារគូរលើទិន្នន័យរូបថតពីលើអាកាសនៅលើកុំព្យូទ័រគឺជាការងារដែលមានភាពងាយស្រួលជាង។ បន្ថែមទៅលើការធ្វើចំណាត់ថ្នាក់ប្រើប្រាស់

ដីរបស់រូបថតផ្កាយរណបដោយពឹងផ្អែកលើកុំព្យូទ័រ ការអង្កេតនៅវាលដោយប្រើប្រាស់ GPS អាចជួយបំពេញបន្ថែមដល់ដំណើរការធ្វើបច្ចុប្បន្នភាពនៅពេលដែលត្រូវធ្វើការកត់ត្រា និងធ្វើផែនទីលក្ខណៈភូមិសាស្ត្រពិសេសជាក់លាក់។ ការធ្វើបច្ចុប្បន្នភាពប្រើប្រាស់ដីលើកដំបូងនេះ ជួយចង្អុលបង្ហាញជាបឋមអំពីការប្រែប្រួលការប្រើប្រាស់ដី។




**ផែនទី ៩ ៖** ដំណើរការធ្វើបច្ចុប្បន្នភាពការប្រើប្រាស់ដីក្នុងខេត្តតាកែវ (ផែនទីប្រើប្រាស់ដីឆ្នាំ១៩៩៩ ខាងឆ្វេង) រូបថតបច្ចុប្បន្នភាពពី Google Earth (កណ្តាល) និងផែនទីបច្ចុប្បន្នភាពប្រើប្រាស់ដីឆ្នាំ២០១៤ (ខាងស្តាំ)

## គម្របព្រៃឈើ និងការគ្រប់គ្រង

ព្រៃឈើជួយរក្សាលំហូរទឹកនៅក្នុងទីជម្រាល និងជាប្រភពនៃផលនិងអនុផលព្រៃឈើដែលមានសារៈសំខាន់ដល់ជីវភាពរស់នៅជនបទ។ ព្រៃឈើផ្តល់អុសសម្រាប់ប្រើប្រាស់ដែលជាប្រភពផ្គត់ផ្គង់ថាមពលយ៉ាងសំខាន់សម្រាប់ជនបទ និងគ្រួសារមួយចំនួននៅទីប្រជុំជន និងផ្តល់ឈើគ្រឿងសំណង់ (ឧ.សម្រាប់ប្រើជារបង)។ ព្រៃឈើក៏ផ្តល់នូវការការពារផ្នែកជំនឿ (គោរពបូជា) ហើយសម្រាប់ក្រុមជនជាតិដើមភាគតិចវិញ ផ្នែកខ្លះនៃព្រៃឈើត្រូវបានចាត់ចែងប្រើប្រាស់ជាតំបន់បញ្ចុះសព។ ធនធានព្រៃឈើដើរតួយ៉ាងសំខាន់ក្នុងការកាត់ បន្ថយការប្រែប្រួលអាកាសធាតុហើយព្រៃឈើក៏ជាវិស័យសេដ្ឋកិច្ចដែលពាក់ព័ន្ធនៅក្នុងខេត្តមួយចំនួនផងដែរ ។

## ទិន្នន័យដែលត្រូវការ

### *ទិន្នន័យចាំបាច់*

- បច្ចុប្បន្នភាពគម្របព្រៃឈើ
- សម្បទានព្រៃឈើ (ប្រសិនបើមាន)
- តំបន់ការពារ (ប្រសិនបើមាន)
- សហគមន៍ព្រៃឈើ (ប្រសិនបើមាន)
- ការដាំដើមឈើ (ប្រសិនបើមាន)

### *ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)*

- សត្វ៖ ប្រភេទសត្វសំខាន់
- ការពិពណ៌នាពីរុក្ខជាតិព្រៃឈើ

- ការចំណាយសម្រាប់គម្រោងសេវាកម្មប្រព័ន្ធអេកូឡូស៊ី (ប្រសិនបើមាន)
- គម្រោង REDD+ (ប្រសិនបើមាន)

## ការវិភាគ និងលទ្ធផល

- កសាងផែនទី និងរៀបរាប់ពីគម្របព្រៃឈើ (ទំហំតំបន់ និងដង់ស៊ីតេ កម្រិតនៃការបាត់បង់គម្របព្រៃឈើ)
- កសាងផែនទី និងវិភាគទីតាំងបច្ចុប្បន្ន និងការគ្រប់គ្រងនៃ៖
    - ព្រៃការពារ
    - គម្រោងព្រៃសហគមន៍
    - គម្រោង REDD+
    - ព្រៃស្ថិតនៅក្រោមគម្រោងទូទាត់សេវាកម្មបរិស្ថាន (PES)
    - សម្បទានព្រៃ
    - កន្លែងបណ្តុះឈើ និងការដាំដើមឈើ
    - ទម្រង់នៃការអនុវត្តការគ្រប់គ្រងព្រៃឈើផ្សេងៗទៀត
- សម្រាប់ប្រភេទទម្រង់ទាំងអស់ខាងលើនេះ វាពិភាក្សា និងចងក្រងជាឯកសារអំពីភាពខ្លាំង និងភាពខ្សោយ ក៏ដូចជាសក្តានុពលសម្រាប់ធ្វើការចាត់ចែង ឬពង្រីកបន្ថែម។

## ជាជម្រើស

ពិពណ៌នាពីប្រភេទព្រៃឈើសំខាន់ៗ ជីវៈចម្រុះ សត្វនិងរុកជាតិ ប្រភេទពូជសំខាន់ៗ។ល។




**ផែនទី ១០៖** គម្របព្រៃឈើដែលមានស្រាប់ និងប្រភេទផ្សេងៗគ្នានៃការគ្រប់គ្រងព្រៃឈើ ខេត្តកំពង់ឆ្នាំង

## ការគ្រប់គ្រងជលផល

ជលផលមានតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រដល់ជីវិតរស់នៅរបស់ប្រជាជនកម្ពុជា និងការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស ក៏ដូចជាការការពារបរិស្ថាន ការអភិរក្សជីវៈចម្រុះ អភិបាលកិច្ចល្អ និងការកាត់បន្ថយភាពក្រីក្រ (Fisheries Administration, 2011b)។ ជលផលរួមមានការនេសាទត្រីទឹកសាបត្រីទឹកប្រៃ និងជលវប្បកម្ម។ តាមការសិក្សាស្រាវជ្រាវថ្មីៗរបស់ Inland Fisheries Research and Development Institute (IFReDI) (2013) បានបង្ហាញឲ្យឃើញថាប្រភពអាហារដ៏សំខាន់បំផុតទី២បន្ទាប់ពីស្រូវគឺធនធានជលវារី (ធនធានបានមក ពីទឹក ដូចជាត្រី សត្វក្នុងទឹកដូចជាក្តាម សិប្បសត្វ និងកង្កែបជាដើម) ចំនួន៦៣គីឡូក្រាម សម្រាប់មនុស្សម្នាក់ក្នុងមួយឆ្នាំត្រូវជា៧៦%នៃប្រូតេអ៊ីនសរុបពីសត្វដែលប្រជាជនកម្ពុជាបានទទួលទាន។ ដោយសារតែជលផលមានសារៈសំខាន់សម្រាប់ប្រជាជនកម្ពុជា ដូច្នេះវាជាការចាំបាច់ណាស់ដើម្បីធានាដល់ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព។

### ទិន្នន័យដែលត្រូវការ

***ទិន្នន័យចាំបាច់***

- កន្លែងនេសាទ (ត្រីទឹកសាប ទឹកប្រៃ និងជលវប្បកម្ម)
- សហគមន៍នេសាទ
- តំបន់អភិរក្សជលផល

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ការចាប់ត្រី
- ការពិពណ៌នាពីបរិស្ថានកន្លែងនេសាទ៖ ត្រី និងបញ្ជីសារពើភ័ណ្ឌជលសត្វដ៏ទៃទៀត

### ការវិភាគ និងលទ្ធផល

- កសាងផែនទី និងពិពណ៌នាពីកន្លែងនេសាទសំខាន់ៗ (ទំហំ ប្រភេទនៃធនធានជលផល)។
- កសាងផែនទី និងពិពណ៌នាពីទីតាំង និងស្ថានភាពគម្រោងសហគមន៍នេសាទ វិភាគពីភាពខ្លាំង និងភាព ខ្សោយ ក៏ដូចជាតម្រូវការ ឬសក្តានុពលសម្រាប់ការអភិវឌ្ឍនាពេលអនាគត។
- កសាងផែនទី និងពិពណ៌នាពីទីតាំងតំបន់អភិរក្សជលផលដែលនៅសល់បន្ទាប់ពីការលុបបំបាត់ឡូត៍នេសាទ វិភាគពីភាពខ្លាំង និងភាពខ្សោយ ក៏ដូចជាតម្រូវការ ឬសក្តានុពលសម្រាប់ការអភិវឌ្ឍនាពេលអនាគត។

### ជាជម្រើស

- ពិពណ៌នាពីប្រភេទធនធានជលផលសំខាន់ៗ ជីវៈចម្រុះ សត្វនិងរុក្ខជាតិ ប្រភេទពូជសំខាន់ៗ និង បរិមាណ ស្តុកត្រីជាដើម។ល។




**ផែនទី១១៖** ទីតាំងកន្លែងនេសាទត្រីដែលមានស្រាប់ និងប្រភេទផ្សេងៗនៃការគ្រប់គ្រងជលផលខេត្តកំពង់ឆ្នាំង

## ការគ្រប់គ្រងតំបន់ការពារ (ការអភិរក្សសត្វ និងរុក្ខជាតិ )

តំបន់ការពារត្រូវបានបង្កើតឡើងក្រោមយុត្តាធិការរបស់ក្រសួងបរិស្ថាន ដើម្បីធានាដល់ការការពារបរិស្ថាន ដីធ្លី ព្រៃឈើ ដីសើម និងតំបន់ឆ្នេរ។ តំបន់ការពារត្រូវបានរក្សាដើម្បីការពារជីវិតសត្វព្រៃ ធានាដល់ស្ថេរភាពទីជម្រាល និងការពារដល់ទេសភាព និងធម្មជាតិដែលមានសារៈសំខាន់សម្រាប់ការកំសាន្ត ការអប់រំ និងវិទ្យាសាស្ត្រ។ ទោះបីជាការគ្រប់គ្រងដី និងធនធានធម្មជាតិប្រកបដោយចីរភាពមានតែក្នុងតំបន់ការពារ ក៏ប៉ុន្តែដោយសារការគ្រប់គ្រងដែលមានការកំណត់ច្បាស់លាស់បានធ្វើឲ្យកន្លែងទាំងនេះក្លាយជាកន្លែងដ៏សំខាន់ សម្រាប់ការអភិវឌ្ឍដែនដីប្រកបដោយចីរភាព។

## ទិន្នន័យដែលត្រូវការ

***ទិន្នន័យចាំបាច់***

- ទីតាំងតំបន់ការពារ និងមុខងារសំខាន់ៗ
- ការបែងចែកតំបន់ខាងក្នុង (ប្រសិនបើមាន)

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ការពិពណ៌នាពីអេកូឡូស៊ី និងជីវចម្រុះនៅក្នុងតំបន់ការពារ

## ការវិភាគ និងលទ្ធផល

- ធ្វើផែនទីបង្ហាញទីតាំង និងប្រភេទតំបន់ការពារ (ឧទ្យានជាតិ ដែនជម្រកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាង ព្រៃលិចទឹកសំខាន់ៗ ការអភិរក្សជីវសាស្ត្រ តំបន់ការពារបេតិកភ័ណ្ឌធម្មជាតិ ឧទ្យាន សមុទ្រ)។
- វិភាគពីប្រសិទ្ធភាពនៃការការពារធនធាន បញ្ហាចំបងដែលប៉ះពាល់ដល់ការគ្រប់គ្រង និងវិធានការដោះស្រាយដែលត្រូវយកមកអនុវត្ត។
- កសាងផែនទី និងវិភាគអំពីការបែងចែកតំបន់ការពារដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន៖
    - តំបន់ស្នូល
    - តំបន់អភិរក្ស
    - តំបន់ប្រើប្រាស់ប្រកបដោយចីរភាព
    - តំបន់សហគមន៍
- ពិភាក្សាពីតម្រូវការ និងសក្តានុពលសម្រាប់ធ្វើឲ្យប្រសើរឡើងដល់ការគ្រប់គ្រងតំបន់ការពារនាពេលអនាគត។

## ជាជម្រើស

ការពិពណ៌នាពីព្រៃឈើសំខាន់ៗ ឬប្រភេទធនធានជលផលនៅក្នុងតំបន់ការពារ៖ ជីវៈចម្រុះសត្វ និង រុក្ខជាតិ ប្រភេទពូជសំខាន់ៗ ប្រព័ន្ធជីវៈចម្រុះ។ល។




**ផែនទី ១២ ៖** តំបន់ការពារដែលមានស្រាប់ក្នុងខេត្តកំពង់ឆ្នាំង

## កសិកម្ម

កសិកម្ម គឺមានសារៈសំខាន់ណាស់ ហើយវាក៏ជាប្រភេទប្រើប្រាស់ដីមួយយ៉ាងសំខាន់ក្នុងប្រទេសកម្ពុជា។ កសិកម្មចូលរួមចំណែកយ៉ាងខ្លាំងដល់ផលិតផលក្នុងស្រុកសរុប (GDP) និងជួយផ្តល់ការងារជាច្រើនដល់ប្រជាពលរដ្ឋ។ ផលិតកម្មកសិកម្ម ទាមទារឲ្យឆ្លើយតបទៅនឹងសុវត្ថិភាពស្បៀងអាហារសម្រាប់កំណើនប្រជាជនឆ្លើយតបទៅនឹងតម្រូវការស្បៀងអាហារចម្រុះ និងចូលរួមបង្កើតចំណូលតាមរយៈការនាំចេញ។ ផ្ទៃដីព្រៃឈើជាច្រើននៅក្នុងប្រទេសកម្ពុជា ត្រូវបានបំលែងទៅជាដីកសិកម្ម ខណៈដែលតំបន់កសិកម្មនៅតាមអនុទីប្រជុំជនបានពង្រីកខ្លួនក្លាយទៅជាតំបន់លំនៅឋាន។

កសិកម្ម គឺជាសមាសធាតុមួយយ៉ាងសំខាន់ នៅក្នុងសមាហរណកម្មកសាងផែនការរៀបចំដែនដីនៅក្នុងគ្រប់ខេត្តទាំងអស់។ ដោយសារតែត្រូវបង្កើតយុទ្ធសាស្ត្រលម្អិតអភិវឌ្ឍន៍វិស័យកសិកម្ម ហើយដាក់បញ្ចូលទៅក្នុងដែនដីក្នុងកម្រិតថ្នាក់ស្រុក ផែនការរៀបចំដែនដីត្រូវធ្វើការកំណត់នូវការប្រែប្រួលការប្រើប្រាស់ដីសម្រាប់អនាគតជាមួយនឹងមុខងារប្រកួតប្រជែង និងការប្រើប្រាស់តំបន់ទេសភាពសាធារណៈរបស់ខេត្ត។

### ទិន្នន័យដែលត្រូវការ

***ទិន្នន័យចាំបាច់***

- តំបន់ធ្វើកសិកម្ម និងទិន្នផលរបស់ដំណាំសំខាន់ៗ ដែលធ្វើការបែងចែកផ្សេងគ្នារវាងដំណាំស្រូវ ដំណាំមិនមែនស្រូវ និងដំណាំសក្តានុពលផ្សេងៗទៀត
- តំបន់កែច្នៃ និងស្តុកទុកផលិតផលកសិកម្ម

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ពិពណ៌នាពីប្រព័ន្ធចិញ្ចឹមសត្វ និងដំណាំរួមមានសុចនាករបច្ចេកទេសដូចជាតម្លៃផលិតកម្ម និងប្រាក់ចំណេញជាដើម។

### ការវិភាគ និងលទ្ធផល

- គណនា និងកសាងផែនទីតំបន់ធ្វើកសិកម្ម និងវិភាគពីរបាយដំណាំនៅក្នុងខេត្ត (ជាមួយនឹងការប្រែប្រួលបរិស្ថានរូបសាស្ត្រ និងជីវសាស្ត្រ)។
- នៅតំបន់ដែលមានជនជាតិដើម វាមានសារៈសំខាន់ណាស់ក្នុងការកំណត់ប្រព័ន្ធប្រើប្រាស់ដីកសិកម្មពនេចរ (ចំការវិលជុំ) ដែលជាទូទៅរួមមានភាពចម្រុះនៃទម្រង់ប្រើប្រាស់ដីកសិកម្មអចិន្ត្រៃយ៍។ វាក៏មានសារៈសំខាន់ណាស់ដែរក្នុងការបញ្ចូលការរៀបចំការកាន់កាប់ដីធ្លីរបស់ជនជាតិដើមភាគតិច ទោះបីជាការកាន់កាប់ដីនោះត្រូវបានទទួលស្គាល់ជាផ្លូវការជាកម្មសិទ្ធិរួម ឬក៏មិនទាន់បានទទួលស្គាល់ក៏ដោយ។ នៅក្នុងកម្រិតថ្នាក់ខេត្ត ការកំណត់នូវប្រព័ន្ធកាន់កាប់ដីទូទៅបែបនេះ គឺអាចមានលក្ខណៈគ្រប់គ្រាន់ ប៉ុន្តែគួរតែមានការកសាងផែនទីលម្អិតបន្ថែមទៀតនៅកម្រិតកសាងផែនការថ្នាក់ឃុំ និងថ្នាក់ស្រុក។

- កសាងផែនទីតំបន់ដែលធ្វើប្រពលវប្បកម្មកសិកម្ម និងពហុកសិកម្មពីកម្រិតទាបទៅកម្រិតខ្ពស់ កំណត់តំបន់កសិឧស្សាហកម្មនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ច ឬជាផ្នែកនៃការកាន់កាប់ដីក្នុងទ្រង់ទ្រាយធំ។

**ជាជម្រើស**

- ធ្វើការវិភាគ និងកំណត់លក្ខណៈសម្បត្តិប្រព័ន្ធដាំដុះផ្សេងៗគ្នាជាដំណាំស្រូវនិងដំណាំមិនមែនស្រូវ
    - ប្រតិទិនរដូវកាលដាំដុះ (រដូវប្រាំង និងរដូវវស្សា)
    - ទិន្នផលមធ្យមសម្រាប់ផលិតកម្មដំណាំស្រូវ និងដំណាំមិនមែនស្រូវ
    - ឧបសគ្គរាំងចំពោះការបង្កបង្កើនផល (ដី ទឹក ពលកម្ម បច្ចេកវិទ្យា ការទទួលបានធាតុចូល...)
    - ឧបសគ្គរាំងចំពោះការធ្វើពាណិជ្ជកម្ម (ការទៅកាន់ទីផ្សារ តម្លៃដើម តម្លៃលក់...)




**ផែនទី ១៣៖** សារៈសំខាន់នៃទំហំតំបន់ធ្វើកសិកម្ម (តាមឃុំ) ឆ្នាំ២០១២ នៅខេត្តកំពង់ឆ្នាំង

**ការកាន់កាប់ដី**

សក្តានុពល និងបញ្ហាប្រឈមនៃការប្រើប្រាស់ធនធានជលផល ព្រៃឈើ និងកសិកម្ម បានផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងការរៀបចំចាត់ចែងការកាន់កាប់ដី ដូច្នេះវាបានទទួលនូវការចាប់អារម្មណ៍យ៉ាងខ្លាំងពីអន្តរជាតិ តាមរយៈសៀវភៅណែនាំស្ម័គ្រចិត្តសម្រាប់អភិបាលកិច្ចការកាន់ដីធ្លី ធនធានព្រៃឈើ និងជលផលប្រកបដោយទំនួលខុសត្រូវ (VGGT)។ ឧទាហរណ៍ ការងារកសិកម្មដែលអាស្រ័យទៅលើគ្រួសារ (កម្លាំងពលកម្មក្នុងគ្រួសារ) គឺមានសារៈសំខាន់ណាស់ចំពោះការអភិវឌ្ឍប្រទេសជាតិ ប៉ុន្តែត្រូវរួមជាមួយផលិតកម្មផ្សេងៗក្នុងកម្រិតប្រតិបត្តិការផ្សេងៗខុសៗគ្នា (ឧ. តាមរយៈសម្បទានដីសេដ្ឋកិច្ចឬសង្គមកិច្ច)។ការពិនិត្យមើលលម្អិតអំពីការរៀបចំចាត់ចែងការកាន់កាប់ដីផ្សេងៗគ្នាទាំងនេះ គឺមានសារៈសំខាន់ណាស់ក្នុងការដោះស្រាយបញ្ហាទាក់ទងទៅនឹងការកាន់កាប់ប្រើប្រាស់ដីនឹងការដោះស្រាយឲ្យបានសមរម្យចំពោះផ្នែកឯកជននៅក្នុងការកសាងយុទ្ធសាស្ត្រអភិវឌ្ឍន៍។

**ទិន្នន័យដែលត្រូវការ**

***ទិន្នន័យចាំបាច់***

- តំបន់បង្ហាញពីយុទ្ធនាការផ្តល់ប័ណ្ណកម្មសិទ្ធដី (ការចុះបញ្ជីជាប្រព័ន្ធ ឬដាច់ដោយដុំ និងតាមបទបញ្ជា០១)
- តំបន់សម្បទានដីសេដ្ឋកិច្ច
- តំបន់សម្បទានដីសង្គមកិច្ច
- តំបន់ដែលមានប័ណ្ណកម្មសិទ្ធដីសហគមន៍
- ការកាន់កាប់ដីក្នុងទំហំធំដែលមិនទាន់ជាផ្លូវការ ឬមិនទាន់ធ្វើការចុះបញ្ជី

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ទិន្នន័យទី២(មានស្រាប់)អំពីការទទួលបានដីនិងការផ្ទេរដី និងចំនួនអ្នកដែលគ្មានដី

**ការវិភាគ និងលទ្ធផល**

- កសាងផែនទី និងពិពណ៌នាពីតំបន់ដែលបានចែកចាយប័ណ្ណកម្មសិទ្ធិដីធ្លីឯកជនដល់ប្រជាពលរដ្ឋ (តាមរយៈ ការចុះបញ្ជីដីធ្លីដាច់ដោយដុំ ឬជាប្រព័ន្ធ ឬក្នុងកំឡុងពេលអនុវត្តបទបញ្ជា០១)។
- កសាងផែនទី និងពិពណ៌នាពីតំបន់ដែលបានផ្តល់ប័ណ្ណកម្មសិទ្ធិសមូហភាពដល់សហគមន៍ (សហគមន៍ជនជាតិដើមភាគតិច)។
- កសាងផែនទី និងវិភាគតំបន់ និងការគ្រប់គ្រងសម្បទានដីសេដ្ឋកិច្ច រួមមានភាពខ្លាំង និងភាពខ្សោយ។ វាក៏មានសារៈសំខាន់ណាស់ដែរក្នុងការពិនិត្យឡើងវិញពីផលប៉ះពាល់នៃការអនុវត្តការងារទាក់ទងទៅនឹងសេដ្ឋកិច្ច សង្គម និងបរិស្ថាន។ ប្រសិនបើមិនមានឯកសារទាំងអស់នេះទេ

គួរតែធ្វើការបង្កើតវាឡើង ៖

- សម្បទានដីសេដ្ឋកិច្ចដែលមានកិច្ចព្រមព្រៀងពីថ្នាក់ជាតិ
- សម្បទានផ្សេងៗទៀតដែលផ្តល់ឲ្យដោយថ្នាក់ក្រោមជាតិទៅដល់សហគ្រាសខ្នាតតូច

- កសាងផែនទី និងវិភាគតំបន់និងស្ថានភាពរបស់សម្បទានដីសង្គមកិច្ចផ្សេងៗគ្នា (ភាពខ្លាំង និងភាពខ្សោយ) ៖
  - គ្រួសារក្រីក្រ
  - គ្រួសារទាហាន
  - ប៉ូលីសយោធា
- ពិនិត្យតំបន់វាលលំហ និងទំនាស់ដែលមិនទាន់លិចចេញជារូបរាង រវាងគ្រួសារកសិករ និងក្រុមហ៊ុន ដោយសារវាទាក់ទងទៅនឹងការទន្ទ្រានកាន់កាប់/ទាមទារយកដីត្រួតលើគ្នា ឬប្រភេទទំនាស់ផ្សេងៗទៀត។ គួរព្យាយាមធ្វើការសម្របសម្រួលដោះស្រាយបញ្ហាទាំងនេះក្នុងកំឡុងពេលដំណើរការកសាងផែនការ ដោយសារទំនាស់ទាំងនោះតែងតែមានផលប៉ះពាល់ដល់ប្រសិទ្ធភាពក្នុងការគ្រប់គ្រងតំបន់ទាំងនោះ។
- កំណត់បង្ហាញតំបន់មានផ្ទៃដីធំដែលមានការទាមទាកាន់កាប់ត្រួតស៊ីគ្នា ដូចជាសម្បទានដីសេដ្ឋកិច្ចលំនៅឋានដែលទន្ទ្រានកាន់កាប់នៅលើដីរដ្ឋ និង/ឬតំបន់សំណង់បណ្តោះអាសន្ន និងពិភាក្សាពីផលប៉ះពាល់ និងដំណោះស្រាយដោយមានការគិតគូរដល់បរិស្ថាន សេដ្ឋកិច្ច និងសង្គមកិច្ច។







**ផែនទី ១៤ ៖** ទីតាំងតំបន់ដែលប័ណ្ណកម្មសិទ្ធិដីធ្លីឯកជនបានចែកជូនហើយក្នុងខេត្តកំពង់ឆ្នាំង(ឆ្វេង) និងសម្បទានដីសេដ្ឋកិច្ច និងតំបន់សម្បទានដីសង្គមកិច្ចបីប្រភេទផ្សេងទៀតក្នុងខេត្តកំពង់ឆ្នាំង(ស្តាំ)

**ការយកថ្ម និងតំបន់យករ៉ែ**

ប្រភេទផ្សេងទៀតនៃការប្រើប្រាស់ដី ដែលត្រូវយកចិត្តទុកដាក់នោះគឺតំបន់ប្រតិបត្តិការអាជីវកម្មយករ៉ែ (ខ្សាច់ ថ្ម ដី មាសជាដើម)។ ជាធម្មតាប្រតិបត្តិការអាជីវកម្មយករ៉ែធ្វើឡើងក្រោមកិច្ចព្រមព្រៀងរវាងរដ្ឋនិង ក្រុមហ៊ុន ប៉ុន្តែវាក៏អាចកើតឡើងតាមរយៈកិច្ចព្រមព្រៀងមិនផ្លូវការផងដែរ។

- កសាងផែនទីតំបន់ដែលធ្វើអាជីវកម្មយករ៉ែ និងប្រភេទកិច្ចព្រមព្រៀង (ដែលគាំទ្រដល់អាជីវកម្ម)។
- វិភាគពីផលប៉ះពាល់ផ្នែកសង្គម សេដ្ឋកិច្ច និងបរិស្ថានមូលដ្ឋានពីដំណើរការយករ៉ែទាំងនោះ។

**ឃ) ប្រជាសាស្ត្រ និងលំនៅឋាន**

**ការពាក់ព័ន្ធ៖** ការកសាងផែនការរៀបចំដែនដី មានគោលបំណងលើកស្ទួយដល់សុខុមាលភាព និងជីវភាពរស់នៅរបស់ប្រជាពលរដ្ឋតាមរយៈការអភិវឌ្ឍដែនដីរបស់ខេត្តប្រកបដោយនិរន្តរភាព។ ដូច្នេះ ដើម្បីធ្វើការរៀបចំដំណើរការកសាងផែនការរៀបចំដែនដី ប្រកបដោយអត្ថន័យ និងមានសារៈសំខាន់នោះ អ្នកកសាងផែនការត្រូវទាមទារឲ្យមានចំណេះដឹងកាន់តែជ្រាលជ្រៅទាក់ទងនឹងប្រជាសាស្ត្រនៅក្នុងខេត្ត។ ចំណុចសំខាន់របស់វានោះ គឺការវិភាគទំនោរនៃការប្រែប្រួលផ្នែកប្រជាសាស្ត្រ ស្ថានភាពបច្ចុប្បន្ន និងការពិពណ៌នាជាក់លាក់ដែលឆ្លើយតបទៅនឹងទម្រង់ (សណ្ឋាន) នៃការតាំងទីលំនៅ។

**ប្រជាសាស្ត្រ**

ទិន្នន័យប្រជាសាស្ត្រដូចជាទំហំរបាយនិងការវិវត្តរបស់ប្រជាជន គឺមានសារៈសំខាន់ណាស់ក្នុងការវាយតម្លៃពីតម្រូវការរបស់ប្រជាជនទាក់ទងទៅនឹងបរិក្ខារ (សេវាកម្ម) អប់រំ និងសុខភាព ហេដ្ឋារចនាសម្ព័ន្ធ ការងារ និងការអភិវឌ្ឍសេដ្ឋកិច្ចទូទៅ។ ដោយសារតែរាល់សកម្មភាពប្រើប្រាស់ដីវាផ្សារភ្ជាប់ទៅនឹងមនុស្សដែលរស់នៅលើដីនោះ ដូច្នេះវាជាការចាំបាច់ណាស់ក្នុងការស្វែងយល់ពីរាល់សកម្មភាពទាក់ទងទៅនឹងដីធ្លីរបស់មនុស្ស ដូចជាចរិកលក្ខណៈនៃការតាំងទីលំនៅឬការបំលែងពីប្រភេទប្រើប្រាស់ដីមួយទៅជាប្រភេទប្រើប្រាស់ដីមួយផ្សេងទៀត។

**ទិន្នន័យដែលត្រូវការ**

***ទិន្នន័យចាំបាច់***

- ទិន្នន័យប្រជាជនទៅតាមដំណាក់កាលពេលវេលា នៅថ្នាក់ឃុំ ឬក្រុមអាយុ
- ទិន្នន័យអន្តោប្រវេសន៍ (ចំណាកនិងចំណូលស្រុក) តាមស្រុក

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ទិន្នន័យប្រជាសាស្ត្រជាក់លាក់ ដូចជាអត្រាមរណៈភាព និងអត្រាកំណើត

**ការវិភាគ និងលទ្ធផល**

មានទិន្នន័យប្រជាសាស្ត្រដែលអាចទុកចិត្តបាន សម្រាប់យកមកធ្វើការវិភាគប្រជាសាស្ត្រដាច់ដោយឡែកពីគ្នា និងវិភាគរយៈពេលវែង (នៅថ្នាក់ស្រុក ឬរហូតដល់ថ្នាក់ឃុំ)។ ការវិភាគរយៈពេលវែងនេះមានសារៈសំខាន់ក្នុងការស្វែងយល់ពីឌីណាមិក (ការវិវត្តប្រែប្រួល) ប្រជាសាស្ត្រនៅក្នុងខេត្ត។

- ផែនទីប្រជាសាស្ត្រមួយចំនួន បង្ហាញពីចំនួន (ទំហំ) ប្រជាជនបច្ចុប្បន្ននៅតាមឃុំ
- ធ្វើការគណនា កសាងផែនទី និងពន្យល់បកស្រាយពី ″អត្រាកំណើនប្រជាសាស្ត្រ″ តាមរូបមន្ត ៖

$$r = \frac{Ln\,(P_t) - Ln\,(P_0)}{t}$$

  - $P_o$ = ជាចំនួនប្រជាសាស្ត្រនៅឆ្នាំគោល $P_t$ = ជាចំនួនប្រជាសាស្ត្រនៅឆ្នាំ t ហើយ ‵ t ‵ ជាចំនួនឆ្នាំរវាង $P_o$ និង $P_t$ ។ អត្រាកំណើនប្រជាជន បង្ហាញពីភាគរយនៃកំណើនប្រជាជនក្នុងរយៈពេលមួយជាក់លាក់។ វាមានអត្ថប្រយោជន៍ក្នុងការប្រៀបធៀបអត្រាកំណើនប្រជាជននេះរវាងស្រុកនិងស្រុក ដើម្បីធ្វើការស្វែងយល់ពីការវិវត្តប្រែប្រួលប្រជាសាស្ត្រផ្សេងៗគ្នានៅក្នុងខេត្ត។

- ធ្វើការគណនា កសាងផែនទី និងពន្យល់បកស្រាយពី ″អត្រាចំណូលនិងចំណាកស្រុកក្នុងស្រុក″ ដោយរូបមន្ត ៖

$$\text{អត្រាចំណូលនិងចំណាកស្រុក} = \frac{\text{ចំនួនអ្នកចំណូលស្រុកសុទ្ធ - ចំនួនអ្នកចំណាកស្រុកសុទ្ធ}}{\text{ចំនួនប្រជាជនសរុបនៅក្នុងស្រុក}} \times ១០០$$

**តម្លៃវិជ្ជមាននៃ** ″អត្រាចំណូលនិងចំណាកស្រុក″ បង្ហាញឲ្យឃើញថាមានប្រជាជនចូលមកក្នុងស្រុកច្រើនជាងប្រជាជនដែលចាកចេញពីស្រុកក្នុងរយៈពេលមួយជាក់លាក់ ខណៈដែល**តម្លៃអវិជ្ជមាន**មានន័យថាមានប្រជាជនចាកចេញពីស្រុកច្រើនជាងអ្នកចូលមកក្នុងស្រុកក្នុងរយៈពេលមួយជាក់លាក់។ កិច្ចការនេះ ផ្តល់នូវព័ត៌មានដ៏មានប្រយោជន៍អំពីចរន្តអន្តោប្រវេសន៍របស់ប្រជាជនដែលចេញក្រៅ និងចូលមកក្នុងស្រុក ។ វាជាសុចនាករដ៏ល្អពីឌីណាមិក (ការវិវត្តប្រែប្រួល) សេដ្ឋកិច្ចរបស់ស្រុក។




**ផែនទី១៥៖** អត្រាកំណើនប្រជាជនតាមស្រុកសម្រាប់រយៈពេលពីឆ្នាំ ១៩៩៨ - ២០០៨ ក្នុងខេត្តកំពង់ឆ្នាំង (ខាងឆ្វេង) និងអត្រាចំណូលនិងចំណាកស្រុកតាមស្រុកនៅក្នុងខេត្តតែមួយក្នុងរយៈពេលដូចគ្នា (ខាងស្តាំ)

- ធ្វើការគណនា កសាងផែនទី និងស្វែងយល់ពី "ដង់ស៊ីតេប្រជាជន" ដោយរូបមន្ត ៖

$$\textbf{ដង់ស៊ីតេប្រជាជន} = \frac{\textbf{ចំនួនប្រជាជនសរុបនៅក្នុងតំបន់}}{\textbf{ផ្ទៃក្រឡារបស់តំបន់}}$$

ព័ត៌មានអំពីដង់ស៊ីតេប្រជាជន អាចឲ្យយើងយកមកប្រើប្រាស់ក្នុងការកំណត់តំបន់ដែលរងសំពាធពីប្រជាជនរស់នៅតិច ឬច្រើនក្នុងតំបន់នោះនៅក្នុងខេត្ត និងជាព័ត៌មានយើងអាចពិភាក្សាផលវិបាកសម្រាប់ការប្រើប្រាស់ និងតម្រូវការដី។




**ផែនទី១៦៖** ដង់ស៊ីតេប្រជាជន (ខាងឆ្វេង) និងអត្រាកំណើន (ខាងស្តាំ) តាមឃុំ នៅខេត្តតាកែវ(២០០៦-២០១៤)

- ធ្វើការគណនា និងស្វែងយល់ពី " ពីរ៉ាមីតអាយុ " របស់ប្រជាជននៅក្នុងខេត្ត (រូបភាព៧)។ ពីរ៉ាមីតអាយុតាមក្រុមផ្តល់នូវព័ត៌មានយ៉ាងសំខាន់អំពីចំណាត់ថ្នាក់អាយុផ្សេងៗគ្នារបស់ប្រជាជន។




**រូបភាព៧៖** ពីរ៉ាមីតអាយុប្រជាជននៅក្នុងខេត្តកំពង់ឆ្នាំងក្នុងឆ្នាំ១៩៩៨ (ខាងឆ្វេង) និងឆ្នាំ២០០៨ (ខាងស្តាំ)

## ជាជម្រើស

- ពិពណ៌នាពីការវិវត្តនៃអត្រាកំណើត និងអត្រាមរណៈភាព

### លំនៅឋានទីប្រជុំជន និងជនបទ

ប្រភេទនៃការប្រើប្រាស់ដី ដែលមិនទាន់បានកំណត់បង្ហាញឲ្យបានច្បាស់លាស់នៅក្នុងចំណុច **គ) ការកាន់កាប់និងការប្រើប្រាស់ដី** គឺជាតំបន់សាងសង់។វាប្រហែលជាខុសប្លែកពីប្រភេទនៃការប្រើប្រាស់ដីដទៃទៀតការប្រើប្រាស់សម្រាប់លំនៅឋានត្រូវបានផ្សារភ្ជាប់ទៅនឹងការអភិវឌ្ឍប្រជាសាស្ត្រ។ ការពិនិត្យល្អិតល្អន់ទៅលើប្រវត្តិនៃការវិវត្តិនិងការតាំងទីលំនៅដែលមានស្រាប់ វាផ្តល់នូវការបញ្ជាក់ពីទីតាំងភូមិសាស្ត្រជាក់ស្តែងនៃការវិភាគប្រជាសាស្ត្រដែលទើបតែធ្វើកន្លងមក។ នៅពេលដែលបានយល់ច្បាស់ពីដង់ស៊ីតេប្រជាជន កំណើន និងអន្តោប្រវេសន៍របស់ប្រជាជននៅកម្រិតថ្នាក់ឃុំនិងស្រុក ហើយនោះ វាទាមទារឲ្យមានការស្វែងយល់បន្ថែមទៀតថាតើអ្វីដែលបានយល់ទាំងអស់នោះ(ដង់ស៊ីតេ កំណើន ចំណាកស្រុកចំណូលស្រុក) ត្រូវបំលែងយកមកប្រើប្រាស់ផ្សារភ្ជាប់ទៅនឹងទម្រង់លំនៅឋានដោយរបៀបណា។ តើតំបន់ទីប្រជុំជនត្រូវពង្រីកទៅតំបន់កសិកម្មនៅជុំវិញនោះ ឬក៏វាត្រូវពង្រីកបំពេញឲ្យកាន់តែណែនតាន់តាប់ក្នុងតំបន់លំនៅឋានមានស្រាប់? តើលំនៅឋានតូចៗត្រូវបញ្ចូលគ្នាទេ? តើលំនៅឋានថ្មីកើតឡើងនៅតាមដងផ្លូវថ្មីឬទេ ឬលំនៅឋានថ្មីនៅតែកើតមានឡើងទោះជាមានទំនាស់លើការកាន់កាប់ដីធ្លីក៏ដោយ (ដូចជាសម្បទាន)? ពិតណាស់ផែនការរៀបចំដែនដីថ្នាក់ខេត្ត មិនលម្អិតដល់បញ្ហាទាំងនេះនោះទេ ប៉ុន្តែការមិនយល់ពីទំនោរប្រែប្រួលនៃការតាំងទីលំនៅសំខាន់ៗពិតជានឹងបង្អាក់ដល់ការរៀបចំគោលការណ៍ទម្រង់លក្ខណៈតំបន់តាំងទីលំនៅដែលចង់បាននាពេលអនាគត។

### ទិន្នន័យដែលត្រូវការ

***ទិន្នន័យចាំបាច់***

- ទីតាំងតំបន់លំនៅឋានទៅតាមដំណាក់កាលពេលវេលា
- ចំណាត់ថ្នាក់ទីប្រជុំជនដោយផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យរបស់វិទ្យាស្ថានស្ថិតិជាតិ ( NIS)

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ព័ត៌មានលម្អិតបន្ថែមទៀតអំពីរចនាសម្ព័ន្ធទីប្រជុំជន

### ការវិភាគ និងលទ្ធផលរំពឹងទុក

- កសាងផែនទី និងពិពណ៌នាពីតំបន់និងរបាយលំនៅឋានជនបទ និងទីប្រជុំជននៅក្នុងខេត្ត។ កំណត់តំបន់ ទីប្រជុំជន (មជ្ឈមណ្ឌលថ្នាក់ស្រុក និងមជ្ឈមណ្ឌលដទៃទៀត) អាស្រ័យទៅតាមលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយវិទ្យាស្ថានស្ថិតិជាតិ (NIS):
    - ដង់ស៊ីតេប្រជាជនដែលមានចំនួនលើសពី ២០០នាក់/គីឡូម៉ែត្រក្រឡា
    - ភាគរយនៃចំនួនអ្នកធ្វើការក្នុងវិស័យកសិកម្មជាបុរសតិចជាង ១៥% និង
    - ចំនួនប្រជាជនសរុបរបស់ឃុំមានចំនួនលើសពី ២០០០ នាក់ (NIS 2011)
- កសាងផែនទីនិងពិពណ៌នាពីការប្រែប្រួលទូទៅនៃទម្រង់នៃការតាំងទីលំនៅ។ ការងារនេះអាចធ្វើការបង្ហាញបានតាមរយៈទីតាំងដែលមានការរីកលូតលាស់នៅទីប្រជុំជន និងជនបទតំបន់មានលំនៅឋានថ្មី ជាពិសេសតាមដងផ្លូវថ្មីនិងនៅក្នុងតំបន់ខ្ពង់រាប។ ការវិភាគពីការរីកលូតលាស់

ទីប្រជុំជន ឲ្យកាន់តែជាក់លាក់បន្ថែមទៀត វាគួរធ្វើឡើងនៅក្នុងកម្រិតនៃការកសាងផែនការថ្នាក់ស្រុក/ក្រុង។

### ង) ការផ្តល់នូវសេវាសង្គម

ការពាក់ព័ន្ធ៖ ហេដ្ឋារចនាសម្ព័ន្ធសង្គមជាទូទៅរួមមានធនធាន (ការផ្គត់ផ្គង់) ដែលជួយសម្រួលដល់សេវាសង្គមដូចជាការអប់រំ សុខភាព ហើយរួមទាំងការផ្តល់នូវបរិក្ខារ (សេវាកម្ម) សម្រាប់វិស័យកីឡា និងវប្បធម៌។ នៅក្នុងកម្រិតផែនការថ្នាក់ខេត្ត វាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការគិតគូរដល់ការផ្គត់ផ្គង់បរិក្ខារ(សេវាកម្ម) សម្រាប់វិស័យសុខាភិបាល និងអប់រំ ក្នុងគោលបំណងធ្វើឲ្យប្រសើរឡើងដល់ប្រជាពលរដ្ឋក្នុងការទទួលបានសេវាទាំងនោះ។ ការផ្តល់មធ្យោបាយងាយស្រួលសម្រាប់វិស័យអប់រំ និងសុខាភិបាលទាំងផ្នែករដ្ឋ និងឯកជនមាននៅក្នុងប្រទេសកម្ពុជា ហើយវិស័យទាំងពីរនេះគួរយកមកពិចារណានៅពេលកសាងផែនការ។ ការវិភាគនេះជួយដល់ការសម្រេចចិត្តថាតើមជ្ឈមណ្ឌលទីប្រជុំជនណាខ្លះត្រូវផ្តល់សេវាសង្គមអ្វីខ្លះទៅដល់ប្រជាជនក្នុងតំបន់ទាំងនោះ ព្រមទាំងនៅតំបន់ជនបទជុំវិញ ដើម្បីកាត់បន្ថយបញ្ហាផ្តល់សេវាមិនបានគ្រប់គ្រាន់ដល់ប្រជាពលរដ្ឋនៅក្នុងខេត្ត ក៏ដូចជាការពង្រឹងប្រសិទ្ធភាពនៃការប្រើប្រាស់បរិក្ខារសម្រាប់រដ្ឋ។

### សុខាភិបាល

ក្រសួងសុខាភិបាល ធ្វើការបែងចែកតំបន់ភូមិសាស្ត្រ អាស្រ័យទៅតាមប្រព័ន្ធឋានានុក្រមដែលគិតទៅលើចំនួនប្រជាជន។ ការបែងចែកចំណាត់ថ្នាក់តំបន់នេះវាខុសពីឋានានុក្រមតាមរដ្ឋបាលធម្មតា (ខេត្ត ស្រុក ឃុំ ភូមិ) ហើយក្រុមការងារខេត្តគួរស្វែងយល់ពីភាពខុសគ្នានេះ។ យោងទៅតាមចំណាត់ថ្នាក់របស់ក្រសួងសុខាភិបាល ស្រុកមួយចំនួនត្រូវបានចងក្រងជាមួយគ្នាបង្កើតជាស្រុកប្រតិបត្តិ ស្រុកប្រតិបត្តិនីមួយៗគ្របដណ្តប់ទៅលើប្រជាពលរដ្ឋចន្លោះពី ១០០ ០០០ ទៅ ២០០ ០០០ នាក់ ហើយមានមណ្ឌលសុខភាពប្រមាណពី ១០ ទៅ ២០ ទីតាំង (មណ្ឌលសុខភាពនីមួយៗគ្របដណ្តប់ចំនួនប្រជាជនប្រមាណជា ១០ ០០០ នាក់) ហើយនិងមានមន្ទីរពេទ្យបង្អែកមួយ។

### ទិន្នន័យដែលត្រូវការ

***ទិន្នន័យចាំបាច់***

- ព្រំប្រទល់ស្រុកប្រតិបត្តិ (OD)
- ប្រភេទផ្សេងៗនៃហេដ្ឋារចនាសម្ព័ន្ធសុខាភិបាល៖ មន្ទីរពេទ្យបង្អែក គ្លីនិចឯកជន ជំនាញឯកទេស មណ្ឌលសុខភាពស្រុកប្រតិបត្តិ មណ្ឌលសុខភាពសាធារណៈ និងប៉ុស្តិ៍សុខភាព

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

លក្ខណៈសម្បត្តិនៃសេវាសុខភាព

## ការវិភាគនិងលទ្ធផល

- កសាងផែនទីទីតាំងសេវាសុខភាពផ្សេងៗគ្នា
- ពិភាក្សាពីលទ្ធភាពក្នុងការទទួលបានសេវាកម្មរបស់ប្រជាពលរដ្ឋនៅគ្រប់តំបន់ទាំងអស់ក្នុងខេត្ត។ ត្រូវចងចាំថាការផ្តល់សេវាសុខភាពប្រភេទផ្សេងៗគ្នា វាក៏បំពេញតម្រូវការឆ្លើយតបទៅនឹងចំនួនប្រជាជន និងទំហំតំបន់ដែលទទួលសេវាកម្មនោះក្នុងកម្រិតខុសៗគ្នាដែរ។

## ជាជម្រើស

- កំណត់លក្ខណៈសម្បត្តិហេដ្ឋារចនាសម្ព័ន្ធសុខភាពនីមួយៗ និងព័ត៌មានអំពីប្រភេទនិងសមត្ថភាពរបស់វា (ទាំងឯកជន និងសាធារណៈ)។




**ផែនទី ១៧៖** ទីតាំងសេវាសុខភាពផ្សេងៗគ្នា (ខាងឆ្វេង) និង ការទទួលបានសេវាកពីមណ្ឌលសុខភាពនៅខេត្តកំពង់ឆ្នាំង

## វិស័យអប់រំ

ជាគោលការណ៍ ការផ្តល់នូវបរិក្ខារ (សេវាកម្ម) សម្រាប់វិស័យអប់រំ គឺមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងវិស័យសុខាភិបាលដែរ គ្រាន់តែវិស័យអប់រំមិនមានស្រុកប្រតិបត្តិនោះទេ។ គុណភាពនៃសេវាអប់រំមាន សារៈសំខាន់ណាស់ ដូច្នេះផែនការរៀបចំដែនដីខេត្តនឹងត្រូវធ្វើការផ្តោតទៅលើលទ្ធភាពក្នុងការទទួលបាន សេវាអប់រំនេះ៖

## ទិន្នន័យដែលត្រូវការ

***ទិន្នន័យចាំបាច់***

- ទីតាំងកន្លែងអប់រំទៅតាមប្រភេទ

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- លក្ខណៈសម្បត្តិរបស់សាលាដូចជាអត្រានៃការចុះឈ្មោះ ចំនួនគ្រូជាដើម។ល។

## ការវិភាគ និងលទ្ធផល

- កសាងផែនទីបង្ហាញទីតាំងផ្តល់សេវាអប់រំទៅតាមប្រភេទផ្សេងៗគ្នា (សាលាមត្តេយ្យ បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ សាកលវិទ្យាល័យ មជ្ឈមណ្ឌលបណ្តុះបណ្តាលជំនាញ និងមជ្ឈមណ្ឌលអប់រំផ្សេងទៀត)។
- ធ្វើការវិភាគមូលដ្ឋានពីលទ្ធភាពអាចទទួលបានសេវាអប់រំ ដើម្បីកំណត់ពីតំបន់លំនៅឋានដែលមានបញ្ហាក្នុងការទទួលបានសេវាកម្មនេះនៅក្នុងខេត្ត។ ត្រូវចងចាំថាការផ្តល់នូវសេវាអប់រំប្រភេទផ្សេងៗគ្នាវានឹងបំពេញតម្រូវការឆ្លើយតបទៅនឹងចំនួនប្រជាជន និងតំបន់ជុំវិញក្នុងកម្រិតខុសគ្នាដែរ។




**ផែនទី ១៨៖** ការទទួលបានសេវាអប់រំថ្នាក់បឋមសិក្សាក្នុងខេត្តតាកែវ

## ជាជម្រើស

- កំណត់លក្ខណៈសម្បត្តិរបស់សាលានីមួយៗ និងព័ត៌មានពីប្រភេទ សមត្ថភាព និងការចុះឈ្មោះចូលរៀនបច្ចុប្បន្ន (ទាំងផ្នែកឯកជន និងសាធារណៈ)។

## ច) ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

**ការពាក់ព័ន្ធ៖** ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត គឺជាសមាសភាគរចនាសម្ព័ន្ធយ៉ាងសំខាន់ផ្តល់នូវបណ្តាញទំនាក់ទំនងគាំទ្រដល់សកម្មភាពសេដ្ឋកិច្ច សេវាកម្ម និងការកំសាន្តលំហែកាយរបស់ខេត្ត។ ជាមួយគ្នានឹងទម្រង់លក្ខណៈនៃការតាំងទីលំនៅ និងប្រព័ន្ធទីតាំងមជ្ឈមណ្ឌលកណ្តាល ហេដ្ឋារចនាសម្ព័ន្ធរូបវន្តគឺជាស្នូលដ៏សំខាន់ ក្នុងការកំណត់រចនាសម្ព័ន្ធទីតាំងភូមិសាស្ត្ររបស់ខេត្ត។ ហេដ្ឋារចនាសម្ព័ន្ធរូបវន្តត្រូវបានបែងចែកជា ៤ ប្រភេទ អាស្រ័យទៅតាមមុខងាររបស់វាមាន៖ ការដឹកជញ្ជូន ការគ្រប់គ្រងទឹក ការគ្រប់គ្រងកាកសំណល់ និងថាមពល។

## ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមានគោលបំណងសម្រួលដល់ចល័តភាព និងភាពងាយស្រួល (ការទទួលបាន)នៅក្នុងខេត្ត ដែលធ្វើឲ្យវាក្លាយជាមូលដ្ឋានដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។ ដោយសារមានករណីគ្រោះថ្នាក់ចរាចរកើតមានឡើងញឹកញាប់និងធ្ងន់ធ្ងរនោះ សុវត្ថិភាពចរាចរត្រូវធ្វើការយកចិត្តទុកដាក់យ៉ាងខ្លាំងនៅក្នុងប្រទេសកម្ពុជា។ នៅក្នុងអត្ថន័យនៃការរៀបចំដែនដី ហេដ្ឋា-រចនាសម្ព័ន្ធដឹកជញ្ជូនបង្កើតបានជាតំបន់ទ្រនាប់ច្រកផ្លូវ(corridors) ដែលអាចមានផលប៉ះពាល់ដល់បរិស្ថាន និងសង្គម (ឧ. ការតាំងទីលំនៅរងនូវផល ប៉ះពាល់ពីការពង្រីកផ្លូវ ឬក៏ផលិតភាពកសិកម្ម និងប្រព័ន្ធអេកូឡូស៊ី មានការញែកដាច់ចេញពីគ្នា និងខូចខាតដោយសារផ្លូវទំនាក់ទំនងថ្មី)។ ដូច្នេះ ការងាររបស់ផែនការរៀបចំដែនដីគឺគិតគូរពីផលប៉ះពាល់ទាំងនេះ តាមរយៈការធ្វើសមាហរណកម្មមុខងាររបស់តំបន់វាលលំហ និងកំណត់នូវជម្រើសផ្លូវសមស្របផ្សេងៗគ្នាសម្រាប់អនាគត។

ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនរួមមានផ្លូវថ្នល់ ផ្លូវដែក និងប្រភេទផ្លូវផ្សេងទៀត ផ្លូវទឹកដែលអាចចរាចរបានផ្លូវអាកាស (ព្រលាន/វាលយន្តហោះ) ក៏ដូចជាហេដ្ឋារចនាសម្ព័ន្ធសម្រាប់ទំនាក់ទំនងមានដូចជាប៉ុស្តិ៍ប្រៃសណីយ៍។ នៅក្នុងប្រទេសកម្ពុជាបណ្តាញផ្លូវគោកគឺមានសារៈសំខាន់បំផុតសម្រាប់ការដឹកជញ្ជូន ប៉ុន្តែផ្លូវទឹកក៏សំខាន់ផងដែរសម្រាប់ការដឹកជញ្ជូននៅតំបន់ណាដែលមានសេវាផ្លូវថ្នល់តិចតួច។ ចំណែកផ្លូវដែកវិញ ក៏ជាជម្រើសមួយ សំខាន់ផងដែរបន្ថែមពីលើការដឹកជញ្ជូនតាមផ្លូវថ្នល់។ ផ្លូវដែកភាគច្រើននៅក្នុងប្រទេសកម្ពុជាឥឡូវបាននឹងកំពុងធ្វើការជួសជុល ហើយក៏មានផ្លូវដែកថ្មីមួយចំនួនក៏កំពុងតែសាងសង់ថ្មីផងដែរ។ ព្រលានយន្តហោះមាន នៅក្នុងក្រុងជាច្រើនទូទាំងប្រទេស ប៉ុន្តែជាទូទៅមិនមានដំណើរការនោះទេ។ សេណារីយ៉ូសម្រាប់ធ្វើការអភិរក្សព្រលានយន្តហោះ និងការកំណត់នូវជម្រើសទីតាំងថ្មីសម្រាប់ព្រលានយន្តហោះទាមទារនូវការពិភាក្សា គ្នា។

**ទិន្នន័យដែលត្រូវការ**

***ទិន្នន័យចាំបាច់***

- ទីតាំងផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក និងស្ថានីយ៍ដឹកជញ្ជូនសំខាន់ៗ

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- លក្ខណៈគុណភាពហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ពេលវេលាធ្វើដំណើរ/ការស្ទះចរាចរ តំបន់សុវត្ថិភាព/គ្រោះថ្នាក់) ដែលមាននៅក្នុងខេត្ត

**ការវិភាគនិងលទ្ធផល**

- កសាងផែនទីទីតាំងជាក់លាក់នៃហេដ្ឋារចនាសម្ព័ន្ធដែលមានស្រាប់ និងបានធ្វើផែនការហើយ រួមមានការ ពិនិត្យគម្រោងកែលម្អផ្លូវដែក ព្រលានយន្តហោះ និងផ្លូវទឹកជាដើម។
- កំណត់ចំណាត់ថ្នាក់ផ្លូវថ្នល់តាមឋានានុក្រម ៖ ផ្លូវថ្នាក់ជាតិ ខេត្ត ឃុំ។
- កំណត់ពីប្រភេទគុណភាពផ្លូវថ្នល់ (ក្រាលកៅស៊ូ គ្រួសក្រហម ដី) និងប្រមូលព័ត៌មានអំពីលទ្ធភាពដែលអាចធ្វើចរាចរ (ដឹកជញ្ជូន) បាននៅរដូវវស្សា។
- កំណត់តំបន់នៅក្នុងខេត្តដែលមានការប្រាស្រ័យទាក់ទង(ចរាចរ)តិចតួចដោយសាររបាយហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនមានតិចតួច (ធ្វើការពិនិត្យជាមួយទីតាំងលំនៅឋាន ជាពិសេសតំបន់លំនៅឋានថ្មី)។
- កំណត់ និងធ្វើផែនទីស្ថានីយ៍ដឹកជញ្ជូន (ធ្វើដំណើរ) សំខាន់ៗនៅក្នុងខេត្ត (ឧ.ស្ថានីយ៍ឡានក្រុង ចម្រុះ ផែ (កប៉ាល់) និងស្ថានីយ៍ផ្លូវដែក) និងវិភាគពីបញ្ហាប្រឈមផ្សេងៗដែលប្រឈមទៅដល់ការគ្រប់គ្រងបណ្ដុំទីតាំង ដឹកជញ្ជូន (ចរាចរ) ទាំងនោះ។ យកចិត្តទុកដាក់ឲ្យបានជិតដល់ចំពោះទីតាំងស្ថានីយ៍ធ្វើដំណើរដែលមានលក្ខណៈចម្រុះ ដែលជាកន្លែងដែលប្រភេទហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្សេងៗគ្នាប្រសព្វជួបគ្នា (ឧ. ផែនៅ ជាប់ជាមួយនឹងស្ថានីយ៍ឡានក្រុង) ។




**ផែនទី ១៩ ៖** បណ្ដាញហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ចរាចរ) ក្នុងខេត្តកំពង់ឆ្នាំង

## ជាជម្រើស

- ពិនិត្យឈ្មោះ/លេខផ្លូវ (ប្រសិនបើមាន)
- ផលិតផែនទីតំបន់នៅក្នុងខេត្តដែលមានផ្លូវប្រឈមនឹងការខូចខាតដោយសារទឹកជំនន់

## (កសិកម្ម) ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក

ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក ក៏សំដៅទៅដល់ហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រ ដែលវាមានសារៈសំខាន់យ៉ាងខ្លាំងក្នុងគាំទ្រដល់ការអភិវឌ្ឍកសិកម្ម។ យើងធ្វើការបែងចែកប្រព័ន្ធធារាសាស្ត្រជាពីរគឺ៖ ប្រព័ន្ធធារាសាស្ត្រសម្រាប់លក្ខណៈគ្រួសារ/ខ្នាតតូច (បូមទឹកចេញពីអាងស្តុបទឹក) និងប្រព័ន្ធធារាសាស្ត្រដែលផ្តល់អត្ថប្រយោជន៍ដល់ក្រុមគ្រួសារនៅក្នុងភូមិ ឬក្រុមរបស់ភូមិ ឬឃុំ។ នៅក្នុងទស្សនទាននៃផែនការរៀបចំដែនដីខេត្ត យើងគិតទៅលើតែហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្រប្រភេទទី២ទេ។ ប្រព័ន្ធធារាសាស្ត្រទាំងនេះពាក់ព័ន្ធទៅនឹងហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ រួមមានប្រភពទឹកដែលមានលំនឹង(ស្ថេរភាព) (ស្ទឹង/ទន្លេឬអាងស្តុបទឹក) ផ្នែករូបវន្ត(ទ្វារទឹក) ដែលកំណត់ការបញ្ជូនទឹកចេញពីអាងស្តុបទឹកទៅកាន់តំបន់ដែលត្រូវស្រោចស្រពតាមរយៈប្រព័ន្ធប្រឡាយខ្វាត់ខ្វែង។

**ទិន្នន័យដែលត្រូវការ**

***ទិន្នន័យចាំបាច់***

- ទីតាំងបណ្ដាញ/ប្រព័ន្ធធារាសាស្ត្រសំខាន់ៗ និង ព័ត៌មានអំពីប្រភពទឹក ប្រឡាយសំខាន់ និង ទ្វារទឹក (ចែកចាយទឹក) និងកន្លែងដែលត្រូវស្រោចស្រព

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ទីតាំងលម្អិត និងការរៀបរាប់ពីប្រឡាយដែលបែកចេញទី២ ទី៣ដែលនាំយកទឹកដល់ទីតាំងដី

**ការវិភាគ និងលទ្ធផល**

- ផលិតផែនទីទីតាំងប្រព័ន្ធធារាសាស្ត្រសំខាន់ៗរួមមាន អាងស្តុបទឹក ទ្វារទឹក(ចែកចាយទឹក) និងកន្លែងដែលត្រូវស្រោចស្រព (ទំហំផ្ទៃដីកសិម្មដែលទទួលបានផលប្រយោជន៍ពីទឹក)។
- កំណត់លក្ខណៈសម្បត្តិប្រព័ន្ធធារាសាស្ត្រនីមួយៗទៅតាមប្រភពទឹករបស់វា (ពីស្ទឹង អាងស្តុកទឹក ...)។
- ពិភាក្សាពីសក្តានុពលទីតាំងសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកសំខាន់ៗ។
- ផលិតផែនទី និងពិពណ៌នាពីទីតាំង ប្រភេទ និងស្ថានភាពនៃការគ្រប់គ្រងទឹកជំនន់សំខាន់ៗ និងការការពារហេដ្ឋារចនាសម្ព័ន្ធ (ទំនប់ របាំងទឹក)។
- ពិភាក្សាពីតម្រូវការសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹកជំនន់នាពេលអនាគត ដោយផ្អែកទៅ លើតំបន់ដែលបានកំណត់ថាជាតំបន់ងាយរងគ្រោះពីទឹកជំនន់ និង " ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ" (ដូចជា មន្ទីរពេទ្យ និងបរិក្ខារមួយចំនួនដែលប្រហាក់ប្រហែលគ្នានេះ ក៏ដូចជាផ្លូវនានាទៅកាន់ហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗទាំងនោះ ឬផ្លូវនានាដែលមានមុខងារតភ្ជាប់សំខាន់ៗនៅក្នុងខេត្ត)។




**ផែនទី ២០៖** ទីតាំងបណ្តាញ/ប្រព័ន្ធធារាសាស្រ្តផ្សេងៗគ្នាក្នុងខេត្តកំពង់ឆ្នាំង

## ជាជម្រើស

- ផលិតផែនទីលម្អិតស្តីអំពីប្រព័ន្ធ/បណ្តាញធារាសាស្រ្ត បង្ហាញពីឋានានុក្រមរបស់ប្រឡាយ និង វិភាគថាតើប្រព័ន្ធ/បណ្តាញធារាសាស្រ្តទាំងនោះនឹងអាចធ្វើឲ្យប្រសើរឡើងដោយរបៀបណា។

## ហេដ្ឋារចនាសម្ព័ន្ធ និងការផ្គត់ផ្គង់ថាមពល

ការផ្គត់ផ្គង់ថាមពល ជាពិសេសនៅតំបន់ជនបទ គឺជាកត្តាដ៏សំខាន់មួយក្នុងការធ្វើឲ្យប្រសើរឡើង និងអភិវឌ្ឍន៍ប្រទេសកម្ពុជាជាពិសេសធ្វើឲ្យប្រសើរឡើងដល់កម្រិតជីវភាព(ស្តង់ដា)នៃការរស់នៅដល់ ការអភិវឌ្ឍឧស្សាហកម្មខ្នាតតូច/មធ្យម/ធំ និងសម្រាប់អភិវឌ្ឍន៍កសិកម្មនៅក្នុងខេត្ត។ ខណៈដែលការ ទទួលបានការផ្គត់ផ្គង់ថាមពលនៅថ្នាក់មូលដ្ឋាន គឺត្រូវតែដោះស្រាយតាមផែនការនៅថ្នាក់ក្រោម (មូលដ្ឋាន) ការតភ្ជាប់ខេត្តទៅនឹងបណ្តាញខ្សែភ្លើងចែកចាយ និងរោងចក្រផលិតថាមពលសំខាន់ៗ ក្នុងខេត្ត (រោងចក្រ ឬទំនប់វារីអគ្គីសនី) ត្រូវកំណត់ឲ្យច្បាស់លាស់ដើម្បីផ្តល់ព័ត៌មានដល់ថ្នាក់ក្រោម។

## ទិន្នន័យដែលត្រូវការ

### *ទិន្នន័យចាំបាច់*

- ទីតាំង និងសមត្ថភាពខ្សែ (បណ្តាញ) ផ្ទេរថាមពល
- ទីតាំងកន្លែងផលិតថាមពល

### *ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)*

- តំបន់មានអគ្គីសនីប្រើប្រាស់

## ការវិភាគ និងលទ្ធផល

- កំណត់ពីទីតាំង និងសារៈសំខាន់នៃប្រភពផ្គត់ផ្គង់អគ្គីសនីដែលមានស្រាប់ និងនៅក្នុងផែនការនៅក្នុងខេត្ត (ខ្សែចែកចាយអគ្គីសនី រោងចក្រអគ្គីសនី ទំនប់វារីអគ្គីសនី)។
- ពិភាក្សាពីតម្រូវការនិងសក្តានុពលសម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថាមពលនាពេលអនាគតនៅក្នុងកម្រិតថ្នាក់ខេត្ត។ នៅពេលដែលបានកំណត់កន្លែងដែលការផ្គត់ផ្គង់ថាមពលមានការខ្វះចន្លោះហើយបានកំណត់ទីតាំងសម្រាប់សាងសង់រោងចក្រថាមពលអគ្គីសនី ឬទំនប់វារីអគ្គីសនីហើយនោះ ត្រូវគិតគូរពិចារណាពីសក្តានុពលផលប៉ះពាល់ផ្នែកបរិស្ថាននិងសង្គម ហើយត្រូវចងចាំថារាល់ការសាងសង់ត្រូវឆ្លងកាត់ការវាយតម្លៃផលប៉ះពាល់ផ្នែកបរិស្ថាន និងសង្គមឲ្យបានហ្មត់ចត់។




**ផែនទី២១៖** ទីតាំងបណ្តាញអគ្គីសនីដែលមានស្រាប់នៅក្នុងខេត្តបាត់ដំបង

**ជាជម្រើស**

- កំណត់តំបន់ និងប្រជាពលរដ្ឋដែលទទួលប្រើប្រាស់ថាមពលអគ្គីសនីពីប្រភពផ្សេងៗគ្នា។
- កំណត់តំបន់ដែលគ្មានអគ្គីសនីប្រើប្រាស់ ហើយពិភាក្សាបញ្ហាប្រឈមទៅនឹងការផ្គត់ផ្គង់ថាមពលអគ្គីសនីនៅក្នុងតំបន់ទាំងនោះ (ប្រភេទ ប្រភព បញ្ហាប្រសិនបើមាន)។

### ឆ) ស្ថានភាពសេដ្ឋកិច្ចខេត្ត (Economic Profile)

**ការពាក់ព័ន្ធ៖** ផែនការរៀបចំដែនដីមានគោលបំណងធ្វើឲ្យប្រសើរឡើងដល់ជីវភាពរស់នៅរបស់ប្រជាជន ដូច្នេះការវិភាគពីទម្រង់សេដ្ឋកិច្ចដែនដីខេត្តគឺជាការងារដ៏សំខាន់មួយ។ វាមានសារៈសំខាន់ណាស់ក្នុងការពិនិត្យពីចរន្តសេដ្ឋកិច្ចមកពីគ្រប់ទិសទី ដូច្នេះយើងអាចយល់ពីកត្តាដែលជួយលើកស្ទួយ និងកត្តាដែលបង្អាក់ដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

**រចនាសម្ព័ន្ធ និងការអភិវឌ្ឍសេដ្ឋកិច្ច**

ការវិភាគទូទៅនៃសេដ្ឋកិច្ចរបស់ខេត្ត ដោយចាប់ផ្ដើមជាមួយនឹងការវិភាគពីផលិតផលក្នុងស្រុកសរុប (GDP) របស់ខេត្ត និងផលិតផលក្នុងស្រុកសរុប (GDP) សម្រាប់មនុស្សម្នាក់ ដើម្បីស្វែងយល់ពីស្ថានភាពសេដ្ឋកិច្ចរបស់ខេត្ត។ ហើយវាក៏មានសារៈសំខាន់ណាស់ដែរក្នុងស្វែងយល់ថាតើវិស័យណាខ្លះដែលមានការពាក់ព័ន្ធសំខាន់ៗនៅក្នុងខេត្ត ដែលទាំងនេះជាមាគ៌ាជួយចង្អុលបង្ហាញដល់ការវិភាគវិស័យសេដ្ឋកិច្ច។

**ទិន្នន័យដែលត្រូវការ**

***ទិន្នន័យចាំបាច់***

- GDP ខេត្ត និង GDP សម្រាប់មនុស្សម្នាក់
- GDP ខេត្ត និងផលិតភាពតាមវិស័យ
- GDP សម្រាប់មនុស្សម្នាក់សម្រាប់កម្រិតថ្នាក់ស្រុក
- GDP ស្រុក និងផលិតភាពតាមវិស័យ

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ទិន្នន័យទៅតាមដំណាក់កាលពេលវេលានៃ GDP ខេត្ត និងស្រុក GDPសម្រាប់មនុស្សម្នាក់ និង តាមវិស័យ

**ការវិភាគនិងលទ្ធផលរំពឹងទុក**

- ពិភាក្សា និងពិពណ៌នាពីលក្ខណៈសម្បត្តិសេដ្ឋកិច្ចសំខាន់ៗរបស់ខេត្ត (ជាមួយនឹងតួនាទីរបស់វានៅក្នុងរូបភាពទូលំទូលាយមួយនៃប្រទេសកម្ពុជា)ទៅនឹងខេត្តជុំវិញ និងជាពិសេសទៅនឹងវិស័យសេដ្ឋកិច្ចផ្សេងៗគ្នា។ កំណត់ពីទំនាក់ទំនងគ្នារបស់វិស័យផ្សេងៗគ្នាដើម្បីកំណត់កន្លែងដែលនឹងត្រូវធ្វើការវិភាគលម្អិតបន្ថែម ទៀត។
- ស្វែងយល់ពី GDP និងផលិតភាពតាមវិស័យ។ ពិភាក្សាថាតើការបង្ហាញព័ត៌មាននៅលើផែនទីវាកាន់តែល្អប្រសើរ ឬក៏ប្រើប្រាស់ត្រឹមដ្យាក្រាមវាគ្រប់គ្រាន់ហើយ។

**ជាជម្រើស**

- ដើម្បីទទួលបាននូវការយល់ដឹងដ៏ល្អប្រសើរមួយពីទំនោរនៃការប្រែប្រួលផ្នែកសេដ្ឋកិច្ចយើងអាចធ្វើការ ប្រមូលផ្តុំនិងវិភាគទិន្នន័យទៅតាមដំណាក់កាលនៃពេលវេលា។

**ការងារ**

ស្ថានភាពការងាររបស់ប្រជាជន គឺជាទិសដៅយ៉ាងសំខាន់មួយដែលអ្នកធ្វើផែនការត្រូវធ្វើការស្វែងយល់ ដោយវាបង្ហាញពីទំនាក់ទំនងគ្នានៃឱកាសសេដ្ឋកិច្ច និងការអភិវឌ្ឍសម្រាប់ប្រជាជនមូលដ្ឋាន។ វិស័យផ្សេងៗដែលផ្តល់ឱកាសការងារនៅមូលដ្ឋាន គឺមធ្យោបាយដ៏សំខាន់សម្រាប់យុទ្ធសាស្ត្រក្នុងការដោះស្រាយដល់ការអភិវឌ្ឍជនបទ និងការធ្វើចំណាកស្រុកពីជនបទទៅទីក្រុង។ ទិន្នន័យជាតិស្តីពីការងារគឺមិនសូវមានបច្ចុប្បន្នភាពនោះទេប៉ុន្តែមានទិន្នន័យមួយចំនួនដែលគួរយកចិត្តទុកដាក់គួរឲ្យកត់សំគាល់បំផុតនោះគឺទិន្នន័យជំរឿន។ ព័ត៌មានស្តីពីការងារនៅក្នុងទិន្នន័យជំរឿនគឺត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកទៅលើការធ្វើចំណាត់ថ្នាក់ការងារ ដែលទទួលស្គាល់យ៉ាងទូលំទូលាយដោយអង្គការសហប្រជាជាតិផ្នែកស្ថិតិ (the UN Statistics division) (http://unstats.un.org/unsd/cr/registry/)។

**ទិន្នន័យដែលត្រូវការ**

***ទិន្នន័យចាំបាច់***

- ស្ថានភាពការងារទូទៅក្នុងស្រុកនីមួយៗដែលមាននៅក្នុងខេត្ត

***ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)***

- ចំណូលក្នុងគ្រួសារ ទិន្នន័យភាពក្រីក្រ

**ការវិភាគ និងលទ្ធផល**

- វាយតម្លៃពីរបាយប្រជាពលរដ្ឋសកម្មទៅតាមប្រភេទមុខរបរសំខាន់ និងស្ថានភាពការងារ។ ធ្វើផែនទី និងរៀបរាប់ពីរបាយការងារសំខាន់ៗទៅតាមទីតាំងនៅក្នុងខេត្ត។ ធ្វើការប្រៀបធៀប និងសម្រេចចិត្តដោយផ្អែកលើសេចក្តីសន្និដ្ឋានជាសក្តានុពលទាំងនោះ ថាតើការកសាងផែនទីស្តីពីឱកាសការងារនៅតាមថ្នាក់ស្រុក ឬមួយនៅតាមថ្នាក់ឃុំមួយណាដែលអាចមានសារៈសំខាន់ជាង។
- ពិភាក្សាពីឌីណាមិកនៃការបង្កើតការងារនៅក្នុងខេត្តៈ វិស័យដែលបង្កើតការងារដោយខ្លួនឯង វិស័យដែលស្រូបយកកម្លាំងពលកម្ម និងវិស័យដែលកំពុងធ្លាក់ចុះកម្លាំងពលកម្ម។
- ពិភាក្សាពីចល័តភាពរបស់ប្រជាជនរកការងារធ្វើ។
- ពិភាក្សាពីកម្លាំងចលករនៃចំណាកស្រុកនិងចំណូលស្រុករកការងារធ្វើនៅក្នុង/ក្រៅខេត្ត(ឬប្រទេស)។

<u>**ជាជម្រើស**</u>

- ទិន្នន័យពីចំណូលរបស់គ្រួសារ និងភាពក្រីក្រ អាចបំពេញបន្ថែមទៅលើព័ត៌មានស្ដីពីការអាចទទួលបានការងារធ្វើ។ ទិន្នន័យទាំងនេះបំពេញបន្ថែមទៅលើទិដ្ឋភាពរួមមួយអំពីសេដ្ឋកិច្ចមូលដ្ឋានដែលកើតចេញពីទស្សនទានរបស់ប្រជាជនមូលដ្ឋាន។




**ផែនទី២២៖** សារៈសំខាន់និងរបាយប្រភេទមុខរបរ (តាមឃុំ និងតាមវិស័យសំខាន់ៗ) ក្នុងខេត្តកំពង់ឆ្នាំង

## វិស័យសេដ្ឋកិច្ចដែលបានជ្រើសរើស

គួរធ្វើការវិភាគនូវវិស័យពាក់ព័ន្ធផ្សេងៗនៅក្នុងខេត្តឲ្យបានលម្អិត ជាពិសេសក្នុងស្វែងយល់ពីកត្តាទីតាំងភូមិសាស្ត្រដែលមានផលចំណេញ ឬក៏បង្អាក់ដល់ផលិតភាពរបស់វិស័យទាំងនោះ។ កសិកម្មជាវិស័យមួយដែលមានសារៈសំខាន់ខ្លាំងនៅក្នុងខេត្តផ្សេងៗជាច្រើន ជាពិសេសនោះ វាបានផ្ដល់នូវការងារដូចដែលបានលើកឡើងហើយនៅក្នុងជំពូកស្ដីពីការប្រើប្រាស់ដី។ ហើយមានវិស័យពាក់ព័ន្ធសំខាន់ផ្សេងៗទៀតដូចជាវិស័យ ពាណិជ្ជកម្ម និងជំនួញ ឧស្សាហកម្ម (មានជាឧទាហរណ៍ក្នុងផែនទី ២៣) ក៏ដូចជាវិស័យទេសចរណ៍ និងការកំសាន្ត (មានជាឧទាហរណ៍ក្នុងផែនទី ២៤)។ វិស័យទាំងនេះគួរតែធ្វើការវិភាគពាក់ព័ន្ធជាមួយនឹងផលិតភាពសេដ្ឋកិច្ច និងការចូលរួមចំណែករបស់វាក្នុងការបង្កើតឱកាសការងា រនិងតម្រូវការទីតាំង និងការផ្ដល់បរិក្ខារ(សេវាកម្ម) របស់វាដែលអាចជា

កត្តាដែលជួយសម្រួល ឬក៏ជាកត្តាឧបសគ្គ និងអាចជាសក្តានុពល និងផលប៉ះ ពាល់ (ទាំងវិជ្ជមាន និង អវិជ្ជមាន) ជាពិសេសសម្រាប់វិស័យឧសហ្សាហកម្ម។




**ផែនទី២៣៖** សារៈសំខាន់ និងរបាយប្រភេទមុខរបរ (តាមវិស័យឧស្សាហកម្ម និងតាមថ្នាក់ស្រុក) ក្នុងខេត្តបាត់ដំបង




**ផែនទី២៤ ៖** ទីតាំងតំបន់ទាក់ទាញទេសចរណ៍សំខាន់ៗក្នុងខេត្តបាត់ដំបង

## តំបន់សេដ្ឋកិច្ចពិសេស

តំបន់សេដ្ឋកិច្ចពិសេស ជាតំបន់ដែលរៀបចំឡើងដើម្បីលើកស្ទួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច។ ដោយទី តាំងនិងមធ្យោបាយទៅកាន់តំបន់នេះនឹងមានឥទ្ធិពលទាក់ទាញអ្នកវិនិយោគ ការកំណត់តំបន់សេដ្ឋកិច្ចពិសេសដ៏សមស្រប គួរតែបញ្ចូលទៅក្នុងដំណើរការកសាងផែនការរៀបចំដែនដី។ ហើយកិច្ចការនេះគួរសិក្សាពីការកាត់បន្ថយហានិភ័យនៃការកើតទំនាស់ ដែលទាក់ទងនឹងការទាមទារការកាន់កាប់ដីធ្លីត្រួតស៊ីគ្នា។ នៅក្នុងចំណុចនេះ ការវិភាគគឺផ្តោតជាសំខាន់ទៅលើស្ថានភាពជាក់ស្តែង (បច្ចុប្បន្ន) របស់តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងខេត្ត។

## ទិន្នន័យដែលត្រូវការ

### *ទិន្នន័យចាំបាច់*

- ទីតាំងតំបន់សេដ្ឋកិច្ចពិសេស (ប្រសិនបើមាន)

### *ទិន្នន័យបន្ទាប់បន្សំ (ជាជម្រើស)*

- ផែនការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស (ប្រសិនបើមាន)

## ការវិភាគ និងលទ្ធផល

- ផលិតផែនទី និងពិពណ៌នាពីតំបន់សេដ្ឋកិច្ចពិសេសនៅក្នុងខេត្ត។ ស្វែងយល់ និងប្រមូលព័ត៌មានពីសេវាកម្មនិងដំណើរការផលិតកម្មកើតចេញពីតំបន់សេដ្ឋកិច្ចពិសេស និងសារៈសំខាន់ និងការពាក់ព័ន្ធផ្សេងៗទៀតសម្រាប់ការអភិវឌ្ឍខេត្ត។
- ពិភាក្សាពីប្រសិទ្ធភាពរបស់តំបន់សេដ្ឋកិច្ចពិសេស និងកត្តាផ្សេងៗជាពិសេសទាក់ទងនឹងទីតាំងដែលជាកត្តាដែលអាចជួយជម្រុញ ឬបង្អាក់ដល់តំបន់សេដ្ឋកិច្ចពិសេស។
- ពិភាក្សាពីតម្រូវការទីតាំង (ភូមិសាស្ត្រ) និងមធ្យោបាយធ្វើឲ្យប្រសើរឡើងដល់ប្រសិទ្ធភាពតំបន់សេដ្ឋកិច្ចពិសេស។
- ពិភាក្សាពីសក្តានុពលផលប៉ះពាល់អវិជ្ជមានរបស់តំបន់សេដ្ឋកិច្ចពិសេសនៅក្នុងខេត្ត។

## ជាជម្រើស

- វិភាគពីស្ថានភាព និងការគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេស (ចំណុចខ្លាំង និងចំណុចខ្សោយ)។
- ពិភាក្សាពីតម្រូវការ និងសក្តានុពលសម្រាប់តំបន់សេដ្ឋកិច្ចពិសេសនាពេលអនាគតនៅក្នុងខេត្ត ត្រូវចងចាំ និងគិតអំពីផលប៉ះពាល់ (ជាសក្តានុពល) ផ្នែកបរិស្ថាន និងសង្គម។

## ការងារ ២.៣ ការពិនិត្យផ្ទៀងផ្ទាត់នៅថ្នាក់ស្រុក សិក្ខាសាលាវិភាគ និងធ្វើបច្ចុប្បន្នភាព

### ស្ថានភាពទូទៅ

ការងារនេះផ្តោតសំខាន់ទៅលើការពិភាក្សាជាមួយថ្នាក់ស្រុក ដើម្បីទាញយកនូវចំណេះដឹងអំពីទិន្នន័យនិងការអភិវឌ្ឍដែនដីនៅក្នុងយុត្តាធិការរបស់ស្រុក។ទិន្នន័យគោលពាក់ព័ន្ធសំខាន់ៗដូចជា (១) ការប្រើប្រាស់ដី (២) ការទទួលបានសេវាសង្គម និង(៣) រចនាសម្ព័ន្ធសេដ្ឋកិច្ច នឹងត្រូវធ្វើការពិនិត្យជាមួយអ្នកពាក់ព័ន្ធនៅកម្រិតថ្នាក់ស្រុក ហើយធ្វើបច្ចុប្បន្នភាព ឬធ្វើការកែតម្រូវចំពោះទិន្នន័យចាស់ៗ ឬមិនសុក្រឹត្យដែលនឹងត្រូវយកមកប្រើប្រាស់។ កិច្ចការងារពិនិត្យទៅលើទិន្នន័យទាំងអស់នេះជួយឲ្យយើងទទួលបាននូវទិន្នន័យដែលអាចទុកចិត្តបាន ក្នុងការយកមកប្រើប្រាស់សម្រាប់កសាងផែនការរៀបចំដែនដីខេត្ត។

សិក្ខាសាលាផ្សេងៗបន្ថែមទៀត មានគោលបំណងធ្វើការកំណត់ និងស្វែងយល់ពីការប្រែប្រួល (ទំនោរនៃការប្រែប្រួល) ក្នុងទីតាំងដែនដីភូមិសាស្ត្រទៅលើប្រធានបទទិន្នន័យគោលពាក់ព័ន្ធសំខាន់ៗទាំងបីខាងលើ និងពិភាក្សាពីផលវិបាក និងកម្លាំងចលករដែលនាំឲ្យមានការប្រែប្រួលទាំងនោះក៏ដូចជាពិភាក្សាពីសមត្ថភាពស្ថាប័ននៅថ្នាក់ស្រុកក្នុងការដោះស្រាយដល់ផលវិបាក និងកម្លាំងចលករដែលបានរកឃើញ។

ស្រុកនៅតាមជនបទភាគច្រើននៅក្នុងប្រទេសកម្ពុជានឹងត្រូវធ្វើការយកចិត្តទុកដាក់ជាពិសេសទៅលើការគ្រប់គ្រង និងការប្រែប្រួលការប្រើប្រាស់ដីធ្លីដោយវាជាធនធានដ៏សំខាន់នៅក្នុងស្រុកទាំងនោះ។ក្នុងដំណាក់កាលនេះ វាក៏ត្រូវធ្វើការវិភាគពីហេដ្ឋារចនាសម្ព័ន្ធផ្លូវដើម្បីឈានទៅដល់ការវិភាគពីរចនាសម្ព័ន្ធសេដ្ឋកិច្ច ហើយការវិភាគនេះវាក៏ចូលរួមគាំទ្រដល់ការវិភាគពីការទទួលបានសេវាសង្គមផងដែរ។ដូច្នេះហើយ វាទាមទារនូវការចំណាយ និងពេលវេលាច្រើនសម្រាប់សិក្ខាសាលានៅក្នុងស្រុកទាំងនេះដោយអាស្រ័យទៅលើទំហំការងារ (ឧ.ប្រហែលជាត្រូវចំណាយពេលពេញមួយថ្ងៃសម្រាប់ការវិភាគពីហេដ្ឋារចនាសម្ព័ន្ធផ្លូវ)។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកផ្តួចផ្តើម និងអនុវត្ត
  - ក្រុមការងារខេត្ត
  - ដាតាបេស/អ្នកជំនាញ GIS
- អ្នកដែលត្រូវចូលរួម/ធ្វើការពិភាក្សា
  - អាជ្ញាធរស្រុក (ក្រុមប្រឹក្សា ការិយាល័យអភិបាលស្រុក)
  - ការិយាល័យជំនាញជុំវិញស្រុក
  - មេឃុំ
  - អ្នកពាក់ព័ន្ធផ្សេងៗទៀតក្នុងស្រុក (សមាគម អង្គការក្រៅរដ្ឋាភិបាលជាដើម។ល។)

**សកម្មភាព/វិធីសាស្ត្រ**

- រៀបចំសិក្ខាសាលានៅតាមស្រុកនីមួយៗ ដោយមានការចូលរួមពីអ្នកពាក់ព័ន្ធសំខាន់ៗនៅក្នុងស្រុក ពីស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ និងតំណាងក្រុមប្រឹក្សាឃុំ (ប្រសិនបើបាន)។ ក៏ត្រូវគិតឲ្យបានហ្មត់ចត់ពីការចូលរួមរបស់អ្នកពាក់ព័ន្ធមកពីស្រុកដ៏ទៃទៀតដែរ ឧទាហរណ៍ដូចជាតំណាងសហគមន៍ជនជាតិដើម អ្នកផលិតស្បៀង សហគ្រិន និងអ្នកកាន់កាប់ដីទាំងផ្លូវការ និងមិនផ្លូវការនៅក្នុងស្រុក (រួមទាំងវិស័យឯកជន និងសង្គមស៊ីវិល)។
- រៀបចំដំណើការចងក្រងបកប្រែរូបថតពីលើអកាស រូបថតផ្កាយរណប ផែនទីដែលពាក់ព័ន្ធដោយប្រើប្រាស់រួមគ្នានឹងចំណេះដឹងដែលទទួលបានមកពីអ្នកពាក់ព័ន្ធទាំងអស់ ដោយសារអ្នកពាក់ព័ន្ធទាំងអស់នោះមានចំណេះដឹងយ៉ាងល្អប្រសើរអំពីបញ្ហាគ្រប់គ្រងដីធ្លីនៅមូលដ្ឋាន។
- វិភាគទៅលើប្រធានបទសំខាន់ៗនីមួយៗដោយប្រើប្រាស់វិធីសាស្ត្រដូចខាងក្រោម៖
    - បង្ហាញទិន្នន័យដែលមានស្រាប់នៅលើផែនទី (ឧ. ផែនទីប្រើប្រាស់ដីបច្ចុប្បន្ន)
    - ពិនិត្យ និងធ្វើបច្ចុប្បន្នភាពព័ត៌មាននៅលើផែនទី។
    - កំណត់តំបន់/ផ្នែក នៅលើរូបថតពីលើអាកាស (ឧ. ផ្នែក/តំបន់ប្រើប្រាស់ដី)។
    - កំណត់ និងស្វែងយល់ពីការប្រែប្រួលដែលមានការពាក់ព័ន្ធ (ឧ. ការប្រែប្រួលការប្រើប្រាស់ដី) និង បញ្ហានៃការគ្រប់គ្រង។
    - ពិភាក្សាពីកម្លាំងចលករ និងផលវិបាកក៏ដូចជាសមត្ថភាពរបស់ស្រុកក្នុងការដោះស្រាយឆ្លើយតបទៅនឹងកម្លាំងចលករ និងផលវិបាកទាំងនោះ។
- គុណភាព និងភាពពេញលេញគ្រប់គ្រាន់នៃឯកសារលទ្ធផលនៃការពិភាក្សានេះ នឹងត្រូវធ្វើការពិភាក្សាជាមួយនឹងក្រុមការងារខេត្ត មុននឹងយកទិន្នន័យថ្នាក់ស្រុកទាំងនោះទៅប្រើប្រាស់បញ្ចូលទៅក្នុងកម្រិតថ្នាក់ស្រុកនៅក្នុងជំហានបន្ទាប់។
- **គន្លឹះសំខាន់៖** ការងារដែលបានរៀបរាប់ខាងលើនេះ ត្រូវការពេលវេលាច្រើន និងទាមទារនូវការរៀបចំ និងការសម្របសម្រួលឲ្យបានល្អ។ បច្ចុប្បន្នភាពការប្រើប្រាស់ដី និងបណ្ដាញផ្លូវនឹងជួយដល់ការពិភាក្សាអំពីរចនាសម្ព័ន្ធសេដ្ឋកិច្ច និងការផ្ដល់សេវាសង្គម ដូច្នេះវាត្រូវធ្វើការដោះស្រាយជាមុន។ ប្រហែលជាត្រូវការចំណាយពេលប្រមាណជា៣ថ្ងៃសម្រាប់ការងារនេះទាំងមូល (មួយថ្ងៃសម្រាប់ការវិភាគនិងធ្វើបច្ចុប្បន្នភាពប្រើប្រាស់ដី មួយថ្ងៃសម្រាប់ការវិភាគនិងធ្វើបច្ចុប្បន្នភាពប្រព័ន្ធផ្លូវ កន្លះថ្ងៃសម្រាប់វិភាគពីរចនាសម្ព័ន្ធសេដ្ឋកិច្ច និងកន្លះថ្ងៃទៀតសម្រាប់វិភាគពីសេវាសង្គម)។ ដើម្បីចំណេញពេលនោះ យើងអាចរៀបចំសិក្ខាសាលារួមគ្នាមួយជាមួយស្រុកដែលនៅជាប់គ្នា ដែលសិក្ខាសាលានេះអាចឲ្យអ្នកចូលរួមទាំងអស់សិក្សានិងផ្លាស់ប្ដូរចំណេះដឹងទាក់ទងទៅនឹងបញ្ហា និងសក្ដានុពលរវាងស្រុកទាំងនោះ(អន្តរស្រុក)។ អ្នកចូលរួមមកពីស្រុកទាំងអស់ត្រូវបើកចិត្តទូលាយ និងចូលរួមក្នុងការពិភាក្សា ហើយសិក្ខាសាលារួមគ្នាជាមួយស្រុកច្រើននេះ ក៏អាចនាំឲ្យកើតមានបញ្ហានៃការសម្របសម្រួលបន្ថែមផងដែរ។

## ក) ការប្រើប្រាស់ដី

**១. ធ្វើបទបង្ហាញពីបច្ចុប្បន្នភាពប្រើប្រាស់ដីដល់អ្នកពាក់ព័ន្ធមកពីថ្នាក់ស្រុក៖** ក្នុងកំឡុងពេលសិក្ខាសាលាថ្នាក់ស្រុក ផែនទីប្រើប្រាស់ដី (ដែលបានធ្វើបច្ចុប្បន្នភាពហើយ) ត្រូវធ្វើការបង្ហាញ និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធ ទាំងអស់។

**២. ធ្វើការកំណត់ និងធ្វើបច្ចុប្បន្នភាពការប្រើប្រាស់ដីបន្ថែមទៀត៖** អ្នកចូលរួមគ្រប់រូបមកពីវិស័យផ្សេងៗ ត្រូវបានអញ្ជើញឲ្យធ្វើការពិនិត្យទៅលើផែនទីប្រើប្រាស់ដី ដើម្បីស្វែងយល់និងណែនាំតម្រង់ទិសឲ្យបានសមស្រប។ អ្នកចូលរួមម្នាក់ៗ ក៏នឹងត្រូវអញ្ជើញឲ្យពិភាក្សាផ្តល់នូវបច្ចុប្បន្នភាពព័ត៌មានពីស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្ន។ ការពិភាក្សានេះ ត្រូវធ្វើការរៀបចំជាមុន ហើយគួរធ្វើការរៀបចំ និងកំណត់ឲ្យបានច្បាស់ជាមុនផងដែរនូវព័ត៌មានគោលដៅ (ដែលត្រូវការ)។ ចំពោះការរៀបចំសម្រាប់ការពិភាក្សានេះ វាគួរតែប្រើប្រាស់នូវក្រដាសកាលស្តើងដែលអាចមើលធ្លុះ (អាចជាផ្លាស្ទិចថ្លា) ដាក់ពីលើផែនទីដែលអាចឲ្យអ្នកចូលរួមទាំងអស់គូរពីលើវាបានដោយ ប៊ិចហ្វឺត។

**៣. ការកំណត់ផ្នែក/តំបន់ប្រើប្រាស់ដី៖** ផ្អែកលើការពិភាក្សាពីបច្ចុប្បន្នភាព អ្នកចូលរួម កំណត់នូវផ្នែក/តំបន់ប្រើប្រាស់ដីផ្សេងៗគ្នា។ តំបន់ទាំងនេះវាអាចជាប្រភេទប្រើប្រាស់ដីដែលតំណាងជាទូទៅមួយ ប៉ុន្តែវាមានទម្រង់ សណ្ឋានប្រើប្រាស់ដីមានលក្ខណៈដាច់ផ្សេងគ្នាច្បាស់លាស់ ដូចជាតំបន់លំនៅឋាន តំបន់លិចទឹក ព្រៃឈើកសិ រុក្ខកម្ម (ចម្រុះ) ស្រែ និងចំការជាដើម។ល។

**៤. ការវិភាគការប្រែប្រួលការប្រើប្រាស់ដី និងធ្វើបច្ចុប្បន្នភាពការប្រើប្រាស់ដីលើកទី២៖** ការធ្វើបច្ចុប្បន្នភាព និងវិនិច្ឆ័យពីស្ថានភាពប្រើប្រាស់ដីបច្ចុប្បន្នក្នុងកំឡុងពេលធ្វើសិក្ខាសាលាថ្នាក់ស្រុក នឹងផ្តល់ឲ្យក្រុមការងារថ្នាក់ខេត្តនូវព័ត៌មានប្រើប្រាស់ដីនៅក្នុងកម្រិតថ្នាក់ស្រុកទៅតាមឆ្នាំខុសៗគ្នា។ ព័ត៌មានប្រើប្រាស់ដីទៅតាមដំណាក់កាលពេលវេលា ជួយឲ្យក្រុមការងារខេត្តឈានទៅដល់ការវិភាគពីការប្រែប្រួលការប្រើប្រាស់ដី(ផែនទី២៥)។ កិច្ចការងារនេះមានសារៈសំខាន់ណាស់ដល់ការកំណត់ពីយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពសម្រាប់ការគ្រប់គ្រងដី ដែលនឹងត្រូវធ្វើឡើងនៅក្នុងជំហានបន្ទាប់នៃដំណើរការកសាងផែនការរៀបចំដែនដីថ្នាក់ខេត្ត។

ជាបឋម ត្រូវពិនិត្យ និងកំណត់ប្រភេទនៃការប្រែប្រួលការប្រើប្រាស់ដីសំខាន់ៗនៅក្នុងស្រុកដូចជា៖

- ការកាប់បំផ្លាញព្រៃឈើ ការរេចរឹលខូចខាតដល់គម្របព្រៃឈើ
- ការពង្រីកតំបន់កសិកម្ម ប្រពលវប្បកម្មនៃផលិតកម្មកសិកម្ម
- ការបង្កើតតំបន់/លំនៅឋានថ្មី ការពង្រីកតំបន់ទីប្រជុំជន
- ការបង្កើត/ពង្រីកឧស្សាហកម្ម
- ការប្រែប្រួលធនធាន/គុណភាពទឹក
- ការប្រែប្រួលការរៀបចំ/គ្រប់គ្រងការកាន់កាប់ដី

ទី ២ នៅពេលដែលប្រភេទនៃការប្រើប្រាស់ដីផ្សេងៗគ្នាត្រូវបានកំណត់ហើយនោះ វាមានសារៈសំខាន់ណាស់ក្នុងការវិភាគ ពីការប្រែប្រួលការប្រើប្រាស់ដីនានាដែលមានជាមួយអ្នកពាក់ព័ន្ធនៅថ្នាក់ស្រុក។ ហើយត្រូវធ្វើការកំណត់ពិភាក្សា និងចងក្រងឯកសារដោយប្រុងប្រយ័ត្នអំពីកម្លាំងចលករនិងផលវិបាកនៃការប្រែប្រួល ទាំងនោះ (តារាង ៣)។

ជាសកម្មភាពចុងក្រោយ អ្នកពាក់ព័ន្ធនៅថ្នាក់ស្រុកទាំងអស់ គួរធ្វើការពិភាក្សាពីសមត្ថភាពរបស់ស្ថាប័ននៅថ្នាក់ស្រុកក្នុងការដោះស្រាយកម្លាំងចលករ និងផលវិបាកនៃការប្រែប្រួលទាំងអស់នោះ (ភាពខ្លាំង និងភាពខ្សោយរបស់ស្ថាប័ននៅថ្នាក់ស្រុក)។ ប្រធានបទតាមវិស័យនានាដែលទាក់ទងនឹងការណែនាំជាគោលនយោបាយដែលទទួលបានពីក្រសួងខ្សែបណ្ដោយរបស់ខ្លួនផងដែរ ដែលមាននៅថ្នាក់ស្រុក(ឬមិនមាន)ដើម្បីដោះស្រាយផលវិបាកនៃការប្រែប្រួលការប្រើប្រាស់ដី ឬកាត់បន្ថយនូវផលវិបាកទាំងនោះ និងការសម្របសម្រួលកិច្ចខិតខំប្រឹងប្រែងជាមួយការិយាល័យពាក់ព័ន្ធមកពីស្រុកដទៃផ្សេងទៀត។







**ផែនទី ២៥ ៖** ការប្រើប្រាស់ដីនៅក្នុងស្រុកបវេល ឆ្នាំ២០០២ និង ២០១០ (ខាងឆ្វេង) និងការប្រែប្រួលការប្រើប្រាស់ដីរវាងឆ្នាំ ២០០២ និង២០១០ (ខាងស្តាំ)

**តារាង២៖** ការចងក្រងឯកសារនៃការប្រែប្រួលការប្រើប្រាស់ដី (សំដៅដល់ផែនទីប្រែប្រួលការប្រើប្រាស់ដីខាងលើ ស្រុកបវេល ខេត្តបាត់ដំបង)

| ប្រភេទនៃការប្រែប្រួលការប្រើប្រាស់ដី | ការប្រែប្រួលការប្រើប្រាស់ដីផ្សេងៗគ្នា* | ផលវិបាក/ផលប៉ះពាល់ | | សមត្ថភាពរបស់ស្ថាប័នថ្នាក់ស្រុកក្នុងការដោះស្រាយជាមួយនឹងការប្រែប្រួល ទាំងនោះ |
|---|---|---|---|---|
| | | **វិជ្ជមាន** | **អវិជ្ជមាន** | |
| ការកាប់រានដីព្រៃឈើសម្រាប់ធ្វើកសិកម្ម | មូលហេតុ (ប្រហាក់ប្រហែល): អន្តោប្រវេសន៍ និងការកាប់ឈើខុសច្បាប់<br><br>មូលហេតុសំខាន់ : ភាពក្រីក្រនៅក្នុងតំបន់ទំនាបកណ្តាល នាំឲ្យមានចំណាកស្រុកទៅកាន់តំបន់ខ្ពង់រាប<br><br>ការគ្រប់គ្រងដីធ្លីដោយទាហានបន្ទាប់ពីសង្គ្រាម | តំបន់អភិវឌ្ឍន៍កសិកម្មថ្មី ការបង្កើននូវឱកាសក្នុងការចិញ្ចឹមជីវិត | ទាញយកផលព្រៃឈើ ការប្រែប្រួលចរន្តខ្សែទឹកហូរ ខ្វះសុវត្ថិភាពកាន់កាប់ដីធ្លី (ដីសាធារណៈរបស់រដ្ឋ យោងទៅតាមច្បាប់ភូមិបាល ២០០១) | បញ្ហាភាគច្រើនលើសពីសមត្ថភាពគ្រប់គ្រងរបស់អាជ្ញាធរស្រុក<br><br>រដ្ឋបាលព្រៃឈើពាក់ព័ន្ធនឹងការការពារព្រៃឈើជាមួយនឹងសហគមន៍ និងដីការបង្កាប់ធ្វើឲ្យប្រសើរឡើងដល់ព្រៃឈើឡើងវិញ ប៉ុន្តែវាមានផលប៉ះពាល់ក្នុងកម្រិតមួយប៉ុណ្ណោះ<br><br>អាជ្ញាធរស្រុកមានការពាក់ព័ន្ធទៅនឹងការកំណត់តំបន់មានសក្តានុពលសម្រាប់សម្បទានដីសង្គមកិច្ច។<br><br>ការដោះស្រាយទំនាស់ដីធ្លីគឺជាកិច្ចការប្រចាំថ្ងៃ ដែលធ្វើឡើងនៅការិយាល័យភូមិបាលស្រុក |

**ខ) ការទទួលបានសេវាសង្គម និងការកំណត់តំបន់ផ្តល់នូវសេវាទាំងនោះ**

សិក្ខាសាលាថ្នាក់ស្រុក គួរមានមុខងារផ្សេងបន្ថែមទៀតក្នុងការបង្ហាញ ផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពទិន្នន័យទីតាំងភូមិសាស្ត្រទាក់ទងទៅនឹងការទទួលបានសេវាសង្គម។ មេឃុំ អភិបាលស្រុក និងការិយាល័យពាក់ព័ន្ធនៅថ្នាក់ស្រុកទាំងអស់ គួរត្រូវបានអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចពិភាក្សានេះ។

**១. <u>ការធ្វើបទបង្ហាញពីការទទួលបានសេវាសង្គម៖</u>** ផែនទីស្តីអំពីសេវាសង្គមផ្សេងៗដែលបានធ្វើឡើងនៅក្នុងការងារ២.២ នឹងត្រូវធ្វើការបង្ហាញ ហើយទំហំនៃការផ្តល់សេវានីមួយៗនៅក្នុងស្រុក នឹងត្រូវធ្វើការពិភាក្សាផងដែរ។

<u>**២. ការពិនិត្យ និងធ្វើបច្ចុប្បន្នភាពនៃការទទួលបានសេវាសង្គម៖**</u> ទីតាំងផ្តល់សេវាសង្គមនៅក្នុងស្រុកនឹងត្រូវធ្វើការពិនិត្យ និងធ្វើបច្ចុប្បន្នភាពប្រសិនបើចាំបាច់។ ត្រូវធ្វើការកំណត់ដល់ការធ្វើឲ្យប្រសើរឡើងដល់ផែនការដែលមានស្រាប់ ឬកំណត់នូវហេដ្ឋារចនាសម្ព័ន្ធសង្គមថ្មី។

<u>**៣. ការកំណត់តំបន់ផ្តល់សេវាសង្គម៖**</u> សេវាសង្គម ស្ថិតនៅក្នុងតំបន់លំនៅឋានក្នុងទីប្រជុំជន ប៉ុន្តែសេវាកម្មរបស់វាមិនមែនគ្រាន់តែផ្តល់ជូនដល់ទីប្រជុំជននោះទេ វាត្រូវផ្តល់ជូនដល់តំបន់ជនបទនៅជុំវិញមួយចំនួនផងដែរដោយអាស្រ័យទៅលើប្រភេទសេវាទាំងនោះ។សម្រាប់សេវាសុខភាពត្រូវធ្វើការផ្តល់សេវាតាមរយៈស្រុកប្រតិបត្តិដែលបានធ្វើការរៀបរាប់ហើយនៅក្នុងដំណាក់កាលការងារមុន។ អ្នកពាក់ព័ន្ធនៅថ្នាក់ស្រុកគួរធ្វើការពិភាក្សាកំណត់ និងធ្វើផែនទីស្តីពីផ្នែកណារបស់ស្រុក និងប្រជាជនណាខ្លះដែលត្រូវបានទទួលសេវាពីមជ្ឈមណ្ឌលទីប្រជុំជនមួយណា។ គួរធ្វើការបែងចែកនូវកម្រិតសេវាពីរផ្សេងគ្នា៖ មួយសម្រាប់សេវាមូលដ្ឋាន (ដូចជាមណ្ឌលសុខភាព សាលាបឋមសិក្សា) និងមួយទៀតសម្រាប់សេវាមានលក្ខណៈប្រសើរជាងនេះ (ដូចជាមន្ទីរពេទ្យបង្អែកស្រុកប្រតិបត្តិ សាលាអនុវិទ្យាល័យផ្សេងៗ) ដែលវាផ្តល់នូវសេវាកម្មគ្របដណ្តប់ដល់តំបន់ធំជាងកម្រិតសេវាកម្មមូលដ្ឋានមុននេះ។ សេវាកម្រិតខ្ពស់ជាងនេះទៀត (ប្រសើរជាងនេះ) នឹងធ្វើការបង្ហាញនៅថ្នាក់ខេត្ត។ដំណាក់កាលចុងក្រោយនៃការងារនេះសម្រាប់លំនៅឋានទាំងអស់នៅថ្នាក់ស្រុក វាគួរច្បាស់លាស់ថាសេវាកម្រិតណា (សេវាកម្រិតថ្នាក់មូលដ្ឋានឬកម្រិតខ្ពស់)ដែលលំនៅឋានទាំងនោះទទួលបាន ហើយអ្វីដែលមជ្ឈមណ្ឌលទីប្រជុំជនធ្វើការដោះស្រាយឲ្យ និងកន្លែងណាដែលសេវាទាំងនេះត្រូវធ្វើការផ្តល់ជូន។

<u>**៤. ការវិភាគពីការផ្តល់សេវា៖**</u> ពិភាក្សា និងចងក្រងឯកសារពីការទទួលបានសមត្ថភាព និងបញ្ហាគ្រប់គ្រង សម្រាប់តំបន់ផ្តល់សេវាដែលបានកំណត់ហើយនីមួយៗ ក៏ដូចជាសមត្ថភាពរបស់ស្ថាប័នថ្នាក់ស្រុកក្នុងការដោះស្រាយចំពោះបញ្ហាដែលបានរកឃើញទាំងនោះ។

### គ) រចនាសម្ព័ន្ធសេដ្ឋកិច្ច និងការធ្វើបច្ចុប្បន្នភាព

សិក្ខាសាលាថ្នាក់ស្រុក គួរត្រូវបានប្រើប្រាស់បន្ថែមទៀតសម្រាប់ធ្វើការបង្ហាញ ផ្ទៀងផ្ទាត់ធ្វើបច្ចុប្បន្នភាព និងវិភាគព័ត៌មានដែលពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ចរបស់ខេត្តនិងស្រុក។ នេះមិនសំដៅដល់ជលផលព្រៃឈើ និងកសិកម្មប្រពលវប្បកម្ម ប៉ុន្តែវាសំដៅដល់បណ្តុំប៉ូលសេដ្ឋកិច្ចនិងច្រកផ្លូវសេដ្ឋកិច្ចតាមរយៈឧស្សាហកម្ម ពាណិជ្ជកម្ម និងទេសចរណ៍ដែលកំពុងតែដំណើរការ។

<u>**១. បទបង្ហាញនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច៖**</u> ធ្វើបទបង្ហាញពីតួនាទីសេដ្ឋកិច្ចរបស់ស្រុកនៅក្នុងខេត្ត វិស័យការងារ និងសេដ្ឋកិច្ចសំខាន់ៗ និងទីតាំងតំបន់ដែលពាក់ព័ន្ធសម្រាប់សេដ្ឋកិច្ចខេត្ត និងស្រុក (ដូចជាមជ្ឈមណ្ឌលទីប្រជុំជន ទីផ្សារ ការិយាល័យ តំបន់សេដ្ឋកិច្ចពិសេស សម្បទានដីសេដ្ឋកិច្ច ឬតំបន់យករ៉ែជាដើម)។

**២. ការផ្ទៀងផ្ទាត់ និងធ្វើបច្ចុប្បន្នភាពរចនាសម្ព័ន្ធសេដ្ឋកិច្ច៖** អញ្ជើញអ្នកពាក់ព័ន្ធធ្វើការពិនិត្យលើផែនទីដែលបង្ហាញពីទីតាំង និងតំបន់បម្រើដល់សេដ្ឋកិច្ច និងតំបន់ផ្សេងៗទៀតនៅក្នុងស្រុក ដូចជាតំបន់សេដ្ឋកិច្ចពិសេស/សម្បទានដី សេដ្ឋកិច្ចថ្មី ឬពង្រីកបន្ថែម និងទីតាំងតំបន់ដែលពាក់ព័ន្ធផ្សេងៗ។

**៣. ការកំណត់បណ្តុំប៉ូល និងច្រកផ្លូវសេដ្ឋកិច្ច ៖** ប៉ូលអភិវឌ្ឍន៍មានស្រាប់ (ដូចជាលំនៅឋានទីប្រជុំជនដែលមានមុខងារសេដ្ឋកិច្ចសំខាន់ៗតំបន់សេដ្ឋកិច្ចពិសេស ឬបណ្តុំការងារផ្សេងៗទៀតដែលពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ច) និងទីតាំងដែលមានការកើនឡើងនូវសក្តានុពលត្រូវបានកំណត់និងធ្វើផែនទីភ្ជាប់ទៅនឹងទីតាំងជាបណ្តុំប៉ូលសេដ្ឋកិច្ចមួយ ហើយវាត្រូវបានធ្វើចំណាត់ថ្នាក់អាស្រ័យទៅតាមមុខងាររបស់វា (ដូចជាមុខងារកសិកម្ម ជំនួញ និងពាណិជ្ជកម្ម ទេសចរណ៍ ឧស្សាហកម្ម ឬក៏ធ្វើការផ្តោតលម្អិតជាងនេះ)។ បណ្តាញសំខាន់ៗ និងបណ្តុំនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តដែលភ្ជាប់ទៅនឹងបណ្តុំប៉ូលសេដ្ឋកិច្ចនេះ នឹងធ្វើឲ្យវាមានដំណើរការ គឺវាកើតឡើងតាមរយៈទីតាំងដែលបានកំណត់និងធ្វើផែនទីជាច្រកផ្លូវសេដ្ឋកិច្ចដែលគួរធ្វើចំណាត់ថ្នាក់ប្រសិនបើមានលក្ខណៈសមស្រប។

**៤.ការវិភាគពីរចនាសម្ព័ន្ធសេដ្ឋកិច្ច៖** ពិភាក្សា និងចងក្រងឯកសារសក្តានុពលសេដ្ឋកិច្ច និងកត្តាដែលជួយឲ្យដំណើរការ និងកត្តាដែលបង្អាក់ដល់បណ្តុំប៉ូល និងច្រកផ្លូវសេដ្ឋកិច្ចដែលបានកំណត់នេះ ក៏ដូចជាសមត្ថភាពរបស់ស្ថាប័ននៅថ្នាក់ស្រុក ក្នុងការដោះស្រាយបញ្ហានិងសក្តានុពលដែលបានរកឃើញ។

ការវិភាគពីច្រកផ្លូវសេដ្ឋកិច្ច គឺត្រូវមានការគាំទ្រយ៉ាងខ្លាំងពីការធ្វើបច្ចុប្បន្នភាព និងការវិភាគហេដ្ឋារចនាសម្ព័ន្ធផ្លូវដែលរៀបរាប់នៅខាងក្រោម។ ហើយការធ្វើបច្ចុប្បន្នភាពនិងវិភាគហេដ្ឋារចនា-សម្ព័ន្ធផ្លូវ ក៏ជួយដល់ការស្វែងយល់ឲ្យបានប្រសើរអំពីបញ្ហាក្នុងការទទួលបានសេវាសង្គមផងដែរ។ ការពិភាក្សាបន្ថែមទៀតអំពីមធ្យោបាយដឹកជញ្ជូនដែលមានស្រាប់ផ្សេងទៀត (ព្រលានយន្តហោះ ផ្លូវដែក) អាស្រ័យទៅលើការពាក់ព័ន្ធនៅមូលដ្ឋាន ប៉ុន្តែការពិភាក្សានេះអាចនឹងមានប្រសិទ្ធភាពជាងប្រសិនបើធ្វើការពិភាក្សានៅថ្នាក់ខេត្ត។

អ្នកចូលរួមដើម្បីធ្វើការវិភាគ និងបច្ចុប្បន្នភាពហេដ្ឋារចនាសម្ព័ន្ធផ្លូវ គួរមានការចូលរួមពីមេភូមិ មេឃុំ និងអ្នកតំណាងពីការិយាល័យអភិវឌ្ឍន៍ជនបទ (ដែលទទួលខុសត្រូវលើផ្លូវស្រុក និងឃុំ) និងសាធារណៈការនិងដឹកជញ្ជូន។ មេភូមិ និងមេឃុំជាទូទៅគាត់មានផែនទីព្រាងគូរដោយដៃសម្រាប់ភូមិឃុំគាត់ ដែលអាចយកមកប្រើប្រាស់បាន និងជួយដល់ការពិភាក្សារបស់គាត់ក្នុងសិក្ខាសាលា។ ក្រុមការងារខេត្តត្រូវយកមកជាមួយនូវផែនទីបណ្តាញផ្លូវដែលមានស្រាប់ និងរូបថតផ្កាយរណបតាមឃុំ ក៏ដូចជាក្រដាសផ្លាស្ទិច ដើម្បីគ្របពីលើផែនទីដែលអាចឲ្យអ្នកចូលរួមធ្វើការពិភាក្សានិងគូរលើផែនទីបាន។

- បង្ហាញពីគោលបំណងនៃកិច្ចប្រជុំ និងពន្យល់វិធីសាស្ត្រ។
- ធ្វើការបែងចែកអ្នកចូលរួមទាំងអស់ទៅជាក្រុមពិភាក្សាតូចៗទៅតាមឃុំរបស់ពួកគាត់ (គួរមានអ្នកសម្របសម្រួលម្នាក់មកពីក្រុមការងារខេត្តជួយធ្វើការសម្របសម្រួលដល់ក្រុមពិភាក្សា)។
- ធ្វើការផ្ទៀងផ្ទាត់ហេដ្ឋារចនាសម្ព័ន្ធផ្លូវដែលមានស្រាប់ (បន្ថែមផ្លូវដែលខ្វះ ហើយលុបចោលផ្លូវដែលលើស) និងគូរផ្លូវគ្រោងថ្មី/ពង្រីកបន្ថែមដែលមានស្រាប់ និងប៉ាន់ប្រមាណពីការវិវត្តរបស់វា។
- កំណត់ពីប្រភេទ និងគុណភាពផ្លូវ (ផ្លូវជាតិ ខេត្ត ស្រុក ឃុំ/ ក្រាលកៅស៊ូ ក្រួសក្រហម ផ្លូវដី) និងស្ថានភាពបច្ចុប្បន្ន។
- បែងចែកចំណាត់ថ្នាក់ប្រភេទផ្លូវ (ស្របទៅតាមអនុក្រឹត្យលេខ ៤២ ឬប្រព័ន្ធចំណាត់ថ្នាក់ជាក់ស្តែងដោយខ្លួនឯង) ។
- កំណត់តំបន់ដែលមានបញ្ហាក្នុងការធ្វើដំណើរ។
- ធ្វើអាទិភាពលើការពង្រីកបណ្តាញផ្លូវនាពេលអនាគត និងការថែរក្សាអាស្រ័យទៅលើ ប្រភេទផ្លូវ និងតម្រូវការព្យាករណ៍សម្រាប់អនាគតទៅតាមការលើកឡើងរបស់មេភូមិ និងមេឃុំ។

**លទ្ធផលរំពឹងទុក**

- បច្ចុប្បន្នភាពដាតាបេសទិន្នន័យទីតាំងភូមិសាស្ត្រក្នុងប្រព័ន្ធកុំព្យូទ័រត្រូវបានរៀបចំឡើង។
- បានធ្វើបច្ចុប្បន្នភាពផែនទី និងការវិភាគផ្សេងៗដែលធ្វើកន្លងមក។
- បានកំណត់នូវការប្រែប្រួលការប្រើប្រាស់ដី និងផ្នែក/តំបន់ប្រើប្រាស់ដីសម្រាប់ស្រុកនីមួយៗ និងបានផលិតផែនទីការប្រែប្រួលការប្រើប្រាស់ដីសម្រាប់ស្រុកនីមួយៗ។ បានធ្វើនិងរៀបចំឯកសារស្តីអំពីអន្តរអំពើនៃកម្លាំងចលករនៃការប្រែប្រួលការប្រើប្រាស់ដី និងផលវិបាករបស់វារួមទាំងការវិភាគស្ថានភាពអ្នកពាក់ព័ន្ធមកពីថ្នាក់ស្រុកក្នុងការដោះស្រាយជាមួយនឹងបញ្ហាគ្រប់គ្រង និងការប្រែប្រួលការប្រើប្រាស់ដី។
- ឬក៏វិភាគ និងធ្វើបច្ចុប្បន្នភាពបណ្តាញផ្លូវ រួមទាំងការកំណត់ និងធ្វើចំណាត់ថ្នាក់ប្រភេទ និងគុណភាពផ្លូវ ក៏ដូចជាបញ្ហាគ្រប់គ្រង និងការទទួលបានសេវាពីផ្លូវទាំងនោះ។
- បានធ្វើផែនទីនិងកំណត់តំបន់ដែលផ្តល់នូវសេវាសង្គម។ ធ្វើនិងរៀបចំឯកសារស្តីអំពីការវិភាគការទទួលបានសេវាសង្គម សមត្ថភាព និងការគ្រប់គ្រងសេវាទាំងនោះ រួមទាំងការវិភាគស្ថាប័នរបស់អ្នកពាក់ព័ន្ធថ្នាក់ ស្រុកក្នុងការដោះស្រាយទៅលើការទទួលបានសេវា សមត្ថភាព និងបញ្ហាគ្រប់គ្រងដែលបានរកឃើញ។
- បានធ្វើផែនទី និងកំណត់នូវបណ្តុំប៉ូល និងច្រកផ្លូវសេដ្ឋកិច្ចសម្រាប់ស្រុកនីមួយៗ។ ធ្វើនិងរៀបចំឯកសារស្តីអំពីការវិភាគអំពីសក្តានុពលនិងបញ្ហាទាក់ទងនឹងរចនាសម្ព័ន្ធសេដ្ឋកិច្ច រួមទាំងការវិភាគស្ថាប័នរបស់អ្នកពាក់ព័ន្ធថ្នាក់ស្រុកក្នុងការដោះស្រាយទៅលើបញ្ហា និងសក្តានុពលដែលបាន រកឃើញ (កំណត់)។

## ការងារ ២.៤ ការវិភាគស្ថាប័នដោយផ្អែកទៅលើការវិភាគ SWOT នៅថ្នាក់ខេត្ត

### ស្ថានភាពទូទៅ

ការងារមុនៗ បានកំណត់ពីបញ្ហាដែនដីដែលពាក់ព័ន្ធទៅនឹងការគ្រប់គ្រង និងការប្រែប្រួលការប្រើប្រាស់ដី ការទទួលបានសេវាសង្គម និងរចនាសម្ព័ន្ធសេដ្ឋកិច្ច ហើយនិងបានវិភាគពីបុព្វហេតុផលវិបាក និងសមត្ថភាពអ្នកពាក់ព័ន្ធថ្នាក់ស្រុកក្នុងការដោះស្រាយ។ ក្នុងដំណាក់កាលការងារនេះ វាចាំបាច់ណាស់ក្នុងការវិភាគពី កម្រិតថ្នាក់ខេត្ត ដើម្បីស្វែងយល់ថាតើមានយុទ្ធសាស្ត្រ ផែនការ កម្មវិធី និងគោលនយោបាយណាខ្លះ និងសមត្ថភាពថ្នាក់ខេត្ត ដែលមានស្រាប់ក្នុងការដោះស្រាយទៅនឹងបញ្ហាដែនដីដែលបានរកឃើញ។ ក្នុងជំហាននេះ មានគោលបំណងសំខាន់ៗមួយចំនួន៖ (១) ចូលរួមចំណែកក្នុងការធ្វើសមាហរណកម្មយុទ្ធសាស្ត្រ ផែនការ កម្មវិធី និងគោលនយោបាយតាមវិស័យ និងខ្សែបណ្ដោយ (២) ដោយភ្ជាប់បញ្ហាដែនដីជាមួយនឹងសមត្ថភាពរបស់ខេត្តដែលមានស្រាប់ ដែលវានឹងជួយដល់ការកសាងយុទ្ធសាស្ត្រសម្រាប់ការអនុវត្តដែលអាចធ្វើបាន និងប្រកបដោយប្រសិទ្ធភាពនៅជំហានបន្ទាប់ ។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកផ្តួចផ្តើម និងអនុវត្ត
  - ក្រុមការងារខេត្ត
  - អ្នកជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)/គ្រប់គ្រងទិន្នន័យ
- អ្នកដែលត្រូវចូលរួមពិភាក្សា
  - មន្ទីរជំនាញជុំវិញខេត្ត
  - អ្នកពាក់ព័ន្ធថ្នាក់ខេត្តផ្សេងទៀត (សមាគម អង្គការក្រៅរដ្ឋាភិបាល។ល។)

### សកម្មភាពការងារ/វិធីសាស្ត្រ

- ក្រុមការងារខេត្តនឹងធ្វើការវិភាគ SWOT ទាក់ទងទៅនឹងបញ្ហាដែនដីដែលពាក់ព័ន្ធផ្សេងៗដែលបានរកឃើញ ដោយផ្អែកទៅលើសមត្ថភាពខេត្ត និងយុទ្ធសាស្ត្រ ផែនការ កម្មវិធី និង គោលនយោបាយ (PPPS) វិស័យដែលពាក់ព័ន្ធ។ នៅពេលដែលតួនាទី និងការទទួលខុសត្រូវរបស់អ្នកពាក់ព័ន្ធមានការត្រួតស៊ីគ្នាវាចាំបាច់ណាស់ក្នុងការធ្វើការសម្របសម្រួលលើបញ្ហានេះ។ ដោយសារអ្នកពាក់ព័ន្ធមានចំនួនច្រើន ការវិភាគអាចធ្វើឡើងតាមរយៈការជួបប្រជុំពិភាក្សាម្តងមួយៗដើម្បីពិភាក្សាឲ្យបានស៊ីជម្រៅ និងភាពមិនស៊ីសង្វាក់គ្នា។ អានុភាពនៃទំហំកិច្ចប្រជុំដែលត្រូវធ្វើឡើងនេះ គឺអាស្រ័យទៅលើចំនួនបញ្ហាដែនដីដែលពាក់ព័ន្ធទៅនឹងការកសាងផែនការរៀបចំដែនដី។
- ការពិភាក្សា SWOT ត្រូវធ្វើការរៀបចំរចនាសម្ព័ន្ធឲ្យបានល្អប្រសើរ ៖ រៀបចំសេចក្តីសង្ខេបពេញលេញមួយនៃបញ្ហាដែលពាក់ព័ន្ធ និងតួអង្គថ្នាក់ខេត្តដែលនឹងមានការពាក់ព័ន្ធក្នុងការដោះស្រាយបញ្ហាទាំងនោះ។ជាពិសេសនោះត្រូវពិនិត្យមើលឲ្យបានល្អិតល្អន់ពីឯកសារគោលនយោបាយ

ដែលមានការពាក់ព័ន្ធជាមុន ដូចជា៖

- ផែនការវិនិយោគរំកិល ៣ឆ្នាំ និងផែនការអភិវឌ្ឍន៍៥ឆ្នាំរបស់ខេត្ត
- ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ
- គោលនយោបាយតាមវិស័យរបស់ក្រសួងជំនាញរបស់អ្នកពាក់ព័ន្ធ និងបញ្ហាដែនដីដែលបានរកឃើញ

- ការវិភាគ SWOT នេះគួររៀបចំនូវរចនាសម្ព័ន្ធដែលមានលក្ខណៈ "សាមញ្ញ"។ វាចាំបាច់ណាស់ក្នុងការធ្វើការ ណែនាំពីដំណើរការវិភាគ SWOT។ វាមានប្រយោជន៍ណាស់ក្នុងការប្រើប្រាស់ផែនទីជាឯកសារជំនួយក្នុង កំឡុងពេលធ្វើការសម្របសម្រួលការពិភាក្សា។ យើងអាចធ្វើការបែងចែកជាពីរផ្នែកសំខាន់ៗ៖

| ប្រអប់ព័ត៌មាន |
|---|
| ឧបករណ៍ SWOT |
| S (Strength = **ភាពខ្លាំង**) គឺមានប្រយោជន៍ជួយឲ្យសម្រេចបាននូវគោលបំណង។ **ភាពខ្លាំង** ជាធនធានដែលអាចរួមមានអ្វីៗដូចជា ៖ ការដឹងពីរបៀប ឆន្ទៈ ជំនាញ ការគាំទ្រ ព័ត៌មាន ហេដ្ឋារចនាសម្ព័ន្ធ... **ភាពខ្លាំង**ក៏ជួយ ដល់ការប្រើប្រាស់ និងទាញយកផលប្រយោជន៍ពីសក្តានុពល និងឱកាសផងដែរ។<br>W (Weaknesses = **ភាពខ្សោយ**) គឺគំរាមកំហែងចំពោះការសម្រេចឲ្យបាននូវគោលបំណង។ ភាពខ្សោយអាចជាអ្វីៗដូចជា៖ការដឹងពីរបៀបនៅមានកម្រិតបច្ចេកទេសនិងជំនាញមិនគ្រប់គ្រាន់ ព័ត៌មានតិចតួចអំពីឱកាស ការគ្រប់គ្រង និងការសាងផែនការខុសគ្នា បទពិសោធន៍នៅមានកម្រិត។ ភាពខ្សោយរារាំងដល់ការប្រើប្រាស់និងទាញយកប្រយោជន៍ប្រកបដោយប្រសិទ្ធភាពពីឱកាសដែលមានស្រាប់ និងឱកាសសម្រាប់អនាគត។<br>O (Opportunities = **ឱកាស**) គឺជាលក្ខខណ្ឌខាងក្រៅដែលអាចមានប្រយោជន៍ជួយឲ្យសម្រេចបាននូវគោលបំណងនាពេលអនាគត។ ឱកាស ជាអ្វីដែលអាចមានប្រៀបទៅលើអ្នកដទៃ។ យើងត្រូវធ្វើការប្រើប្រាស់ទាញយកផលប្រយោជន៍ពីឱកាសនិងសក្តានុពលដទៃទៀត។<br>T (**ការគំរាមកំហែង/បញ្ហាប្រឈម**) គឺជាលក្ខខណ្ឌខាងក្រៅដែលអាចរារាំងដល់ការធ្វើឲ្យប្រសើរឡើង/ការអភិវឌ្ឍនាពេលអនាគត។ ការគំរាមកំហែងមិនមែនចាំបាច់ត្រូវតែមើលពីផ្នែក(ជ្រុង)អវិជ្ជមាននោះទេ។ ការគំរាមកំហែងក៏អាចជាបញ្ហាប្រឈមផងដែរ។ |

- នៅទីនេះ និងពេលឥឡូវ (ភាពខ្លាំង និងភាពខ្សោយ)
  - តើអ្វីដែលអ្នកពាក់ព័ន្ធមានមោទនភាពចំពោះ និងធ្វើបានល្អ?
  - តើអ្វីជាធនធានសំខាន់ៗរបស់អ្នកពាក់ព័ន្ធ?
  - តើអ្វីដែលអ្នកពាក់ព័ន្ធធ្វើមិនសូវបានល្អ?
  - តើអ្វីជាឧបសគ្គសំខាន់ៗដែលអ្នកពាក់ព័ន្ធប្រឈមជាមួយ?

- អ្វីដែលអាចជា ( ឱកាស និងការគំរាមកំហែង)
  - តើអ្វីជាគោលបំណងយុទ្ធសាស្ត្ររបស់អ្នកពាក់ព័ន្ធនៅក្នុងខេត្ត ដែលទាក់ទងទៅនឹងបញ្ហាដែនដី ដែលពាក់ព័ន្ធផ្សេងៗ។
  - តើអ្នកពាក់ព័ន្ធទាំងអស់មានផែនការដើម្បីឲ្យសម្រេចបាននូវគោលបំណង យុទ្ធសាស្ត្រទាំងអស់នេះដោយរបៀបណា?
  - តើមានកត្តាអ្វីខ្លះដែលជួយគាំទ្រដល់អ្នកពាក់ព័ន្ធដើម្បីឲ្យសម្រេចបាន នូវគោលបំណង យុទ្ធសាស្ត្រទាំងអស់នេះ?
  - តើមានកត្តាអ្វីខ្លះ ឬបញ្ហាប្រឈមអ្វីខ្លះដែលជួយគាំទ្រដល់អ្នកពាក់ព័ន្ធ ដើម្បីឲ្យសម្រេចបាននូវគោលបំណងយុទ្ធសាស្ត្រទាំងអស់នេះ?

☑ លទ្ធផលពីកិច្ចប្រជុំពិភាក្សាម្តងមួយៗនេះ នឹងត្រូវយកមកបញ្ចូលគ្នាទាំងអស់ស្របតាមទម្រង់បែបបទនៃបញ្ហាដែនដីពាក់ព័ន្ធដែលបានរកឃើញនិងជាមួយអ្នកពាក់ព័ន្ធនានា។ ក្រុមការងារថ្នាក់ខេត្តគួរធ្វើការពិភាក្សាដើម្បីសន្និដ្ឋានរួមមួយ ដោយផ្អែកលើមូលដ្ឋាននេះ ដែលលទ្ធផលពិភាក្សាត្រូវដាក់បញ្ចូលក្នុងរបាយការណ៍បច្ចេកទេស។

**លទ្ធផលរំពឹងទុក**

- សង្ខេបនូវសេចក្តីសន្និដ្ឋាន និងលទ្ធផលសំខាន់ៗពីការវិភាគ SWOT ស្តីអំពីបញ្ហាប្រឈម និង សក្តានុពល (ស្ថាប័នរដ្ឋ និងមិនមែនរដ្ឋ)ក្នុងដោះស្រាយជាមួយនឹងបញ្ហាដែលពាក់ពាក់ព័ន្ធទាំងនោះ។

## ការងារ ២.៥ ការវិភាគទម្រង់លក្ខណៈដែនដីបច្ចុប្បន្ននៅក្នុងដែនដីខេត្ត

### ស្ថានភាពទូទៅ

ការវិភាគទម្រង់លក្ខណៈដែនដីបច្ចុប្បន្ននៅក្នុងដែនដីខេត្តជាដំណាក់ការសន្និដ្ឋាននៃការវិភាគស្ថានភាព។ នៅក្នុងដំណាក់ការនេះពេលវេលាជាច្រើនត្រូវបានប្រើប្រាស់សម្រាប់បង្កើតនូវដាតាបេសទិន្នន័យដែនដីដ៏ទូលំទូលាយមួយដែលផ្ទុកទៅដោយព័ត៌មានលម្អិតដែលបានពិនិត្យជាក់លាក់ បានធ្វើបច្ចុប្បន្នភាព និងឯកភាពគ្នារួចហើយ។ មូលដ្ឋានព័ត៌មានទាំងនេះត្រូវបានធ្វើការវិភាគស្របជាមួយនឹងទម្រង់លក្ខណៈដែនដី បញ្ហា និងទំនោរប្រែប្រួលនៃការអភិវឌ្ឍ រួមមានកត្តាដែលមានឥទ្ធិពល និងសមត្ថភាពរបស់ស្ថានប័នក្នុងការដោះស្រាយបញ្ហាទាំងនោះ។ នៅក្នុងចំណុចជាច្រើន ការពិចារណាពីអន្តរវិស័យត្រូវបានលើកយកមកនិយាយរួចហើយ។

នៅក្នុងការងារនេះ ទិន្នន័យនិងព័ត៌មានផ្សេងៗដែលមានត្រូវបានដាក់បញ្ចូលគ្នានៅក្នុងរូបភាពបំព្រួញមួយរបស់ខេត្តដែលប្រមូលផ្តុំដោយព័ត៌មានសំខាន់ៗ ដែលសង្ខេបពីក្របខ័ណ្ឌដែនដីបច្ចុប្បន្នរបស់ខេត្ត និងបង្កើតបានជាទម្រង់មូលដ្ឋានគ្រឹះមួយសម្រាប់ធ្វើការកសាងទម្រង់លក្ខណៈដែនដីរបស់

ខេត្តនាពេលអនាគតនិងយុទ្ធសាស្ត្រឆ្លើយតបទៅនឹងការអភិវឌ្ឍខេត្ត។ទម្រង់លក្ខណៈដែនដីបច្ចុប្បន្ន ត្រូវបានបង្កើតឡើងដោយប្រធានបទ និងចក្ខុវិស័យផ្សេងៗគ្នាបី៖

- **ប្រព័ន្ធប្រើប្រាស់ដី** ដែលមានតំបន់ដែលផ្តោត និងញែកដាច់ចេញពីគ្នានូវទិដ្ឋភាពទេសភាពផ្សេងៗគ្នា អាស្រ័យទៅលើមុខងារ ការប្រើប្រាស់ និងឌីណាមិក (ការវិវត្ត) ដែលមានឥទ្ធិពលលើតំបន់ទាំងនោះ។
- **ប្រព័ន្ធមជ្ឈមណ្ឌលទីប្រជុំជន** ដែលផ្តោតទៅលើទីតាំង និងកំណត់ចំណាត់ថ្នាក់របស់មជ្ឈមណ្ឌលទីប្រជុំជននិងតំបន់ជុំវិញអាស្រ័យទៅលើការផ្គត់ផ្គង់សេវាសង្គមដល់ប្រជាពលរដ្ឋ។
- **រចនាសម្ព័ន្ធសេដ្ឋកិច្ច** ដែលផ្តោតទៅលើទីតាំងបណ្តុំប៉ូល និងតំបន់ទ្រនាប់ច្រកផ្លូវដែលពាក់ព័ន្ធទៅនឹងសេដ្ឋកិច្ចរបស់ខេត្ត។ ព័ត៌មានដែលបង្ហាញនៅលើផែនទី គឺជាព័ត៌មានសង្ខេបសួលមួយដូច្នេះហើយ វាមិនមានភាពងាយស្រួលក្នុងការបកស្រាយផែនទីទាំងនោះដោយគ្មានព័ត៌មានបន្ថែមនោះទេ។ ព័ត៌មានទាំងនោះមានភាពស្មុគស្មាញណាស់។ ដូច្នេះផែនទីទាំងបីទាក់ទងទៅនឹងប្រធានបទសំខាន់ៗទាំងបីខាងលើទាមទារឲ្យមានភាពច្បាស់លាស់ និងពន្យល់ឲ្យបានហ្មត់ចត់ ព្រោះវាជាព័ត៌មានដ៏សំខាន់សម្រាប់ការវិភាគស្ថានភាព។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- ការអនុវត្ត
  - ក្រុមការងារខេត្ត
  - អ្នកជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ (GIS)/គ្រប់គ្រងទិន្នន័យ
- ការគាំទ្រ
  - ក្រុមប្រឹក្សាខេត្ត
  - គ.ជ.ន.ខ

### សកម្មភាពការងារ/វិធីសាស្ត្រ

- កសាងរចនាសម្ព័ន្ធ និងរៀបចំការវិភាគពីទម្រង់លក្ខណៈដែនដីបច្ចុប្បន្នរបស់ដែនដីខេត្តលើប្រធានបទបីសំខាន់ៗ៖
  - ប្រព័ន្ធប្រើប្រាស់ដី
  - ប្រព័ន្ធមជ្ឈមណ្ឌលទីប្រជុំជន
  - រចនាសម្ព័ន្ធសេដ្ឋកិច្ច
- រៀបចំកិច្ចពិភាក្សាមួយរយៈពេល ១ទៅ២ថ្ងៃ សម្រាប់ប្រធានបទនីមួយៗខាងក្រោម៖

### ក) ការកំណត់ និងវិភាគប្រព័ន្ធប្រើប្រាស់ដី

មុខងារ និងទម្រង់លក្ខណៈទិដ្ឋភាពទេសភាពបច្ចុប្បន្ននៃការប្រើប្រាស់ដីនៅក្នុងខេត្តត្រូវបានធ្វើចំណាត់ថ្នាក់ជាប្រភេទផ្សេងៗគ្នា និងបង្ហាញឲ្យឃើញតាមរយៈវិធីសាស្ត្រប្រព័ន្ធប្រើប្រាស់ដី។ ប្រព័ន្ធប្រើប្រាស់ដីមួយ គឺជាតំបន់ដែលមានលក្ខណៈនៃការប្រើប្រាស់ដីសំខាន់ ការគ្រប់គ្រងនិងការវិវត្តនៃការប្រែប្រួលការប្រើប្រាស់ដីមានលក្ខណៈប្រហាក់ប្រហែលគ្នា។គុណសម្បត្តិពីការប្រើប្រាស់វិធីសាស្ត្រនេះ គឺថាមិនត្រឹមតែការប្រើប្រាស់ដី និងគម្របដីត្រូវបានបង្ហាញឡើងវិញនោះទេ ប៉ុន្តែវាក៏បង្ហាញពីឌីណាមិក (ការវិវត្ត) នៃអន្តរអំពើរវាងមនុស្សនិងបរិស្ថានផងដែរ។គោលបំណងនៃវិធីសាស្ត្រនេះ គឺដើម្បីកំណត់ពីការគ្រប់គ្រង មុខងារ និងទម្រង់លក្ខណៈបច្ចុប្បន្នរបស់ទិដ្ឋភាពទេសភាពខេត្ត និងដើម្បីកំណត់ពីមុខងារទិដ្ឋភាពទេសភាពដែលចង់បាន និងយុទ្ធសាស្ត្រឆ្លើយតបទៅនឹងមុខងារទាំងនោះនៅក្នុងជំហានបន្ទាប់។

- ប្រព័ន្ធប្រើប្រាស់ដី គឺអាស្រ័យទៅលើ (១) ផ្នែក/តំបន់ប្រើប្រាស់ដី និង (២) ផែនទីបម្រែបម្រួលការប្រើប្រាស់ដីដែលបានកសាងឡើងសម្រាប់ស្រុកនីមួយៗតាំងពីដំបូង។ វាត្រូវធ្វើការបង្ហាញជារួម និងមានភាពជាក់លាក់សម្រាប់ខេត្តទាំងមូល។ ការបង្ហាញជារួមនេះ គឺអាចធ្វើឡើងនិងជួយសម្រួលពីកម្មវិធី GIS ហើយនិងចាប់ផ្តើមដោយគ្រាន់តែដាក់បញ្ចូលព័ត៌មានស្រុកជាមួយគ្នាទៅលើផ្នែក (តំបន់) ប្រើប្រាស់ដី និងការប្រែប្រួលការប្រើប្រាស់ដីក្នុងផែនទីពីរផ្សេងគ្នារបស់ខេត្ត។
- ដើម្បីធ្វើការបង្ហាញជារួមទូទៅ និងដាក់ច្របាច់បញ្ចូលគ្នាពីភាពខុសៗគ្នានៃការប្រើប្រាស់ដី និងការប្រែប្រួលការប្រើប្រាស់ដីនៅទូទាំងស្រុកទាំងអស់ក្រុមការងារខេត្ត ត្រូវធ្វើការកំណត់នូវប្រព័ន្ធចំណាត់ថ្នាក់មួយ។ មានវិធីសាស្ត្រដែលអាចប្រើបានផ្សេងៗគ្នាជាច្រើន ហើយគួរតែមានការគាំទ្រពីអ្នកសម្របសម្រួលខាងក្រៅ។ វិធីសាស្ត្រសាមញ្ញនោះ គឺបង្កើតតារាងមាទ្រីក (matrix) ដែលផ្អែកទៅលើលទ្ធផលរបស់សិក្ខាសាលាថ្នាក់ស្រុកផ្សេងៗគ្នា (ការងារ២.៣) ដោយមាន (X) ជាប្រភេទប្រើប្រាស់ដីបច្ចុប្បន្នសំខាន់ៗទាំងអស់ ដែលបានកំណត់ក្នុងចំណងជើងម៉ាទ្រីក (Matrix head)/ជួរដេកដំបូង និង (Y) ជាប្រភេទការប្រែប្រួលការប្រើប្រាស់ដីផ្សេងៗគ្នាទាំងអស់នៅក្នុងជួរឈរដំបូង។ ដោយដាក់ប្រសព្វកាត់គ្នា (intersection) រវាងប្រភេទប្រើប្រាស់ និងប្រភេទនៃការប្រែប្រួលការប្រើប្រាស់ដី យើងនឹងកំណត់បាននូវប្រព័ន្ធប្រើប្រាស់ដីផ្សេងៗគ្នា តាមរយៈការពិភាក្សាដែលមានការសម្របសម្រួលមួយ (ឧ. នៅក្នុងផែនទី ២៦ វាបង្ហាញពីដំណាក់ការអភិវឌ្ឍន៍ឆ្ពោះទៅរកការកសាងផែនទីប្រព័ន្ធប្រើប្រាស់ដីនៅក្នុងខេត្តតាកែវ ផ្នែក(តំបន់)ប្រើប្រាស់ដីសំខាន់ៗមួយ គឺកសិកម្មដីទំនាប។ តំបន់នេះនៅភាគខាងត្បូងដែលត្រូវបានមើលឃើញពីលក្ខណៈសម្បត្តិរបស់វាតាមរយៈការបំលែងគួរឲ្យកត់សំគាល់នៃដីវាលស្មៅទៅជាកសិកម្ម ដូច្នេះប្រព័ន្ធប្រើប្រាស់ដីដាច់ដោយឡែកមួយ "ដីវាលស្រែថ្មី" ត្រូវបានកំណត់និងធ្វើផែនទីឡើងនៅក្នុងតំបន់ដែលមានការប្រែប្រួលការប្រើប្រាស់ដី ដែលនឹងកំពុងតែកើតមានឡើង។)

- **គន្លឹះសំខាន់៖** ជាជម្រើសផ្សេងទៀត ក៏មានវិធីសាស្រ្តស្មុគស្មាញជាងនេះបន្តិច ដែលអាចផ្ទូរផ្ទង ប្រភេទប្រើប្រាស់ដីសំខាន់ៗ ជាមួយនឹង "របបគ្រប់គ្រង" ដែលអាចបញ្ចូលរវាងការប្រែប្រួល ការប្រើប្រាស់ដីដែលបានអង្កេត និងរបបគ្រប់គ្រងដីដែលបានអង្កេត (ឧ. មិនប្រើប្រាស់/ព្រៃ ការប្រើប្រាស់ប្រកបដោយនិរន្តរភាព ឬគ្រប់គ្រងទូលំទូលាយ រេចរឹល ប្រើប្រាស់ជាប្រពលវប្បកម្ម អភិវឌ្ឍន៍/បំលែងទាំងស្រុង)។ នេះនឹងពង្រឹងដល់លក្ខណៈអេកូឡូស៊ីហើយនិងអាចមានឥទ្ធិពល ដល់ព័ត៌មាននិរន្តរភាពនៃប្រព័ន្ធប្រើប្រាស់ដី។




**ផែនទី២៦៖** ការកំណត់ប្រព័ន្ធប្រើប្រាស់ដីនៅក្នុងខេត្តតាកែវ (ផ្នែកប្រើប្រាស់ដី - ខាងឆ្វេង, ការប្រែប្រួលការ ប្រើប្រាស់ដី - កណ្ដាល , និងប្រព័ន្ធប្រើប្រាស់ដីថ្មី - ខាងស្តាំ)

- សម្រាប់ប្រព័ន្ធប្រើប្រាស់ដីនីមួយៗ ដែលបានកំណត់ និងធ្វើផែនទីហើយ ក្រុមការងារខេត្តត្រូវ កំណត់នូវបញ្ហាគ្រប់គ្រងដីសំខាន់ៗឬឌីណាមិក(ការវិវត្ត) ដែលមានឥទ្ធិពលដល់ប្រព័ន្ធទាំងនោះ។ កិច្ចការងារនេះ គឺពឹងផ្អែកទៅលើលទ្ធផលមានស្រាប់ ដែលបានបង្កើតឡើងក្នុងកំឡុងពេល សិក្ខាសាលាថ្នាក់ស្រុក ប៉ុន្តែវាក៏ត្រូវពឹងផ្អែកទៅលើព័ត៌មានដ៏ទៃទៀតដែលបានបង្កើតឡើងតាម រយៈដំណើរការកសាងផែនការ។
- ការវិភាគពីប្រព័ន្ធប្រើប្រាស់ដី នឹងត្រូវបានធ្វើពេញលេញ (បញ្ចប់) ជាមួយនឹងការពិភាក្សាដែល មានការសម្របសម្រួលមួយស្តីអំពីទំនាក់ទំនងរវាងបញ្ហា ដែលបានរកឃើញជាមួយនឹងបុព្វហេតុ និងផលប៉ះពាល់សម្រាប់ប្រព័ន្ធប្រើប្រាស់ដីនីមួយៗដែលបានរកឃើញ។ នេះជួយឲ្យក្រុមការងារ ខេត្ត យល់ពីទំនាក់ទំនងនៃការគ្រប់គ្រង និងមុខងាររបស់តំបន់ផ្សេងៗគ្នាដែលជាលក្ខខណ្ឌ ដំបូងដែលពាក់ព័ន្ធសម្រាប់កំណត់នូវយុទ្ធសាស្រ្តអភិវឌ្ឍន៍ដែនដីតាមវិស័យ និងមន្ទីរនៅក្នុង ជំហានបន្ទាប់។ ការពិភាក្សា គួរធ្វើការបង្ហាញ និងរៀបចំជាឯកសារ។

- **គន្លឹះសំខាន់៖** ការវិភាគពីទំនាក់ទំនាក់ទំនងនៃបញ្ហា មូលហេតុ និងផលវិបាក គឺជាការងារមួយដ៏លំបាកនៅក្នុងដំណើរការកសាងផែនការ។ ក្រុមការងារខេត្តដែលមិនបានធ្វើការវិភាគរបៀបនេះពីមុនមក គួរតែស្វែងរកជំនួយពីអ្នកសម្របសម្រួលដែលមានបទពិសោធន៍មកពីខាងក្រៅ។

### ខ) ការធ្វើចំណាត់ថ្នាក់ និងវិភាគពីមជ្ឈមណ្ឌលទីប្រជុំជន

គោលនយោបាយវិស័យអប់រំ និងសុខភាព គឺដើម្បីធ្វើការកំណត់ពីប្រភេទសេវាកម្ម ឬបរិក្ខារអ្វីខ្លះដែលនឹងត្រូវផ្តល់ជូនប្រជាពលរដ្ឋចំនួនប៉ុន្មាននាក់ ហើយក្នុងកម្រិតចម្ងាយប៉ុន្មាន។ ដូច្នេះ ទីតាំងផ្តល់សេវាទាំងនេះត្រូវការភ្ជាប់ទៅនឹងទម្រង់លក្ខណៈតំបន់តាំងទីលំនៅ។ វិធីសាស្រ្តមួយដែលអាចធ្វើទៅបាន គឺ**ទស្សនទាននៃមជ្ឈមណ្ឌលទីប្រជុំជន**។ ទស្សនទាននេះកំណត់ពីកន្លែងដែលត្រូវផ្តល់សេវាកម្មទាំងនោះ ដោយផ្អែកទៅលើការធ្វើចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជនដែលនឹងត្រូវផ្តល់សេវាក្នុងកម្រិតផ្សេងៗគ្នាដោយផ្អែកទៅលើ ចំណាត់ថ្នាក់របស់មជ្ឈមណ្ឌលទាំងនោះ។ ត្រូវយល់ថាបរិក្ខារ (ការសម្របសម្រួល)ផ្សេងៗត្រូវការចំនួនអ្នកប្រើប្រាស់ផ្សេងៗគ្នា ដើម្បីប្រើប្រាស់បរិក្ខារទាំងនោះឲ្យស្របទៅតាមសមត្ថភាពរបស់វា និងឲ្យមានដំណើរការប្រកបដោយប្រសិទ្ធភាព។ ការងារនេះនឹងបង្កើតបានជាមូលដ្ឋានសម្រាប់កំណត់ចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជនខេត្តដែលចង់បាន ដើម្បីដោះស្រាយបញ្ហាដែលបានកំណត់ទាក់ទងនឹងការទទួលបានសេវានានា។ ដោយសារតែមូលហេតុសេដ្ឋកិច្ចតំបន់ជនបទមិនមែនជាជម្រើសល្អទេ ហើយវាមានត្រឹមតែហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសមួយចំនួនដូចជាការផ្គត់ផ្គង់អគ្គីសនីនិងទឹក។អ្នកនៅជនបទទាំងនោះត្រូវធ្វើដំណើរទៅកាន់ទីប្រជុំជនដែលនៅក្បែរខ្លួនដើម្បីទទួលបាននូវសេវាផ្សេងៗបន្ថែមទៀត។

បច្ចុប្បន្ននេះ មិនមានគោលការណ៍ណែនាំជាគោលនយោបាយស្តីអំពីការធ្វើចំណាត់ថ្នាក់សេវាដោយផ្អែកទៅតាមឋានានុក្រមមជ្ឈមណ្ឌលទីប្រជុំជននោះទេ។ តារាង ៤ ខាងក្រោម រៀបរាប់ពីបញ្ជីបរិក្ខារ (សេវា សម្របសម្រួល) ដែលបានកំណត់នៅក្នុងដំណើរការកសាងផែនការរៀបចំដែនដីខេត្តបាត់ដំបង ដែលគួរធ្វើការពិនិត្យ និងអាចធ្វើការកែតម្រូវឲ្យស្របទៅតាមលក្ខខណ្ឌមូលដ្ឋាន។

**តារាង៣៖** ការធ្វើចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជននៅក្នុងខេត្តបាត់ដំបង

| **អនុមជ្ឈមណ្ឌលរង** | **មជ្ឈមណ្ឌលរង** | **មជ្ឈមណ្ឌលកណ្តាល** |
|---|---|---|
| ការផ្តល់សេវាកម្ម នៅក្នុងអនុមជ្ឈមណ្ឌលរង៖<br>• មណ្ឌលសុខភាព<br>• កន្លែងព្យាបាលខ្នាតតូច<br>• សាលាបឋមសិក្សា និងអនុវិទ្យាល័យ<br>• ប៉ុស្តិ៍ប្រៃសណីយ៍<br>• មជ្ឈមណ្ឌលរដ្ឋបាលឃុំ<br>• កន្លែងសម្រាប់ប្រារព្ធព្រឹត្តិការណ៍វប្បធម៌<br>• ផ្គត់ផ្គង់អាហារ/អាហារដ្ឋាន<br>• ផ្សារលក់ទំនិញមូលដ្ឋានប្រចាំថ្ងៃ និងអាហារ | ការផ្តល់សេវាកម្មក្នុងមជ្ឈមណ្ឌលរង (បន្ថែមពីលើអ្វីដែលមាននៅក្នុងអនុមជ្ឈមណ្ឌលរង) ៖<br>• មជ្ឈមណ្ឌលសុខភាពស្រុកប្រតិបត្តិ<br>• កន្លែងសម្រាប់ព្រឹត្តិការណ៍កីឡា<br>• សាខាធនាគារ និងវិទ្យាស្ថានមីក្រូហិរញ្ញវត្ថុ<br>• មានវិទ្យាស្ថានអប់រំកម្រិតអនុ-វិទ្យា ល័យច្រើនជាងមួយកន្លែង<br>• អាហារដ្ឋានច្រើនជាងមួយកន្លែង | ការផ្តល់សេវាកម្មក្នុងមជ្ឈមណ្ឌលកណ្តាល (បន្ថែមពីលើអ្វីដែលមាននៅក្នុងមជ្ឈមណ្ឌលរង) ៖<br>• មន្ទីរពេទ្យ (+ គ្លីនិកឯកជន)<br>• អ្នកឯកទេសខាងសុខភាព<br>• ការអប់រំកម្រិតខ្ពស់<br>• ផ្សារលក់សំលៀកបំពាក់ គ្រឿងអេឡិចត្រូនិច និងសម្ភារៈសំណង់<br>• ទីស្នាក់ការរដ្ឋបាលស្រុក<br>• កន្លែងស្នាក់នៅដែលមានកម្រិតខុសៗគ្នា<br>• មានព្រឹត្តិការណ៍កីឡា និងវប្បធម៌ទៀងទាត់<br>• មានអាហារដ្ឋានច្រើនកន្លែង |
| | មជ្ឈមណ្ឌលរង ក៏បម្រើជាច្រកមួយទៅកាន់កន្លែងសំខាន់ៗដទៃទៀត ឬក៏ដើរតួជាប៉ូលមជ្ឈមណ្ឌលដែលតភ្ជាប់ទៅនឹងផ្លូវខេត្តសំខាន់ៗយ៉ាងហោចណាស់ចំនួនពីរ។ | មជ្ឈមណ្ឌលកណ្តាល ក៏ត្រូវភ្ជាប់ទៅនឹងផ្លូវជាតិសំខាន់ៗយ៉ាងតិចមួយ ហើយចម្ងាយអប្បបរិមាទៅកាន់មជ្ឈមណ្ឌលដែលមានកម្រិតដូចគ្នាត្រូវមានចម្ងាយយ៉ាងតិច ២០គីឡូម៉ែត្រ។ |

- ប្រហាក់ប្រហែលគ្នាទៅនឹងប្រព័ន្ធប្រើប្រាស់ដី នៅក្នុងជំហានដំបូង លទ្ធផលដែលបានមកពីសិក្ខាសាលាថ្នាក់ស្រុកត្រូវបញ្ចូលគ្នាទៅក្នុងកម្រិតថ្នាក់ខេត្ត។ មជ្ឈមណ្ឌលទីប្រជុំជននិងតំបន់ផ្តល់សេវាកម្មនៅជុំវិញវា ត្រូវធ្វើការបញ្ចូលគ្នាទៅក្នុងផែនទីកម្រិតខេត្តចំនួនពីរ ដែលផែនទីមួយគ្របដណ្តប់លើសេវាកម្មមូលដ្ឋាននិងផែនទីមួយទៀតគ្របដណ្តប់លើសេវាកម្មកម្រិតខ្ពស់ (ដែលគួរតែមានមជ្ឈមណ្ឌលតិច ប៉ុន្តែវាផ្តល់នូវសេវាក្នុងទ្រង់ទ្រាយធំ) ដើម្បីងាយស្រួលក្នុងការពិភាក្សាអំពីលទ្ធភាពទទួលបាននូវសេវារបស់តំបន់ដែលនៅជុំវិញ។
- ក្រុមការងារខេត្ត ត្រូវធ្វើការពិភាក្សាផែនទីព្រាងទាំងពីរ កំណត់ឡើងវិញពីតំបន់ដែលចាំបាច់ និងប្រមូលព័ត៌មានតាមស្រុកនីមួយៗដូច្នេះវានឹងបង្កើតបានជាប្រព័ន្ធដែលមានការឯកភាពមួយ(ស៊ីគ្នា)។
- បន្ទាប់មកក្រុមការងារខេត្ត នឹងត្រូវចូលរួមពាក់ព័ន្ធនៅក្នុងការកសាងការធ្វើចំណាត់ថ្នាក់សេវាកម្មដែលចង់បាន ប៉ុន្តែត្រូវមានភាពជាក់ស្តែងដោយត្រូវធ្វើទៅតាមឋានានុក្រមបីកម្រិតផ្សេងៗគ្នាពីកម្រិតខ្ពស់ កម្រិត មធ្យម និងកម្រិតទាប។ នៅក្នុងដំណាក់ការនេះ បរិក្ខារផ្នែកអប់រំ និងសុខភាពត្រូវតែធ្វើការបំពេញបន្ថែម

ជាមួយបរិក្ខារសេវាផ្សេងៗទៀតដែលពាក់ព័ន្ធសម្រាប់បម្រើជូនដល់ប្រជាពលរដ្ឋ ដូចជារដ្ឋបាល វប្បធម៌ ផ្សារ សណ្ឋាគារ និងភោជនីយដ្ឋាន។ល។

- បន្ទាប់មកទៀត ផែនទីព្រាងទាំងពីរ នឹងត្រូវដាក់បញ្ចូលគ្នា ហើយនិងបញ្ចូលការធ្វើចំណាត់ថ្នាក់សម្រាប់កម្រិតខ្ពស់ (មើលផែនទី ២៧ សម្រាប់មជ្ឈមណ្ឌលទីប្រជុំជនក្នុងខេត្តតាកែវ)។




**ផែនទី២៧៖** ចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជនក្នុងខេត្តតាកែវ

- សម្រាប់មជ្ឈមណ្ឌលកណ្តាល អនុមជ្ឈមណ្ឌល និងអនុមជ្ឈមណ្ឌលរងនីមួយៗ ក្រុមការងារខេត្តគួរធ្វើការពិនិត្យ និងរៀបចំឯកសារពីការផ្គត់ផ្គង់សេវាបច្ចុប្បន្ន និងកំណត់ពីបញ្ហានៃការទទួលបានសេវាកម្មនិងសមត្ថភាពក្នុងការផ្តល់សេវាទាំងនោះ។ មជ្ឈមណ្ឌលជាច្រើននឹងធ្លាក់ចូលកម្រិតមួយដោយឯកឯងដែលមិនបានផ្តល់គ្រប់សេវាកម្មដូចដែលបានគិតទុកមុនសម្រាប់ថ្នាក់មជ្ឈមណ្ឌលនោះ។ ខណៈដែលផែនទីសម្រេចចុងក្រោយនឹងបង្ហាញជាក់ស្តែងពីសេវាដែលមានស្រាប់ គួរធ្វើការរៀបចំឯកសារអំពីសេវាទាំងនេះហើយកន្លែងដែលមានការខ្វះខាតនូវសេវាមួយចំនួនក៏គួរធ្វើការបង្ហាញនៅលើផែនទីផងដែរ (ឧ.អនុមជ្ឈមណ្ឌលរងដែលមានមុខងារកម្រិតកណ្តាលមួយចំនួន)។ ធ្វើការពិចារណាទៅលើការបែងចែកមុខងាររបស់មជ្ឈមណ្ឌលដែលនៅជិតគ្នាផងដែរ។

- ជាចុងក្រោយ ក្រុមការងារខេត្តគួរធ្វើការពិភាក្សា និងរៀបចំឯកសារស្តីអំពីការផ្គត់ផ្គង់សេវារួមបច្ចុប្បន្ន និងទំនាក់ទំនងនៃការទទួលបានសេវា សមត្ថភាព និងបញ្ហាផ្សេងៗទៀតដែលបានកំណត់ក៏ដូចជាមូលហេតុ និងផលប៉ះពាល់របស់វាផងដែរ។
- **គន្លឹះសំខាន់៖** ត្រូវចាំពីសក្តានុពលមជ្ឈមណ្ឌលកណ្តាល និងអនុមជ្ឈមណ្ឌលនៅក្នុងតំបន់។

### គ) ការកំណត់ និងវិភាគពីរចនាសម្ព័ន្ធសេដ្ឋកិច្ចខេត្ត

រចនាសម្ព័ន្ធសេដ្ឋកិច្ចបច្ចុប្បន្ន មានគោលបំណងបង្ហាញពីទីតាំងប៉ូល និងច្រកផ្លូវសេដ្ឋកិច្ចដែលពាក់ព័ន្ធសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចរបស់ខេត្ត។ ដូចគ្នាទៅនឹងសមាសភាពពីរខាងដើមរបស់ទម្រង់លក្ខណៈដែនដីខេត្ត (ការកំណត់និងវិភាគប្រព័ន្ធប្រើប្រាស់ដី និងការធ្វើចំណាត់ថ្នាក់និងវិភាគពីមជ្ឈមណ្ឌលទីប្រជុំជន) សមាសភាគមួយនេះ (ការកំណត់ និងវិភាគពីរចនាសម្ព័ន្ធសេដ្ឋកិច្ចខេត្ត) ធ្វើការកសាងទិន្នន័យតាមវិស័យ ដែលបានប្រមូលបានវិភាគ និងបានធ្វើបច្ចុប្បន្នភាពហើយនៅក្នុងកំឡុងពេលសិក្ខាសាលាថ្នាក់ស្រុក។

- ធ្វើការបញ្ចូលគ្នានូវលទ្ធផលពីសិក្ខាសាលាថ្នាក់ស្រុកទៅក្នុងកម្រិតថ្នាក់ខេត្ត។ ពិនិត្យឡើងវិញទៅលើការធ្វើចំណាត់ថ្នាក់របស់តំបន់ប៉ូលបណ្តុំសេដ្ឋកិច្ច ដែលបានធ្វើឡើងនៅក្នុងសិក្ខាសាលាថ្នាក់ស្រុក។ តំបន់ប៉ូលនីមួយៗត្រូវតែធ្វើការកំណត់និងដាក់នៅលើផែនទី និងបង្ហាញពីលក្ខណៈសម្បត្តិរបស់វាដោយផ្អែកលើការពាក់ព័ន្ធផ្នែកសេដ្ឋកិច្ច និងសមត្ថភាពក្នុងការស្រូបយកកម្លាំងពលកម្ម (មើលផែនទី ២៨ សម្រាប់ជាឧទាហរណ៍ពីខេត្តតាកែវ )។ ឧទាហរណ៍សម្រាប់ការធ្វើចំណាត់ថ្នាក់៖
    - បណ្តុំប៉ូលអភិវឌ្ឍន៍ឧស្សាហកម្ម
        - ប៉ូលអភិវឌ្ឍន៍ឧស្សាហកម្មសំខាន់ (ចំបង) ដែលមានឧស្សាហកម្មខ្នាតធំ។
        - ប៉ូលអភិវឌ្ឍន៍ឧស្សាហកម្មសំខាន់ទីពីរ (បន្ទាប់) ដែលមានដង់ស៊ីតេសហគ្រាសខ្នាតតូច និងមធ្យមខ្ពស់។
    - ប៉ូលអភិវឌ្ឍន៍កសិកម្ម
        - ការសម្របសម្រួលសម្រាប់ការផ្ទុកទុក/ឃ្លាំង រោងចក្រកែច្នៃកសិកម្ម។
        - ពិនិត្យពីទំនាក់ទំនងទីប្រជុំជន និងជនបទដែលមានស្រាប់ ដោយគិតពីការផលិតទៅដល់ការប្រើប្រាស់ ការផលិតទៅកាន់ទីផ្សារ ។ល។
    - ប៉ូលអភិវឌ្ឍន៍ឆ្លងកាត់ព្រំប្រទល់
        - កំណត់ពីហេដ្ឋារចនាសម្ព័ន្ធឆ្លងកាត់ព្រំប្រទល់សំខាន់ៗ (ជំនួញ ពាណិជ្ជកម្ម ។ល។)

    - អាចសំគាល់បានតាមរយៈការមាន ឬការខ្វះខាតនូវសេវាសម្រាប់ការអភិវឌ្ឍ។
  - ប៉ូលទេសចរណ៍
    - កំណត់ហេដ្ឋារចនាសម្ព័ន្ធទេសចរណ៍សំខាន់ៗ
    - អាចសំគាល់បានតាមរយៈការមាន ឬការខ្វះខាតនូវសេវាសម្រាប់ការអភិវឌ្ឍវិស័យទេសចរណ៍នេះ។




**ផែនទី ២៨ ៖** ការកំណត់ប៉ូលអភិវឌ្ឍន៍សំខាន់ៗនៅក្នុងខេត្តតាកែវ

- ពិនិត្យឡើងវិញជាប្រព័ន្ធនិងរៀបចំឯកសារស្តីពីបញ្ហានៃបណ្តុំប៉ូលអភិវឌ្ឍន៍ផ្សេងៗគ្នា សក្តានុពល និងមូលហេតុដែលបានកំណត់ ទំនាក់ទំនងរបស់វាទៅនឹងប្រព័ន្ធដឹកជញ្ជូន និងទំនាក់ទំនងជាមួយប៉ូលអភិវឌ្ឍន៍ផ្សេងទៀត។ ដូចគ្នានឹងសកម្មភាពពីមុនៗ ដំណាក់កាលនេះផ្អែកទៅលើលទ្ធផលដែលបានមកពីសិក្ខាសាលាថ្នាក់ស្រុកផ្សេងៗគ្នា។ ពិនិត្យបន្ថែមទៅលើការរួមគ្នា (Senergies) រវាងប៉ូលទាំងនោះដោយផ្តោត ជាពិសេសលើបណ្តាញដឹកជញ្ជូន(ច្រកផ្លូវ) ដែលភ្ជាប់បណ្តាញទាំងនោះ។

**លទ្ធផលរំពឹងទុក**

- បានផលិតផែនទី និងធ្វើការវិភាគពីប្រព័ន្ធប្រើប្រាស់ដី ការធ្វើចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជន និងរចនា សម្ព័ន្ធសេដ្ឋកិច្ច។
- បានធ្វើការវិភាគ និងរៀបចំឯកសារអំពីបញ្ហាសំខាន់ៗ និងកត្តាដែលមានឥទ្ធិពលដល់បញ្ហាទាំងនោះសម្រាប់ប្រព័ន្ធប្រើប្រាស់ដីនីមួយៗ មជ្ឈមណ្ឌលទីប្រជុំជននីមួយៗ ក៏ដូចជាសម្រាប់បណ្តុំប៉ូល និងច្រកផ្លូវសេដ្ឋកិច្ចផ្សេងៗផងដែរ។
- ការវិភាគលើប្រធានបទស្នូលសំខាន់បីនេះ ត្រូវបានធ្វើបទបង្ហាញ និងពិគ្រោះយោបល់ជាមួយ គ.ដ.ន.ខ។

## ជំហានទី៣ កំណត់ចក្ខុវិស័យសម្រាប់អនាគត

**គោលបំណងរួម**

- កំណត់សេណារីយ៉ូអភិវឌ្ឍន៍ដែលពាក់ព័ន្ធ ដើម្បីប្រមើលមើលសក្តានុពល និងឧបសគ្គនាពេលអនាគតសម្រាប់ការអភិវឌ្ឍដែនដី
- បង្កើតចក្ខុវិស័យសំខាន់ៗសម្រាប់ការអភិវឌ្ឍខេត្ត
- បង្កើតគោលដៅរយៈពេលវែងដែលស៊ីគ្នាជាមួយនឹងចក្ខុវិស័យ

### ការងារ ៣.១ កំណត់សេណារីយ៉ូអភិវឌ្ឍន៍សម្រាប់អនាគត

### ស្ថានភាពទូទៅ

ផែនការរៀបចំដែនដីជាពិសេសនៅក្នុងកម្រិតថ្នាក់ខេត្ត ជាផែនការដែលមានរយៈពេលវែង។ វិធីសាស្ត្រកសាងផែនការ គឺផ្អែកទៅលើកត្តាផ្សេងៗគ្នា។ ទី១៖ វាផ្អែកទៅលើសក្តានុពល និងតម្រូវការដែលបានវិភាគនៅក្នុងជំហានទី២ ទី២៖ វាផ្តល់នូវការគាំទ្រដល់ការអនុវត្តគោលនយោបាយរដ្ឋាភិបាលដែលបង្កើតឡើងសម្រាប់ការអភិវឌ្ឍតាមការចង់បានពីថ្នាក់ជាតិ ពីវិស័យ ឬពីថ្នាក់ខេត្ត។ ទី៣ ៖ ការកសាងផែនការគឺឧបករណ៍យុទ្ធសាស្ត្រមួយដែលវាធ្វើការដោះស្រាយការអភិវឌ្ឍដែលបានប្រមើលមើលទុកមុនពេលដែលការអភិវឌ្ឍនេះកើតមានឡើងពិតប្រាកដ។ សេណារីយ៉ូមានតួនាទីជួយឲ្យយល់ពីការអភិវឌ្ឍដែលបានប្រមើលមើលទុកមុន៖

**មធ្យោបាយដែលមានសក្តានុពលក្នុងការបង្កើតសេណារីយ៉ូ៖**

- មធ្យោបាយដើម្បីសម្លឹងមើលទៅអនាគត គឺការក្រឡេកគិតមើលពីអតីតកាល។ វាអាចកំណត់ទំនោរនៃការប្រែប្រួលចេញពីអ្វីដែលកើតឡើងជាយូរមកនិងអ្វីដែលទើបនឹងកើតឡើងក្នុងពេលថ្មីៗកន្លងមក និងស្វែងយល់ថាតើហេតុអ្វីបានជាវាកើតឡើងដោយរបៀបហ្នឹង។ ផ្អែកទៅលើមូលដ្ឋាននេះ យើងអាចធ្វើការសិក្សាប៉ាន់ស្មានអំពីទំនោរនៃការប្រែប្រួលដែលអាចនឹងវិវត្តទៅនៅថ្ងៃអនាគត។ វិធីសាស្ត្រនេះត្រូវបានប្រើប្រាស់សម្រាប់ការព្យាករណ៍ប្រជាសាស្ត្រ ហើយវាអាចយកមប្រើប្រាស់យ៉ាងងាយស្រួសអំពីលក្ខណៈនៃនគរូបនីយកម្ម ការបំផ្លាញព្រៃឈើ ការអភិវឌ្ឍកសិកម្មនាពេលអនាគត។ល។ លទ្ធផលនៃការវិភាគការប្រែ ប្រួលការប្រើប្រាស់ដី (ការងារ២.៣ និង២.៥) និងការវិភាគ SWOT ស្ថាប័ន (ការងារ ២.៤) គឺជាឧបករណ៍ដែលយកមកប្រើក្នុងការពិភាក្សានេះ។ វាគួរតែយកមកប្រើវិញជា “ជាគំនិត” នៅក្នុងការពិភាក្សានេះ ដើម្បីព្យាករណ៍ពីថាតើបម្រែបម្រួលដែលបានរកឃើញ និងវិភាគហើយ នឹងដើរតួយ៉ាងណាខ្លះនាពេលអនាគត។
- វិធីសាស្ត្រផ្សេងទៀតក្នុងការប្រមើលមើលទៅអនាគត គឺផ្អែកទៅលើការសិក្សាបែបវិទ្យាសាស្ត្រថ្នាក់ជាតិ(អន្តរជាតិ)។ មានការព្យាករណ៍ជាច្រើនដែលបានធ្វើការសិក្សាឡើងដោយអ្នកវិទ្យាសាស្ត្រដែលគួរយកមកពិចារណាខណៈពេលកសាងផែនការរៀបចំដែនដី។ ការប្រែប្រួលអាកាសធាតុ

ជាឧទាហរណ៍មួយដែលវិទ្យាសាស្ត្រពិភពលោកបានយល់ស្រប ហើយវានឹងមានផលប៉ះពាល់ដល់ការប្រើប្រាស់និងការគ្រប់គ្រងដីធ្លី។ ការប្រែប្រួលអាកាសធាតុកើតឡើងភាគច្រើនដោយសារតែការប្រែប្រួលនៃវដ្តទឹក ដូច្នេះព័ត៌មានអាកាសធាតុសម្រាប់អនាគតអាចទាញយកមកពីគ្រោះធម្មជាតិដែលបានកើតឡើងពីអតីតកាលដូចជា៖ ទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។ ត្រូវធ្វើការឆ្លើយទៅនឹងសំនួរគន្លឹះមួយចំនួនគឺ ៖ តើអ្វីនឹងកើតមានឡើងប្រសិនបើទឹកជំនន់និងភាពរាំងស្ងួតក្នុងកម្រិតធ្ងន់ធ្ងរដែលបានរកឃើញកើតមានក្នុងអតីតកាលនឹងបន្តកើតមានឡើងញឹកញាប់នាពេលអនាគត? តើយើងត្រូវរៀបចំដោះស្រាយបញ្ហាទាំងនោះដោយរបៀបណា?

- វាប្រហាក់ប្រហែលគ្នានេះដែរ ក៏មានឧបករណ៍ដែលអាចយកមកប្រើបង្កើតសេណារីយ៉ូផងដែរ ដែលវាផ្អែក ទៅលើម៉ូដែលដែលបានដាក់កម្មវិធីហើយ (programmed models) ដូចជាឧបករណ៍បង្កើតសេណារីយ៉ូ InVEST instrument (http://www.naturalcapitalproject.org/invest/)។ វាផ្តល់នូវវិធីសាស្ត្រសាមញ្ញបំផុត សម្រាប់បង្កើតសេណារីយ៉ូដោយផ្អែកទៅលើគោលការណ៍ ដែលបានកំណត់ដោយអ្នកប្រើប្រាស់ផ្ទាល់នៅទីកន្លែងណាដែលអាចកើតមានការប្រែប្រួលដី និងទំហំវិសាលភាពតំបន់ដែលកើតមានការប្រែប្រួលដីនេះ។ វាអាចប្រើប្រាស់បង្កើតនូវលក្ខណៈពិសេសផ្សេងទៀតដែលជួយជម្រុញដល់ការយល់ដឹងពីទំនាក់ទំនង នៃការធ្វើសេចក្តីសម្រេចចិត្តលើការប្រើប្រាស់ដី។ សាកលវិទ្យាល័យភូមិន្ទភ្នំពេញបានធ្វើការសាកល្បង និងប្រើឧបករណ៍នេះសម្រាប់ការងារនៅខេត្តមណ្ឌលគិរី។
- វាក៏មានសារៈសំខាន់ណាស់ផងដែរ ក្នុងការស្វែងរកអ្វីដែលបានកើតមានពីមុននៅកន្លែងផ្សេងៗនៅក្នុងប្រទេស ឬពិភពលោក។ ការអភិវឌ្ឍរបស់ទីក្រុង និងតំបន់ណាមួយ គឺវាមានភាពប្រហាក់ប្រហែលគ្នាទៅនឹងទីក្រុងដទៃទៀតដែលស្ថិតនៅផ្នែកណាមួយរបស់ប្រទេស ឬពិភពលោក។ ការរៀនសូត្រពីតំបន់ផ្សេងៗដែលមានការអភិវឌ្ឍបីបួនជំហានមុន អាចជួយឲ្យយើងជៀសវាងនូវកំហុសក្នុងការកសាងផែនការ។ ឧទាហរណ៍ការលូតលាស់ផ្នែកសេដ្ឋកិច្ច អ្នកដែលមានលុយច្រើននឹងប្រើប្រាស់ឡានច្រើនដែលវានាំឲ្យមានផលប៉ះពាល់ដល់ការអភិវឌ្ឍដែនដីរបស់ទីក្រុង។

## អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- ការអនុវត្ត
    - ក្រុមការងារខេត្ត

## សកម្មភាពការងារ/វិធីសាស្ត្រ

- ដើម្បីកំណត់ និងពិភាក្សាពីទំនោរនៃការប្រែប្រួលនាពេលអនាគតទាំងនេះយើងអាចធ្វើការវិភាគសេណា រីយ៉ូទៅលើប្រធានបទសំខាន់ៗផ្សេងៗគ្នា៖
    - សេណារីយ៉ូកំណើនប្រជាសាស្ត្រ មានសារៈសំខាន់ណាស់សម្រាប់កសាងផែនការរៀបចំដែនដីដោយសារការប្រើប្រាស់ដី កើតមានឡើងដោយសារទំនាក់ទំនងរវាងមនុស្ស និងដី។

- ○ សេណារីយ៉ូការប្រែប្រួលការប្រើប្រាស់ដីក៏មានសារៈសំខាន់ប្រហាក់ប្រហែលគ្នាដែរ។ ទំនោរនៃការប្រែប្រួលពីអតីតកាលអាចប្រើសម្រាប់សេចក្តីសន្និដ្ឋានសម្រាប់អនាគត ក្នុងការស្វែងយល់ពីទំនោរនៃការប្រែប្រួលនគរូបនីយកម្ម ការកាប់បំផ្លាញព្រៃឈើ និងទម្រង់នៃការប្រែប្រួលការប្រើប្រាស់ដីផ្សេងៗទៀត។ ទំនោរការប្រែប្រួលដែលមានអាចផ្តល់ព័ត៌មានល្អថាតើសេណារីយ៉ូនៃការប្រែប្រួលការប្រើប្រាស់ដីណាអាចនឹងមានសារៈសំខាន់។
- ○ សេណារីយ៉ូផ្អែកលើម៉ូដែល (គម្រូ) ប្រៀបធៀប អាចជួយឲ្យយល់ថាតើការអភិវឌ្ឍប្រើប្រាស់ដីផ្សេងៗគ្នា នឹងមានឥទ្ធិពលលើគ្នាទៅវិញទៅមកដោយរបៀបណា (ដូចជាការពង្រីកផ្លូវនិងគម្របព្រៃឈើ ផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ និងការអភិវឌ្ឍលំនៅឋាន)។
- ○ សេណារីយ៉ូអភិវឌ្ឍន៍សេដ្ឋកិច្ចមានលក្ខណៈអាចធ្វើការស្រាវជ្រាវបាន ដោយផ្អែកទៅលើបទពិសោធន៍អន្តរជាតិអំពីថាតើការអភិវឌ្ឍពិតប្រាកដណាមួយនឹងមានឥទ្ធិពល (ដូចជាផ្លូវផ្សេងៗដែលភ្ជាប់ទៅនឹង ប៉ូលបណ្តុំសេដ្ឋកិច្ច)។
- ○ ការប្រែប្រួលអាកាសធាតុ រួមមានប្រធានបទចម្រុះអន្តរវិស័យ (Cross cutting themes) ដែលយើងត្រូវធ្វើការគិតគូរពាល់ពេលដែលយើងធ្វើការពិចារណា និងប្រមើលមើលពីការប្រែប្រួលនាពេលអនាគត។ កន្លែងដែលមានភាពរាំងស្ងួតកើនឡើង វាមានផលប៉ះពាល់ដល់ផលិតភាពកសិកម្ម ដូច្នេះការព្យាករណ៍ប្រជាសាស្ត្រត្រូវធ្វើការពិចារណាដល់សក្តានុពលនៃការធ្វើចំណាកស្រុករបស់កសិករដែលរងនូវផលប៉ះពាល់។ កន្លែងដែលមានការកើនឡើងកម្រិតនីវ៉ូទឹកសមុទ្រ និងទឹកជំនន់ជារឿយៗ វានឹងមានផលប៉ះពាល់ដល់លំនៅឋាន។ ដើម្បីបញ្ចូលការគិតគូរដល់បញ្ហាទាំងអស់នេះ យើងត្រូវការព័ត៌មានពីការប្រែប្រួលអាកាសធាតុហើយគួរធ្វើការវិភាគពីភាពងាយរងគ្រោះដោយអង្គការជំនាញ។

- ការបង្កើតសេណារីយ៉ូផ្សេងៗគ្នា វាទាមទារនូវកិច្ចខិតខំ និងចំណាយពេលខុសៗគ្នា។ វាគួររៀបចំពេល ពីមួយទៅពីរថ្ងៃសម្រាប់ការវិភាគសេណារីយ៉ូដ៏សំខាន់អំពីកំណើនប្រជាសាស្ត្រ។
- សេណារីយ៉ូដែលបានលើកឡើងមួយចំនួនគឺលើសពីសមត្ថភាពរបស់ក្រុមការងារខេត្ត។ ជាពិសេសការបង្កើតសេណារីយ៉ូដែលផ្អែកលើម៉ូដែល (model based) និងការវាយតម្លៃភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងផលវិបាករបស់វា ត្រូវទាមទារនូវជំនាញបន្ថែមទៀត។ ប្រសិនបើជំនាញនេះមិនបានបំពាក់បំប៉នជូនដល់ក្រុមការងារខេត្តនោះទេនោះវាទាមទារនូវជំនួយពីខាងក្រៅ។

## ក) សេណារីយ៉ូកំណើនប្រជាសាស្ត្រ

ការព្យាករណ៍ប្រជាសាស្ត្រ មានគោលបំណងធ្វើការប៉ាន់ប្រមាណពីចំនួនប្រជាជនសរុបក្នុងខេត្ត នៅក្នុងឆ្នាំខាងមុខណាមួយជាក់លាក់។ ការងារនេះ ពឹងផ្អែកទៅលើកំណើនប្រជាជន និងដង់ស៊ីតេប្រជាជនជាក់ស្តែងពីអតីតកាលនៅក្នុងស្រុកផ្សេងៗគ្នារបស់ខេត្ត។ វាក៏គួរធ្វើការពិចារណាពីកំណើនធម្មជាតិដែលរំពឹងទុក និងតុល្យភាពអន្តោប្រវេសន៍ប្រជាពលរដ្ឋរបស់ស្រុកនីមួយៗ។

- ប្រសិនបើអាចធ្វើទៅបាន គួរប្រមូលផ្តុំសុច្ចនាករប្រជាសាស្ត្រសំខាន់ៗទាំងអស់ដែលមានសម្រាប់ស្រុកនីមួយៗ។ ព័ត៌មានអំពីកំណើនប្រជាជនពីអតីតកាលនេះគួរធ្វើការញែកចេញពីគ្នារវាងកំណើនធម្មជាតិ (កើត មរណៈភាព និងអាយុសង្ឃឹមរស់) និងតុល្យភាពអន្តោប្រវេសន៍ (ចំណូលស្រុក និងចំណាកស្រុក)។
- ដោយផ្អែកទៅលើអត្រាកំណើនប្រជាជនពីអតីតកាលដែលទើបនឹងបានគណនាហើយ ក្រុមការងារត្រូវធ្វើការប្រមើលមើលពីសេណារីយ៉ូកំណើនបីបួនផ្សេងគ្នាសម្រាប់អនាគត ដោយផ្អែកទៅលើអត្រាទាំងពីរនេះ (ទាបជាងបន្តិច ប្រហាក់ប្រហែល ឬខ្ពស់ជាងបន្តិច) (រូបភាព៨)។ វាមានសារៈសំខាន់ក្នុងការពិចារណាទៅលើការព្យាករណ៍ប្រជាជនថ្នាក់ខេត្តដែលធ្វើឡើងដោយវិទ្យាស្ថានស្ថិតិជាតិ (វិទ្យាស្ថានស្ថិតិជាតិ ២០១០)




**រូបភាព៨៖** សេណារីយ៉ូកំណើនប្រជាជនខេត្តបាត់ដំបង ២០០៨ - ២០៣០ ដោយផ្អែកទៅលើអត្រាកំណើន ប្រជាជន ៣.១០%/ឆ្នាំ រវាងឆ្នាំ១៩៩៨ និង២០០៨

- ដើម្បីទទួលបាននូវសេណារីយ៉ូដែលកាន់តែមានភាពជាក់លាក់ ត្រូវធ្វើការព្យាករណ៍ប្រជាជនសម្រាប់ស្រុកនីមួយៗនៅក្នុងខេត្តដោយផ្អែកលើ ១) អត្រាកំណើនប្រជាជនជាក់លាក់របស់ស្រុក ២)ដង់ស៊ីតេប្រជាជនជាក់ស្តែងរបស់ស្រុក ៣) សក្តានុពលរបស់ស្រុកសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច (តារាង៥)។
- ប្រសិនបើអាចរកបានការវិភាគពីភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនោះ ក្រុមការងារខេត្ត គួរធ្វើការពិភាក្សាពីសក្តានុពលដែលមានឥទ្ធិពលដល់ការព្យាករណ៍ប្រជាជន។

**តារាង៤ ៖** សេណារីយ៉ូកំណើនប្រជាជនតាមស្រុក ក្នុងខេត្តបាត់ដំបង ២០០៨-២០៣០

| | កំណើនប្រជាជនអតីតកាល | | | ការព្យាករណ៍ប្រជាជន | |
|---|---|---|---|---|---|
| | ប្រជាជនសរុបឆ្នាំ ២០០២ | ប្រជាជនសរុបឆ្នាំ ២០០៧ | អត្រាកំណើនតាមស្រុក ២០០០-២០០៧ | អត្រាកំណើនតាមស្រុក (%/ឆ្នាំ) | ចំនួនប្រជាជនដែលបានព្យាករណ៍ ២០៣០ |
| បាណន់ | 83,631 | 94,039 | 1.75 | 1.75 | 140,152 |
| ថ្មគោល | 114,351 | 116,718 | 0.35 | 1 | 146,734 |
| បាត់ដំបង | 137,949 | 136,203 | -0.12 | 1.8 | 205,298 |
| បវេល | 92,035 | 95,847 | 2.75 | 2.5 | 169,133 |
| ឯកភ្នំ | 66,494 | 72,992 | 1.06 | 1 | 91,763 |
| មោងឫស្សី | 144,071 | 153,396 | 1.59 | 2 | 241,890 |
| រតនមណ្ឌល | 31,154 | 39,409 | 5.13 | 4 | 97,132 |
| សង្កែ | 108,281 | 115,564 | 1.22 | 1.2 | 152,046 |
| សំឡូត | 21,810 | 32,266 | 4.86 | 5 | 99,106 |
| សំពៅលូន | 16,318 | 21,397 | 5.89 | 5 | 65,721 |
| ភ្នំព្រឹក | 12,434 | 51,450 | 19.01 | 5 | 158,030 |
| កំរៀង | 25,906 | 42,992 | 17.87 | 5 | 132,051 |
| គាស់ក្រឡ | 25,476 | 26,623 | 0.74 | 3 | 52,543 |
| សរុប | 879,910 | 998,896 | | | **1,917,480** |

- ការព្យាករណ៍ចំនួនប្រជាជនជារួម សម្រាប់ខេត្តត្រូវបានធ្វើការប្រៀបធៀបជាមួយនឹងសេណារីយ៉ូប្រជាសាស្ត្រជាក់លាក់របស់ស្រុកទាំងអស់។ ជាលទ្ធផល សេណារីយ៉ូអត្រាកំណើនប្រជាជនកើន ៣% ក្នុងមួយឆ្នាំត្រូវបានជ្រើសរើសសម្រាប់ឧទាហរណ៍នេះ។

**ខ) សេណារីយ៉ូសម្រាប់ការប្រែប្រួលការប្រើប្រាស់ដី**

ព័ត៌មានពីការប្រែប្រួលការប្រើប្រាស់ដីរួមទាំងព័ត៌មានពីកម្លាំងចលករនៃការប្រែប្រួលទាំងនោះ គឺអាចរកបានសម្រាប់កម្រិតថ្នាក់ស្រុក និងខេត្ត ដែលវាជាសមិទ្ធិផលដែលកើតចេញពីជំហានការងារ ២.២ ដល់ ២.៥។ ដោយផ្អែកលើព័ត៌មានទាំងនេះ គឺវាមានលក្ខណៈគ្រប់គ្រាន់ក្នុងការចង្អុលបង្ហាញថាតើទំនោរនៃការប្រែប្រួលមួយណាគួរធ្វើការព្យាករណ៍ទៅថ្ងៃអនាគត ហើយស្ថិតនៅក្រោមលក្ខខណ្ឌអ្វី។ ឧទាហរណ៍ពីខេត្តបាត់ដំបងខាងក្រោម ការថយចុះគម្របព្រៃឈើដោយបានមកតាមការអង្កេតដោយមានការពង្រីកសិកម្មបន្ថែមត្រូវបានធ្វើការត្រួតពិនិត្យបន្ថែមទៀត តាមរយៈសេណារីយ៉ូសម្រាប់ការប្រែប្រួលការប្រើប្រាស់ដី។

- ធ្វើផែនទីស្តីអំពីការវិវត្តការប្រែប្រួលគម្របព្រៃឈើ (ផែនទីជាដំណាក់កាលពេលវេលា) ស្របជាមួយនឹងការអភិវឌ្ឍ/ពង្រីកតំបន់កសិកម្មនិងពិភាក្សាពីផលវិបាកដែលអាចកើតមានឡើងពាក់ព័ន្ធជាមួយនឹងសេណារីយ៉ូនៃការវិវត្តផ្សេងៗគ្នាៈ
    - ពិភាក្សាពីឱកាសដែលអាចនឹងកើតមានឡើងនៃការពង្រីកសិកម្ម (តម្រូវការដីនាពេលអនាគត) ដោយពិចារណាអំពីសេណារីយ៉ូកំណើនប្រជាសាស្ត្រ។
    - ពិភាក្សាពីសារៈសំខាន់នៃការអភិរក្សព្រៃឈើ និងផលវិបាកសង្គមនិងបរិស្ថានដែលអាចកើតមាន ដោយផ្អែកទៅលើការកាប់បំផ្លាញព្រៃឈើ/សេណារីយ៉ូដាំដើមឈើឡើងវិញ។
    - ពិភាក្សាពីសេណារីយ៉ូតុល្យភាពដែលនឹងជួយធានាដល់ការអភិវឌ្ឍកសិកម្ម និងការពារដល់ធនធានព្រៃឈើសម្រាប់ការគ្រប់គ្រងទីជម្រាលប្រកបដោយចីរភាព។




**ផែនទី ២៩ ៖** ការវិវត្តគម្របព្រៃឈើ និងការពង្រីកសិកម្មក្នុងខេត្តបាត់ដំបង

- វិធីសាស្ត្រសាមញ្ញមួយ គឺជាការប្រៀបធៀបសេណារីយ៉ូ "កិច្ចការកើតឡើងតាមធម្មតាតាមបែបធម្មជាតិ" ដែលនៅក្នុងករណីនេះការព្យាករណ៍អំពីអត្រានៃការបំលែងពីដីព្រៃទៅជាដីកសិកម្មកាលពីអតីតកាល រួមផ្សំជាមួយនឹងសេណារីយ៉ូអភិវឌ្ឍន៍ផ្សេងៗទៀត អាស្រ័យទៅលើការប៉ាន់ស្មានជាក់ស្តែងដែលនៅក្នុងករណី នេះអាចជាសេណារីយ៉ូ "អភិរក្ស" ឬក៏សេណារីយ៉ូ "រក្សាតុល្យភាព" ដែលបានស្នើឡើង។ជារៀយៗ គោលនយោបាយថ្នាក់ជាតិដូចជាគោលនយោបាយជាតិស្តីអំពី

ផែនការរៀបចំដែនដី នឹងផ្តល់នូវការតម្រង់ទិសថាតើសេណារីយ៉ូមួយណាដែលត្រឹមត្រូវគួរយកមកប្រើប្រាស់ជាងគេ។

- ឧទាហរណ៍ផ្សេងទៀតអំពីសេណារីយ៉ូអភិវឌ្ឍទម្រង់លក្ខណៈនៃការតាំងទីលំនៅ។ ទំនោរនៃការប្រែប្រួលសំខាន់ៗនៃការពង្រីកលំនៅឋានដែលគួរយកមកធ្វើការពិចារណា គឺលំនៅឋានតាមប្រព័ន្ធផ្លូវដឹកជញ្ជូនសំខាន់ៗ និងសំខាន់បន្ទាប់ទីពីរការពង្រីកទម្រង់លក្ខណៈតំបន់តាំងទីលំនៅបន្ទាប់ពីមានចំណាកស្រុកពីតំបន់ទំនាបទៅតំបន់ខ្ពង់រាប និងការពង្រីកទម្រង់លក្ខណៈតំបន់តាំងទីលំនៅដែលមានស្រាប់នៅតំបន់ទីប្រជុំជន។ ដោយផ្អែកទៅលើសេណារីយ៉ូអភិវឌ្ឍផ្សេងៗគ្នា(ដូចខាងលើ) ត្រូវធ្វើការពិភាក្សាពីផលវិបាក និងប្រភេទបញ្ហាដែលនឹងត្រូវធ្វើការដោះស្រាយតាមរយៈការផ្តល់ហេដ្ឋារចនាសម្ព័ន្ធសង្គម និងរូបវន្ត និងការ បង្កើតការងារ។
- **គន្លឹះសំខាន់៖** សេណារីយ៉ូសាមញ្ញនៃការប្រែប្រួលការប្រើប្រាស់ដី មិនត្រឹមតែប្រើសម្រាប់សកម្មភាពជាក់ស្តែងនោះទេវាអាចប្រើសម្រាប់ការប្រែប្រួលការប្រើប្រាស់ដីដែលបានប្រមើលមើលទុកមុន ដូចជាគម្រោងអភិវឌ្ឍសំខាន់ៗដែលបានធ្វើផែនការហើយ (ផ្លូវថ្មី ទំនប់ លំនៅឋានសម្បទាន។ល។)។ ខណៈដែលគ្មានទំនោរនៃការប្រែប្រួល អាចត្រូវបានធ្វើការព្យាករណ៍នៅទីនោះផលវិបាកអាចត្រូវបានធ្វើការពិភាក្សា(ដោយមានបទពិសោធន៍ក្នុងស្រុកគ្រប់គ្រាន់) និងសេណារីយ៉ូដទៃទៀតជាច្រើនត្រូវបានប្រមើលមើលទុកមុន។

### គ) ភាពងាយរងគ្រោះ និងសេណារីយ៉ូប្រែប្រួលអាកាសធាតុ

ប្រទេសកម្ពុជាមានភាពងាយរងគ្រោះខ្លាំងទៅនឹងការប្រែប្រួលអាកាសធាតុ ដោយប្រជាជនមួយផ្នែកធំនៅកម្ពុជា ពឹងផ្អែកទៅលើវិស័យដែលអាស្រ័យលើអាកាសធាតុសម្រាប់ចិញ្ចឹមជីវិត ដូចជាជលផលនិងកសិកម្មពឹងផ្អែកលើទឹកភ្លៀង។ នៅក្នុងប្រទេសកម្ពុជាការប្រែប្រួលអាកាសធាតុកើតឡើងតាមរយៈការកើនឡើងនៃវដ្តរបស់ទឹកដែលនាំឲ្យកើតមាននូវព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ (extreme weather) កើនឡើង (ទឹកជំនន់ ខ្យល់ព្យុះ និងភាពរាំងស្ងួតជាដើម។ល។)។ ភាពងាយរងគ្រោះតាមវិស័យនីមួយៗ ប្រព័ន្ធឬតំបន់ជាក់លាក់មួយចំនួន ដោយសារការប្រែប្រួលទាំងនេះអាស្រ័យទៅលើការទទួលរងនូវភាពប្រឈម (Exposure) ទៅនឹងហានិភ័យ ភាពរួសរបស់វា (sensitivity) (ក្នុងកម្រិតណាមួយដែលវានឹងត្រូវរងផលប៉ះពាល់) និងអាស្រ័យទៅលើសមត្ថភាពរបស់វាក្នុងការសម្របទៅនឹងការប្រែប្រួលទាំងនោះ។ ការវាយតម្លៃពីភាពងាយរងគ្រោះ អាចមានចាប់ពីការវាយតម្លៃសាមញ្ញដែលមានគោលបំណងចំបងក្នុងការយល់ដឹងជាទូទៅ រហូតដល់ការវាយតម្លៃដែលមានភាពស្មុគស្មាញខ្លាំង។ អ្វីដែលអាចធ្វើទៅបាន និងសមហេតុសមផលសម្រាប់ផែនការរៀបចំដែនដីថ្នាក់ខេត្ត គឺត្រូវពឹងផ្អែកជាចំបងទៅលើជំនាញការ និងសមត្ថភាពដែលអាចរកបាន។

<table>
<tr><th colspan="3">ប្រអប់ព័ត៌មាន</th></tr>
<tr><td colspan="3">ភាពងាយរងគ្រោះ៖ ត្រូវបានឲ្យនិយមន័យថាជា "កម្រិតដែលប្រព័ន្ធមួយងាយរងគ្រោះ ឬមិនអាចធ្វើការដោះស្រាយជាមួយនឹងផលអវិជ្ជមានពីការប្រែប្រួលអាកាសធាតុបានរួមមាន វិសមប្បអាកាសធាតុនិងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ (McCarthy, Canziani, Leary, Dokken, & White, 2001)" ។ នៅក្នុងនិយមន័យនេះ ប៉ារ៉ាម៉ែត្រសំខាន់នៃភាពងាយរងគ្រោះ គឺបញ្ហាទាំងឡាយដែលបង្កផលប៉ះពាល់ដល់ប្រព័ន្ធមួយឲ្យទទួលរងនូវភាពប្រឈម ភាពរួសរបស់វា និងសមត្ថភាពសម្របខ្លួនរបស់វាផងដែរ។</td></tr>
<tr><td>ភាពប្រឈម(Exposure)</td><td>ភាពរួស (Sensitivity)</td><td>សមត្ថភាពសម្របខ្លួន</td></tr>
<tr><td>ភាពប្រឈម គឺទាក់ទងទៅនឹងធម្មជាតិ និងកម្រិតដែលប្រព័ន្ធមួយ ជួបប្រទះបញ្ហា(ភាពតានតឹង) នយោបាយ សង្គម ឬ បរិស្ថាន ។ លក្ខណៈសម្បត្តិ នៃបញ្ហា (ភាពតានតឹង)រួមមានទំហំនៃបញ្ហា ភាពញឹកញាប់នៃការកើតមានបញ្ហា រយៈពេលដែលកើតមាន និងទំហំតំបន់ ដែលទទួលរងគ្រោះមហន្តរាយ។</td><td>ភាពរួស គឺជាកម្រិតដែលតំបន់ ឬសហគមន៍មួយអាចរងនូវផលប៉ះពាល់ (វិជ្ជមាននិងអវិជ្ជមាន) ពីការប្រែប្រួលទាំងនោះ (ទាក់ទងនឹងអាកាសធាតុ)</td><td>សមត្ថភាពសម្របខ្លួន គឺជាសមត្ថភាពរបស់ប្រព័ន្ធមួយក្នុងការសម្របទៅនឹងការផ្លាស់ប្តូរនិងការប្រែប្រួលអាកាសធាតុ ទៅនឹងការបំផ្លាញសក្តានុពលមួយចំនួន ទៅនឹងការទាញផលប្រយោជន៍ពីឱកាសនោះ ឬក៏ទៅនឹងការដោះស្រាយជាមួយផលវិបាកផ្សេងៗ។</td></tr>
</table>

- នៅក្នុងកម្រិតថ្នាក់ខេត្ត ក្រុមការងារខេត្ត គួរស្វែងយល់ថាតើមានទិន្នន័យប្រែប្រួលអាកាសធាតុដែលអាចរកបានទេសម្រាប់តំបន់។ ការវិភាគពីភាពងាយរងគ្រោះទូទៅមួយ ដែលគ្របដណ្តប់ទៅលើធនធាន និងការប្រើប្រាស់ដីផ្សេងៗគ្នា គួរជាការងារដ៏ប្រសើរមួយសម្រាប់កម្រិតថ្នាក់ក្រុង ក៏ដូចជាប្លង់គោលប្រើប្រាស់ដីថ្នាក់ស្រុក។នៅក្នុងកម្រិតថ្នាក់ខេត្ត ការវាយតម្លៃរួមនិងល្បឿនពីភាពដែលងាយរងគ្រោះរបស់ប្រព័ន្ធប្រើប្រាស់ដីផ្សេងៗគ្នាចំពោះផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុផ្សេងៗដែលបានប្រមើលមើល អាចជាការងារដែលគួរឲ្យចាប់អារម្មណ៍ ហើយសម្រាប់ក្រុមការងារអាចយល់ពីបញ្ហាទាំងនោះ៖
  - វាស់/កំណត់ធនធាន និងសម្បត្តិសំខាន់ៗសម្រាប់ប្រព័ន្ធប្រើប្រាស់ដីនីមួយៗ ។
  - កម្រិតទំហំភាពប្រឈមរបស់វាចំពោះព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរ ឧ.ដូចជាក្នុងកម្រិតពី១ ទៅ១០។
  - វាស់/កម្រិតទំហំភាពរួសរបស់វា ឧ.ដូចជាក្នុងកម្រិតពី១ ទៅ១០។
  - វាស់/កម្រិតទំហំសមត្ថភាពសម្របខ្លួនរបស់វា ឧ.ដូចជាក្នុងកម្រិតពី១ ទៅ១០។
  - គណនាភាពងាយរងគ្រោះរបស់ប្រព័ន្ធប្រើប្រាស់ដីនីមួយៗទៅនឹងហេតុការណ៍ផ្សេងៗ រៀបចំឯកសារមូលហេតុនៃការរងគ្រោះ។
  - ពិភាក្សាពីវិធីសាស្ត្រដែលមានសក្តានុពលដើម្បីសម្របខ្លួន។

- អ្នកវិទ្យាសាស្ត្រ និងអ្នកធ្វើការងារអភិវឌ្ឍបានធ្វើការបង្កើត និងធ្វើការសាកល្បងនូវវិធីសាស្ត្រផ្សេងៗក្នុងការស្វែងយល់ និងវាស់វែងពីភាពងាយរងគ្រោះ។ នៅក្នុងខេត្តបាត់ដំបងក្រុមអ្នកស្រាវជ្រាវធ្វើការងារសហការជាមួយនឹងក្រុមការងារខេត្ត បានបង្កើតវិធីសាស្ត្រវិភាគពីភាពងាយរងគ្រោះនៃការបង្កបង្កើនផលកសិកម្មទៅនឹងទឹកជំនន់។ ការស្រាវជ្រាវមើលទៅលើភាពងាយរងគ្រោះបីកម្រិតផ្សេងគ្នា៖ សម្រាប់តំបន់ទី ជម្រាល សម្រាប់ថ្នាក់ឃុំ និងសម្រាប់កម្រិតគ្រួសារ។ ក្នុងកម្រិតថ្នាក់ឃុំបានបង្កើតនូវផែនទីនៃភាពងាយគ្រោះនៅក្នុងកម្រិតផ្សេងៗគ្នា ដែលអាចធ្វើការបកស្រាយដោយផ្អែកលើភាពផ្សេងៗគ្នានៃប្រព័ន្ធអេកូកសិកម្ម (agro-ecological) នៅទីជម្រាល។




**ផែនទី៣០ ៖** ភាពងាយរងគ្រោះនៃផលិតផលកសិកម្មទៅនឹងទឹកជំនន់ (តាមឃុំ)

វាលើសពីអ្វីដែលត្រូវបរិយាយនៅក្នុងសៀវភៅនេះ ក្នុងការពិនិត្យទៅលើវិធីសាស្ត្រផ្សេងៗបន្ថែមទៀត ប៉ុន្តែអ្នកអានអាចមើលបន្ថែមសៀវភៅដែលសរសេរទាក់ទងនឹងជំនាញនេះ ឧទាហរណ៍ដូចជាការនិពន្ធដោយ (Doch, Diepart, & Heng, 2015) ។

### លទ្ធផលរំពឹងទុក៖

- ការពិភាក្សាដែលបានរៀបចំបានជាឯកសារស្តីអំពីថាតើសេណារីយ៉ូប្រជាសាស្ត្រផ្សេងៗមានអ្វីខ្លះ។
- ការពិភាក្សាដែលបានរៀបចំបានជាឯកសារស្តីអំពីសេណារីយ៉ូនៃការប្រែប្រួលការប្រើប្រាស់ដី។
- ការពិភាក្សាដែលបានរៀបចំបានជាឯកសារស្តីអំពីទំនោរនៃការប្រែប្រួលអាកាសធាតុ និងសេណារីយ៉ូអំពីផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុជាមួយនឹងការពិពណ៌នាពីភាពងាយរងគ្រោះតាមតំបន់ទៅនឹងព្រឹត្តិការណ៍ធាតុអាកាសធ្ងន់ធ្ងរជាក់លាក់ ( specific extreme weather events)។

## ការងារ ៣.២ ការពិពណ៌នាពីចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍រយៈពេលវែង

### ស្ថានភាពទូទៅ

ផែនការរៀបចំដែនដី គឺជាឧបករណ៍យុទ្ធសាស្ត្រមួយសម្រាប់ការអភិវឌ្ឍដែនដីដោយសារវាធ្វើការផ្តោតសំខាន់ទៅលើការស្វែងរកនូវមធ្យោបាយដ៏ល្អបំផុត ថាតើត្រូវប្រែក្លាយពីស្ថានភាពបច្ចុប្បន្នឲ្យឈានទៅដល់ស្ថានភាពអនាគតមួយតាមការចង់បានដោយរបៀបណា។ ខណៈដែលការងារមុនៗបានធ្វើការកំណត់ពីទម្រង់លក្ខណៈដែនដីបច្ចុប្បន្នរបស់ខេត្ត ហើយជួយឲ្យយល់ពីសក្តានុពលនិងសេណារីយ៉ូអនាគតដែលបានប្រមើលមើល និងសក្តានុពលសម្រាប់អភិវឌ្ឍន៍ដែនដី ការងារនេះធ្វើឡើងដើម្បីទទួលបាននិងពិពណ៌នាពីអនាគតដែលជាការចង់បានរបស់អ្នកពាក់ព័ន្ធទាំងអស់។

សមាសភាពគន្លឹះសំខាន់ៗពីរដើម្បីសម្រេចបានអនាគតតាមការចង់បាននេះគឺ ចក្ខុវិស័យនៃការអភិវឌ្ឍនាពេលអនាគត និងគោលដៅអភិវឌ្ឍន៍រយៈពេលវែងដែលមានភាពស៊ីគ្នា។ ការចាប់ផ្តើមដំណើការកសាងផែនការរៀបចំដែនដីនៅក្នុងប្រទេសកម្ពុជា បានចោទជាសំនួរដដែលៗថាតើត្រូវបង្កើតអ្វីមុន ចក្ខុវិស័យ ឬក៏សមាសភាគរបស់វាមុន (ឬគោលដៅរយៈពេលវែងមុន)។ ជារូមវិធីសាស្ត្រទាំងពីរអាចយកមកប្រើបាន។ ទោះបីជាយ៉ាងណាក៏ដោយការត្រឡប់ចុះឡើងរវាងការបង្កើតសមាសភាគទាំងពីរនេះ គឺមិនអាចជៀសផុតបាននោះទេ ដោយវាទាំងពីរត្រូវបំពេញបន្ថែមឲ្យគ្នាទៅវិញទៅមក ប៉ុន្តែទាំងពីរនេះមានលក្ខណៈសំខាន់ច្បាស់លាស់ រៀងៗខ្លួន។

តួនាទីរបស់ចក្ខុវិស័យ គឺជាគោលការណែនាំមួយដែលផ្តល់នូវគំនិតស្នូលសម្រាប់អភិវឌ្ឍន៍ដែនដីរបស់ខេត្ត។ គោលដៅរយៈពេលវែង ទោះជាមានលក្ខណៈទូលំទូលាយក៏ដោយ គឺវាឆ្លើយតបទៅនឹងទិសដៅសំខាន់បំផុតសម្រាប់ការអភិវឌ្ឍដែនដីខេត្ត។ វាមិនគួរមានការត្រួតជាន់គ្នានោះទេ ប៉ុន្តែវាគួរតែមានលក្ខណៈទូលំទូលាយ ដែលបានដាក់បញ្ចូលនូវរាល់បញ្ហាសំខាន់ៗទាំងអស់ដែលបានរកឃើញតាមរយៈការវិភាគស្ថានភាពនិងការអភិវឌ្ឍសេណារីយ៉ូ។ ដោយវាជាការចាប់ផ្តើមសម្រាប់ការរៀបចំយុទ្ធសាស្ត្រអភិវឌ្ឍន៍លម្អិតសម្រាប់ការ អភិវឌ្ឍដែនដី ដូច្នេះការបង្កើតនូវចក្ខុវិស័យ និងគោលដៅរយៈពេលវែង គួរឆ្លុះបញ្ចាំងទាំងអាទិភាពរបស់អ្នកពាក់ព័ន្ធ និងតម្រូវការបច្ចេកទេស។ ការសម្របសម្រួល គឺជាការងារប្រឈមដ៏លំបាកមួយសម្រាប់កិច្ចការនេះ។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកផ្តួចផ្តើម
    - ក្រុមការងារខេត្ត

- អ្នកដែលត្រូវចូលរួម
    - អ្នកពាក់ព័ន្ធទាំងអស់ (តារាង១)
- ការគាំទ្រ
    - ក្រុមប្រឹក្សាខេត្ត
    - គ.ជ.ន.ខ

**សកម្មភាពការងារ/វិធីសាស្ត្រ**

- ការងារនេះ ទាមទារការរៀបចំឲ្យបានហ្មត់ចត់ដោយក្រុមការងារខេត្ត សម្រាប់សិក្ខាសាលាធំមួយ ដែលមានអ្នកចូលរួមច្រើន ហើយអាចមានការកែតម្រូវឡើងវិញ និងបន្តការស្វែងរកការគាំទ្រពី គ.ជ.ន.ខ និងក្រុម ប្រឹក្សាខេត្ត។
- អ្នកចូលរួម នឹងត្រូវស្វែងយល់តាមរយៈការធ្វើបទបង្ហាញ និងការពិភាក្សា៖
    - ទំនាក់ទំនងការងារនេះ (ដំណាក់កាលនេះ) នៅក្នុងដំណើរការកសាងផែនការ។
    - ទម្រង់លក្ខណៈដែនដីបច្ចុប្បន្នរបស់ខេត្តជាមួយនឹងសមាសភាគទាំងបីរបស់វានិងសារៈសំខាន់ របស់របស់វា។ ព័ត៌មាន និងផែនទីដែលបានជ្រើសរើសពីការងារ ២.២ និង២.៣ អាចជួយ គាំទ្រដល់បទបង្ហាញនេះ។
    - សក្តានុពល និងសេណារីយ៉ូដែលបានប្រមើលមើលទុកមុន សម្រាប់ការអភិវឌ្ឍដែនដីនាពេល អនាគត។
    - តួនាទីរបស់ចក្ខុវិស័យនិងគោលដៅរយៈពេលវែង និងគោលការណ៍ដែលប្រើប្រាស់សម្រាប់ បង្កើតចក្ខុវិស័យនិងគោលដៅ។
    - វិធីសាស្ត្រក្នុងការបង្កើតចក្ខុវិស័យ និងគោលដៅ និងការពាក់ព័ន្ធរបស់វា។
- គោលការណ៍សម្រាប់បង្កើតគោលដៅរយៈពេលវែង ត្រូវបានកំណត់ទោះបីជាមិនទាន់បានកត់ សម្គាល់ច្បាស់លាស់នៅក្នុងគោលនយោបាយជាតិស្តីអំពីការកសាងផែនការរៀបចំដែនដី។ គោលបំណង (២.៣) នៃគោលនយោបាយ ដែលជាទូទៅហៅថា "យុទ្ធសាស្ត្រ" (ជាពិសេសការងារ ៤.១, ៤.៣ រហូតដល់៤.៧) ផ្តល់នូវការតម្រង់ទិសជាគោលនយោបាយផ្សេងៗ ដែលគោលដៅ (ហើយគោលបំណង និងសកម្មភាពបន្តបន្ទាប់) ត្រូវស្របជាមួយវា។ ក្រុមការងារគួរមានចំណេះដឹង ច្រើនទាក់ទងនឹងការបង្កើតគោលនយោបាយ គន្លឹះទាំងនេះដើម្បីជាមាគ៌ាណែនាំដល់ការសម្រេចចិត្ត។
- វិធីសាស្ត្រក្នុងការបង្កើតនេះ គឺផ្អែកទៅលើការពិគ្រោះយោបល់ដោយមានការសម្របសម្រួល ដែល អាចចាប់ផ្តើមជាមួយនឹងការងារប្រហាក់ប្រហែលទៅនឹងការវិភាគ SWOT ដើម្បីរៀបចំមូលដ្ឋានគ្រឹះ សម្រាប់ការពិភាក្សាបន្តបន្ទាប់ទៀតនៃគំនិតសម្រាប់ការអភិវឌ្ឍតាមការចង់បាននៅក្នុងខេត្ត។ វាទាក់ទងបន្ថែមទៀតជាមួយនឹងការប្រើប្រាស់តារាងម៉ាទ្រីក (matrix) យុទ្ធសាស្ត្រអភិវឌ្ឍន៍លម្អិត ដែលធ្វើការញែកចេញនូវប្រភេទផ្សេងៗគ្នា នៃសំណើដែលបានលើកឡើងដោយអ្នកពាក់ព័ន្ធ

(គោលដៅរយៈពេលវែង គោលបំណងយុទ្ធសាស្ត្រ សកម្មភាពចំបង ឬបន្ទាប់បន្សំ)។ អ្នកពាក់ព័ន្ធនឹងមានការលំបាកក្នុងការលើកឡើងនូវ "កម្រិតត្រឹមត្រូវលម្អិត" តារាងម៉ាទ្រីកធានាថាគ្មានគំនិតណាមួយនឹងត្រូវបាត់បង់នោះទេ វាត្រូវមានទំនាក់ទំនងជាមួយគ្នា ហើយជៀសវាងនូវការត្រួតជាន់គ្នា។ គួរធ្វើការប្រមូលគំនិតទាំងឡាយសម្រាប់ចក្ខុវិស័យក្នុងទម្រង់អនាមិកតាមរយៈកាតដែលបានចែកជូនតាំងពីចាប់ផ្តើមដំបូង វាគួរធ្វើការប្រមូលនៅពាក់កណ្តាលពេលពិភាក្សា ហើយគួធ្វើការពិភាក្សានៅពេលចុងបញ្ចប់នៃសិក្ខាសាលា។ អ្នកចូលរួមនឹងយល់ត្រួសៗពីទំហំនៃការអភិវឌ្ឍដែលចង់បានហើយអាចយល់ថាតើចក្ខុវិស័យដែលបានស្នើឡើងណាខ្លះអាចបញ្ចូលនូវអ្វីដែលជាការចង់បានទាំងអស់នេះទៅក្នុងពាក្យស្លោកដែលមានការទាក់ទាញមួយ។

- ដើម្បីឲ្យអ្នកពាក់ព័ន្ធទាំងអស់ចូលរួមយ៉ាងសកម្ម និងជាការចូលរួមដែលមានការរៀបចំបានទុកជាមុនដើម្បីពិភាក្សាលើប្រធានបទដែលមានភាពស្រពេចស្រពិលនេះ ជាបញ្ហាប្រឈមខ្លាំងផងដែរចំពោះអ្នកសម្របសម្រួល។ ក្រុមការងារខេត្តគួរធ្វើការពិភាក្សាពីវិធីសាស្ត្រដែលលក្ខណៈច្នៃប្រឌិតសម្រាប់សម្របសម្រួលនៅក្នុងការរៀបចំសិក្ខាសាលានេះផងដែរ។ ជាពិសេសគួរមានបញ្ចូលពីរបៀបដឹកនាំការពិភាក្សាឲ្យចំប្រធានបទនិងវិស័យដែលត្រូវបានពិនិត្យមើលកន្លងមក ដោយមិនធ្វើឲ្យមានការបញ្ឈប់ដំណើរការពិគ្រោះយោបល់ ពិភាក្សាដែលកំពុងតែមានឡើយ។ ការពិគ្រោះយោបល់ជាមួយគ្នាជាមុននូវរាល់បញ្ហាទាំងអស់នេះក៏ជាផ្នែកមួយរបស់យុទ្ធសាស្ត្រនេះដែរ។
- បន្ទាប់ពីសិក្ខាសាលា ក្រុមការងារ ត្រូវធ្វើការត្រួតពិនិត្យតារាងម៉ាទ្រីកឲ្យបានល្អិតល្អន់ លប់ចោលនូវអ្វីដែលជាន់គ្នាឬការងារដែលបានធ្វើខុស (ឧ.សកម្មភាពជាគោលបំណងជាដើម) ពិនិត្យមើលពីការមិនបានភ្ជាប់គ្នា និងភាពមិនស៊ីគ្នា ក៏ដូចជាធ្វើការពិចារណាជារួមទៅលើតារាងម៉ាទ្រីកនេះ។
- ចក្ខុវិស័យ និងគោលដៅរយៈពេលវែងដែលបានចេញជាលទ្ធផលហើយ គួរត្រូវបានគាំទ្រដោយគ.ដ.ន.ខ និងក្រុមប្រឹក្សាខេត្ត ដើម្បីឲ្យមានអាណត្តិច្បាស់លាស់មួយសម្រាប់ការបកស្រាយលម្អិតលើយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី។ ឧទាហរណ៍មួយពីខេត្តបាត់ដំបងនៃគោលដៅរយៈពេលវែង និងការពន្យល់របស់វាមានបង្ហាញនៅចំណុចលទ្ធផលរំពឹងទុកខាងក្រោមនេះ។

## លទ្ធផលរំពឹងទុក

- គោលដៅអភិវឌ្ឍន៍រយៈពេលវែងជាក់លាក់ត្រូវបានបង្កើតឡើងនិងធ្វើការពន្យល់ល្អិតល្អន់ស្របទៅនឹងការវិភាគស្ថានភាព និងសេណារីយ៉ូអភិវឌ្ឍន៍នាពេលអនាគត។ គោលដៅរយៈពេលវែងនេះត្រូវបានបំពេញបន្ថែមដោយចក្ខុវិស័យដ៏សំខាន់សម្រាប់ការអភិវឌ្ឍដែនដីនាពេលអនាគត។
- គោលដៅអភិវឌ្ឍន៍រយៈពេលវែងត្រូវបានធ្វើការពន្យល់ និងបានរៀបចំជាឯកសារសង្ខេប។

- តារាងម៉ាទ្រីកយុទ្ធសាស្ត្រអភិវឌ្ឍន៍លម្អិត (A log-frame matrix) ត្រូវបានបង្កើតឡើងដែលក្នុងនោះមានលើសពីគោលដៅរយៈពេលវែង គឺគំនិតដំបូងសម្រាប់គោលដៅយុទ្ធសាស្ត្រ និងសកម្មភាពសំខាន់ៗ ។

ឧទាហរណ៍៖ គោលដៅអភិវឌ្ឍន៍រយៈពេលវែងទាំង ៥ របស់ខេត្តបាត់ដំបង ៖

**ជាតំបន់បង្កបង្កើនផលកសិកម្មដែលមានគុណភាពខ្ពស់ប្រកបដោយចីរភាព**

ខេត្តបាត់ដំបង នឹងពង្រឹងតួនាទីរបស់ខ្លួនជាអ្នកផលិតនូវផលិតផលកសិកម្មចម្រុះដែលមានគុណភាពខ្ពស់នៅក្នុងតំបន់ពាយ័ព្យក៏ដូចជានៅក្នុងប្រទេសកម្ពុជា។ ខេត្តបាត់ដំបងមានសក្តានុពលកសិកម្មខ្ពស់ដែលនឹងអាចយកមកប្រើប្រាស់ ដើម្បីជួយបង្កើនផលិតភាពកសិកម្មតាមរយៈបច្ចេកទេសទំនើបស្រូវប្រពលវប្បកម្ម ដែលនឹងចូលរួមចំណែកដល់ការថែរក្សានូវសុវត្ថិភាពស្បៀងនៅក្នុងតំបន់ក៏ដូចជានៅក្នុងប្រទេសកម្ពុជាទាំងមូល។ ម្យ៉ាងវិញទៀតចំការដំណាំនឹងជួយពង្រឹងដល់ការផ្គត់ផ្គង់ផលិតផលកសិកម្មចម្រុះជាច្រើនប្រភេទដល់ ទីផ្សារនៅក្នុងតំបន់ ក្នុងស្រុក និងទីផ្សារអន្តរជាតិ។ ដើម្បីធានាឲ្យបាននូវកំណើនលើវិស័យកសិកម្មប្រកបដោយចីរភាពនោះតំបន់កសិកម្មនឹងត្រូវបានកំណត់ក្នុងដែនដីរបស់ខេត្តទៅតាមគោលការណ៍នៃការគ្រប់គ្រងទី ជម្រាលប្រកបដោយចីរភាព។

**ជាមជ្ឈមណ្ឌលពាណិជ្ជកម្ម និងកែច្នៃផលិតផលកសិកម្ម**

ខេត្តបាត់ដំបង នឹងជាមជ្ឈមណ្ឌលនៅក្នុងតំបន់មួយសម្រាប់ធ្វើការប្រមូលផ្តុំការទិញលក់ និងការកែច្នៃផលិតផលកសិកម្មហើយ និងចូលរួមជម្រុញដល់ការផ្សព្វផ្សាយពីផលិតផលរបស់ខេត្តឲ្យបានស្គាល់ទូទាំងប្រទេស។ ចំពោះការកែច្នៃផលិតផលកសិកម្មក្រោយពេលប្រមូលផល នឹងកើនតម្លៃបន្ថែមតាមរយៈខ្សែសង្វាក់ផលិតកម្ម ផលិតផលកសិកម្មដែលជាកត្តាមួយបង្កើតឲ្យមានការងារធ្វើ និងលើកទឹកចិត្តដល់សហគ្រាសក្នុងតំបន់។ ជាមួយគ្នានេះដែរការខិតខំប្រឹងប្រែងលើការកែច្នៃផលិតផលកសិកម្មនេះនឹងជួយលើកស្ទួយដល់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋនិងចូលរួមចំណែកដល់ការអភិវឌ្ឍតំបន់ជនបទនៅក្នុងខេត្តបាត់ដំបង។

**ជាតំបន់ទេសចរណ៍ វប្បធម៌ ប្រវត្តិសាស្ត្រ និងធម្មជាតិ**

ខេត្តបាត់ដំបង នឹងក្លាយជាមជ្ឈមណ្ឌលទេសចរណ៍សំខាន់នៅក្នុងប្រទេសកម្ពុជា។ វិស័យទេសចរណ៍នឹងត្រូវបានលើកកំពស់ទៅតាមលក្ខណៈពិសេសរបស់វា៖ ប្រវត្តិសាស្ត្រ អត្តសញ្ញាណវប្បធម៌ និងសម្បត្តិធម្ម ជាតិ។ មរតកស្ថាបត្យកម្ម និងបុរាណវិទ្យារបស់ខេត្ត នឹងត្រូវបានធ្វើការអភិរក្ស និងអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ទីតាំងសាសនាដែលមានភាពទាក់ទាញភ្ញៀវទេសចរណ៍ដូចជា៖ វត្តអារាម ព្រៃភ្នំដែលជាកន្លែងទីសក្ការៈ និងជំនឿផ្សេងៗ នឹងត្រូវការពារទាំងនៅក្នុងតំបន់ជនបទ និង

ទីក្រុងសម្រាប់ភាពចាំបាច់ផ្នែកវប្បធម៌របស់វា។ អេកូទេសចរណ៍ ដែលគោរពដល់បរិស្ថានធម្មជាតិ នឹងក្លាយជាកម្លាំងចលករមួយយ៉ាងសំខាន់ក្នុងការលើកស្ទួយនិងជម្រុញការការពារធនធានធម្មជាតិ។

**ជាតំបន់អភិបាលកិច្ច និងអភិវឌ្ឍន៍ធនធានមនុស្ស**

ខេត្តបាត់ដំបង នឹងក្លាយទៅជាខេត្តគំរូមួយសម្រាប់ការងារអភិបាលកិច្ចល្អ។ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ នឹងធ្វើឡើងតាមបែបលទ្ធិប្រជាធិបតេយ្យ តម្លាភាព យុត្តិធម៌ និងគោរពទៅតាមក្របខ័ណ្ឌច្បាប់ដែលតម្រូវឲ្យមានការចូលរួមពីភាគីពាក់ព័ន្ធជាច្រើនដូចជា៖ អង្គការសហគមន៍ ភ្នាក់ងាររដ្ឋាភិបាល សង្គមស៊ីវិល វិស័យឯកជន និងសាធារណជន។ ភាពជាដៃគូរវាងវិស័យឯកជន និងសាធារណៈក្នុងការគ្រប់គ្រងតំបន់នឹងត្រូវបានបង្កើតឡើង ហើយសហគមន៍នឹងត្រូវបានទទួលស្គាល់ថាជាជនបង្គោលសម្រាប់ការអភិវឌ្ឍជនបទ។

**ជាតំបន់សមាហរណកម្មដ៏សមស្របមួយរវាងសេដ្ឋកិច្ច វប្បធម៌ និងធម្មជាតិ**

ខេត្តបាត់ដំបង នឹងក្លាយជាខេត្តគំរូមួយក្នុងការធ្វើការអភិវឌ្ឍដែនដីរបស់ខ្លួន ប្រកបដោយតុល្យភាពល្អរវាងតំបន់សាងសង់ និងតំបន់លំហ។ រចនាសម្ព័ន្ធ និងលក្ខខណ្ឌនៃដែនដីនឹងផ្តល់ឱកាសសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងដោយសារមានប្រព័ន្ធគមនាគមន៍ល្អប្រសើរបានផ្តល់ភាពងាយស្រួលក្នុងការទទួលបាននូវសេវាសង្គមផ្សេងៗតាមរយៈអ័ក្សដឹកជញ្ជូន។ ប្រព័ន្ធបរិស្ថានផ្សេងៗគ្នា នឹងត្រូវធ្វើការការពារនៅគ្រប់ទីកន្លែងទាំង អស់នៅក្នុងខេត្ត។ ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាពនឹងត្រូវធ្វើការការពារអត្តសញ្ញាណវប្បធម៌របស់ប្រជាជនដែលជាតម្លៃស្នូលរបស់វា និងក្នុងគ្រប់តំបន់ទាំងអស់របស់ខេត្ត។

## ជំហានទី៤ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី

**គោលបំណងរួម**

- បញ្ចប់នូវតារាងម៉ាទ្រីករបស់គោលដៅ គោលបំណង និងសកម្មភាព
- បង្កើតនិងកសាងផែនទីយុទ្ធសាស្ត្រអភិវឌ្ឍដែនដីខេត្តដែលដោះស្រាយចំពោះលក្ខណៈនៃការប្រើប្រាស់ដីនាពេលអនាគត ការផ្តល់សេវា និងរចនាសម្ព័ន្ធសេដ្ឋកិច្ចនាពេលអនាគត
- ធ្វើការរៀបចំឲ្យស្របគ្នានៃយុទ្ធសាស្ត្រតាមវិស័យជាមួយនឹងយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី និងបច្ចុប្បន្នភាពផែនការតាមវិស័យ
- គាំទ្រដល់យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដីរួមមានការធ្វើសកម្មភាពបកក្រោយទៅលើផែនការតាមវិស័យ

### ការងារ ៤.១ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី

#### ស្ថានភាពទូទៅ

យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី គឺជាមធ្យោបាយដែលផែនការរៀបចំដែនដីខេត្ត មានគោលបំណងសម្រេចឲ្យបាននូវគោលដៅអភិវឌ្ឍន៍រយៈពេលវែងរបស់វា ដោយផ្អែកទៅលើទម្រង់លក្ខណៈដែនដីបច្ចុប្បន្នរបស់ខេត្ត។ មធ្យោបាយទាំងនេះ មានលក្ខណៈសមាហរណកម្មជាមួយគ្នា ព្រោះវាជាលទ្ធផលនៃការថ្លឹងថ្លែងរវាងផលប្រយោជន៍ និងការទាមទាររបស់វិស័យផ្សេងៗ។ សំនួរសំខាន់ៗនៃបញ្ហានេះ គឺត្រូវបានដឹងលឺយ៉ាងទូលំទូលាយ រវាងការផលិតទល់នឹងការការពារ រវាងជនបទទល់នឹងទីប្រជុំជន រវាងអាកាសធាតុទល់នឹងអ្វីៗទាំងអស់ ដែលទាំងនេះជាឧទាហរណ៍ដែលមានការចាប់អារម្មណ៍ជាងគេ។ ចំណុចសំខាន់នៃការកសាងផែនការរៀបចំដែនដីនេះ គឺការកែប្រែពីពាក្យ "**ទល់នឹង**" ទៅជាពាក្យ "**រួមនឹង/ជាមួយនឹង**" តាមដែលអាចធ្វើទៅបានដែលហៅថាការធ្វើផែនការសមាហរណកម្ម។

ខណៈដែលសៀវភៅនេះត្រូវបានបង្កើតឡើង មានផែនការរៀបចំដែនដីខេត្តតែមួយគត់ដែលបានរៀបចំឡើងរហូតដល់ដំណាក់កាលលើសពីជំហានទី៤ហើយ បានធ្វើការងារនេះឡើងពីរបីឆ្នាំមុនមុនពេលដែលសៀវភៅគោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើង។ ជាលទ្ធផលវិធីសាស្ត្រដែលនឹងពន្យល់នៅក្នុងជំហាននេះ គឺមានការពន្យល់លើសពីផែនការរៀបចំដែនដីដែលបានធ្វើពីមុនកន្លងមក។ ទោះបីជាយ៉ាងណាក៏ដោយ ឧទាហរណ៍ពីផែនការរៀបចំដែនដីដែលបានធ្វើកន្លងមក គឺមានតម្លៃនិងត្រូវបានបញ្ចូលក្នុងចំណុចខាងក្រោមនេះ។ ភាពខុសប្លែកគ្នាដ៏សំខាន់នោះ គឺថានៅក្នុងឧទាហរណ៍យុទ្ធសាស្ត្រផ្សេងៗត្រូវបានបង្ហាញនៅលើផែនទីផ្សេងៗគ្នា ខណៈដែលវិធីសាស្ត្រដែល

បានលើកឡើងនៅទីនេះ គឺធ្វើការបញ្ចូលយុទ្ធសាស្ត្រដែនដីផ្សេងៗគ្នាទៅក្នុងផែនទីចំនួនបីជាមួយនឹងការពន្យល់បំពេញបន្ថែមទៀត។

**អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?**

- អ្នកផ្តួចផ្តើម និងអនុវត្ត
    - ក្រុមការងារខេត្ត
- ការគាំទ្រ
    - គ.ដ.ន.ខ

**សកម្មភាពការងារ/វិធីសាស្ត្រ**

- នៅក្នុងដំណាក់កាលដំបូង ក្រុមការងារត្រូវបំពេញបន្ថែមទៅលើតារាងម៉ាទ្រីកផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍លម្អិតរបស់គោលដៅ គោលបំណង និងសកម្មភាពដែលជាលទ្ធផលបានមកពីសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធស្តីអំពីគោលដៅរយៈពេលវែងនិងចក្ខុវិស័យ។ នេះអាចជាលទ្ធផលដ៏សមស្របចេញពីលទ្ធផលជាច្រើន នៃការវិភាគស្ថានភាព និងគោលដៅដែលបានកំណត់ ប៉ុន្តែវាជាដំណើរការដ៏លំបាកមួយ។
- ក្រុមការងារខេត្ត គួរធ្វើការបង្ហាញឲ្យច្បាស់ហើយសម្រាប់លទ្ធផលនីមួយៗដែលជាលទ្ធផលរំពឹងទុកនៅក្នុងតារាងម៉ាទ្រីក ថាតើទម្រង់លក្ខណៈដែនដីនៅពេលអនាគតណាខ្លះនឹងត្រូវធ្វើការដោះស្រាយ ឬរងនូវផលប៉ះពាល់ពីលទ្ធផលទាំងនោះ (ការប្រើប្រាស់ដី មជ្ឈមណ្ឌលទីប្រជុំជន និងសេដ្ឋកិច្ច)។
- ក្រុមការងារខេត្ត ត្រូវធ្វើបទបង្ហាញម៉ាទ្រីកស្មុគស្មាញនេះ និងសមាសភាគរបស់ម៉ាទ្រីកនេះដល់ គ.ដ.ន.ខ ដើម្បីស្វែងរកនូវការណែនាំ និងការគាំទ្រ។ ការងារនេះមិនអាចសម្រេចបានក្នុងកិច្ចប្រជុំខ្លីនោះទេ ប៉ុន្តែអាចសម្រេចបានតាមរយៈសិក្ខាសាលាផ្ទៃក្នុងរយៈពេលមួយឬពីរថ្ងៃ។
- បន្ទាប់ពីនោះមកធ្វើការចាប់ផ្តើមការកសាងផែនការជាក់ស្តែង។ សម្រាប់សមាសភាគនីមួយៗនៃសមាសភាគទាំងបីរបស់ទម្រង់លក្ខណៈដែនដីខេត្តដែលបានប្រមើលមើលទុក ការវិភាគដែនដីគឺជាកិច្ចការដ៏សំខាន់ក្នុងការកំណត់ស្វែងរកនូវយុទ្ធសាស្ត្រ ដើម្បីធ្វើសមាហរណកម្មគោលបំណងផ្សេងៗ (និងសកម្មភាព) នៅពេលអនាគតខាងមុខ។ សម្រាប់សមាសភាគផ្សេងៗគ្នានេះបានជាលទ្ធផលយុទ្ធសាស្ត្រផ្សេងៗគ្នាដែលនឹងធ្វើការពន្យល់បន្ថែមនៅខាងក្រោម។ ក្រុមការងារខេត្តត្រូវធ្វើការពិភាក្សា និងរៀបចំឯកសារពីមូលហេតុសម្រាប់ដាក់បញ្ចូលផ្នែកដែនដីទៅក្នុងយុទ្ធសាស្ត្រនិងជម្រើសសក្តានុពលផ្សេងៗទៀត។
- ជាលទ្ធផលរួមមួយយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដីផ្សេងៗគ្នា ត្រូវបានធ្វើសមាហរណកម្មនៅលើផែនទីមួយដែលបង្ហាញពីទំនាក់ទំនងរបស់វាក្នុងដែនដី និងការមានឥទ្ធិពលលើគ្នាទៅវិញទៅមក។

**ក) ការប្រើប្រាស់ដីនាពេលអនាគត និងមុខងារនៃទេសភាព**

- ផែនទីប្រើប្រាស់ដីពេលអនាគត និងមុខងារទេសភាព គឺផ្អែកទៅលើនិងបង្កើតឡើងពីផែនទីប្រព័ន្ធប្រើប្រាស់ដីបច្ចុប្បន្ន ដោយបញ្ចូលនូវយុទ្ធសាស្ត្រដែលឆ្លើយតបទៅនឹងគោលបំណងនានាដែលបានកំណត់ដោយផ្អែកទៅលើការវិភាគដែនដី។
- មធ្យោបាយទាក់ទងនឹងដែនដីនៃផែនការរៀបចំដែនដីថ្នាក់ខេត្ត ដែលពាក់ព័ន្ធជាមួយនឹងមុខងារទេសភាពនិងការប្រើប្រាស់ដី គឺត្រូវមានការជាប់ទាក់ទងនឹងការធ្វើអាទិភាព ការលើកស្ទួយ និងការដាក់កម្រិតទៅលើមុខងារ និងការប្រើប្រាស់តំបន់ពិសេសមានន័យថាៈ
    - **ការកំណត់អាទិភាព** កំណត់តំបន់ដែលគាំទ្រដល់ការប្រើប្រាស់ ឬមានមុខងារជាក់លាក់ណាមួយហើយការប្រើប្រាស់ផ្សេងទៀត ក៏ត្រូវបានអនុញ្ញាតផងដែរប្រសិនបើវាមិនមានទំនាស់ជាមួយនឹងតំបន់ដែលបានកំណត់អាទិភាពហើយនោះ (ឧ. សហគមន៍នេសាទ)។
    - **ការលើកស្ទួយ** ជាការកំណត់តំបន់មួយដែលមុខងារឬការប្រើប្រាស់ជាក់លាក់មួយដែលគួរត្រូវបានគាំទ្រ (ឧ. គម្រោងធារាសាស្ត្រសម្រាប់កសិកម្ម)។
    - **ការដាក់កម្រិត** កំណត់តំបន់មួយដែលមុខងារ ឬការប្រើប្រាស់ជាមូលដ្ឋានតែមួយគត់ត្រូវបានអនុញ្ញាត ដូចជាតំបន់ការពារ។
- មធ្យោបាយទាក់ទងនឹងដែនដីត្រូវបានប្រើប្រាស់ ដើម្បីលើកស្ទួយដល់ការប្រើប្រាស់ដែលមានទិសដៅសម្រាប់ផលិតកម្មផ្សេងៗ (កសិកម្ម ព្រៃឈើ ជលផល ) ជាមួយនឹងការផ្តល់នូវការថែរក្សាដល់ធនធានធម្មជាតិ និងបរិស្ថានរស់នៅ តំបន់កំសាន្តក្នុងតំបន់មូលដ្ឋាន និងតំបន់ដែលបានប្រមើលមើលទុកសម្រាប់គ្រប់គ្រងទឹកជំនន់ និងសម្រាប់ធ្វើអាជីវកម្មធនធានរ៉ែផងដែរ។

**<u>ឧទាហរណ៍ពីការកសាងផែនការរៀបចំដែនដីខេត្តបាត់ដំបងៈ</u>**

| | |
|---|---|
| គោលបំណង ៖ | ការគ្រប់គ្រងទីជម្រាលប្រកបដោយចីរភាព |
| សកម្មភាព ៖ | កំណត់ និងជម្រុញការរៀបចំការកាន់កាប់ព្រៃឈើសម្រាប់ការអភិរក្ស (តំបន់ការពារ) និងការបង្កបង្កើនផល ( សហគមន៍ព្រៃឈើ និងសហគមន៍នេសាទ)។ |




**ផែនទី៣១៖** ការកំណត់តំបន់គ្រប់គ្រងទីជម្រាលនាពេលអនាគតក្នុងខេត្តបាត់ដំបង

**ការពន្យល់៖** ផែនទីក្នុងខេត្តបាត់ដំបងបានកំណត់តំបន់ការពារ (ដែលកម្រិតដល់មុខងារប្រើប្រាស់ផ្សេងៗ) ក៏ដូចជាតំបន់សហគមន៍ព្រៃឈើ (កំណត់នូវអាទិភាពមុខងារប្រើប្រាស់មួយ) ទោះបីជាយ៉ាងណាក៏ដោយការញែកចេញរវាងតំបន់មានស្រាប់ និងតំបន់សម្រាប់អនាគតមិនត្រូវបានបញ្ចេញជារូបភាពឲ្យឃើញនោះទេ ដែលធ្វើឲ្យមានការលំបាកក្នុងការស្វែងយល់នូវសកម្មភាពដែលត្រូវធ្វើ។ ជាមួយគ្នានេះផងដែរ ដោយការផ្តោតមើលទៅលើតែគោលបំណងមួយ វាមានការលំបាកក្នុងការវិភាគពីទំនាក់ទំនងទៅនឹងយុទ្ធសាស្ត្រ និងការប្រើប្រាស់ដី ដទៃទៀត។

ត្រូវកត់សំគាល់ថាការរៀបចំការកាន់កាប់ដីនៅក្នុងឧទាហរណ៍នេះ គឺមានលក្ខណៈជាក់លាក់ទៅលើការអនុញ្ញាតឲ្យមានការប្រើប្រាស់ជាសក្តានុពលដ៏ទៃទៀត ជាជាងការសរុបរួម (ចាត់ថ្នាក់) ជាអាទិភាព ឬការហាមឃាត់ ប៉ុន្តែគួរអនុវត្តតាមគោលការណ៍មូលដ្ឋានដូចគ្នា។

សកម្មភាព៖ ការធ្វើឲ្យប្រសើរឡើងដល់ប្រព័ន្ធធារាសាស្ត្រសម្រាប់ស្រែប្រពលវប្បកម្ម។




**ផែនទី៣២៖** ទីតាំងអភិវឌ្ឍន៍ធារាសាស្ត្រនាពេលអនាគតក្នុងខេត្តបាត់ដំបង

ការពន្យល់៖ នៅក្នុងឧទាហរណ៍នេះ ទីតាំងសម្រាប់ប្រព័ន្ធធារាសាស្ត្រនាពេលអនាគត ត្រូវបានកំណត់ដើម្បីគាំទ្រដល់ស្រែប្រពលវប្បកម្ម (ជម្រុញមុខងារប្រើប្រាស់)។ តំបន់ដែលត្រូវពង្រីកបន្ថែមជាក់ស្តែងត្រូវបានកំណត់ផងដែរ។

- ឧទាហរណ៍ទាំងពីរនេះដាក់បង្ហាញឲ្យឃើញពីវិធីសាស្ត្រដែលល្អ ប៉ុន្តែគួរត្រូវបានបញ្ចូលគ្នាទៅក្នុងផែនទីរួមមួយដែលក្នុងនោះមានទាំងយុទ្ធសាស្ត្រផ្សេងៗគ្នា ដែលទាក់ទងទៅនឹងមុខងារទេសភាព និងការប្រើប្រាស់ដី។ ក្នុងករណីដែលផែនទីផ្ទុកដោយយុទ្ធសាស្ត្រច្រើនពេក ក្រុមការងារខេត្តគួរពិនិត្យឡើងវិញថា តើការអនុវត្តយុទ្ធសាស្ត្រទាំងនោះមានភាពជាក់ស្តែង (ពិតប្រាកដ) ដែរឬទេ តាមរយៈធនធានដែលមាន និងថាតើយុទ្ធសាស្ត្រណាខ្លះត្រូវបានដោះស្រាយបញ្ហាក្នុងកម្រិតត្រឹមត្រូវ (ឬក៏វាគួរតែស្ថិតនៅក្នុងទំហំដែនដី ឬសំខាន់សម្រាប់ផែនការថ្នាក់ស្រុក)។
- ផែនទីចុងក្រោយគួរមានភ្ជាប់ជាមួយបញ្ជីដែលមានការពន្យល់ពីសមាហរណកម្មយុទ្ធសាស្ត្រទាំងអស់ គោលបំណងដែលវាគាំទ្រ និងមូលហេតុសម្រាប់ការកំណត់ដែនដី។

## ខ) មជ្ឈមណ្ឌលទីប្រជុំជននាពេលអនាគត និងការផ្តល់សេវាកម្ម

- ផែនទីមជ្ឈមណ្ឌលទីប្រជុំជននាពេលអនាគត និងការផ្តល់សេវាកម្មគឺផ្អែកទៅលើ និងត្រូវបានបង្កើតឡើងពីផែនទីកំណត់ចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជនបច្ចុប្បន្ន ដោយសមាហរណកម្មជាមួយយុទ្ធសាស្ត្រដែលឆ្លើយតបទៅនឹងគោលបំណងផ្សេងៗដែលបានកំណត់។
- មធ្យោបាយដែនដីនៃផែនការរៀបចំដែនដីថ្នាក់ខេត្តដែលទាក់ទងជាមួយនឹងមជ្ឈមណ្ឌលទីប្រជុំជន និងការទទួលបានសេវាកម្ម គឺសំដៅដល់ការកំណត់ចំណាត់ថ្នាក់ជាមជ្ឈមណ្ឌលកណ្តាល/ធំ អនុមជ្ឈមណ្ឌលនិងអនុមជ្ឈមណ្ឌលរងដែលត្រូវបានធ្វើការពន្យល់កន្លងមកថ្មីៗនេះនិងតំបន់ជនបទដែលបានកំណត់នៅជុំវិញតំបន់ដែលផ្តល់នូវសេវាកម្ម។ តាមរយៈការរៀបចំចំណាត់ថ្នាក់នេះ ផែនការនេះមានផលវិបាកដល់វិស័យផ្សេងៗ ថាតើសេវាអ្វីដែលនឹងត្រូវធ្វើការផ្តល់ជូនដើម្បីបំពេញចន្លោះសក្តានុពល។ តារាងនៅក្នុងឧទាហរណ៍ ពីខេត្តបាត់ដំបងផ្តល់នូវការពន្យល់ណែនាំបន្ថែម។
- មធ្យោបាយទាក់ទងនឹងដែនដី ត្រូវបានប្រើប្រាស់ដើម្បីធ្វើឲ្យប្រសើរឡើងដល់សង្គម និងការផ្គត់ផ្គង់សេវាសង្គមផ្សេងៗ វាមិនមែនគ្រាន់តែសម្រាប់មជ្ឈមណ្ឌលទីប្រជុំជននោះទេ ប៉ុន្តែក៏សម្រាប់តំបន់ជនបទជុំវិញដែលបានកំណត់ផងដែរ ។

### ឧទាហរណ៍ពីផែនការរៀបចំដែនដីខេត្តបាត់ដំបង

គោលបំណង៖ ជួយឲ្យសម្រេចបានការអភិវឌ្ឍដែនដីប្រកបដោយតុល្យភាពនៅក្នុងខេត្ត

សកម្មភាព៖ អភិវឌ្ឍន៍មជ្ឈមណ្ឌលទីប្រជុំជន ស្របតាមរចនាសម្ព័ន្ធពហុមណ្ឌលដែលមានការបែងចែកឋានានុក្រមរបស់មជ្ឈមណ្ឌលនីមួយៗ ។




**ផែនទី៣៣៖** រចនាសម្ព័ន្ធពហុមជ្ឈមណ្ឌលរបស់មជ្ឈមណ្ឌលទីប្រជុំជនក្នុងខេត្តបាត់ដំបង

ការពន្យល់៖ ផែនទីរចនាសម្ព័ន្ធពហុមជ្ឈមណ្ឌលពីខេត្តបាត់ដំបង ជាឧទាហរណ៍មួយដ៏ល្អសម្រាប់ការធ្វើចំណាត់ថ្នាក់មជ្ឈមណ្ឌលទីប្រជុំជននាពេលអនាគត ដែលបានប្រមើលមើលទុករួមមានមជ្ឈមណ្ឌលកណ្តាល(ធំ) អនុមជ្ឈមណ្ឌល អនុមជ្ឈមណ្ឌលរង ក៏ដូចជាទំនាក់ទំនងរវាងមជ្ឈមណ្ឌលទាំងនោះ។

- ផែនទីនេះក៏មានអបជាមួយតារាង ៦ ដែលបង្ហាញពីមជ្ឈមណ្ឌលទាំងអស់ មុខងារបច្ចុប្បន្ន និងនាពេលអនាគត ដែលនឹងត្រូវផ្តល់ជូននិងកម្រិតមជ្ឈមណ្ឌលបច្ចុប្បន្ន និងនាពេលអនាគត (តារាងខាងក្រោមបានសង្ខេបជាឧទាហរណ៍នៅក្នុងសៀវភៅនេះ)។

**តារាង៥ ៖** មុខងាររបស់មជ្ឈមណ្ឌលទីប្រជុំជននាពេលអនាគត និងមានស្រាប់ក្នុងខេត្តបាត់ដំបង

| មជ្ឈមណ្ឌលថ្នាក់ស្រុក | កម្រិតមានស្រាប់ | មុខងារដែលមានស្រាប់ | កម្រិតនាពេលអនាគត | មុខងារជាក់លាក់នាពេលអនាគត |
|---|---|---|---|---|
| បាត់ដំបង | មជ្ឈមណ្ឌលកណ្តាល | • មជ្ឈមណ្ឌលសេវាកម្ម និងពាណិជ្ជកម្ម<br>• មជ្ឈមណ្ឌលជំនួញ និងកែច្នៃផលិតផលកសិកម្ម<br>• មជ្ឈមណ្ឌលអប់រំ និងចំណេះដឹង<br>• មជ្ឈមណ្ឌលនៃទេសចរណ៍ វប្បធម៌ និងកេរ្តិ៍តំណែល | មជ្ឈមណ្ឌលកណ្តាល | • មជ្ឈមណ្ឌលសេវាកម្ម និងពាណិជ្ជកម្ម<br>• មជ្ឈមណ្ឌលជំនួញ និងកែច្នៃផលិតផលកសិកម្ម<br>• មជ្ឈមណ្ឌលអប់រំ និងចំណេះដឹង<br>• មជ្ឈមណ្ឌលនៃទេសចរណ៍ វប្បធម៌ និងកេរ្តិ៍តំណែល |
| ឯកភ្នំ | អនុមជ្ឈមណ្ឌលរង | • គាំទ្រដល់មុខងារក្រុងបាត់ដំបង<br>• មជ្ឈមណ្ឌលកែច្នៃត្រី | អនុមជ្ឈមណ្ឌលរង | • គាំទ្រដល់មុខងារក្រុងបាត់ដំបង<br>• មជ្ឈមណ្ឌលកែច្នៃត្រី<br>• មជ្ឈមណ្ឌលអេកូទេសចរណ៍<br>• ស្តុបទុកផលិតផលកសិកម្ម និងកែច្នៃមុនពេលធ្វើពាណិជ្ជកម្ម |
| បាណន់ | អនុមជ្ឈមណ្ឌលរង | • គាំទ្រដល់មុខងារក្រុងបាត់ដំបង (ការស្នាក់នៅ) | អនុមជ្ឈមណ្ឌលរង | • គាំទ្រដល់មុខងារក្រុងបាត់ដំបង (ការស្នាក់នៅ)<br>• ស្តុកផលិតផលកសិកម្មមុននឹងធ្វើការកែច្នៃនៅបាត់ដំបង ឬរតនមណ្ឌល<br>• មជ្ឈមណ្ឌលអេកូទេសចរណ៍ |
| សំឡូត | អនុមជ្ឈមណ្ឌលរង | • គាំទ្រដល់មុខងារស្រុករតនមណ្ឌល | អនុមជ្ឈមណ្ឌលរង | • គាំទ្រដល់ស្រុករតនមណ្ឌលលើមុខងារកែច្នៃកសិកម្ម<br>• មជ្ឈមណ្ឌលអេកូទេសចរណ៍<br>• ស្តុកផលិតផលកសិកម្មមុននឹងធ្វើការកែច្នៃនៅបាត់ដំបង រតនមណ្ឌល ឬប្រទេសថៃ |

| | | | | |
|---|---|---|---|---|
| បវេល | អនុមជ្ឈមណ្ឌល | • ជាច្រកទៅកាន់ស្វាយស៊ីសុផុន និងប្រទេសថៃ<br>• មជ្ឈមណ្ឌលសម្រាប់កែច្នៃផលិតផលកសិកម្ម (ស្រូវ) | អនុមជ្ឈមណ្ឌល | • ជាមជ្ឈមណ្ឌលបណ្តុំការដឹកជញ្ជូនរវាងផ្លូវជាតិលេខ៥ និងតំបន់ព្រំប្រទល់ប្រទេសថៃ<br>• មជ្ឈមណ្ឌលសម្រាប់កែច្នៃផលិតផលកសិកម្ម (ស្រូវ)<br>• គាំទ្រដល់ស្រុកនៅតាមព្រំដែនផ្នែកហិរញ្ញវត្ថុ ធានាគារ និងការអប់រំ |
| កំរៀង | អនុមជ្ឈមណ្ឌល | • ច្រកអន្តរជាតិសំខាន់ទៅប្រទេសថៃ<br>• ភ្ជាប់ទៅភ្នំព្រឹក សំពៅលូន និងប៉ៃលិនបង្កើតបានជាច្រកផ្លូវអភិវឌ្ឍន៍តាមព្រំដែន<br>• មជ្ឈមណ្ឌលសម្រាប់ការកែច្នៃកសិផល (ដំឡូងមី) និងស្តុបទុកមុនពេលធ្វើពាណិជ្ជកម្មទៅកាន់ប្រទេសថៃឬភ្នំពេញ | អនុមជ្ឈមណ្ឌល | • ច្រកអន្តរជាតិសំខាន់ទៅប្រទេសថៃ<br>• ភ្ជាប់ទៅភ្នំព្រឹក សំពៅលូន និងប៉ៃលិនបង្កើតបានជាច្រកផ្លូវអភិវឌ្ឍតាមព្រំដែន<br>• មជ្ឈមណ្ឌលសម្រាប់ការកែច្នៃកសិផល (ដំឡូងមី) និងស្តុបទុកមុនពេលធ្វើពាណិជ្ជកម្មទៅកាន់ប្រទេសថៃឬភ្នំពេញ |
| សំពៅលូន | អនុមជ្ឈមណ្ឌល | • ច្រកអន្តរជាតិទីពីរទៅកាន់ប្រទេសថៃ<br>• ភ្ជាប់ទៅភ្នំព្រឹក និងកំរៀងបង្កើតបានជាច្រកអភិវឌ្ឍន៍តាមព្រំដែន | អនុមជ្ឈមណ្ឌល | • ច្រកអន្តរជាតិទីពីរទៅកាន់ប្រទេសថៃ<br>• ភ្ជាប់ទៅភ្នំព្រឹក និងកំរៀង បង្កើតបានជាច្រកផ្លូវអភិវឌ្ឍន៍តាមព្រំដែន<br>• មជ្ឈមណ្ឌលសម្រាប់កែច្នៃកសិផល (ដំឡូងមី) និងស្តុកទុកមុននឹងធ្វើជំនួញទៅកាន់ប្រទេសថៃ ឬភ្នំពេញ |

**គ) រចនាសម្ព័ន្ធសេដ្ឋកិច្ចសម្រាប់អនាគត**

- ផែនទីរចនាសម្ព័ន្ធសេដ្ឋកិច្ចសម្រាប់អនាគត គឺផ្អែកទៅលើ និងកសាងឡើងពីផែនទីរចនាសម្ព័ន្ធសេដ្ឋកិច្ចបច្ចុប្បន្នដោយសមាហរណកម្មជាមួយយុទ្ធសាស្ត្រ ដែលឆ្លើយតបទៅនឹងគោលបំណងផ្សេងៗដែលបានកំណត់ដោយប្រើប្រាស់នូវការវិភាគដែនដី។
- មធ្យោបាយទាក់ទងនឹងដែនដីដែលទាក់ទងទៅនឹងរចនាសម្ព័ន្ធសេដ្ឋកិច្ច គឺធ្វើការកំណត់នូវទីតាំងបណ្តុំសេដ្ឋកិច្ចនិងទិសដៅផ្លូវច្រកសេដ្ឋកិច្ចដែលបានរៀបរាប់ហើយ។ ការវិភាគដែនដី គឺមានការពាក់ព័ន្ធជាពិសេសសម្រាប់ការវិភាគទីតាំងឬទីកន្លែង ក៏ដូចជាការវិភាគនៃជម្រើសផ្សេងៗសម្រាប់ច្រកផ្លូវ (corridor routes) សេដ្ឋកិច្ច ដោយការវិភាគទាំងនេះមានការពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងប្រសិទ្ធភាពសេដ្ឋកិច្ច ក៏ដូចជាទាក់ទងទៅនឹងទំនាស់នៃការប្រើប្រាស់ដីដ៏ទៃទៀតផងដែរ។
- មធ្យោបាយដែនដី ត្រូវបានប្រើប្រាស់ដើម្បីលើកស្ទួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច ដោយជៀសវាងឬកាត់បន្ថយផលប៉ះពាល់អវិជ្ជមានទៅលើមុខងារ និងការប្រើប្រាស់ដីដ៏ទៃទៀត។

**<u>ឧទាហរណ៍ពីផែនការរៀបចំដែនដីខេត្តបាត់ដំបង</u>**

**គោលបំណង ៖** ជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច (មិនមែនកសិកម្ម) សម្រាប់ដែនដីទាំងមូល

**សកម្មភាព ៖** កំណត់តំបន់អភិវឌ្ឍន៍ឧស្សាហកម្មនាពេលអនាគតនៅក្នុងខេត្តបាត់ដំបង ស្របជាមួយនឹងការផ្គត់ផ្គង់ថាមពល។




**ផែនទី៣៤ ៖** ទីតាំងតំបន់ឧស្សាហកម្មនាពេលអនាគតស្របជាមួយនឹងការចែកចាយថាមពលអគ្គីសនី និងបណ្តាញវារីអគ្គីសនីនៅក្នុងតំបន់នាពេលអនាគត និងប្រព័ន្ធប្រើប្រាស់ដីនាពេលអនាគត

សកម្មភាព ៖ ធ្វើឲ្យប្រសើរឡើងដល់បណ្តាញប្រព័ន្ធផ្លូវក្នុងខេត្តបាត់ដំបង




**ផែនទីទី៣៥៖** ប្រព័ន្ធផ្លូវខេត្តនាពេលអនាគតសម្រាប់ខេត្តបាត់ដំបង ជាមួយនឹងប្រភេទការងារហេដ្ឋារចនាសម្ព័ន្ធជាក់លាក់ដែលត្រូវការសម្រាប់ផ្នែកផ្សេងៗគ្នានៃប្រព័ន្ធទាំងនោះ (ថែទាំ ជួសជុល និងកសាងថ្មី)

ការពន្យល់៖ ផែនទីទាំងពីរខាងលើបង្ហាញពីទិដ្ឋភាពរចនាសម្ព័ន្ធសេដ្ឋកិច្ចនាពេលអនាគត ដែលផែនទីដំបូងធ្វើការកំណត់ជាពិសេសពីប៉ូលអភិវឌ្ឍន៍ឧស្សាហកម្ម ហើយផែនទីទាំងពីរនាំមកនូវសមាសភាគសំខាន់ៗនៃបណ្តាញច្រកផ្លូវសេដ្ឋកិច្ច (corridors) ដែលភ្ជាប់ និងគាំទ្រដល់ប៉ូលបណ្តុំសេដ្ឋកិច្ចនៅក្នុងខេត្ត។ ផ្លូវដែលបានធ្វើផែនការ និងត្រូវបានចង្អុលបង្ហាញនៅក្នុងឧទាហរណ៍ផែនទីទី ២ ក៏ដូចជាអាទិភាពសម្រាប់ការថែទាំផ្លូវផងដែរ។ ផែនទីទាំងនេះគួរបញ្ចូលផែនទីគោលដែលមានព័ត៌មានសេដ្ឋកិច្ចតាមស្រុក។ គួរធ្វើការបញ្ចូលមុខងារផ្សេងៗដ៏ទៃទៀតផងដែរ សម្រាប់ផែនទីរចនាសម្ព័ន្ធសេដ្ឋកិច្ចលម្អិតនាពេលអនាគត។

- ដូចក្នុងករណីពីរដំបូង ផែនទីគួរធ្វើការបំពេញបន្ថែមដោយព័ត៌មានជាអក្សរបន្ថែមទៀតដែលរៀបរាប់ពីយុទ្ធសាស្ត្រ គោលបំណង និងមូលហេតុនៅពីក្រោយ។

### ឃ) សមាហរណកម្មយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី

ជាការសរុបរួមមួយយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដីផ្សេងៗគ្នា ត្រូវបានធ្វើសមាហរណកម្មនៅលើផែនទីមួយ ដើម្បីបង្កើតនូវទំនាក់ទំនងក្នុងដែនដី និងការមានឥទ្ធិពលរវាងគ្នាទៅវិញទៅមក។ ផែនទីនេះជួយកំណត់ ការរួមបញ្ចូលគ្នា (synergies) ដែលអាចធ្វើទៅបាន ឬបដិវាទកម្ម ដូចនេះហើយវាជាមគ្គុទ្ទេសន៍សម្រាប់ការពិភាក្សាបន្ថែមរវាងវិស័យផ្សេងៗ។




**ផែនទី ៣៦៖** យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដីដែលបានធ្វើសមាហរណកម្មនៅក្នុងខេត្តបាត់ដំបង

### លទ្ធផលរំពឹងទុក

- តារាងម៉ាទ្រីកយុទ្ធសាស្ត្រអភិវឌ្ឍន៍លម្អិត ជាមួយនឹងគោលបំណង និងសកម្មភាព ត្រូវបានបង្កើតឡើងរួចរាល់ដោយមានភាពច្បាស់លាស់ និងមានភាពស៊ីគ្នា។
- យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដីត្រូវបានធ្វើសមាហរណកម្មទៅក្នុងផែនទីស្តីពីការប្រើប្រាស់ដីសម្រាប់អនាគតនិងមុខងារទេសភាព ផែនទីស្តីពីមជ្ឈមណ្ឌលទីប្រជុំជននាពេលអនាគតនិងការផ្តល់សេវា និងផែនទីស្តី ពីរចនាសម្ព័ន្ធសេដ្ឋកិច្ចនាពេលអនាគត ក៏ដូចជាបានពន្យល់ជា លាយល័ក្ខអក្សរ និងគាំទ្រពី គ.ដ.ន.ខ។

### ការងារ ៤.២ សម្របយុទ្ធសាស្ត្រតាមវិស័យ និងបច្ចុប្បន្នភាពផែនការតាមវិស័យ

### ស្ថានភាពទូទៅ

ដើម្បីសម្រេចយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី វាមានសារៈសំខាន់ណាស់ក្នុងការកំណត់ថាតើវិស័យនីមួយៗ វិស័យដាច់ដោយឡែក និងកិច្ចខិតខំប្រឹងប្រែងរួមគ្នា នឹងចូលរួមចំណែកដល់ការអនុវត្តយុទ្ធសាស្ត្រដោយរបៀបណា។ នេះទាមទារនូវការកែតម្រូវលើផែនការតាមវិស័យជាក់លាក់មួយចំនួនទៅតាមសមាហរណកម្មបញ្ច្រាសមកវិញ ដែលដំណើរការបានចាប់ផ្តើមដោយធ្វើសមាហរណកម្មជាមួយផែនការតាមវិស័យផ្សេងៗ ការរួមគ្នា (synergies) និងការត្រូតស៊ីគ្នាដែលលើកឡើងនៅក្នុងផែនការរៀបចំដែនដីថ្នាក់ខេត្ត ដែលត្រូវធ្វើសមាហរណកម្មទៅក្នុងផែនការតាមវិស័យឥលូវនេះ។ ដំណើរការនេះនឹងធ្វើឲ្យប្រសើរឡើងដល់ការអនុវត្តផែនការនាពេលអនាគត។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកផ្តួចផ្តើម និងអនុវត្ត
  - ក្រុមការងារខេត្ត
- អ្នកចូលរួម
  - មន្ទីរជំនាញ
- ការគាំទ្រ
  - គ.ដ.ន.ខ

### សកម្មភាពការងារ/វិធីសាស្ត្រ

- រៀបចំសិក្ខាសាលាដោយចាប់ផ្តើមជាមួយនឹងបទបង្ហាញពីយុទ្ធសាស្ត្រអភិវឌ្ឍដែនដីខេត្តដែលបានធ្វើសមាហរណកម្មទៅក្នុងផែនទីអភិវឌ្ឍនាពេលអនាគតទាំងបី។សមិទ្ធផលសង្ខេបសម្រាប់ផែនការតាមវិស័យដូចជា៖
  - ផ្លូវផ្សេងទៀត សម្រាប់កសាងផ្លូវដែលបានធ្វើផែនការ(ឆ្លើយទៅនឹងអាទិភាពផ្សេងៗសម្រាប់ទំនាក់ទំនង បម្លាស់ទី ឬទទួលសេវា ឬក៏ដើម្បីកាត់បន្ថយដល់ផលប៉ះពាល់បរិស្ថាន និងសង្គម)

   - ជម្រើសទីតាំងថ្មីផ្សេងសម្រាប់សម្បទាន តំបន់ និងប៉ូលបណ្តុំសេដ្ឋកិច្ច (ដើម្បីបង្កើនប្រសិទ្ធភាព ឬកាត់បន្ថយដល់ផលប៉ះពាល់អវិជ្ជមាន)។
   - ជម្រើសតំបន់ថ្មីផ្សេងសម្រាប់ប្រព័ន្ធស្រោចស្រពថ្មី (ដើម្បីឆ្លើយតបនឹងភាពស្ថិតរម្ងួតក្នុងខេត្ត និងជៀសវាងផលប៉ះពាល់ដល់ទីជម្រាល) ។
   - ជម្រើសតំបន់ថ្មីផ្សេងសម្រាប់ពង្រីកទីប្រជុំជន (រក្សាតំបន់គ្រប់គ្រងទឹកជំនន់មិនឲ្យមានការអភិវឌ្ឍ)។
   - អាទិភាពថ្មីផ្សេងសម្រាប់បរិក្ខារសេវាសង្គម និងបរិក្ខារសេវាកម្មដ៏ទៃទៀត។
   - ការបញ្ចូលផ្លូវថ្មី តំបន់ការពារថ្មី និងបរិក្ខារសង្គមថ្មី។
- អ្វីដែលលើកឡើងខាងលើ ត្រូវបានពិភាក្សា ហើយក៏បានពិភាក្សាផងដែរទៅលើអ្វីដែលមានស្រាប់ ឬសក្តានុពលដែលត្រួតគ្នារវាងវិស័យ និងការគ្រប់គ្រងតំបន់មួយចំនួន។
- នៅពេលដែលកើតមានទំនាស់ គួរធ្វើការដោះស្រាយម្តងមួយករណី ហើយធ្វើការដោះស្រាយទៅតាមបរិបទមួយដែលមានការចូលរួមពីភាគីពាក់ព័ន្ធទាំងអស់។ ប្រសិនបើត្រូវការការសម្រេចចិត្តចុងក្រោយ គឺត្រូវសម្រេចដោយអភិបាលខេត្ត គ.ដ.ន.ខ និងក្រសួងជំនាញប្រសិនបើចាំបាច់។
- បន្ទាប់មកវិស័យនីមួយៗ ធ្វើបច្ចុប្បន្នភាពផែនការរបស់ខ្លួន និងស្វែងរកនូវការអនុម័តពីក្រសួងជំនាញរបស់ខ្លួន។

**លទ្ធផលរំពឹងទុក**

- យុទ្ធសាស្ត្រតាមវិស័យត្រូវបានធ្វើបច្ចុបប្បន្នភាពដោយផ្អែកទៅលើផលវិបាក នៃផែនការរៀបចំដែនដីថ្នាក់ខេត្ត។
- ផែនការតាមវិស័យដែលបានធ្វើបច្ចុប្បន្នភាពហើយត្រូវបានធ្វើការអនុម័តដោយអាជ្ញាធរមានសមត្ថកិច្ច។

## ការងារ ៤.៣ ការពិភាក្សាផ្ទៃក្នុងជាមួយអាជ្ញាធរខេត្ត

### ស្ថានភាពទូទៅ

សេចក្តីព្រាងចុងក្រោយនៃគោលដៅរយៈពេលវែង ចក្ខុវិស័យ និងសេណារីយ៉ូអភិវឌ្ឍន៍នាពេលអនាគត ក៏ដូចជាយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី នឹងត្រូវធ្វើបទបង្ហាញជូនចំពោះ គ.ដ.ន.ខ និងក្រុមប្រឹក្សាខេត្តដើម្បីពិភាក្សាពិគ្រោះយោបល់ ធ្វើការកែតម្រូវ និងផ្តល់ការគាំទ្រ។ នៅពេលដែលអ្វីៗដែលមាននៅក្នុងផែនការរៀបចំដែនដីច្បាស់លាស់អស់ហើយក្នុងដំណាក់កាលនេះ វាពិតជាមានសារៈសំខាន់ណាស់ក្នុងការជួយជម្រុញដល់ការចាប់អារម្មណ៍ និងការគាំទ្រពីអាជ្ញាធរខេត្ត សម្រាប់ការអនុវត្ត និងត្រួតពិនិត្យទៅលើផែនការរៀបចំដែនដីថ្នាក់ខេត្តនៅក្នុងដំណាក់កាលបន្ទាប់ទៀត។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកផ្តួចផ្តើម និងអនុវត្ត
    - ក្រុមការងារខេត្ត
- អ្នកចូលរួម
    - ក្រុមប្រឹក្សាខេត្ត
    - គ.ដ.ន.ខ

### សកម្មភាពការងារ/វិធីសាស្ត្រ

- រៀបចំសិក្ខាសាលាបង្ហាញនិងពិភាក្សាជាមួយនឹងក្រុមប្រឹក្សាខេត្ត និងគ.ដ.ន.ខ ពីលទ្ធផលនៃការវិភាគសេណារីយ៉ូ គោលដៅរយៈពេលវែង និងយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី។
- សំនួរ និងសំណូមពររបស់អាជ្ញាធរខេត្តនឹងត្រូវបានយកមកពិចារណាដោយក្រុមការងារខេត្ត។ កន្លែងណាដែលត្រូវបានស្នើឲ្យមានការកែតម្រូវ ផលវិបាករបស់វា ត្រូវតែមានការពិភាក្សា ហើយប្រសិនបើមានការឯកភាព ក្រុមការងារខេត្ត មានភារកិច្ចធ្វើបច្ចុប្បន្នភាពលើការងារនោះ។

### លទ្ធផលរំពឹងទុក

- អាជ្ញាធរខេត្តមានការឯកភាពទៅលើលទ្ធផលកសាងផែនការទាំងមូល និងអបអរសាទរចំពោះសេចក្តីព្រាងផែនការ។

## ជំហានទី៥ ការអនុវត្ត ត្រួតពិនិត្យ វាយតម្លៃ និងធ្វើបច្ចុប្បន្នភាពផែនការ

**គោលបំណងរួម**

- ការទទួលខុសត្រូវសម្រាប់ការអនុវត្ត គឺច្បាស់លាស់ និងត្រូវបានពន្យល់
- ទំនាក់ទំនងទៅនឹងផែនការវិនិយោគ និងផែនការអភិវឌ្ឍន៍ ផែនការរៀបចំដែនដី និងផែនការតាមវិស័យ មានភាពច្បាស់លាស់ និងត្រូវបានពន្យល់
- ការត្រួតពិនិត្យទៅលើការអនុវត្ត គឺមានភាពច្បាស់លាស់ និងត្រូវបានពន្យល់
- កំណត់បច្ចុប្បន្នភាពដំណើរការដោយផ្អែកទៅលើភាពស៊ីគ្នាជាមួយនឹងវដ្តដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍។

### ការងារ ៥.១ ការអនុវត្ត និងការត្រួតពិនិត្យ

### ស្ថានភាពទូទៅ

ផែនការរៀបចំដែនដីខេត្ត ត្រូវបានធ្វើការអនុវត្តទៅតាមមធ្យោបាយផ្សេងៗ និងដោយអ្នកពាក់ព័ន្ធផ្សេងៗ។ ផែនការរៀបចំដែនដីថ្នាក់ខេត្តផ្ទាល់មិនមែនភ្ជាប់ប្រជាជនខេត្តមួយទៅនឹងលក្ខខណ្ឌរបស់ផែនការនោះទេ ប៉ុន្តែវាមានភ្ជាប់ទៅនឹងរដ្ឋបាលនិងផែនការតាមវិស័យផ្សេងៗដែលនឹងមានបច្ច័យផ្ទាល់ដល់ប្រជាជននៅក្នុងខេត្ត។ វាមានសារៈសំខាន់ណាស់ក្នុងការកំណត់ឲ្យច្បាស់លាស់ពីតួនាទីរបស់អ្នកពាក់ព័ន្ធទាំងអស់នៅក្នុងការអនុវត្តផែនការរៀបចំដែនដីថ្នាក់ខេត្ត ហើយអ្នកធ្វើសេក្តីសម្រេចចិត្តទាំងអស់ត្រូវការសម្រេចចិត្តដោយផ្អែកទៅលើចំណេះដឹងដែលមាននៅក្នុងផែនការនេះជាចាំបាច់។ វាចាំបាច់ណាស់ក្នុងការកំណត់ការទទួលខុសត្រូវក៏ដូចជាយន្តការនៃការអនុវត្តនិងស្វែងរកការគាំទ្រពីអភិបាលខេត្ត និងក្រុមប្រឹក្សាខេត្ត។

**អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?**

- អ្នកផ្តួចផ្តើម
    - ក្រុមការងារខេត្ត
- អ្នកចូលរួម
    - គណៈអភិបាលខេត្ត
    - មន្ទីរជំនាញ
    - គ.ជ.ន.ខ
    - ក្រុមប្រឹក្សាខេត្ត

## សកម្មភាពការងារ/វិធីសាស្ត្រ

- រៀបចំសិក្ខាសាលាធ្វើបទបង្ហាញនិងពិគ្រោះយោបល់៖
  - យន្តការ និងការទទួលខុសត្រូវលើការអនុវត្ត
  - តារាងម៉ាទ្រីកដែលមានគោលដៅ គោលបំណង និងសកម្មភាព ក៏ដូចជាផែនទីអភិវឌ្ឍន៍នាពេល អនាគតទាំងបីជាមួយនឹងយុទ្ធសាស្ត្រដែនដី
  - គោលបំណង និងគោលការណ៍នៃការត្រួតពិនិត្យ
- កំណត់ពីការទទួលខុសត្រូវសម្រាប់ការអនុវត្ត ដោយផ្អែកទៅលើការយល់ដឹងពីរបៀបដែលផែនការរៀបចំដែនដី ត្រូវធ្វើការអនុវត្ត។

ផែនការរៀបចំដែនដីថ្នាក់ខេត្ត គឺភាគច្រើនមានផលប៉ះពាល់ដោយប្រយោល មានន័យថា យុទ្ធសាស្ត្រដែលបានលើកឡើងនៅក្នុងផែនការរៀបចំដែនដីត្រូវតែធ្វើសមាហរណកម្មទៅក្នុង៖

ក) ផែនការតាមវិស័យ (មើលចំណុច៤.២) - ប្រសិនបើមានយុទ្ធសាស្ត្រដែនដីជាក់លាក់ (ឧ. ជម្រើសផ្លូវផ្សេងទៀតសម្រាប់ធ្វើផ្លូវថ្មី តំបន់ការពារថ្មីដែលនឹងត្រូវបង្កើត)។ វិស័យពាក់ព័ន្ធទទួលខុសត្រូវទៅតាមមន្ទីរជំនាញរបស់ខ្លួន។

ខ) ផែនការវិនិយោគនិងផែនការអភិវឌ្ឍន៍ - ប្រសិនបើយុទ្ធសាស្ត្រទាមទារនូវវិធីសាស្ត្រអភិវឌ្ឍន៍ (ឧ. ការកំណត់ទីតាំងដែលគួររៀបចំកសាងបរិក្ខារជាក់លាក់ណាមួយឬការគ្រប់គ្រងព្រៃឈើទាមទារនូវការបណ្តុះបណ្តាលជាក់លាក់ណាមួយ)។ ក្រសួងមហាផ្ទៃ/គណៈកម្មាធិការសម្រាប់អភិវឌ្ឍន៍តាមបែបលទ្ធិប្រជាធិប្បតេយ្យថ្នាក់ក្រោមជាតិ (NCDD) ជាអ្នកទទួលបន្ទុក។

គ) ផែនការប្រើប្រាស់ដី(ប្លង់គោល)កម្រិតទាប - ប្រសិនបើយុទ្ធសាស្ត្រដែនដីទាមទារការពន្យល់ដែនដីលម្អិតបន្ថែមទៅលើមាត្រដ្ឋានផ្សេងៗគ្នា (ឧ.ការប្រមើលមើលទៅលើតំបន់ទូទៅមួយដើម្បីផ្តល់សម្បទានដីសង្គមកិច្ច ប៉ុន្តែទីតាំងជាក់លាក់មិនត្រូវបានកំណត់នៅ ឡើយ) - គ.ដ.ន.ខ ជាអ្នកទទួល បន្ទុក។

ការអនុវត្តផ្ទាល់នៃផែនការរៀបចំដែនដីថ្នាក់ខេត្តដែលមានស្រាប់ ដូចជាកន្លែងណាដែលត្រូវឆ្លើយតបទៅនឹងអាណត្តិទៀងទាត់របស់អង្គភាពរដ្ឋបាល ឧទាហរណ៍ពាក់ព័ន្ធទៅនឹងការបង្កើតទស្សនទាន ឬការអង្កេត និងការវិភាគ។

ការទទួលខុសត្រូវរួមសម្រាប់ការអនុវត្តផែនការរៀបចំដែនដីថ្នាក់ខេត្តសម្រេចលើក្រុមប្រឹក្សាខេត្ត និង គ.ដ.ន.ខ ។

- ដោយផ្អែកលើការយល់ដឹងទាំងនេះ ធ្វើការសម្របសម្រួលការពិភាក្សាមួយដែលស្វែងរកនូវការបំពេញបន្ថែមទៅលើតារាងម៉ាទ្រីកជាមួយនឹងតម្រូវការត្រួតពិនិត្យ ដូចជាក្របខ័ណ្ឌពេលវេលា ការទទួលខុសត្រូវ និងសុច្ចនាករផ្សេងៗជាដើម។ វាគួរធ្វើការបញ្ជាក់ឲ្យបានច្បាស់ពីកន្លែងដែលត្រូវធ្វើសមាហរណកម្មទៅក្នុងផែនការដ៏ទៃទៀត។ ឧទាហរណ៍ ការកសាងប្រព័ន្ធធារាសាស្ត្រថ្មីអាចទាមទារនូវការសិក្សាលម្អិតបន្ថែមទៀត (ការទទួលខុសត្រូវតាមវិស័យ) និងម្យ៉ាងវិញទៀតក៏ត្រូវធ្វើការសាងសង់ជាក់ស្តែង (ផែនការវិនិយោគ និងផែនការអភិវឌ្ឍន៍) ផងដែរ។
- តារាងលទ្ធផលម៉ាទ្រីក ត្រូវជូនដំណឹងដល់ គ.ដ.ន.ខ ពីពេលវេលា និងរបៀបធ្វើបច្ចុប្បន្នភាពព័ត៌មានដែលត្រូវការ។ វាគួរផ្តល់នូវឯកសារយោងជាក់លាក់បន្ថែមទៀត សម្រាប់រៀបចំផែនការវិនិយោគនិងអភិវឌ្ឍន៍ ដូច្នេះយុទ្ធសាស្ត្រដែនដីត្រូវបានបំពេញបន្ថែមហើយគោរពតាមវិធានការណ៍នៃការអភិវឌ្ឍ។
- ដោយការអភិវឌ្ឍដែនដីខេត្តស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាខេត្ត យន្តការធ្វើរបាយការណ៍រវាងគ.ដ.ន.ខ និងក្រុមប្រឹក្សាខេត្តដោយផ្អែកទៅលើតារាងម៉ាទ្រីកដែលបានពង្រីកបន្ថែម ទាមទារឲ្យមានការពិភាក្សា និងឯកភាព។ ឧទាហរណ៍ គ.ដ.ន.ខ អាចតម្រូវឲ្យផ្តល់ (ធ្វើបច្ចុប្បន្នភាព) ព័ត៌មានដល់ក្រុមប្រឹក្សា រាល់ត្រីមាសក្នុងការប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា ហើយវាត្រូវបំពេញបន្ថែមដោយរបាយការណ៍ពាក់ព័ន្ធពី មន្ទីរជំនាញ។
- តារាងម៉ាទ្រីក គួរត្រូវបានគាំទ្រដោយអាជ្ញាធរមានសមត្ថកិច្ចនិងជាផ្នែកមួយនៃផែនការរៀបចំដែនដីថ្នាក់ខេត្តដែលបានអនុម័ត។

**លទ្ធផលរំពឹងទុក**

- តារាងម៉ាទ្រីកច្បាស់លាស់មួយរួមបញ្ចូលសកម្មភាពដែលត្រូវការទាំងអស់ ដែលជាលទ្ធផលមកពីផែនការរៀបចំដែនដីថ្នាក់ខេត្តត្រូវបានបង្កើតឡើង ដោយវាចង្អុលបង្ហាញយ៉ាងច្បាស់ពីតម្រូវការសម្រាប់ផែនការតាមវិស័យ ការរៀបចំផែនការវិនិយោគ និងអភិវឌ្ឍន៍ ក៏ដូចជាការរៀបចំផែនការរៀបចំដែនដីនៅថ្នាក់ក្រោម ដោយបំពេញបន្ថែមជាមួយលក្ខណៈសំខាន់ៗនៃការត្រួតពិនិត្យដូចជារយៈពេល និងសុច្ចនាករ។ តារាង ម៉ាទ្រីកនេះ ត្រូវបានគាំទ្រដោយអភិបាលខេត្ត ក្រុមប្រឹក្សាខេត្ត គ.ដ.ន.ខ និងមន្ទីរជំនាញ។
- មានការឯកភាពទៅលើយន្តការនៃការធ្វើរបាយការណ៍ស្តីអំពីការត្រួតពិនិត្យទៅលើការអនុវត្តផែនការរៀបចំដែនដីថ្នាក់ខេត្ត។

## ការងារ ៥.២ ការវាយតម្លៃ ធ្វើបច្ចុប្បន្នភាព និងការធ្វើឲ្យមានភាពរលូននៃការធ្វើផែនការ

### ស្ថានភាពទូទៅ

យោងតាមគោលនយោបាយជាតិស្តីអំពីផែនការរៀបចំដែនដី ផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ ៥ ឆ្នាំម្តង។ ការធ្វើបច្ចុប្បន្នភាពនេះនឹងត្រូវស៊ីពេលច្រើន ដូចនេះហើយ វាត្រូវការរៀបចំផែនការឲ្យបានល្អជាមុន។ វាគួរពឹងផ្អែកទៅលើការវាយតម្លៃដែលបង្ហាញថាតើផែនការរៀបចំដែនដីថ្នាក់ខេត្តចូលរួមដល់ការអភិវឌ្ឍដែនដីប្រកបដោយចីរភាព និងមានភាពរលូនជាមួយវដ្តនៃការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំដោយរបៀបណា។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកផ្តួចផ្តើម
    - ក្រុមការងារខេត្ត
- អ្នកចូលរួម
    - គណៈអភិបាល
    - មន្ទីរជំនាញ
    - គ.ដ.ន.ខ
    - ក្រុមប្រឹក្សាខេត្ត

### សកម្មភាពការងារ/វិធីសាស្រ្ត

- សម្រាប់ការធ្វើបច្ចុប្បន្នភាពលើកដំបូងនៃផែនការរៀបចំដែនដីថ្នាក់ខេត្ត ការកែសម្រួលដែលធ្វើឡើងស្របពេលគ្នាជាមួយនឹងវដ្តនៃការរៀបចំផែនការអភិវឌ្ឍន៍រយៈពេល ៥ ឆ្នាំ មានសារៈសំខាន់ជាងការដែលមិនបត់បែនរង់ចាំរហូតទាល់តែគ្រប់ ៥ ឆ្នាំ ទើបធ្វើបច្ចុប្បន្នភាពនោះ។ ការវិភាគស្ថានភាព ចក្ខុវិស័យ និងគោលដៅ គួរផ្តល់ព័ត៌មានសម្រាប់ការរៀបចំផែនការអភិវឌ្ឍន៍។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ត្រូវធ្វើការបំពេញបន្ថែមជាលក្ខណៈប្រព័ន្ធ ដោយមធ្យោបាយដែលបានប្រមើលមើលទុកមុននៅក្នុងផែនការលម្អិត។ ដូច្នេះផែនការរៀបចំដែនដីត្រូវធ្វើបច្ចុប្បន្នភាព និងអនុម័តមុនពេលដែលការកសាងផែនការលម្អិតចាប់ផ្តើម។ ការរួមគ្នា (synergies) ជាមួយនឹងផែនការលម្អិត គឺមានសារៈសំខាន់ណាស់ និងសម្រួលដល់ការបង្កើតផែនការនេះ ខណៈដែលក្របខ័ណ្ឌកសាងផែនការខេត្តទាំងមូលកាន់តែមានប្រសិទ្ធភាព និងកាន់តែរហ័ស។

- ដំណើរការបន្ទ័គ្នានេះ ត្រូវធ្វើការគិតពីចំនុចចុងក្រោយបញ្ចប់វិញ៖
    - កំណត់កាលបរិច្ឆេទចាប់ផ្តើមដំណើរការកសាងផែនការលម្អិត.

ជំហានទី១
ជំហានទី២
ជំហានទី៣
ជំហានទី៤
ជំហានទី៥
ជំហានទី៦

  - ធ្វើការគិតត្រលប់ថយក្រោយវិញថាតើ នៅពេលណាដែលគួរចាប់ផ្តើមដំណើរការធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដីថ្នាក់ខេត្ត ដើម្បីឲ្យដំណើរការនេះអាចបញ្ចប់ឲ្យបានទាន់ពេលវេលាមុនពេលចាប់ផ្តើមកសាងផែនការថ្នាក់ស្រុក។ ក្នុងខណៈដែលដំណើរការកសាងផែនការរៀបចំដែនដីអាចត្រូវចំណាយពេលប្រហែលជា ២ ឆ្នាំ វាគួរតែទុករយៈពេលបម្រុងខ្លីមួយពី ៣ ទៅ ៦ ខែ ផ្សេងទៀត នៅចន្លោះពេលរវាងការអនុម័តដែលបានគ្រោងទុកលើផែនការរៀបចំដែនដីដែលបានធ្វើបច្ចុប្បន្នភាពរួចហើយនិងការចាប់ផ្តើមដំណើរការកសាងផែនការថ្នាក់ស្រុក។
  - ការធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដីខេត្ត គួរយោងទៅតាមការវាយតម្លៃជាមុនមួយដែលធ្វើការវិភាគពីភាពជោគជ័យ ឬមុខងាររបស់ផែនការរៀបចំដែនដីថ្នាក់ខេត្ត ជាផែនការនៃការអភិវឌ្ឍដែនដីប្រកបដោយចីរភាព។ ដំណើរការធ្វើបច្ចុប្បន្នភាពត្រូវផ្អែកទៅលើបទពិសោធន៍ការងារ។ ការវាយតម្លៃរបៀបនេះ ទាមទារនូវការរៀបចំ ក៏ដូចជាត្រូវការពេលវេលាគ្រប់គ្រាន់ផងដែរ។ លើកលែងតែបទពិសោធន៍មុនៗមិនអំណោយផលឲ្យធ្វើ ដូច្នេះត្រូវទុករយៈពេល ៦ ខែសម្រាប់ការងារនេះ (ការរៀបចំ ការវាយតម្លៃ និងសេចក្តីសន្និដ្ឋាន) ហាក់ដូចជាសមហេតុផល។ នេះជាការទទួលខុសត្រូវរបស់ គ.ដ.ន.ខ និងទាមទារឲ្យមានការចូលរួមពេញលេញពីគណៈកម្មាធិការនេះ។ វាក៏ត្រូវបានផ្តល់ការណែនាំឲ្យរកអ្នកជំនាញពីខាងក្រៅផងដែរ ដើម្បីជួយក្នុងដំណើរការនេះ។

- ការបន្សុីគ្នាជាមួយនឹងផែនការលម្អិតអាចនាំឲ្យមានតម្រូវការធ្វើបច្ចុប្បន្នភាពរយៈពេលខ្លីមួយប៉ុណ្ណោះ ខណៈដែលការវាយតម្លៃមិនអាចផ្តល់នូវបទពិសោទន៍ដ៏មានអត្ថន័យពីការអនុវត្តនោះ។ ដូច្នេះវាអាចមានសារៈសំខាន់ ក្នុងការមានគោលបំណងធ្វើឲ្យមានភាពបន្សុីគ្នាជាមួយនឹងដំណើរការកសាងផែនការលម្អិតបន្ទាប់ លម្អិតបន្ទាប់ទី២ ហើយផែនការលម្អិតបន្ទាប់ទៀត នៅតែប្រើប្រាស់ផែនការរៀបចំដែនដីថ្នាក់ខេត្តជាឯកសារយោង (បង្គោល) ។
- **គន្លឹះសំខាន់៖** ការងារ៥.១ និង៥.២ ឆ្លើយតបទៅនឹងក្រុមអ្នកពាក់ព័ន្ធដូចគ្នានិងរៀបចំក្នុងសិក្ខាសាលារួមមួយ។

## ជំហានទី៦ បញ្ចប់ដំណើរការកសាងផែនការ

**គោលបំណងរួម**

- ដំណើរការពិភាក្សាជាសាធារណៈចុងក្រោយ
- បញ្ចប់របាយការណ៍បច្ចេកទេស
- ការគាំទ្រដល់ផែនការរៀបចំដែនដីថ្នាក់ខេត្តដោយក្រុមប្រឹក្សាខេត្ត
- ការឯកភាពដោយ គ.ដ.ន.ជ

### ការងារ ៦.១ ការពិភាក្សាជាសាធារណៈចុងក្រោយជាមួយអ្នកពាក់ព័ន្ធទាំងអស់

### ស្ថានភាពទូទៅ

សិក្ខាសាលាពិគ្រោះយោបល់សាធារណៈ ផ្តល់ឱកាសដល់សាធារណៈជនធ្វើការផ្តល់យោបល់ទៅលើសេចក្តីព្រាងនៃផែនការរៀបចំដែនដីថ្នាក់ខេត្ត។ ដើម្បីធានាដល់ការចូលរួមដ៏ទូលំទូលាយមួយ អ្នកពាក់ព័ន្ធផ្សេងៗជាច្រើន គួរត្រូវបានអញ្ជើញចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈចុងក្រោយ (ឧទាហរណ៍ដូចជាអ្នកតំណាងឃុំ វិស័យឯកជន សមាគមកសិករ)។ គោលបំណងរបស់សិក្ខាសាលាគឺ ដើម្បីប្រមូលយោបល់និងប្រតិកម្មតបផ្សេងៗ និងដើម្បីយល់ថាតើជាទូទៅសាធារណៈជនអាចទទួលយកផែនការនេះដោយរបៀបណា។ សិក្ខាសាលានេះ ក៏ជួយដល់ក្រុមការងារខេត្តធ្វើការកែតម្រូវទៅលើសេចក្តីព្រាងនេះ ឲ្យកាន់តែជាក់លាក់ដែលមានលក្ខណៈគ្រប់គ្រាន់សម្រាប់ការបិទផ្សាយជាសាធារណៈនៅក្នុងបរិបទមួយដែលវាតំណាងពីការឯកភាពពីអ្នកពាក់ព័ន្ធទាំងអស់។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- ការសម្របសម្រួល
  - ក្រុមការងារខេត្ត
- អ្នកចូលរួម
  - គ.ដ.ន.ខ
  - ក្រុមប្រឹក្សាខេត្ត និងខុទ្ទកាល័យខេត្ត
  - មន្ទីរជំនាញជុំវិញខេត្ត
  - រដ្ឋបាលស្រុក (ក្រុមប្រឹក្សា និងគណៈអភិបាល)
  - វិស័យឯកជន (សភាពាណិជ្ជកម្ម)
  - តំណាង អង្គការក្រៅរដ្ឋាភិបាល
  - អង្គការដៃគូអភិវឌ្ឍន៍អន្តរជាតិ
  - តំណាងពីអង្គការសហគមន៍សំខាន់ៗនៅក្នុងខេត្ត
- ការគាំទ្រ
  - គ.ដ.ន.ខ
  - ក្រុមប្រឹក្សាខេត្ត

**សកម្មភាពការងារ/វិធីសាស្ត្រ**

- ផ្សព្វផ្សាយសេចក្ដីព្រាងផែនការរៀបចំដែនដីថ្នាក់ខេត្ត ដល់អ្នកពាក់ព័ន្ធដែលត្រូវចូលរួមទាំងអស់ យ៉ាងហោចណាស់ឲ្យបាន ២ សប្ដាហ៍មុនពេលសិក្ខាសាលាចាប់ផ្ដើម។
- ចាប់ផ្ដើមសិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈជាមួយនឹងបទបង្ហាញទូទៅខ្លីមួយពីដំណើរការកសាងផែនការនិងលទ្ធផលសំខាន់ៗរបស់វា(ការវិភាគស្ថានភាព សេណារីយ៉ូ ចក្ខុវិស័យ គោលដៅ និងយុទ្ធសាស្ត្រសម្រាប់អភិវឌ្ឍដែនដីនាពេលអនាគត)។
- ផ្ដួចផ្ដើមការពិភាក្សាជាមួយអ្នកចូលរួមទាំងអស់ដើម្បីទទួលបាននូវប្រតិកម្មតបពីអ្នកពាក់ព័ន្ធទាំងអស់ទាក់ទងទៅនឹងសមាសភាគនៃផែនការរៀបចំដែនដី។
- សមាសភាគដែលទទួលបានក្នុងសិក្ខាសាលានេះ គួរធ្វើការរៀបចំជាឯកសារឲ្យបានល្អ និង ពិចារណាទៅលើការរៀបចំរបាយការណ៍បច្ចេកទេសចុងក្រោយរបស់ផែនការរៀបចំដែនដីថ្នាក់ខេត្ត។

**លទ្ធផលរំពឹងទុក**

- អ្នកពាក់ព័ន្ធទាំងអស់បានដឹង និងយល់ពីខ្លឹមសារនៃផែនការរៀបចំដែនដីថ្នាក់ខេត្ត។
- មតិយោបល់ដែលអ្នកចូលរួមផ្ដល់ឲ្យ នឹងត្រូវបញ្ចូលទៅក្នុងសេចក្ដីព្រាងចុងក្រោយនៃរបាយការណ៍បច្ចេកទេសផែនការរៀបចំដែនដីថ្នាក់ខេត្ត។

### ការងារ ៦.២ ការរៀបចំរបាយការណ៍បច្ចេកទេសចុងក្រោយ

**ស្ថានភាពទូទៅ**

ដោយផ្អែកលើសេចក្ដីព្រាងនៃរបាយការណ៍ដែលបានបង្កើតឡើងកន្លងមក និងការផ្ដល់មតិដែលបានធ្វើឡើងក្នុងកំឡុងពេលសិក្ខាសាលាពិគ្រោះយោបល់ចុងក្រោយ ក្រុមការងារខេត្តនឹងរៀបចំរបាយការណ៍បច្ចេកទេសចុងក្រោយរបស់ផែនការរៀបចំដែនដីថ្នាក់ខេត្ត។

**អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?**

- ការសម្របសម្រួល
    - ក្រុមការងារខេត្ត
- អ្នកចូលរួម
    - ក្រុមការងារខេត្ត
    - គ.ដ.ន.ខ
    - ក្រុមប្រឹក្សាខេត្ត និង ខុទ្ទកាល័យខេត្ត

### សកម្មភាពការងារ/វិធីសាស្ត្រ

- ការទទួលខុសត្រូវចំពោះការសរសេរបញ្ចប់ជំពូកនីមួយៗរបស់របាយការណ៍ គឺគួរធ្វើការរៀបចំទៅតាមក្រុមនីមួយៗផ្សេងៗគ្នា ដោយផ្អែកទៅលើជំនាញបទពិសោធន៍របស់សមាជិកក្រុម និងមានកិច្ចសហប្រតិបត្តិការជាមួយនឹងសាមីមន្ទីរជំនាញតាមវិស័យ ។
- ប្រមូលផ្តុំជំពូកទាំងអស់ និងធ្វើការពិនិត្យទៅលើជំពូកទាំងអស់នេះជាចុងក្រោយដែលគួររៀបចំឡើងដោយក្រុមការងារខេត្ត និង គ.ដ.ន.ខ តាមរយៈកិច្ចខិតខំប្រឹងប្រែងសហការគ្នា។

### លទ្ធផលរំពឹងទុក

- របាយការណ៍បច្ចេកទេសចុងក្រោយ និងពេញលេញមួយរបស់ផែនការរៀបចំដែនដីថ្នាក់ខេត្តត្រូវបានរៀបចំឡើង។ ឧបសម្ព័ន្ធ៣ ផ្តល់នូវគោលសំខាន់ៗនៃរបាយការណ៍បច្ចេកទេសនៃផែនការរៀបចំដែនដីថ្នាក់ខេត្ត។

## ការងារ ៦.៣ ការបិទផ្សាយជាសាធារណៈ និងការគាំទ្រលើផែនការដោយក្រុមប្រឹក្សាខេត្ត

### ស្ថានភាពទូទៅ

សេចក្តីព្រាងនៃរបាយការណ៍បច្ចេកទេសផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវបានធ្វើការបិទផ្សាយជាសារធារណៈសម្រាប់រយៈពេល ៩០ ថ្ងៃ នៅសាលាខេត្ត និងសាលាស្រុកនីមួយៗនៅក្នុងខេត្ត។ ការបិទផ្សាយនេះផ្តល់ឱកាសដល់ប្រជាពលរដ្ឋ សមាគម អង្គការក្រៅរដ្ឋាភិបាល ធ្វើការពិនិត្យលើរបាយការណ៍ និងលើកជាសំណូមពរនិងធ្វើការរិះគន់ជាចុងក្រោយ។ តួនាទីដ៏សំខាន់របស់ក្រុមការងារខេត្ត និងគ.ដ.ន.ខ គឺធ្វើការចងក្រងឯកសារអំពីមតិយោបល់ផ្សេងៗដែលទទួលបានមកតាមរយៈចំណាប់អារម្មណ៍របស់សាធារណៈ ក្នុងពេលបិទផ្សាយជាសាធារណៈនោះ។ ការរៀបចំឯកសារនេះ ត្រូវបំពេញបន្ថែមដល់សេចក្តីព្រាងរបាយការណ៍បច្ចេកទេស និងត្រូវធ្វើការចែករំលែកជាមួយនឹងក្រុមប្រឹក្សាខេត្ត និងគ.ដ.ន.ជ នៅពេលដែល ស្វែងរកការគាំទ្រក៏ដូចជាការអនុម័ត។ នៅពេលដែលដំណើរការនេះបានបញ្ចប់ទៅដោយជោគជ័យ ក្រុមប្រឹក្សាខេត្តធ្វើការគាំទ្រឯកភាពជាផ្លូវការចំពោះរបាយការណ៍បច្ចេកទេសផែនការរៀបចំដែនដីថ្នាក់ខេត្ត។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- ការសម្របសម្រួល
    - ក្រុមការងារខេត្ត
- អ្នកចូលរួម
    - ក្រុការងារខេត្ត
    - គ.ដ.ន.ខ

**សកម្មភាពការងារ/វិធីសាស្ត្រ**

- ក្រុមការងារខេត្ត គួរផ្តល់នូវការអនុញ្ញាត (ភ្លើងខៀវ) ឲ្យចាប់ផ្តើមការបិទផ្សាយជាសាធារណៈ។
- ក្រុមការងារ នឹងធ្វើការរៀបចំ និងបិទផ្សាយជាសាធារណៈផែនទីទំហំA0 ដែលបង្ហាញពីយុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដីទាំងអស់ដែលបានព្យាករណ៍ដោយផែនការ និងការពន្យល់ជាសង្ខេបទៅលើការព្យាករណ៍ជាលាយល័ក្ខអក្សរ។
- អាជ្ញាធរស្រុកនិងខេត្ត គួរនៅធ្វើការអង្កេតរយៈពេល ៩០ ថ្ងៃ នៃការបិទផ្សាយដើម្បីផ្តល់ឱកាសសម្រាប់សាធារណៈជនធ្វើការពិចារណាលើផែនការ និងសំណូមពរធ្វើការកែតម្រូវឬផ្តល់ជាអនុសាសន៍ផ្សេងៗ។
- សំណើទាំងអស់ គួរត្រូវបានធ្វើការដោះស្រាយឆ្លើយតបឲ្យបានសមរម្យទៅតាមដំណើរការដែលមានការឯកភាពរួមមួយ។ ក្រុមការងារគួរធ្វើការកត់ត្រាដោយអព្យាក្រឹត្យរាល់សំណើប្រតិកម្មតប និងការរិះគន់ដែលបានលើកឡើងទាំងអស់។ វាគួរធ្វើការចងក្រងបែងចែកសំណើប្រតិកម្មតប និងការរិះគន់ទាំងអស់នេះទៅតាមប្រភេទ និងក្រុមដើម្បីធ្វើការដោះស្រាយសំណើទាំងអស់នោះជាប្រព័ន្ធនិងប្រកបដោយប្រសិទ្ធភាព។ បញ្ជីសំណើ (ដែលបានរៀបចំទៅតាមក្រុម) ដែលបានមកពីការបិទផ្សាយជាសាធារណៈត្រូវការធ្វើការបំពេញបន្ថែមជាមួយនឹងការរៀបចំឯកសារស្តីពី ថាតើសំណើទាំងនោះត្រូវបានធ្វើការដោះស្រាយដោយរបៀបណា (ឧ. ទទួលយក ទទួលយកខ្លះ មិនទទួល) និងមូលហេតុនៅពីក្រោយ។
- ធ្វើការរៀបចំកិច្ចប្រជុំគាំទ្រជាមួយក្រុមប្រឹក្សាខេត្ត ដែលនៅក្នុងកិច្ចប្រជុំនេះនឹងធ្វើបទបង្ហាញស្តីពីផែនការរៀបចំដែនដីថ្នាក់ខេត្តនេះដល់ក្រុមប្រឹក្សាខេត្ត។ បទបង្ហាញថ្មីនេះត្រូវបន្ថែមទៅលើបទបង្ហាញមុនៗ និងបន្ថែមនូវការពាក់ព័ន្ធរបស់ក្រុមប្រឹក្សានៅក្នុងដំណើរកសាងផែនការជាពិសេសផ្តោតលើបញ្ហាចំបងទាំងឡាយ ដែលបានលើកឡើងនៅពេលបិទផ្សាយជាសាធារណៈ ហើយនិងពីរបៀបដែលបញ្ហាទាំងនោះត្រូវបានធ្វើការដោះស្រាយ។ ត្រូវចងចាំថាក្រុមប្រឹក្សាខេត្តអាចទាមទារឲ្យធ្វើការកែតម្រូវ ឬសំណូមពរឲ្យធ្វើការពន្យល់បញ្ជាក់បន្ថែម ដូច្នេះវាអាចត្រូវការនូវការរៀបចំកិច្ចប្រជុំផ្សេងទៀតសម្រាប់ការអនុម័តជាក់ស្តែង។

 

***រូបភាព៩៖*** បទបង្ហាញចុងក្រោយនៃផែនការរៀបចំដែនដីខេត្តបាត់បងដល់ក្រុមប្រឹក្សាខេត្ត

### លទ្ធផលរំពឹងទុកនៃការងារ ៦.៣

- ការបិទផ្សាយជាសាធារណៈ ត្រូវបានធ្វើឡើង និងអង្កេតរយៈពេល៩០ថ្ងៃ ហើយបញ្ហាទាំងឡាយដែលបានលើកឡើង នឹងត្រូវធ្វើការដោះស្រាយ និងចងក្រងជាឯកសារត្រឹមត្រូវ។
- ក្រុមប្រឹក្សាខេត្ត បានពិនិត្យរបាយការណ៍បច្ចេកទេសឡើងវិញ និងបានឯកភាពទៅលើអត្ថន័យរបស់វា និងដាក់ជូន គ.ដ.ន.ជ សម្រាប់ការឯកភាពចុងក្រោយ។

### ការងារ ៦.៤ ការឯកភាពលើផែនការដោយគណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ

### ស្ថានភាពទូទៅ

- របាយការណ៍បច្ចេកទេសចុងក្រោយនៃផែនការរៀបចំដែនដីថ្នាក់ខេត្តត្រូវបានដាក់ជូន គ.ដ.ន.ជ សម្រាប់ពិនិត្យ។
- តំណាងរបស់ គ.ដ.ន.ខ គួរធ្វើបទបង្ហាញពីដំណើរការកសាងផែនការ និងលទ្ធផលសំខាន់ៗ (បទបង្ហាញដែលបានរៀបចំឡើង សម្រាប់សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈចុងក្រោយ ហើយវាបានធ្វើការកែប្រែបន្ទាប់ពីសិក្ខាសាលានោះ)។ បទបង្ហាញនេះគួរគ្របដណ្តប់ទៅលើបញ្ហាដែលបានលើកឡើងក្នុងពេល បិទផ្សាយជាសាធារណៈ និងរបៀបដែលវាត្រូវបានដោះស្រាយ។
- មតិយោបល់ដែលទទួលបានកំឡុងពេលធ្វើបទបង្ហាញនេះពី គ.ដ.ន.ជ គួរធ្វើការចងក្រងជាឯកសារឲ្យបានល្អ និងគិតគូរដល់ការធ្វើការកែតម្រូវលើរបាយការណ៍បច្ចេកទេសចុងក្រោយ នៃផែនការរៀបចំដែនដីថ្នាក់ខេត្តដោយផ្អែកលើមតិយោបល់ដែលទទួលបានទាំងនោះ។
- គ.ដ.ន.ជឯកភាពលើផែនការរៀបចំដែនដីថ្នាក់ខេត្ត និងចាប់ផ្តើមដំណើរការរៀបចំការអនុម័តលើផែនការតាមរយៈអនុក្រឹត្យ។

### អ្នកណាខ្លះនឹងត្រូវពាក់ព័ន្ធនឹងការងារនេះ?

- អ្នកផ្តួចផ្តើម
  - គ.ដ.ន.ជ
- អ្នកចូលរួម
  - គ.ដ.ន.ជ
  - តំណាងក្រុមប្រឹក្សាខេត្ត និងខុទ្ទកាល័យខេត្ត
  - គ.ដ.ន.ខ
  - ក្រុមការងារខេត្ត

### លទ្ធផលរំពឹងទុក

- ការឯកភាពជាចុងក្រោយលើផែនការរៀបចំដែនដីថ្នាក់ខេត្តដោយ គ.ដ.ន.ជ។
- ផែនការរៀបចំដែនដីថ្នាក់ខេត្ត ត្រូវបានអនុម័តដោយអនុក្រឹត្យ។

## ឯកសារយោង

Cambodia Tree Seed Project. (2003). The gene-ecological zonation of Cambodia. Phnom Penh.

Centre for Research on the Epidemiology of Disasters. (2011). The International Disaster Database. Brussels: Université Catholique de Louvain - http://www.emdat.be/.

Doch, S., Diepart, J.-C., & Heng, C. (2015). A multi-scale flood vulnerability assessment of agricultural production in the context of environmental change: The case of the Sangkae River watershed, Battambang province. In J.-C. Diepart (Ed.), *Learning for resilience: Insights from Cambodia's rural communities* (pp. 19-49). Phnom Penh: The Learning Institute.

IPCC. (2013). Summary for Policymakers. In T. F. Stocker, D. Qin, G.-K. Plattner, M. Tignor, S. K. Allen, J. Boschung, A. Nauels, Y. Xia, V. Bex & P. M. Midgley (Eds.), *Climate Change 2013: The Physical Science Basis. Contribution of Working Group I to the Fifth Assessment Report of the Intergovernmental Panel on Climate Change*. Cambridge - United Kingdom and New York - USA: Cambridge University Press.

McCarthy, J. J., Canziani, O. F., Leary, N. A., Dokken, D. J., & White, K. S. (2001). Climate Change 2001: Impacts, Adaptation, and VulnerabilityContribution of Working Group II to the Fourth Assessment Report of the Intergovernmental Panel on Climate Change. Cambridge - United Kingdom and New York - USA.: Cambridge University Press.

National Institute of Statistics. (2010). *Report 12: Population projections of Cambodia*. Phnom Penh.

National Institute of Statistics. (2012). *Reclassification of Urban areas in Cambodia, 2011*. Phnom Penh: Natioanl Institute of Statisctics and UNFPA.

O'Keefe, T. C., Elliott, S. R., & Naiman, R. J. (Sine Die). Introduction to Watershed Ecology. *Watershed Academy Web. Distance Learning Modules on Watershed Management*. Retrieved from http://www.epa.gov/watertrain

# ឧបសម្ព័ន្ធ

## **ឧបសម្ព័ន្ធ១៖** សុច្ឆនាកររបស់សិក្ខាសាលាដែលនឹងត្រូវធ្វើឡើងក្នុងកំឡុងពេលដំណើរការកសាងផែនការរៀបចំដែនដី

| ការងារ | ចំណងជើង | គោលបំណង | អ្នកចូលរួម | ទីកន្លែង |
|---|---|---|---|---|
| ការងារ ១.១ | ការចាប់ផ្តើមសិក្ខាសាលាជាមួយអ្នកពាក់ព័ន្ធទាំងអស់ | ▪ បង្កើនការយល់ដឹងពីការផ្តួចផ្តើមកសាងផែនការ<br>▪ ពន្យល់ពីគោលបំណង និងទំហំផែនការរៀបចំដែនដីថ្នាក់ខេត្ត<br>▪ ពិភាក្សាពីតួនាទីនិងការរំពឹងទុករបស់អ្នកពាក់ព័ន្ធទាំងអស់ | ▪ ក្រុមប្រឹក្សានិងគណៈអភិបាលខេត្ត<br>▪ មន្ទីរជំនាញជុំវិញខេត្ត<br>▪ រដ្ឋបាលឯកភាពស្រុក<br>▪ តំណាងសមាគម និងអង្គការក្រៅរដ្ឋាភិបាល<br>▪ អង្គការដៃគូអភិវឌ្ឍអន្តរជាតិ<br>▪ តំណាងពីអង្គការសហគមន៍នៅក្នុងខេត្ត | សាលាខេត្ត |
| ការងារ ២.២ | សិក្ខាសាលាកសាងផែនការរៀបចំដែនដីស្រុក | ▪ បច្ចុប្បន្នភាពទិន្នន័យ<br>▪ វិភាគការប្រែប្រួលការប្រើប្រាស់ដី<br>▪ ពិនិត្យទៅលើភាពខ្លាំង បញ្ហា សក្តានុពល និងយុទ្ធសាស្ត្រ តាមវិស័យ | ▪ ក្រុមការងាររៀបចំទីក្រុង និងដែនដី<br>▪ ការិយាល័យជំនាញជុំវិញស្រុក<br>▪ រដ្ឋបាលស្រុក<br>▪ ក្រុមប្រឹក្សាឃុំ<br>▪ តំណាងសមាគមកសិករ<br>▪ អ្នកពាក់ព័ន្ធដទៃទៀត | សាលាស្រុកនៅក្នុងស្រុកនីមួយៗរបស់ខេត្ត |
| ការងារ ៤.២ | សិក្ខាសាលាយុទ្ធសាស្ត្រតាមវិស័យ និងអន្តរវិស័យ | ▪ ធ្វើបទបង្ហាញយុទ្ធសាស្ត្រអភិវឌ្ឍដែនដីអន្តរវិស័យដល់វិស័យនីមួយៗ<br>▪ កំណត់និងធ្វើការដោះស្រាយបញ្ហាទំនាស់រវាងវិស័យទាំងនោះ<br>▪ កំណត់(ស្វែងរក)ថាតើវិស័យទាំងនោះចូលរួមដល់យុទ្ធសាស្ត្ររួមដោយរបៀបណា | ▪ ក្រុមការងាររៀបចំទីក្រុង និងដែនដី<br>▪ គ.ដ.ន.ខ<br>▪ មន្ត្រីពីមន្ទីរជំនាញជុំវិញខេត្ត<br>▪ ក្រុមប្រឹក្សាខេត្ត<br>▪ គណៈអភិបាលខេត្ត | សាលាខេត្ត |
| ការងារ ៦.១ | សិក្ខាសាលាពិគ្រោះយោបល់ជាសាធារណៈចុងក្រោយ | ▪ ធ្វើការចែកចាយឯកសារផែនការរៀបចំដែនដីខេត្ត<br>▪ ផ្តល់ឱកាសដល់អ្នកពាក់ព័ន្ធទាំងអស់ផ្តល់ជាមតិយោបល់ និងសំណូមពរលើការពិនិត្យឡើងវិញ | ▪ ក្រុមប្រឹក្សាខេត្តនិងគណៈអភិបាលខេត្ត<br>▪ មន្ទីរជំនាញជុំវិញខេត្ត<br>▪ រដ្ឋបាលឯកភាពស្រុក<br>▪ ក្រុមប្រឹក្សាឃុំ<br>▪ តំណាងពីសមាគម និងអង្គការក្រៅរដ្ឋាភិបាល<br>▪ អង្គការដៃគូរអភិវឌ្ឍអន្តរជាតិ<br>▪ តំណាងពីអង្គការសហគមន៍សំខាន់ៗនៅក្នុងខេត្ត | សាលាខេត្ត |

## ឧបសម្ព័ន្ធ២៖ តារាងទិន្នន័យទីតាំងភូមិសាស្ត្រ និងទិន្នន័យមិនមានភ្ជាប់ទៅទីតាំង (spatial and non-spatial) ដែលត្រូវការ

| ផ្នែក | ប្រធានបទ | ទិន្នន័យ | ប្រភព | បច្ចុប្បន្នភាព | ទទួលតាមគេហទំព័រ |
|---|---|---|---|---|---|
| ភូមិសាស្ត្រ | រដ្ឋបាល | ព្រំប្រទល់រដ្ឋបាល (ប្រទេស ខេត្ត ស្រុក និងឃុំ) | នាយកដ្ឋានភូមិសាស្ត្រ(ភ្នំពេញ) | តាមដែលអាចរកបាន | |
| | | ទីតាំងមជ្ឈមណ្ឌលរដ្ឋបាល | នាយកដ្ឋានភូមិសាស្ត្រ(ភ្នំពេញ) | តាមដែលអាចរកបាន | |
| បរិស្ថានរូបសាស្ត្រ | សណ្ឋានដី | ខ្សែរយៈកម្ពស់ | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យពី Jica) | | |
| | | Digital Elevation Model/hillshade | គណៈកម្មការទន្លេមេគង្គ(MRC) Interactive Atlas | | |
| | ទីជម្រាល | ព្រំព្រទល់ទីជម្រាល(ដៃទីជម្រាល) | គណៈកម្មការទន្លេមេគង្គ(MRC) Interactive Atlas | | |
| | អាកាសធាតុ | ទិន្នន័យធាតុអាកាស (កំណកអាកាស និងសីតុណ្ហភាព) | មន្ទីរធនធានទឹក និងឧតុនិយមខេត្ត | តាមដែលអាចរកបាន | |
| | ជលវិទ្យា | ផ្ទៃទឹក | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យពី Jica) | | |
| | | ខ្សែទឹក | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យពី Jica) | | |
| | | គ្រោះទឹកជំនន់ (តំបន់កណ្តាល) | គណៈកម្មការទន្លេមេគង្គ(MRC) Interactive Atlas | ១៩៩៩ | |
| | ភូគព្ភសាស្ត្រ | ថ្ម | គណៈកម្មការទន្លេមេគង្គ(MRC) Interactive Atlas | | |
| | | | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យពី Jica) | | |
| | ដី | ដី (ជាមួយនឹងចំណាត់ថ្នាក់អង្គការ FAO) | គណៈកម្មការទន្លេមេគង្គ(MRC) Interactive Atlas | | ៣ |
| | អេកូឡូស៊ី | តំបន់អេកូឡូស៊ីតាមហ្សែន | រដ្ឋបាលព្រៃឈើ/DANIDA/DED | | ៣ |
| ប្រជាសាស្ត្រ និងលំនៅឋាន | ប្រជាសាស្ត្រ | ចំនួនប្រជជនតាមអាយុ តាមឃុំ/ស្រុក សម្រាប់ច្រើនឆ្នាំជាប់គ្នា | ជំរឿនប្រជាជន ១៩៩៨ -២០០៨ | ១៩៩៨ និង ២០០៨ | ១ |
| | | | ទិន្នន័យឃុំ | ២០០៦-២០១១ | ២ |
| | | ចំនួនអ្នកចំណូល និងចំណាកស្រុកក្នុងរយៈពេលជាក់លាក់មួយ | ជំរឿនប្រជាជន ២០០៨ | ២០០៨ | ១-៣ |
| | | ប្រជាជនតាមក្រុមអាយុ | ជំរឿនប្រជាជន ២០០៨ | ២០០៨ | ១ |
| | | | ទិន្នន័យឃុំ | ២០០៦-២០១១ | ២-៣ |
| | លំនៅឋាន | ទីតាំងនិងទំហំរបស់លំនៅឋានសំខាន់នៅតំបន់ជនបទ | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យពី Jica) | ១៩៩៩ | |
| | | ទីតាំងនិងទំហំរបស់មជ្ឈមណ្ឌលទីប្រជុំជនសំខាន់ៗ | មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់និងសុរិយោដី (ដ.ន.ស.ស) | តាមដែលអាចរកបាន | |
| | | ទីតាំងនិងការពិពណ៌នាពីសំណង់បណ្តោះអាសន្ននៅតំបន់ជនបទ/ទីប្រជុំជន | រដ្ឋបាលខេត្ត | តាមដែលអាចរកបាន | |
| ហេដ្ឋារចនា សម្ព័ន្ធរូបវ័ន្ត | ហេដ្ឋរចនាសម្ព័ន្ធដឹកជញ្ជូន | ទីតាំងនិងប្រភេទ/ស្ថានភាពផ្លូវ (កម្រិត ផ្ទៃផ្លូវ និងការអាចប្រើប្រាស់បាន) | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យពី Jica) - មន្ទីរសាធារណៈការ និងដឹកជញ្ជូនខេត្ត ឬ មន្ទីរ ដ.ន.ស.សខេត្ត | ១៩៩៩ សម្រាប់ទិន្នន័យJICA, អាចរកបានមកពីប្រភពផ្សេងទៀត | |
| | | ទីតាំងនិងប្រភេទស្ពាន | | | |
| | | ទីតាំងនិងស្ថានភាពផ្លូវដែក | | | |
| | | ទីតាំងនិងប្រភេទមធ្យោយធ្វើដំណើរផ្សេងៗទៀត | | | |

| | | | | | |
|---|---|---|---|---|---|
| | ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទឹក | ទីតាំងនិងស្ថានភាពប្រព័ន្ធធារាសាស្ត្រសំខាន់ៗ (ប្រឡាយ ទ្វារទឹក តំបន់គ្រប់គ្រងចែកចាយទឹក) | ទិន្នន័យឃុំ | ២០០៦-២០១១ | ២ |
| | | | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យ Jica) | ១៩៩៩ | |
| | | | មន្ទីរធនធានទឹក និងឧតុនិយមខេត្ត | តាមដែលអាចរកបាន | |
| | | ទីតាំងនិងស្ថានភាពហេដ្ឋារចនាសម្ព័ន្ធការពារទឹកជំនន់ (ទំនប់ និងទ្វាទឹក) | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យ Jica) | ២០០៦-២០១១ | |
| | | | មន្ទីរធនធានទឹក និងឧតុនិយមខេត្ត | តាមដែលអាចរកបាន | |
| | ហេដ្ឋារចនាសម្ព័ន្ធថាមពល | ទីតាំងនិងសមត្ថភាពនៃការចែកចាយអគ្គីសនី | Open Development Cambodia | ២០១១ | ៣ |
| | | | មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត | តាមដែលអាចរកបាន | |
| | | ទីតាំងនិងសមត្ថភាពនៃស្ថានីយ៍វារីអគ្គិសនី និងអាងស្តុបទឹក | Open Development Cambodia | តាមដែលអាចរកបាន | ៣ |
| | | | មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត | តាមដែលអាចរកបាន | |
| | ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងកាកសំណល់ | ទីតាំងនិងសមត្ថភាពនៃទីតាំងចាក់សំរាមសំខាន់ៗ | មន្ទីរបរិស្ថានខេត្ត | តាមដែលអាចរកបាន | |
| ហេដ្ឋារចនាសម្ព័ន្ធសង្គម | ការអប់រំ | ទីតាំងមជ្ឈមណ្ឌលអប់រំ ចំនួនសិស្ស/គ្រូ ស្ថានភាពចុះឈ្មោះចូលរៀន និងអត្រាអក្ខរកម្ម | ក្រសួងអប់រំយុវជននិងកីឡា | | ៣ |
| | | | ទិន្នន័យឃុំ | ២០០៦-២០១១ | ២ |
| | | | ទិន្នន័យភូមសាស្ត្រនៃជំរឿន NIS-MoP | ២០០៨ | |
| | សុខភាព | ទីតាំងមន្ទីរពេទ្យ/មណ្ឌលសុខភាព ចំនួនអ្នកជំងឺ/ពេទ្យ | ទិន្នន័យឃុំ | ២០០៦-២០១១ | ២ |
| | | | ទិន្នន័យភូមសាស្ត្រនៃជំរឿន វិទ្យាស្ថានស្ថិតិជាតិ - ក្រសួងផែនការ | ២០០៨ | |
| | សាសនា | ទីតាំង និងសារសំខាន់នៃតំបន់សម្រាប់ការគោរពសំខាន់ៗ (សម្រាប់សាសនា) | ក្រសួងធម្មការ និងសាសនាខេត្ត | | |
| ការប្រើប្រាស់ដី | គម្របដី | ទីតាំងក្រុម/ប្រភេទគម្របដីផ្សេងៗគ្នា | ក្រសួងសាធារណៈការ និងដឹកជញ្ជូន (ទិន្នន័យ Jica) | 1999 | |
| | | | ផែនទីប្រើប្រាស់ដីឃុំ ផលិតដោយក្រសួង ដ.ន.ស ដោយផ្អែកលើទិន្នន័យពី JICA | 1999 | |
| | | រ៉ាស្ទ័រ/រូបថតគម្របដី (Land cover raster) | Google earth portal | តាមដែលអាចរកបាន | ៥ |
| | | | Landsat | តាមដែលអាចរកបាន | ៦ |
| | តំបន់សាងសង់ | ចំណាត់ថ្នាក់តំបន់ទីប្រជុំជន និងហេដ្ឋារចនាសម្ព័ន្ធក្នុងតំបន់ទីប្រជុំជន | មន្ទីរ ដ.ន.ស.ស ខេត្ត | | |
| | ផលិតផលកសិកម្ម | តំបន់បង្កបង្កើនផលសម្រាប់ ដំណាំផ្សេងៗនៅរដូវប្រាំង និងរដូវវស្សា | | | |
| | | ទិន្នផលដំណាំផ្សេងៗ | មន្ទីរកសិកម្មខេត្ត | តាមដែលអាចរកបាន | |
| | | ទំហំដីបង្កបង្កើនផលសម្រាប់មួយគ្រួសារ | ទិន្នន័យឃុំ | ២០០៦-២០១១ | ២ |
| | | ទីតាំងនិងសារៈសំខាន់នៃសកម្មភាពចិញ្ចឹមសត្វ | | | |
| | ប័ណ្ណកម្មសិទ្ធិឯកជន | តំបន់ដែលបានទទួលប័ណ្ណកម្មសិទ្ធិដីធ្លីតាមរយៈកម្មវិធីLMAP/LASSP និងបទបញ្ញា០១ | មន្ទីរ ដ.ន.ស.ស ខេត្ត | តាមដែលអាចរកបាន | |
| | សម្បទាន | ទីតាំងនិងស្ថានភាពសម្បទានដីសង្គមកិច្ច (ថ្នាក់ជាតិ និងក្រោមជាតិ) | មន្ទីរ ដ.ន.ស.ស ខេត្ត | តាមដែលអាចរកបាន | |

| | | | | | |
|---|---|---|---|---|---|
| | | ទីតាំងនិងស្ថានភាពសម្បទានដីសេដ្ឋកិច្ច (ថ្នាក់ជាតិ និងក្រោមជាតិ) | | | |
| | | សម្បទានដីសេដ្ឋកិច្ច | Open Development Cambodia | ២០១១ | ៣ |
| | | | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២០១១ | ៤ |
| | | | រដ្ឋបាលខេត្ត | ២០១១ | |
| | ព្រៃឈើ | គម្របព្រៃ (១៩៩៣-១៩៩៧-២០០២-២០០៦) | រដ្ឋបាលព្រៃឈើ (ខ័ណ្ឌ) | ១៩៩៣-១៩៩៧-២០០២-២០០៦-២០១០ | |
| | | សហគមន៍ព្រៃឈើ | រដ្ឋបាលព្រៃឈើ (ខ័ណ្ឌ) | តាមដែលអាចរកបាន | |
| | | | Open Development Cambodia | ២០១១ | 3 |
| | | ទីតាំងនិងសមត្ថភាពនៃការដាំដើមឈើ (កន្លែងបណ្តុះកូនឈើ) | រដ្ឋបាលព្រៃឈើ (ខ័ណ្ឌ) | តាមដែលអាចរកបាន | |
| | | តំបន់ការពារ (អភិរក្ស) ក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ | រដ្ឋបាលព្រៃឈើ (ខ័ណ្ឌ) | តាមដែលអាចរកបាន | |
| | | | Open Development Cambodia | ២០១១ | ៣ |
| | | សម្បទានព្រៃឈើ | រដ្ឋបាលព្រៃឈើ (ខ័ណ្ឌ) | តាមដែលអាចរកបាន | |
| | | តំបន់ស្តារព្រៃឈើឡើងវិញ | រដ្ឋបាលព្រៃឈើ (ខ័ណ្ឌ) | តាមដែលអាចរកបាន | |
| | តំបន់ការពារ | តំបន់ការពារស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងបរិស្ថាន | មន្ទីរបរិស្ថានខេត្ត | តាមដែលអាចរកបាន | |
| | | | Open Development Cambodia | ២០១១ | ៣ |
| | | សហគមន៍ក្នុងតំបន់ការពារ (CPA) | មន្ទីរបរិស្ថានខេត្ត | តាមដែលអាចរកបាន | |
| | | ទីតាំងតំបន់អភិរក្សដែលគ្រប់គ្រងដោយក្រសួងបរិស្ថាន (TSBR) | | | |
| | ជលផល | ទីតាំងនិងស្ថានភាពគម្រោងសហគមន៍នេសាទ | រដ្ឋបាលជលផល (ខ័ណ្ឌ) | តាមដែលអាចរកបាន | |
| | | តំបន់នេសាទ និងតំបន់អភិរក្ស | រដ្ឋបាលជលផល (ខ័ណ្ឌ) | តាមដែលអាចរកបាន | |
| | ថ្ម សីលា | ទីតាំងនិងប្រភេទតំបន់អាជីវកម្មត្បូង/ថ្ម | | | |
| | | តំបន់ដែលចាត់ជាសម្បទានរ៉ែ | មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត | តាមដែលអាចរកបាន | |
| | | | មន្ទីរ ដ.ន.ស.ស ខេត្ត | តាមដែលអាចរកបាន | |
| | | | Open Development Cambodia | ២០១១ | ៣ |
| សេដ្ឋកិច្ច | ឧស្សាហកម្ម | ប្រភេទ ទីតាំង និងកម្រិតការងាររបស់ឧស្សាហកម្ម/សហគ្រាស ខ្នាតតូច មធ្យម និងខ្នាតធំ | មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត | តាមដែលអាចរកបាន | |
| | | ផ្សារ (ទីតាំង និងប្រភេទ) | មន្ទីរឧស្សាហកម្ម រ៉ែ និងថាមពលខេត្ត | តាមដែលអាចរកបាន | |
| | សេដ្ឋកិច្ចសង្គម | ស្ថានភាពការងារធ្វើ ទិន្នន័យអ្នកមាន/អ្នកក្រ រចនាសម្ព័ន្ធចំណូល | ទិន្នន័យឃុំ | ២០០៦-២០១១ | ២ |
| | | | ជំរឿនប្រជាជន ១៩៩៨ និង២០០៨ | ១៩៩៨និង ២០០៨ | ១ |
| | | តំបន់សេដ្ឋកិច្ចពិសេស | Open Development Cambodia | ២០១១ | ៣ |
| | | ប្រភេទនិងសារសំខាន់នៃសហគ្រាស | ជំរឿនសេដ្ឋកិច្ច ២០១១ | ២០១២ | ៣ |
| | ការងារ | មុខរបរពលរកម្មរបស់គ្រួសារ | | | |

| | | | | | |
|---|---|---|---|---|---|
| | | មុខរបរសំខាន់ៗរបស់គ្រួសារ | | | |
| | | អន្តោប្រវេសន៍រកការងារ | | | |
| | ភាពក្រីក្រ | កំណត់អត្តសញ្ញាណអ្នកក្រ | | | |
| | ជំនួញ | ទីតាំងនិងប្រភេទពាណិជ្ជកម្មសំខាន់ៗ | | | |
| | ពាណិជ្ជកម្ម | ប្រភេទនិងតម្លៃផលិតផលនាំចូលនិងនាំចេញ | | | |
| | ទេសចរណ៍ | ទីតាំង និងប្រភេទតំបន់ទាក់ទាញទេសចរណ៍សំខាន់ៗ | មន្ទីរទេសចរណ៍ខេត្ត | តាមដែលអាចរកបាន | |

១ http://celade.cepal.org/khmnis/census/khm1998/
http://celade.cepal.org/khmnis/census/khm1998/

២ http://db.ncdd.gov.kh/

៣ http://www.opendevelopmentcambodia.net

៤ http://www.maff.gov.kh

៥ http://www.google.com/earth/index.html

៦ http://landsat.usgs.gov/products_data_at_no_charge.php

## ឧបសម្ព័ន្ធ៣៖ រចនាសម្ព័ន្ធសម្រាប់របាយការណ៍បច្ចេកទេសផែនការរៀបចំដែនដីថ្នាក់ខេត្ត

### ជំពូក១៖ សេចក្តីផ្តើម

- បុព្វកថា
- គោលបំណង
- ស្ថាប័នកសាងផែនការរៀបចំដែនដី
- វិធីសាស្ត្រកសាងផែនការរៀបចំដែនដី

### ជំពូក២៖ ការវិភាគស្ថានភាព

| ការវិភាគតាមវិស័យ | *ផែនទីដែលត្រូវការ* |
|---|---|
| • រដ្ឋបាល | → ព្រំប្រទល់រដ្ឋបាលសំខាន់ៗ និងមជ្ឈមណ្ឌលស្រុក ឃុំ និងភូមិ |
| • បរិស្ថានរូបសាស្ត្រជីវសាស្ត្រ | → លក្ខណៈអាកាសធាតុនៅក្នុងខេត្ត |
| | → សណ្ឋានដី (រយៈកំពស់ និងជម្រាល) ជាមួយនឹងការកំណត់ទម្រង់ដីសំខាន់ៗ |
| | → ជីជាតិដី(សម្រាប់កសិកម្ម) |
| | → មធ្យោបាយតាមផ្លូវទឹក និងផ្ទៃទឹក |
| | → ព្រំប្រទល់ដៃទីជម្រាលស្ទឹង |
| | → ការបែងចែកតំបន់អេកូឡូស៊ីតាមហ្សែន |
| | → ទម្រង់ទឹកជំនន់ និងភាពរាំងស្ងួត |
| • ការកាន់កាប់ដី និងការប្រើប្រាស់ដីដែលមានស្រាប់ | → ការប្រែប្រួលការប្រើប្រាស់ដី |
| | → ការប្រើប្រាស់ដីបច្ចុប្បន្ន |
| | → គម្របព្រៃឈើ និងការរៀបចំគ្រប់គ្រងព្រៃឈើសំខាន់ៗ |
| | → ធនធានជលផល និងការរៀបចំការគ្រប់គ្រងជលផលសំខាន់ៗ |
| | → តំបន់ការពារ |
| | → តំបន់ដែលបានទទួលប័ណ្ណកម្មសិទ្ធដីធ្លី |
| | → ផែនទីសម្បទាន (សេដ្ឋកិច្ច និងសង្គមកិច្ច) |
| • ប្រជាសាស្ត្រ និងលំនៅឋាន | → ដង់ស៊ីតេប្រជាជន |
| | → អត្រាកំណើនប្រជាជន |
| | → អត្រាចំណូលនិងចំណាកស្រុក |
| | → លំនៅឋាន |
| • ហេដ្ឋារចនាសម្ព័ន្ធសង្គម | → ទីតាំង និងការទទួលបានហេដ្ឋារចនាសម្ព័ន្ធសុខភាព |
| | → ទីតាំង និងការទទួលបានហេដ្ឋារចនាសម្ព័ន្ធអប់រំ |
| • ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត | → ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន |
| | → ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងកាកសំណល់ (កសិកម្ម) |
| | → ការផ្គត់ផ្គង់ និងហេដ្ឋារចនាសម្ព័ន្ធថាមពល |
| • រចនាសម្ព័ន្ធសេដ្ឋកិច្ច | → របាយការងារទៅតាមប្រភេទ |

→ ទីតាំងអភិវឌ្ឍសេដ្ឋកិច្ចសំខាន់ៗ
→ តំបន់អភិវឌ្ឍសេដ្ឋកិច្ចពិសេស

រចនាសម្ព័ន្ធដែនដីខេត្ត

| | *ផែនទីដែលត្រូវការ* |
|---|---|
| • ការវិភាគនិងការកំណត់ប្រព័ន្ធប្រើប្រាស់ដី | → ប្រព័ន្ធប្រើប្រាស់ដី |
| • ចំណាត់ថ្នាក់ និងការវិភាគមជ្ឈមណ្ឌលទីប្រជុំជន | → ទីតាំងរបស់មជ្ឈមណ្ឌលទីប្រជុំជន និងតំបន់ជុំវិញ |
| • ការវិភាគមុខងារ និងរចនាសម្ព័ន្ធសេដ្ឋកិច្ច | → ការកំណត់ទីតាំងបណ្តុំប៉ូលសេដ្ឋកិច្ច និងច្រកផ្លូវអភិវឌ្ឍន៍សំខាន់ៗ |

## ជំពូក៣៖ ចក្ខុវិស័យ និងគោលដៅអភិវឌ្ឍន៍រយៈពេលវែង

សេណារីយ៉ូអភិវឌ្ឍន៍នាពេលអនាគត
គោលដៅអភិវឌ្ឍន៍រយៈពេលវែង
ចក្ខុវិស័យអភិវឌ្ឍន៍

## ជំពូក៤៖ យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី

យុទ្ធសាស្ត្រអភិវឌ្ឍន៍ដែនដី

| | *ផែនទីដែលត្រូវការ* |
|---|---|
| ក. មុខងារទេសភាពនិងការប្រើប្រាស់ដីនាពេល អនាគត | → ផែនទីមុខងារទេសភាពនិងការប្រើប្រាស់ដីនាពេល អនាគត |
| ខ. ការផ្តល់សេវាកម្ម និងមជ្ឈមណ្ឌលទីប្រជុំជន នាពេលអនាគត | → ផែនទីនៃការផ្តល់សេវាកម្ម និងមជ្ឈមណ្ឌលទីប្រជុំជន នាពេលអនាគត |
| គ. រចនាសម្ព័ន្ធសេដ្ឋកិច្ចនាពេលអនាគត | → ផែនទីរចនាសម្ព័ន្ធសេដ្ឋកិច្ចនាពេលអនាគត |

ផែនការតាមវិស័យដែលបានធ្វើបច្ចុប្បន្នភាព និងយុទ្ធសាស្ត្រតាមវិស័យដែលបានបន្ស៊ីគ្នា

## ជំពូក៥៖ ការអនុវត្ត ត្រួវពិនិត្យ និងវាយតម្លៃ

តារាងម៉ាទ្រីកអនុវត្ត
ការត្រួតពនិត្យ វាយតម្លៃ និងបច្ចុប្បនភាពផែនការ

សៀវភៅណែនាំជាសេរីនេះ កើតចេញពីកិច្ចខិតខំប្រឹងប្រែងសប្រតិបត្តិការរវាងក្រុមការងារកសាងផែនការរៀបចំដែនដីនៅថ្នាក់ខេត្ត/ក្រុង/ស្រុក អ្នកជំនាញការ និងអ្នកធ្វើសេចក្ដីសម្រេចចិត្តនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងទីប្រឹក្សាអង្គការ GIZ ។

ក្រុមអ្នករៀបរៀងនិងផ្ទៀងផ្ទាត់ជួយសម្រួលដល់ការផលិតសៀវភៅនេះឡើងរួមមាន៖ ឯកឧត្តមបណ្ឌិត **ប៉ែន សុផល** ឯកឧត្តមបណ្ឌិត **ម៉េង ប៊ុណ្ណារិទ្ធិ** Walter Koditek, Jean-Christophe Diepart, Thomas Hänert និង Florian Rock ។